**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកោះកុង**

លេខ ០៧៦/២២ រ.ប.ក

# របាយការណ៍

# ស្តីពី

# ការអនុវត្តការងាររបស់រដ្ឋបាលខេត្តប្រចាំឆ្នាំ ២០២១ និងទិសដៅការងារឆ្នាំ២០២២

# សេចក្តីផ្តើម

ខេត្តកោះកុង មានទីតាំងស្ថិតនៅភាគនិរតី នៃប្រទេសកម្ពុជា ចម្ងាយ 290 គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ខាងលិច និងខាងត្បូងជាប់នឹងឈូងសមុទ្រថៃ និងប្រទេសថៃ ខាងជើងជាប់នឹងខេត្តពោធិ៍សាត់ និងមានផ្ទៃដីសរុប 10,045.58គ.ម$^2$ ចែកជា 01ក្រុង 06ស្រុក 26ឃុំ 03 សង្កាត់ និង 119ភូមិ។

នៅទូទាំងខេត្ត មានគ្រួសារសរុបចំនួន 33,131គ្រួសារ មានប្រជាជនសរុប 146,052នាក់ ស្រី 72,917នាក់ មានប្រជាជនចម្រុះជាតិសាសន៍ដូចជា៖ ខ្មែរ ចិន ថៃ ចាម និងវៀតណាម។ល។ មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋ គឺ ធ្វើពាណិជ្ជកម្ម ផ្តល់សេវាកម្ម ជួញដូរ ធ្វើស្រែចម្ការ រកអនុផលព្រៃឈើ នេសាទ ធ្វើកម្មកររោងចក្រ និងសំណង់។

ខេត្តកោះកុងមាន ៖

| ល.រ | ការបរិយាយ | សរុប | ឯកតា |
|---|---|---|---|
| 1 | ផ្ទៃដីសរុប | 10,045.58 | គីឡូម៉ែត្រការ៉េ |
| 2 | ចំនួនក្រុង ស្រុក | 7 | ក្រុង ស្រុក |
| 3 | ចំនួនឃុំ សង្កាត់ | 29 | ឃុំ សង្កាត់ |
| 4 | ចំនួនភូមិ | 119 | ភូមិ |
| 5 | ចំនួនគ្រួសារ | 33,131 | គ្រួសារ |
| 6 | ចំនួនប្រជាពលរដ្ឋសរុប | 146,052 | នាក់ |
| 7 | ចំនួនស្ត្រីសរុប | 72,917 | នាក់ |

ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍរយៈពេល 5ឆ្នាំ (2021-2025) តាមរយៈការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្ត ឆ្នាំ2020-2022 ការអនុវត្តការងារប្រចាំឆ្នាំរបស់រដ្ឋបាលខេត្តមាន 06ផ្នែក ដែលក្នុងនោះមាន ៖

- **ផ្នែកទី១ ÷ ការគ្រប់គ្រងរដ្ឋបាលខេត្ត**
  ផ្នែកទី១នេះ បរិយាយអំពីលទ្ធផលនៃការអនុវត្តការងាររដ្ឋបាល ផែនការនិងការគាំទ្រមូលដ្ឋាន ការគ្រប់គ្រងធនធានមនុស្ស ការងារអន្តរវិស័យ ការងារហិរញ្ញវត្ថុ ការងារអង្គភាពលទ្ធកម្ម ការងារអង្គភាពច្រកចេញចូលតែមួយ និងការងារបន្ថែមថ្មីនានារបស់រដ្ឋបាលខេត្ត។
- **ផ្នែកទី២ ÷ ការងាររដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់**
  ផ្នែកទី២នេះ បរិយាយជាសង្ខេបអំពីលទ្ធផលនៃការអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងបញ្ហាប្រឈមដែលបានជួបប្រទះ ព្រមទាំងសំណើដំណោះស្រាយបញ្ហាប្រឈមទាំងនោះ។
- **ផ្នែកទី៣ ÷ ការងាររបស់មន្ទីរ អង្គភាពជំនាញ**
  ផ្នែកទី៣នេះ បរិយាយអំពីលទ្ធផលនៃការអនុវត្តការងាររបស់មន្ទីរ អង្គភាពជំនាញនានា ដែលមានទីតាំងនៅក្នុងដែនសមត្ថកិច្ចខេត្ត និងការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង។
- **ផ្នែកទី៤ ÷ បញ្ហាប្រឈម និងដំណោះស្រាយ**
  ផ្នែកទី៤នេះ បរិយាយអំពីបញ្ហាប្រឈមនានាដែលរដ្ឋបាលខេត្ត និងមន្ទីរ អង្គភាពជំនាញបានជួបប្រទះ និងសំណើដំណោះស្រាយបញ្ហាប្រឈមទាំងនោះ។
- **ផ្នែកទី៥ ÷ ទិសដៅការងារឆ្នាំបន្ទាប់**
  ផ្នែកទី៥នេះ បរិយាយអំពីសកម្មភាពជាអាទិភាព ដែលរដ្ឋបាលខេត្ត និងមន្ទីរ អង្គភាពជំនាញ បានគ្រោងសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់។
- **ផ្នែកទី៦ ÷ សេចក្តីសន្និដ្ឋាន**
  ផ្នែកទី៦នេះ បរិយាយជាសង្ខេបអំពីការសន្និដ្ឋាននៃការអនុវត្តការងាររបស់រដ្ឋបាលខេត្ត ដោយប្រៀបធៀបទៅនឹងផែនការប្រចាំឆ្នាំ ដែលបានគ្រោងទុក។

# ផ្នែកទី១
# ការគ្រប់គ្រងរដ្ឋបាលខេត្ត

## ១.១.ការងាររដ្ឋបាល

### ១.១.១.ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

ក្នុងរយៈពេលមួយឆ្នាំ2021 ការិយាល័យរបៀប និងឯកសារ នៃទីចាត់ការរដ្ឋបាលសាលាខេត្ត បានខិតខំរៀបចំកែសម្រួលបញ្ជីទុកដាក់លិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធ ដើម្បីឆ្លើយតបតាមការណែនាំរបស់គណៈអភិបាលខេត្ត កត់ត្រា និងតាមដានលិខិតចេញ ចូលជាប្រចាំ ទទួលពិនិត្យលិខិតស្នាម និងឯកសារផ្សេងៗ។ លិខិតស្នាមទាំងនោះមានដូចជា ដីកាដែលបានដាក់ចេញចំនួន 56លេខ ដីកាអមចំនួន 152លេខ សេចក្តីសម្រេចចំនួន 93លេខ លិខិតបង្គាប់ការចំនួន 03លេខ លិខិតជូនដំណឹងចំនួន 472លេខ សេចក្តីណែនាំ ចំនួន 20លេខ លិខិតស្នើសុំ ចំនួន 621 លេខ លិខិតអនុញ្ញាតច្បាប់ឈប់សម្រាក ចំនួន 16លេខ លិខិតផ្ទេរសិទ្ធិ ចំនួន 12លេខ របាយការណ៍ ចំនួន 421លេខ លិខិតអញ្ជើញចំនួន 391លេខ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ចំនួន 30លេខ លិខិតអនុញ្ញាតបើកឱសថស្ថាន ចំនួន 08លេខ លិខិតបញ្ជាក់ ចំនួន 05លេខ លិខិតថ្លែងអំណរគុណ ចំនួន 341លេខ លិខិតអនុញ្ញាតសាងសង់ចំនួន 24លេខ លិខិតអនុញ្ញាតប្រកប អាជីវកម្ម ចំនួន 323លេខ ។

**តារាងទី១៖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ដីកាដែលបានដាក់ចេញ | 56 |
| 2 | សេចក្តីសម្រេចដែលបានដាក់ចេញ | 93 |
| 3 | លិខិតរដ្ឋបាលដែលបានដាក់ចេញ | 2,804 |
| 4 | លិខិតចូល | 2,667 |
| 5 | ឯកសារដែលបានធ្វើនីត្យានុកូលកម្ម | 47 |
| 6 | អនុស្សរណៈ ឬកិច្ចព្រមព្រៀង | 0 |
| 7 | សៀវភៅគ្រួសារ (ក៤) | 1,033 |
| 8 | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | 3,019 |

### ១.១.២. ការគ្រប់គ្រងប្រជាពលរដ្ឋ

**តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | សរុបគ្រួសារ | 33,131 |
| 2 | គ្រួសារអចិន្ត្រៃយ៍ | 31,512 |
| 3 | គ្រួសារបណ្តោះអាសន្ន | 1,619 |
| 4 | ប្រជាពលរដ្ឋសរុប | 146,052 |
| 5 | ប្រជាពលរដ្ឋជាស្ត្រី | 72,917 |
| 6 | ប្រជាពលរដ្ឋដែលមានអាយុ 18ឆ្នាំឡើង | 96,293 |
| 7 | ប្រជាពលរដ្ឋចំណាកស្រុក | 2,837 |

### ១.១.៣. ការងារអត្រានុកូលដ្ឋាន

– ជំរឿន និងគ្រប់គ្រងការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋក្នុងខេត្ត រួមមាន៖

  - កំណើតបានចំនួន 2,164នាក់ ស្រី 961នាក់
  - បញ្ជាក់កំណើតបានចំនួន 2,307នាក់ ស្រី 1,006នាក់
  - អាពាហ៍ពិពាហ៍ខ្មែរ និងខ្មែរបានចំនួន 530គូ
  - អាពាហ៍ពិពាហ៍ខ្មែរ និងបរទេសបានចំនួន 01គូ
  - មរណភាពចំនួន 497នាក់ ស្រី 182នាក់
- ស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ តែត្រូវបាត់បង់ ឬ ខូចខាតដោយយថាហេតុ តាមការស្នើសុំរបស់សាមីខ្លួនបានចំនួន 49នាក់ (ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកគិរីសាគរ ស្រុកថ្មបាំង និងស្រុកបូទុមសាគរ)
- ស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋដែលមកចុះបញ្ជីអត្រានុកូលដ្ឋានក្នុងពេលបច្ចុប្បន្ន តាមការស្នើសុំតាមរយៈមេឃុំ ចៅសង្កាត់ បានចំនួន 109នាក់ (ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកបូទុមសាគរ និងស្រុកកោះកុង)
- សម្របសម្រួលការបញ្ជូនសាលក្រមកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន ពីសាលាដំបូងខេត្តកោះកុង ទៅក្រសួងមហាផ្ទៃបានចំនួន 52ច្បាប់
- បានបញ្ចូលទិន្នន័យឯកសារកែតម្រូវ និងមោឃភាពអត្រានុកូលដ្ឋានគ្រប់ប្រភេទក្នុងប្រព័ន្ធគ្រប់គ្រងឯកសារ (www.crdepartment.net) រួចបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេច ធ្វើការកែតម្រូវ និងមោឃភាព ជូនប្រជាពលរដ្ឋបានចំនួន 83ច្បាប់។

១.១.៤. **ការផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ** (រួមទាំងការងារសមាគម អង្គការមិនមែនរដ្ឋាភិបាល និងការងារចងសម្ព័ន្ធមេត្រីភាព )

**តារាងទី៣ ៖ ការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| **ក). ការផ្សព្វផ្សាយព័ត៌មាន** | | |
| 1 | វិទ្យុ | 82 |
| 2 | ទូរទស្សន៍ | 166 |
| 3 | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | 22 |
| 4 | ព្រឹត្តិបត្រព័ត៌មានទស្សនាវដ្តី សារព័ត៌មាន | 00 |
| 5 | ផ្សេងៗ | 8,141 |
| **ខ). ទំនាក់ទំនងសាធារណៈ** | | |
| 1 | សាធារណជនមកទំនាក់ទំនងសាលាខេត្ត | 957 |
| 2 | គណៈប្រតិភូភ្ញៀវជាតិ អន្តរជាតិ | 05 |

១.១.៥. **ការងារគណៈអភិបាល** (រួមទាំងការអនុវត្តតួនាទីជាតំណាងក្រសួង ស្ថាប័ន)

- អភិបាល និងអភិបាលរងខេត្ត បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងពិធីផ្សេងៗ ចំនួន 476លើក
- អភិបាល និងអភិបាលរងខេត្ត បានចូលរួមជាអធិបតី និងជាគណៈអធិបតីក្នុងសិក្ខាសាលា និងពិធីផ្សេងៗ ចំនួន 343លើក។

**តារាងទី៤ ៖ កិច្ចប្រជុំគណៈអភិបាល**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | កិច្ចប្រជុំអឡូមាសរបស់គណៈអភិបាល | 06 |
| 2 | កិច្ចប្រជុំប្រចាំខែ(អឡូមាសទី២)របស់គណៈអភិបាល | 06 |

### ១.១.៦. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

- ក្រុមប្រឹក្សាខេត្ត កើតចេញពីការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ក្រុមប្រឹក្សាខេត្តជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាខេត្តកោះកុង បានបង្កើតគណៈកម្មាធិការរបស់ខ្លួនចំនួន 04 រួមមាន ៖
    1. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
    2. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
    3. គណៈកម្មាធិការលទ្ធកម្ម
    4. គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម។

**តារាងទី៥ ៖ កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | 12 |
| 2 | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | 0 |
| 3 | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | 0 |
| 4 | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | 3 |
| 5 | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | 9 |
| 6 | កិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម | 40 |
| 7 | កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម | 0 |

**តារាងទី៦ ៖ ការរៀបចំវេទិកា** (ពុំមាន)

ដោយសារស្ថានភាពនៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-19 ក្នុងសហគមន៍ 20 កុម្ភៈ 2021 និងដោយអនុវត្តតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ក៏ដូចជាវិធានការការពាររបស់ក្រសួងសុខាភិបាល ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅតាមក្រុង ស្រុក សម្រាប់ឆ្នាំ2021 មិនត្រូវបានអនុវត្តទេ។

| ល.រ | ឈ្មោះវេទិកា | អ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| 1 | | | |

## ១.២. ការងារផែនការ និងការគាំទ្រមូលដ្ឋាន

### ១.២.១. ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខេត្ត

- បានរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (2021-2023) របស់រដ្ឋបាលខេត្តកោះកុង
- បានរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (2022-2024) របស់រដ្ឋបាលខេត្តកោះកុង
- បានបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (2021-2023) ចំនួន 150ក្បាល សម្រាប់បែងចែកជូនដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាល មន្ទីរជំនាញជុំវិញខេត្ត ទីចាត់ការ និងអង្គភាពចំណុះរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់

- បានសហការជាមួយមន្ទីរផែនការ ចុះបើកវគ្គផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីដំណើរការចាប់ផ្តើមរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (2022-2024) ដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដែលមានសមាសភាពចូលរួមសរុបចំនួន 219នាក់ ស្រី 36នាក់
- បានរៀបចំវេទិកាពិគ្រោះយោបល់ ស្តីពីការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល(2022-2024) និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការរៀបចំសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់ក្រុង ស្រុក ដែលមានសមាសភាពចូលរួម ចំនួន 73នាក់ ស្រី 06នាក់
- បានសហការជាមួយមន្ទីរផែនការ រៀបចំសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល(2022-2024) នៅតាមក្រុង ស្រុក ដែលមានសមាសភាពចូលរួម ចំនួន 329នាក់ ស្រី 37នាក់។

**តារាងទី៧ ៖ គម្រោងវិនិយោគបីឆ្នាំរំកិលខេត្ត**

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង(៛) |
|---|---|---|---|
| 1 | សេដ្ឋកិច្ច | 212 | 110,705,600,000 |
| 2 | សង្គមកិច្ច | 120 | 6,689,500,000 |
| 3 | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ | 12 | 10,199,000,000 |
| 4 | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 14 | 158,000,000 |
| សរុប | | **358** | **127,752,100,000** |

### ១.២.២. ការអនុវត្តគម្រោងវិនិយោគខេត្ត

**តារាងទី៨ ៖ ការអនុវត្តគម្រោងវិនិយោគខេត្ត**

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| 1 | សេដ្ឋកិច្ច | 212 | 54 | 0 | 158 |
| 2 | សង្គមកិច្ច | 120 | 35 | 0 | 85 |
| 3 | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ | 12 | 3 | 0 | 9 |
| 4 | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 14 | 0 | 0 | 14 |
| **សរុប** | | **358** | **92** | **0** | **266** |

### ១.២.៣. ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣

- ផែនការសកម្មភាព និងថវិកា ឆ្នាំ2021 របស់ខេត្តកោះកុង ដោយបានបញ្ចូលផែនការរបស់រដ្ឋបាលក្រុង ស្រុក មន្ទីរកិច្ចការនារី និងត្រូវបានទទួលស្គាល់ពី គ.ជ.អ.ប ក្នុងកញ្ចប់ថវិកាសរុប 412,760,000រៀល ក្នុងការគាំទ្រលើការអនុវត្តសកម្មភាពការងារឆ្លើយតបទៅនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានសម្របសម្រួលកិច្ចប្រជុំរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ2022 ស្តីពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការខេត្តកោះកុង ក្រោមអធិបតីភាព លោក **លឹម សាវ៉ាន់** នាយករដ្ឋបាលសាលាខេត្ត ដោយមានការចូលរួមពីតំណាងមន្ទីរផែនការ មន្ទីរកិច្ចការនារី និងទីចាត់ការ អង្គភាពពាក់ព័ន្ធ។ ជាលទ្ធផល ផែនការសកម្មភាព និងថវិកា ឆ្នាំ2022 ខេត្តកោះកុង បានបញ្ចូលរួមគ្នារវាងផែនការរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក មន្ទីរកិច្ចការនារី និង

មន្ទីរផែនការ មានថវិកាសរុប 483,634,000រៀល និងបានផ្ញើទៅក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យ និងដាក់បញ្ចូលក្នុងផែនការសកម្មភាព និងថវិកា ឆ្នាំ2022 របស់ គ.ជ.អ.ប។

**តារាងទី៩ ៖ ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣**

| ឈ្មោះលទ្ធផល | ស្ថានភាព | % សម្រេច | % ចំណាយ |
|---|---|---|---|
| ការរៀបចំ និងការផ្សព្វផ្សាយព័ត៌មាននានា ដើម្បីលើកកម្ពស់វិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីពាក់ព័ន្ធនានា | បញ្ចប់ | 100% | 100% |
| ការពង្រឹងការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងក្រុង ស្រុក ខណ្ឌគោលដៅចំនួន 170 ដោយថ្នាក់រាជធានី ខេត្ត | កំពុងអនុវត្ត | 60% | 60% |
| ការពង្រឹងការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងក្រុង ស្រុក ខណ្ឌគោលដៅចំនួន 170 ដោយថ្នាក់ក្រុង ស្រុក ខណ្ឌ | កំពុងអនុវត្ត | 60% | 60% |
| ការពង្រឹងយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលរាជធានី ខេត្ត | កំពុងអនុវត្ត | 90% | 90% |
| ការពង្រឹងយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | កំពុងអនុវត្ត | 90% | 90% |
| សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកសាងផែនការ និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យត្រូវបានពង្រឹង | កំពុងអនុវត្ត | 90% | 90% |
| ការបញ្ជ្រាបបរិយាប័ន្ន និងសមធម៌សង្គមក្នុងកិច្ចដំណើរការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | បញ្ចប់ | 100% | 100% |
| ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិអំពីបរិយាប័ន្ន និងសមធម៌សង្គមត្រូវបានគាំទ្រ (គ.ក.ស.ក ខេត្ត) | បញ្ចប់ | 100% | 100% |
| ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិអំពីបរិយាប័ន្ន និងសមធម៌សង្គមត្រូវបានគាំទ្រ (គ.ក.ស.ក ក្រុង ស្រុក) | បញ្ចប់ | 100% | 100% |
| ការពង្រឹងតួនាទីខេត្តក្នុងការត្រួតពិនិត្យ និងផ្តល់ការគាំទ្របច្ចេកទេសដល់ក្រុង ស្រុក និងឃុំ សង្កាត់ | កំពុងអនុវត្ត | 95% | 95% |
| ការពង្រឹងតួនាទីក្រុង ស្រុកក្នុងការតាមដាន និងគាំទ្រឃុំ សង្កាត់ | កំពុងអនុវត្ត | 95% | 95% |

### ១.២.៤. ការគាំទ្រមូលដ្ឋាន

- **ការគាំទ្រការអនុវត្តគម្រោងឃុំ សង្កាត់ ឆ្នាំ2021**
  - ចំនួនគម្រោងដែលបានស្នើឡើងក្នុងឆ្នាំ ចំនួន 34គម្រោង
  - គម្រោងដែលបានដេញថ្លៃរួចមានចំនួន 34គម្រោង
  - គម្រោងដែលបានចុះកិច្ចសន្យារួចមានចំនួន 34គម្រោង
    - ចំនួនកិច្ចសន្យាមិនទាន់បានអនុវត្ត ចំនួន 04គម្រោង
    - ចំនួនកិច្ចសន្យាអនុវត្តបានតិចជាង 50% ចំនួន 01គម្រោង
    - ចំនួនកិច្ចសន្យាអនុវត្តបានច្រើនជាង 50% ចំនួន 04គម្រោង
    - ចំនួនកិច្ចសន្យាអនុវត្តបាន 100% ចំនួន 25គម្រោង

- **ការគាំទ្រការរៀបចំគម្រោងក្រុង ស្រុក ឆ្នាំ2021**
  - ចំនួនគម្រោងដែលបានស្នើឡើងក្នុងឆ្នាំ ចំនួន 09គម្រោង
  - ចំនួនគម្រោងដែលកំពុងសិក្សា ចំនួន 00គម្រោង
  - ចំនួនកិច្ចសន្យាអនុវត្តបានតិចជាង 50% ចំនួន 00គម្រោង
  - ចំនួនកិច្ចសន្យាអនុវត្តបានច្រើនជាង 50% ចំនួន 00គម្រោង
  - ចំនួនគម្រោងដែលបញ្ចប់ការអនុវត្ត ចំនួន 09គម្រោង។

**១.២.៥. ការវិនិយោគ**

- **សំណើគម្រោងវិនិយោគអភិវឌ្ឍន៍អេកូទេសចរណ៍ខ្នាតតូច**
  - បានចូលរួមជាមួយប្រតិភូក្រសួងបរិស្ថាន អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធចុះពិនិត្យទីតាំងស្នើសុំគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិខ្នាតតូច (ក្រោម 10ហិកតា) ចំនួន 10គម្រោង ៖
    - ចំនួន 04គម្រោង ស្ថិតក្នុងតំបន់ឧទ្យានជាតិបុទុមសាគរ នៅភូមិសាស្ត្រភូមិជីត្រេះ ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង
    - ចំនួន 03គម្រោង ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃតាតៃ ក្នុងភូមិសាស្ត្រសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ និងឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង
    - ចំនួន 03គម្រោង ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប ក្នុងភូមិសាស្ត្រភូមិអន្លង់វ៉ាក់ ឃុំតាតៃក្រោម ស្រុកកោះកុង។ ជាលទ្ធផល តាមការចុះពិនិត្យទីតាំង និងស្ថានភាពភូមិសាស្ត្រឃើញថា ទីតាំងស្នើសុំគឺសមស្របសម្រាប់ការវិនិយោគគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិខ្នាតតូច ក្នុងនោះក្រុមការងារនឹងរៀបចំកំណត់ហេតុ និងរបាយការណ៍រួមមួយដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និង សម្រេច។
- **សំណើគម្រោងវិនិយោគជួលដីរដ្ឋធ្វើអាជីវកម្ម**
  - បានចូលរួមកិច្ចប្រជុំពិនិត្យលើការកែសម្រួលនូវផែនការអាជីវកម្មរបស់ក្រុមហ៊ុន **កោះ មង្គល រតនៈសម្បត្តិ ឯ.ក** លើសំណើសុំជួលដីរដ្ឋទំហំ 369ហិកតា សម្រាប់វិនិយោគវារីវប្បកម្មស្ថិតនៅស្រុកស្រែអំបិល ដែលដឹកនាំដោយតំណាងក្រសួងបរិស្ថាន
  - បានចូលរួមកិច្ចប្រជុំពិនិត្យផ្ទៀងផ្ទាត់ទីតាំងដីទំហំ 333.38ហិកតា សម្រាប់វិនិយោគអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលបានស្នើសុំដោយក្រុមហ៊ុន **អានកូ វ៉ាធើរ ស៊ីបផ្លាយ** ស្ថិតក្នុងភូមិគៀនក្រឡាញ់ ឃុំភ្ញីមាស ស្រុកគិរីសាគរ ក្រោមការដឹកនាំដោយតំណាងក្រសួងបរិស្ថាន។ ក្រសួងបរិស្ថាន បានអនុញ្ញាតជាគោលការណ៍ក្នុងការស្នើសុំវិនិយោគលើដីរដ្ឋ 01កន្លែងនេះ ក្នុងនោះក្រុមហ៊ុនត្រូវបន្តរៀបចំនីតិវិធីច្បាប់ និងផែនការអាជីវកម្មឱ្យបានច្បាស់លាស់ និងត្រូវរៀបចំអនុវត្តគម្រោងអភិវឌ្ឍន៍ឱ្យបានឆាប់រហ័សស្របតាមផែនការ
  - បានចូលរួមជាមួយប្រតិភូក្រសួងបរិស្ថាន ដើម្បីចុះសិក្សាទីតាំងដីជាក់ស្តែង លើសំណើសុំជួលរបស់ឈ្មោះ ប៊ុន ធី លើដីរដ្ឋជាប់មាត់ព្រែកទំហំ 7,721ម៉ែត្រការ៉េ រយៈពេល 50ឆ្នាំ ស្ថិតក្នុងភូមិទឹកប៉ោង ឃុំបឹងព្រាវ ស្រុកស្រែអំបិល ដើម្បីអភិវឌ្ឍន៍ជាកំពង់ផែខ្នាតតូច។ ជាលទ្ធផល ក្រុមការងារបានគាំទ្រគម្រោងនេះ តែស្នើសុំក្រុមហ៊ុនអនុវត្តឱ្យស្របតាមនីតិវិធីច្បាប់ និងផែនការអាជីវកម្មឱ្យបានច្បាស់លាស់ ដោយត្រូវសិក្សា និងស្នើសុំបច្ចេកទេសពីក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការសាងសង់កំពង់ផែខ្នាតតូចមួយនេះ
  - បានចូលរួមជាមួយប្រតិភូក្រសួងបរិស្ថាន អាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញពាក់ព័ន្ធ និងតំណាងក្រុមហ៊ុន **កោះកុង អេស អ៊ី ហ្សិត ឌូអិលធីឌី** ចុះពិនិត្យទីតាំង និងប្រជុំលើករណីស្នើសុំជួលដីទំហំ 3,439 ម៉ែត្រការ៉េ

ដើម្បីសាងសង់ស្ថានីយប្រេងឥន្ធនៈ ដែលមានទីតាំងស្ថិតក្នុងភូមិសាស្ត្រស្រុកកោះកុង។ តាមការចុះពិនិត្យទីតាំងដីស្នើសុំជួលខាងលើគឺជាន់ទៅនឹងដីអនុក្រឹត្យ 30 អនក្រ.បក ។ ជាលទ្ធផលតំណាងក្រសួងបរិស្ថាន រដ្ឋបាលខេត្ត និងរដ្ឋបាលស្រុក សម្រេចក្នុងការរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំនៃស្ថាប័នរៀងខ្លួនដើម្បីពិនិត្យ និងសម្រេចលើសំណើសុំនេះ

- បានចូលរួមជាមួយប្រតិភូក្រសួងបរិស្ថាន ចុះពិនិត្យគម្រោងស្នើសុំជួលដីរដ្ឋធ្វើអាជីវកម្មខ្សាច់ ចំនួន 02 គម្រោង របស់ក្រុមហ៊ុន Royal Group CO.,LTD ស្ថិតនៅឃុំត្រពាំងរូង ស្រុកកោះកុង និងឃុំប្រឡាយ ស្រុកថ្មបាំង ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញពាក់ព័ន្ធ។ ក្រោយពីការចុះពិនិត្យទីតាំងជាក់ស្តែងគម្រោងស្នើសុំធ្វើអាជីវកម្មខ្សាច់នៅឃុំប្រឡាយ ស្រុកថ្មបាំង អាចមានផលប៉ះពាល់ទៅលើទីជម្រករបស់សត្វក្រពើភ្នំ និងត្រីនាគ ដែលជាប្រភេទសត្វអភិរក្ស។ ក្រុមការងារនៃស្ថាប័នពាក់ព័ន្ធនឹងរៀបចំកំណត់ហេតុរួមមួយដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច
- បានទទួលសំណើសុំរបស់ក្រុមហ៊ុន **ស៊ីអិន ហ្សុងខេម៉ារីន បាយអ៊ីឡូជីខល (ខេមបូឌា) ឯ.ក** ស្តីពីការជួលកោះទទឹងទំហំ 75ហិកតា ស្ថិតក្នុងភូមិសាស្ត្រភូមិកោះស្តេច ឃុំកោះស្តេច ស្រុកគិរីសាគរ ដើម្បីអភិវឌ្ឍជាមជ្ឈមណ្ឌលអភិវឌ្ឍសិក្សាស្រាវជ្រាវការបង្កាត់ពូជមច្ឆាសមុទ្រដ៏ទំនើប និងវារីវប្បកម្មទេសចរណ៍។ រដ្ឋបាលខេត្តបានរៀបចំលិខិត និងឯកសារស្នើសុំនេះជូនទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីពិនិត្យ និងសម្រេច
- បានចូលរួមចុះពិនិត្យទីតាំងស្នើសុំអន្តរាគមន៍ និងទប់ស្កាត់ការសាងសង់រំលោភយកដីធ្លីក្នុងគម្រោងវិនិយោគរបស់ក្រុមហ៊ុន Coast Development Group Co., Ltd. និង ក្រុមហ៊ុន Pineapple Island Development Co., Ltd. ដែលមានទីតាំងនៅកោះម្នាស់ ឃុំកោះស្តេច ស្រុកគិរីសាគរ។ ជាលទ្ធផលក្រុមការងារ បានពិនិត្យឃើញថា ពិតជាមានការសាងសង់រំលោភយកដីធ្លីក្នុង គម្រោងរបស់ក្រុមហ៊ុនពិតប្រាកដមែន ក្នុងនោះ ក្រុមការងារបានរៀបចំរបាយការណ៍ដាក់ជូនលោកជំទាវ អភិបាលខេត្តពិនិត្យ និងសម្រេច
- បានចូលរួមចុះពិនិត្យទីតាំងស្នើសុំជួលដីរដ្ឋទំហំ 36.87ហិកតា ដើម្បីវិនិយោគវារីវប្បកម្ម បង្កាត់ពូជត្រី និងចិញ្ចឹមក្តាម ស្ថិតនៅឃុំជ្រោយប្រស់ ស្រុកកោះកុង។ ជាលទ្ធផល ក្រុមការងារ បានណែនាំដល់អ្នកស្នើសុំឱ្យធ្វើការជួលដីនេះត្រឹមកម្រិត 15ឆ្នាំ (ជួលរយៈពេលខ្លី) ព្រោះគម្រោងនេះ គឺបែបវារីវប្បកម្ម ដែលមិនទាមទារពេលវេលាយូរនោះទេ
- បានចូលរួមចុះពិនិត្យទីតាំងស្នើសុំធ្វើអាជីវកម្មរបស់ក្រុមហ៊ុន **រិទ្ធ រតនៈ អ៊ិនវេសម៉ិន & ថេកណូឡូជី ហេរីធេច ឯ.ក** លើវិស័យវារីវប្បកម្ម ចិញ្ចឹមបង្គា ក្តាម និងផលិត ជីកំប៉ុស្ត ដោយដីមមោកលើផ្ទៃដីទំហំ 1,286 ហិកតា ក្នុងឧទ្យានជាតិបុទុមសាគរ ស្ថិតក្នុងភូមិសាស្ត្រឃុំអណ្តូងទឹក ស្រុកបូទុមសាគរ។ តាមរយៈកិច្ចប្រជុំ និងពិនិត្យលើផែនទីស្នើសុំ គឺទីតាំងដីនេះត្រូវបានរាជរដ្ឋាភិបាលចេញអនុក្រឹត្យកាត់ជាដីសហគមន៍ឃុំអណ្តូងទឹក សម្រាប់ប្រជាពលរដ្ឋមូលដ្ឋានអាស្រ័យផលរួចទៅហើយ ដូច្នេះគម្រោងស្នើសុំនេះគឺក្រសួងបរិស្ថានមិនអាចអនុញ្ញាតជូនក្រុមហ៊ុននោះទេ
- បានចូលរួមចុះពិនិត្យ សិក្សា និងវាយតម្លៃដីជាក់ស្តែងលើដីសាធារណៈរបស់រដ្ឋ ក្រោយរាជរដ្ឋាភិបាលបានអនុញ្ញាតជាគោលការណ៍ក្នុងការជួលជូនវិស័យឯកជនដើម្បីវិនិយោគ លើគម្រោងចំនួន 02 គឺគម្រោងវារីវប្បកម្មក្តាមតាមបែបធម្មជាតិទំហំដី 369ហិកតា និងគម្រោងសាងសង់កំពង់ផែខ្នាតតូចទំហំដី 7,767 ម៉ែត្រការ៉េ ដែលគម្រោងទាំង 02នេះ ស្ថិតនៅស្រុកស្រែអំបិល ខេត្តកោះកុង។ ជាលទ្ធផលក្រុមការងារអន្តរក្រសួង បានណែនាំឱ្យតំណាងក្រុមហ៊ុន ត្រូវរៀបចំគ្រោងការ និងផែនការវិនិយោគឱ្យបានរួចរាល់

និងត្រូវស្នើសុំការបោះបង្គោលព្រំឱ្យបានច្បាស់លាស់ ទើបក្រុមការងារអន្តរក្រសួង នឹងចុះមកពិនិត្យ សិក្សា និងវាយតម្លៃលើការជួលដីដែលជាសម្បត្តិរបស់រដ្ឋនេះម្តងទៀត។

- **សំណើសុំវិនិយោគផ្សេងទៀត**
  - បានប្រជុំពិនិត្យលើសំណើសុំដំឡើងជើងប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្ម ក្នុងភូមិសាស្ត្រខេត្តកោះកុង របស់ក្រុមហ៊ុន អេស ធី អេស អ៊ែតវើថាយស៊ីង ឯ.ក (STS ADVERTISING CO.,LTD) តាមរយៈការពិនិត្យលើឯកសារ និងទីតាំងស្នើសុំចំនួន 11ទីតាំង ភាគច្រើនប៉ះទៅនឹងគម្រោងកែលម្អ និងពង្រីកផ្លូវជាតិលេខ 48 ដែលរដ្ឋាភិបាលកំពុងដោះស្រាយផលប៉ះពាល់ និងគ្រោងអនុវត្តក្នុងពេលឆាប់ៗ ខាងមុខនេះដូចនេះ អង្គប្រជុំក៏បានសម្រេចឱ្យក្រុមហ៊ុនពន្យារពេលក្នុងការស្នើសុំដំឡើងជើងប៉ាណូសិន ដោយរង់ចាំគម្រោងកែលម្អ និងពង្រីកផ្លូវជាតិលេខ48 អនុវត្តចប់ជាស្ថាពរ
  - បានចេញលិខិតស្តីពីការបំពេញបញ្ជីសម្រង់គម្រោងវិនិយោគ ឬអាជីវកម្មនានាដែលមន្ទីរ អង្គភាពជំនាញក្នុងខេត្តកោះកុង បានចុះបញ្ជីឬបានផ្តល់អាជ្ញាប័ណ្ណចាប់តាំងពីឆ្នាំ2005 រហូតដល់ត្រីមាសទី3 ឆ្នាំ2021។ រដ្ឋបាលខេត្តបានទទួលលិខិតឆ្លើយតបចំនួន19 មន្ទីរ អង្គភាព ក្នុងនោះមន្ទីរដែលមានផ្តល់អាជ្ញាប័ណ្ណគម្រោងវិនិយោគ ឬអាជីវកម្មដល់វិស័យឯកជន មានចំនួន 12មន្ទីរ អង្គភាព និងមន្ទីរដែលមិនផ្តល់អាជ្ញាប័ណ្ណ ឬគម្រោងអាជីវកម្មដល់វិស័យឯកជនមានចំនួន 07មន្ទីរ អង្គភាព
  - បានចូលរួមជាមួយប្រតិភូក្រសួងបរិស្ថាន ដឹកនាំដោយ ឯកឧត្តម **រ័ត្ន វីរៈ** អនុរដ្ឋលេខាធិការ ដើម្បីចុះពិនិត្យទីតាំងស្នើសុំធ្វើប្រព័ន្ធផ្លូវមេ និងហេដ្ឋារចនាសម្ព័ន្ធផ្លូវចូលចាប់ពីចំណុចផ្លូវជាតិលេខ48 (ខាងលើតាតៃរីសត) ចូលទីតាំងគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិខ្នាតតូចរបស់ក្រុមហ៊ុនប្រវែងសរុប 4,713 ម៉ែត្រ (ប្រវែង 2,617ម៉ែត្រ ទទឹង 12ម៉ែត្រ និងប្រវែង 2,096ម៉ែត្រ ទទឹង10ម៉ែត្រ) ដែលមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប ក្នុងភូមិសាស្ត្រភូមិអន្លង់វ៉ាក់ ឃុំតាតៃក្រោម ស្រុកកោះកុង។ ជាលទ្ធផលក្រុមការងារគាំទ្រដល់ការស្ថាបនាផ្លូវ1ខ្សែនេះ និងសុំឱ្យក្រុមហ៊ុនស្ថាបនាផ្លូវចូលចាប់ពីចំណុចផ្លូវជាតិលេខ48 តាមព្រំដីគម្រោងវិនិយោគ (ជួលដីរដ្ឋ) រហូតដល់ទីតាំងភូមិកោះអណ្តែត ដែលមានប្រវែងសរុបជាង 6គីឡូម៉ែត្រ និងត្រូវដាក់គម្រោងផ្លូវនេះជាសម្បត្តិសាធារណៈ ដែលប្រជាជនប្រើប្រាស់បានជាទូទៅ។

- **ការអនុវត្តគម្រោងអាហារូបត្ថម្ភនៅកម្ពុជា ខេត្តកោះកុង**
  - បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចប្រតិបត្តិការមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ ដល់រដ្ឋបាលឃុំ សង្កាត់ នៃស្រុកគិរីសាគរ ស្រុកបូទុមសាគរ និងស្រុកថ្មបាំង
  - បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីការវាយតម្លៃកិច្ចមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ តាមរយៈកម្មវិធី ម៉ៃក្រូសុះធីម របស់គម្រោង អាហារូបត្ថម្ភនៅកម្ពុជា
  - បានចុះវាយតម្លៃភាពត្រៀមរួចជាស្រេច ស្តីពីការអនុវត្តមូលនិធិការគាំទ្រការផ្តល់សេវារដ្ឋបាលឃុំ សង្កាត់ សម្រាប់គម្រោងអាហារូបត្ថម្ភនៅកម្ពុជា នៅគ្រប់ឃុំនៃរដ្ឋបាលស្រុកគិរីសាគរ ស្រុកថ្មបាំង និងស្រុកបូទុមសាគរ ដែលជាស្រុកគោលដៅដោយទទួលបានពិន្ទុជាប់ស្ថាពរ
  - គម្រោងអាហារូបត្ថម្ភនៅកម្ពុជា នៃលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ ដល់គណនេយ្យករ និងបេឡាករ នៃក្រុង ស្រុក ឃុំ សង្កាត់ អនុវត្តគម្រោងអាហារូបត្ថម្ភនៅកម្ពុជា នៅសាលប្រជុំ (ខ) សាលាខេត្តកោះកុង ដែលមានអ្នកចូលរួមមកពីស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកគិរីសាគរ នៃខេត្តកោះកុង និងក្រុងកំពង់ឆ្នាំង និងស្រុកកំពង់ត្រឡាច នៃខេត្តកំពង់ឆ្នាំង សរុបចំនួន 40នាក់។

## ១.៣. ការគ្រប់គ្រងធនធានមនុស្ស

### ១.៣.១. ការគ្រប់គ្រងបុគ្គលិក

- បានធ្វើបេសកកម្មជូនក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីសាលាខេត្ត និងមន្ទីរ អង្គភាពជុំវិញខេត្ត ឆ្នាំ 2021 មានចំនួនសរុប 1,102លេខ ។
- បានរៀបចំដាក់ចេញដីកាដូចខាងក្រោម៖
  - ដីកាស្តីពីការតែងតាំង ប្រគល់ភារកិច្ច និងផ្លាស់ប្តូរកន្លែងធ្វើការជូនមន្ត្រីរាជការ នៃរដ្ឋបាលខេត្ត មន្ទីរ អង្គភាព ចំនួន 08ដីកា ដែលមានមន្ត្រីរាជការសរុប 36នាក់
  - ដីកាស្តីពីការដំឡើងថ្នាក់ ឋានន្តរស័ក្តិតាមវេនអតីតភាព និងតាមកម្រិតសញ្ញាបត្រ ចំនួន 03ដីកា ដែលមានមន្ត្រីសរុប 182នាក់
  - ដីកាតាំងស៊ប់មន្ត្រីរាជការនៃមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត 01ដីកា ក្នុងនោះ មានមន្ត្រីរាជការសរុប ចំនួន 27នាក់
  - ដីកាលុបឈ្មោះមន្ត្រីរាជការនៃមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត ចំនួន 02ដីកា
  - ដីកាស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនកាលកំណត់ 01ដីកា
  - ដីកាស្តីពីការដាក់ទណ្ឌកម្មវិន័យមន្ត្រីរាជការ 01ដីកា
  - ដីកាស្តីពីលទ្ធផលនៃការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលខេត្ត ចំនួន 02ដីកា បេក្ខជនបេក្ខនារីប្រឡងជាប់ជាស្ថាពរសរុប 04នាក់ ស្ត្រី 02នាក់
  - ដីកាស្តីពីការផ្ទេរមន្ត្រីរាជការ មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត ចំនួន 10ដីកា
  - ដីកាស្តីពីការដាក់មន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន 03ដីកា
  - ដីកាស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារក្នុងអង្គភាពដើមវិញចំនួន 02ដីកា
- បានរៀបចំសេចក្តីសម្រេចផ្សេងៗ ពាក់ព័ន្ធនឹងការរៀបចំការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលខេត្តកោះកុង ចំនួន 04
- បានរៀបចំលិខិតបង្គាប់ការ 02លេខ មានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាសរុប 03នាក់
- បានរៀបចំលិខិត និងសេចក្តីជូនដំណឹងផ្សេងៗ សរុបចំនួន 08លិខិត
- បានរៀបចំពិធីប្រកាសចូលកាន់មុខតំណែងមន្ត្រីរាជការ ចំនួន 06លើក
- បានរៀបចំកិច្ចប្រជុំពាក់ព័ន្ធការងារបុគ្គលិក 04លើក
- បានរៀបចំការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលខេត្ត 01លើក កាលពីថ្ងៃទី28 ខែវិច្ឆិកា ឆ្នាំ2021។

**តារាងទី១០ ៖ ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| 1 | សមាជិកក្រុមប្រឹក្សា | 18 | 05 |
| 2 | ប្រធានក្រុមប្រឹក្សា | 01 | 00 |
| 3 | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | 01 | 01 |
| 4 | អភិបាល | 01 | 01 |
| 5 | អភិបាលរង | 06 | 00 |
| 6 | នាយករដ្ឋបាល | 01 | 00 |
| 7 | នាយករងរដ្ឋបាល | 03 | 01 |
| 8 | នាយកទីចាត់ការ ប្រធានអង្គភាព | 07 | 00 |

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| 9 | នាយករងទីចាត់ការ និងអនុប្រធានអង្គភាព | 14 | 02 |
| 10 | ប្រធានការិយាល័យ | 13 | 01 |
| 11 | អនុប្រធានការិយាល័យ | 17 | 08 |
| 12 | មន្ត្រីការិយាល័យ | 13 | 04 |
| 13 | បុគ្គលិកកិច្ចសន្យា | 39 | 23 |
| | **សរុប** | **133** | **45** |

- **ស្ថិតិការិយាល័យប្រជាពលរដ្ឋខេត្ត**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| 1 | ប្រធានការិយាល័យប្រជាពលរដ្ឋ | 01 | 00 |
| 2 | អនុប្រធានការិយាល័យប្រជាពលរដ្ឋ | 00 | 00 |
| 3 | ប្រធានផ្នែក | 02 | 00 |
| 4 | អនុប្រធានផ្នែក | 04 | 00 |
| 5 | មន្ត្រី | 01 | 00 |
| | **សរុប** | **08** | **00** |

### ១.៣.២. ការកសាងសមត្ថភាព

- បានរៀបចំរបាយការណ៍ ស្តីពីការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការស៊ីវិលសម្រាប់ឆមាសទី2 ឆ្នាំ2020 នៅរដ្ឋបាលខេត្តកោះកុង ជូនលេខាធិការដ្ឋាន គ.ជ.អ.ប
- បានសម្របសម្រួលចេញលិខិតចាត់បញ្ជូនមន្ត្រីរាជការ ចំនួន 05នាក់ ស្រី 01នាក់ ក្នុងនោះមាន មន្ត្រីនៃរដ្ឋបាលស្រុកថ្មបាំង 03នាក់ និងរដ្ឋបាលស្រុកកោះកុង ចំនួន 02នាក់ ស្រី 01នាក់ ដើម្បីចូលសិក្សាវគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល និងវគ្គវិក្រឹត្យការមន្ត្រីមធ្យមនៃវគ្គបណ្តុះបណ្តាលបន្តឆ្នាំ2021 នៅសាលាភូមិន្ទរដ្ឋបាល
- បានសម្របសម្រួលដល់ក្រុមនិស្សិតមហាវិទ្យាល័យសំណង់ និងគនរោបនីយវិទ្យា នៃសាកលវិទ្យាល័យន័រតុន ចំនួន 04នាក់ ក្នុងការចុះសិក្សាស្រាវជ្រាវដើម្បីសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រ លើប្រធានបទ ស្តីពីការអភិវឌ្ឍន៍ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង
- បានសម្របសម្រួលចេញលិខិត ស្តីពីរបាយការណ៍ថវិកាសរុបសម្រាប់ការអភិវឌ្ឍសមត្ថភាព ឆ្នាំ2019 និងឆ្នាំ 2020 របស់រដ្ឋបាលខេត្តកោះកុង ជូនដល់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
- បានសម្របសម្រួលរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ2021 របស់ខេត្តកោះកុង ក្នុងការគាំទ្រលើការអនុវត្តសកម្មភាពការងារឆ្លើយតបទៅនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយបានដាក់បញ្ចូលនូវផែនការរបស់រដ្ឋបាលក្រុង ស្រុក មន្ទីរកិច្ចការនារី និងត្រូវបានទទួលស្គាល់ពី លេខាធិការដ្ឋាន គ.ជ.អ.ប
- បានសម្របសម្រួលរៀបចំបិទបញ្ចប់សេចក្តីសម្រេចរួមឆ្នាំ2020 រវាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងរដ្ឋបាលខេត្តកោះកុង
- បានចូលរួមសហការជាមួយលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តកោះកុង ចុះសម្របសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ2021 នៅតាមក្រុង ស្រុក ក្នុងខេត្តកោះកុង។

### តារាងទី១១ ៖ ការកសាងសមត្ថភាព

| ល.រ | ឈ្មោះវគ្គសិក្សា | ចំនួនថ្ងៃ | អ្នកចូលរួម | | រៀបចំដោយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| 1 | វគ្គបណ្ដុះបណ្ដាល និងផ្សព្វផ្សាយ ស្ដីពីការដាក់ឱ្យប្រើប្រាស់ទម្រង់ដីកានានាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 14ថ្ងៃ | 195 | 45 | រដ្ឋបាលខេត្ត |
| 2 | ជំនាញព័ត៌មានវិទ្យា និងការឌីហ្សាញ (អនឡាញ) | 01ឆ្នាំ | 05 | 0 | ក្រសួងមហាផ្ទៃ |
| 3 | ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស (អនឡាញ | 5 ថ្ងៃ | 02 | 0 | ក្រសួងមុខងារសាធារណៈ |
| 4 | ការអនុវត្តការងារសេវាសង្គម រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ | 01ថ្ងៃ | 04 | 0 | ក្រសួងមហាផ្ទៃ |
| 5 | ការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម | 03ថ្ងៃ | 03 | 0 | លេខាធិការដ្ឋាន គ ជ អ ប |
| សរុប | | 388 | 209 | 45 | |

### ១.៤ ការងារអន្តរវិស័យ

សរុបពីខែ មករារហូតដល់ខែធ្នូ ឆ្នាំ2021 ទីចាត់ការអន្តរវិស័យ បានខិតខំប្រឹងប្រែងបំពេញការងារដោយបានពិនិត្យ និងចាត់ចែងលើឯកសារលិខិតរដ្ឋបាល ចំនួន 461ឯកសារ។ ក្នុងករណី និងសំណើចាំបាច់មួយចំនួន ទីចាត់ការបាន រៀបចំសេចក្ដីសម្រេច លិខិតបង្គាប់ការ សេចក្ដីជូនដំណឹង និងលិខិតផ្សេងៗទៀត។

**១.៤.១. ការងារសេដ្ឋកិច្ច និងសង្គមកិច្ច** (71**ឯកសារ**)

- បានទទួល និងពិនិត្យសំណើពីក្រសួង មន្ទីរ អង្គភាពជុំវិញខេត្ត មានចំនួន 27លេខ
- បានទទួល និងពិនិត្យសំណើពីបុគ្គលឯកជន និងក្រុមហ៊ុននានា, មានចំនួន 44លេខ។

**១.៤.២. ការគ្រប់គ្រងការអភិវឌ្ឍ និងសំណង់** ( 341**ឯកសារ**)

- បានទទួល និងពិនិត្យសំណើអន្តរាគមន៍ ចុះបញ្ជីដី និងធ្វើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ពាក្យបណ្ដឹងទំនាស់ដីធ្លី រវាងប្រជាពលរដ្ឋជាមួយប្រជាពលរដ្ឋ ប្រជាពលរដ្ឋជាមួយក្រុមហ៊ុនអភិវឌ្ឍន៍នានា មានចំនួន 234 លេខ
- បានទទួល និងពិនិត្យសំណើពីក្រសួង មន្ទីរ និងអង្គភាពនានាជុំវិញខេត្ត មានចំនួន 107លេខ។

**១.៤.៣. កិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ** (49**សំណើ**)

- បានទទួល និងពិនិត្យសំណើពីក្រសួង មន្ទីរ និងអង្គភាពនានាជុំវិញខេត្ត មានចំនួន 24លេខ
- បានទទួល និងពិនិត្យសំណើពី ក្រុមហ៊ុនឯកជន សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន មានចំនួន 25លេខ។

**១.៤.៤. មណ្ឌលកុមារកំព្រារបស់រដ្ឋ ខេត្តកោះកុង**

**ក. ស្ថិតិបុគ្គលិក និងកុមារ**

| ល.រ. | បរិយាយ | សរុប | ស្រី |
|---|---|---|---|
| 1 | ប្រធានមណ្ឌល | 01 | 0 |
| 2 | មន្ត្រីជាប់កិច្ចសន្យា (ម៉ែដោះ) | 01 | 01 |
| 3 | កុមារ | 22 | 03 |

**ខ. ស្ថានភាព**

១. មណ្ឌលកុមារកំព្រារបស់រដ្ឋ

មានអាសយដ្ឋាន ស្ថិតនៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានផ្ទៃដីទំហំ 4,041 ម៉ែត្រក្រឡា និងមានអគារ ចំនួន 01ខ្នង ទទឹង 6ម៉ែត្រ គុណនឹងបណ្តោយ 40ម៉ែត្រ (240ម៉ែត្រក្រឡា) ចែកជា 02 បន្ទប់ស្នាក់នៅ និង 01បន្ទប់ការិយាល័យ។

២. ការឧបត្ថម្ភកុមារ

- មានការផ្គត់ផ្គង់អាហារចំនួន 03ដង ក្នុង 01ថ្ងៃ ជាប្រចាំ (ព្រឹក ថ្ងៃត្រង់ ល្ងាច)។
- មានការផ្គត់ផ្គង់សម្លៀកបំពាក់ចំនួន 01លើក ក្នុង 01ឆ្នាំ (ដើមឆ្នាំ)។
- កុមារបានចូលសិក្សានៅសាលាចំណេះដឹងទូទៅរបស់រដ្ឋទាំងអស់គ្នា។

**គ. លទ្ធផលការងារ**

- បានទទួលថែទាំក្មេងចំនួន 22នាក់ ស្រី 03នាក់
- បានបញ្ជូនកុមារចំនួន 07រូប ទៅសិក្សានៅរាជធានីភ្នំពេញ (វិទ្យាស្ថានសង្គមកិច្ច 02រូប និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈអង្គការដើម្បីភាពញញឹម នៃកុមារ (Pour un Sourire d'Enfant – PSE) ចំនួន 05រូប ស្រី 01រូប)
- បានបញ្ជូនកុមារចំនួន 01រូប ទៅរៀនជំនាញជួសជុលម៉ូតូ នៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។

**តារាងទី១២៖ ការដោះស្រាយពាក្យបណ្តឹង និងការសម្រុះសម្រួលទំនាស់**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| **ក). ការដោះស្រាយពាក្យបណ្តឹង** | | |
| 1 | ពាក្យបណ្តឹងដែលបានដោះស្រាយរួចដោយរដ្ឋបាលខេត្ត | 05 |
| 2 | ពាក្យបណ្តឹងដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | 00 |
| | **សរុប** | 05 |
| **ខ). ការសម្រុះសម្រួលទំនាស់** | | |
| 1 | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយរដ្ឋបាលខេត្ត | 00 |
| 2 | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | 00 |
| | **សរុប** | 00 |

**១.៤.៥. កិច្ចការសេវាសង្គម និងការបង្កើនសិទ្ធិអំណាចស្ត្រី**

**តារាងទី១៣ ៖ ការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក**

| ល.រ | សូចនាករ | ផែនការឆ្នាំ | លទ្ធផលសម្រេច | |
|---|---|---|---|---|
| | | | ជាក់ស្តែង | % |
| 1 | ចំនួនកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ខេត្ត | 12 | 09 | 75% |
| 2 | ចំនួនថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើផ្នែកសេវាសង្គម (រៀល) | 18,000,000 | 11,882,000 | 66% |
| 3 | ខេត្តបានចងក្រងទិន្នន័យអត្រានុកូលដ្ឋាន ដែលទទួលបានពីក្រុង ស្រុក | 0 | 0 | 0 |
| 4 | ចំនួនបេសកកម្មដែល គ.ក.ស.ក ខេត្តបានចុះគាំទ្រ និងផ្តល់សេវាសង្គម | 14 | 13 | 93% |
| 5 | ចំនួនក្រុង ស្រុកដែល គ.ក.ស.ក ខេត្ត បានចុះគាំទ្រ | 07 | 07 | 100 |

| | | | | |
|---|---|---|---|---|
| | | | | |
| 6 | ចំនួនវត្ថុបណ្តុះបណ្តាលដែល គ.ក.ស.ក ខេត្តបានទទួល | 0 | 0 | 0 |

**១.៤.៥. ការងារគ្រប់គ្រងច្រកព្រំដែន**

| អ្នកដំណើរ | ចូល | | | ចេញ | | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សញ្ជាតិ | សរុប | ស្រី | សញ្ជាតិ |
| ជនបរទេស | 00 | 00 | 00 | 161 | 39 | 01 |
| ជនជាតិខ្មែរ | 1,149 | 354 | 01 | 00 | 00 | 00 |

## ១.៥. ការងារហិរញ្ញវត្ថុ

### ១.៥.១. ការអនុវត្តចំណូល និងចំណាយ

- ការអនុវត្តចំណូល និងចំណាយរបស់រដ្ឋបាលខេត្តប្រចាំឆ្នាំ2021 ទីចាត់ការហិរញ្ញវត្ថុសម្រេចបានការងារប្រមូលចំណូល និងចំណាយដែលមានទឹកប្រាក់ដូចខាងក្រោម៖

**តារាងទី១៤ ៖ ការអនុវត្តចំណូល និងចំណាយ**

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| | | | | **ផ្នែកចំណូល** |
| ៧០ | ចំណូលសារពើពន្ធ | 3,134,000,000 | 8,257,705,337 | 263% |
| ៧២ | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 608,000,000 | 794,146,351 | 131% |
| ៧៣ | ផលទុនលើការលក់-ជួលទ្រព្យ សម្បត្តិនិងសេវា | 1,753,000,000 | 1,051,906,964 | 60% |
| ៧៤ | ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម | - | - | - |
| ៧៥ | ការឧត្ថម្ភកធន | 12,620,000,000 | 47,860,500,000 | 379% |
| ៧៦ | ផលហិរញ្ញវត្ថុ | - | 5,400,000 | % |
| ៧៧ | ផលផ្សេងៗ និងផលពិសេស | - | - | - |
| ៧៨ | ការងារនៃរដ្ឋទេយ្យ | - | - | - |
| ០៨ | ចំណូលមូលនិធិបំរុង | - | - | - |
| ១៣ | ឧបត្ថម្ភកធន-វិនិយោគ | - | - | - |
| **សរុបចំណូល** | | 18,115,000,000 | 57,969,658,652 | 320% |
| | | | | **ផ្នែកចំណាយ** |
| ៦០ | ការទិញ | 1,728,047,000 | 1,704,837,300 | 99% |
| ៦១ | សេវាខាងក្រៅ | 38,300,685,000 | 38,102,186,376 | 99% |
| ៦២ | សេវាខាងក្រៅផ្សេងៗ | 394,300,000 | 382,897,000 | 99% |
| ៦៣ | ពន្ធ និងអាករ | 2,000,000 | 2,000,000 | 100% |
| ៦៤ | បន្ទុកបុគ្គលិក | 3,233,968,000 | 2,875,687,850 | 89% |
| ៦៥ | ឧបត្ថម្ភកធន និងជំនួយសង្គម | 1,020,000,000 | 1,020,000,000 | 100% |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | - | - | - |
| ៦៧ | បន្ទុកពិសេស | - | - | - |
| ៦៨ | ទាយជ្ជទានឱ្យដល់រំលួសអចលកម្មរូបី | - | - | - |

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ៦៩ | ចំណាយមិនបានគ្រោងទុក | - | - | - |
| ២០ | អចលកម្មអរូបី | - | - | - |
| ២១ | អចលកម្មរូបី | 15,846,000,000 | 9,815,700,000 | 62% |
| | **សរុបចំណាយ** | **60,525,000,000** | **53,903,308,526** | **89%** |

### ១.៥.២.ការគ្រប់គ្រងទ្រព្យសម្បត្តិ

ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្តកោះកុង ដោយមានការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាសេនាធិការ បានខិតខំតាមដានត្រួតពិនិត្យ ចុះបញ្ជីនូវសម្ភារប្រើប្រាស់ថ្មី ចាស់ ខិតខំសហការជាមួយមន្ត្រីជំនាញចុះធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋបាលខេត្ត និងជំរុញការលុបចេញពីបញ្ជីសារពើភណ្ឌនូវសម្ភារមួយចំនួន ដែលប្រើប្រាស់លែងកើត។

**តារាងទី១៥ ៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ទ្រព្យសម្បត្តិ ដែលបានទិញ ឬទទួល (ថ្មី) | 34 |
| 2 | ទ្រព្យសម្បត្តិ ដែលបានកាត់ចេញ | 0 |

### ១.៦. ការងារលទ្ធកម្ម

- ក្នុងឆ្នាំ2021 អង្គភាពលទ្ធកម្មសាលាខេត្តកោះកុងសម្រេចបានលទ្ធផល ការងារដូចខាងក្រោម៖
  - លទ្ធកម្មទំនិញ អនុវត្តបាន 06គម្រោង
    1. ប្រេងឥន្ធនៈ និងប្រេងរំអិល
    2. សម្ភារការិយាល័យ និងបោះពុម្ព
    3. សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា
    4. សង្ហារឹម
    5. គ្រឿងឧបភោគបរិភោគ
    6. សម្លៀកបំពាក់ និងឧបភោគបរិភោគ
  - លទ្ធកម្មសំណង់ អនុវត្តបាន 09គម្រោង
    1. ការងារសាងសង់អគារច្រកចេញចូលតែមួយស្រុកកោះកុងទំហំ 10ម៉ែត្រ គុណ 21ម៉ែត្រ និង 4ម៉ែត្រ គុណ 4ម៉ែត្រ សម្រាប់ឆ្នាំ2021
    2. ការងារសាងសង់លូជ្រុងកាត់ផ្លូវទំហំ 3ម៉ែត្រ គុណ 2ម៉ែត្រ ប្រវែង 11ម៉ែត្រ ស្ថិតនៅភូមិ1 សង្កាត់ស្មាច់មានជ័យ (ជិតផ្ទះលោកស្រី អៀ អូន) និងសាងសង់លូមូលរំដោះទឹក អង្កត់ផ្ចិត 0.8ម៉ែត្រ បណ្តោយផ្លូវប្រវែង 150ម៉ែត្រ ស្មើនឹង 135កង់ និងអណ្តូងលូចំនួន 10អណ្តូង ស្ថិតនៅតាមបណ្តោយផ្លូវកៅស៊ូក្បែរផ្សារដងទង់ស្ថិតនៅភូមិ2 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុងសម្រាប់ឆ្នាំ2021
    3. ការងារជួសជុលបណ្តាញអគ្គិសនី 100បង្គោល ក្នុងក្រុងខេមរភូមិន្ទ និង 31បង្គោល ក្នុងស្រុកមណ្ឌលសីមា
    4. ការងារជួសជុលផ្លូវបេតុងចំនួន 08ខ្សែ ក្នុងនោះ ក្រុងខេមរភូមិន្ទ ចំនួន 05ខ្សែ និងស្រុកមណ្ឌលសីមា ចំនួន 03ខ្សែ
    5. ការងារជួសជុលផ្លូវដោយចាក់បេតុងអាមេប្រវែង 2,260ម៉ែត្រ ទទឹង 6ម៉ែត្រ កម្រាស់ 0,15ម៉ែត្រ ចិញ្ចើមក្រួសក្រហម 0,50ម៉ែត្រសងខាងផ្លូវ មានផ្ទៃក្រឡាបេតុងអាមេទំហំ 13,560ម៉ែត្រការ៉េ ស្ថិតនៅភូមិ

ត្រពាំង - ភូមិត្រៀក ឃុំស្រែអំបិល ស្រុកស្រែអំបិល និងការងារសាងសង់អគារសាលាខេត្តកោះកុងថ្មី (ជំហាន2) ដែលមានបណ្តោយ 42ម៉ែត្រ ទទឹង 14,5ម៉ែត្រ និងប្រកចូលខាងមុខ (2,5 ម៉ែត្រ គុណ 6ម៉ែត្រ) ស្ថិតនៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុងសម្រាប់ឆ្នាំ2021

6. ការងារជួសជុលអគារសាលមហោស្រពខេត្តកោះកុង ដែលមានបណ្តោយប្រវែង 40ម៉ែត្រ និង ទទឹង 24ម៉ែត្រ ទីតាំងស្ថិតនៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ និងការងារជួសជុលសួនច្បារ ក្រាលការ៉ូក្រានីត និងចាក់បេតុងចិញ្ចើមផ្លូវសងខាងសួនច្បារបណ្តោយ 458ម៉ែត្រ ទទឹង 27ម៉ែត្រចាប់ពីចំណុចមុខវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសតេជោសែនកោះកុង ឆ្ពោះទៅព្រែកកោះប៉ោ ស្ថិតក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានផ្ទៃក្រឡាសរុប 12,366ម៉ែត្រក្រឡា
7. ការងារជួសជុលផ្លូវដោយចាក់កៅស៊ូអាសេ(AC)-កំណាត់ផ្លូវទី1 ប្រវែង 436ម៉ែត្រ ទទឹង 12,75ម៉ែត្រ កំណាត់ផ្លូវទី2 ប្រវែង 436ម៉ែត្រ ទទឹង 12,50ម៉ែត្រ, កំណាត់ផ្លូវទី3 ទំហំ 3,186ម៉ែត្រការ៉េ, កំណាត់ផ្លូវទី4 ប្រវែង 115ម៉ែត្រ ទទឹង 7ម៉ែត្រ ដែលមានកម្រាស់ 70មីលីម៉ែត្រ ទំហំសរុប 15,000ម៉ែត្រការ៉េ ស្ថិតនៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង (ចាប់ពីចំណុចវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសតេជោសែន កោះកុង ឆ្ពោះទៅព្រែកកោះប៉ោ និងពីព្រែកកោះប៉ោ មកកែងផ្លូវកាកបាទក្រហមខេត្តកោះកុង) សម្រាប់ឆ្នាំ2021
8. ការងារជួសជុលផ្លូវដោយចាក់កៅស៊ូអាសេ(AC) កំណាត់ផ្លូវទី1 ប្រវែង 500ម៉ែត្រ ទទឹង 7ម៉ែត្រ កំណាត់ផ្លូវទី2 ប្រវែង 174ម៉ែត្រ ទទឹង 9,7ម៉ែត្រ, កំណាត់ផ្លូវទី3 ប្រវែង 479ម៉ែត្រ ទទឹង 10ម៉ែត្រ កំណាត់ផ្លូវទី4 ប្រវែង 189ម៉ែត្រ ទទឹង 12ម៉ែត្រ, កំណាត់ផ្លូវទី5 ប្រវែង 200ម៉ែត្រ ទទឹង 7ម៉ែត្រ និង កំណាត់ផ្លូវទី6 ប្រវែង 67,71ម៉ែត្រ ទទឹង 20ម៉ែត្រ ដែលមានកម្រាស់ 70មីលីម៉ែត្រ ទំហំសរុប15,000 ម៉ែត្រការ៉េ ស្ថិតនៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង (ចាប់ពីចំណុចបញ្ជាការដ្ឋានកងរាជអាវុធខេត្តកោះកុងឆ្ពោះទៅស្តូប និងមកកែងផ្លូវកាកបាទក្រហមខេត្តកោះកុង)សម្រាប់ឆ្នាំ2021
9. ការងារស្តាបនាផ្លូវកៅស៊ូ(AC)ប្រវែង 2,143ម៉ែត្រ ទទឹង 7ម៉ែត្រ កម្រាស់ 70មីលីម៉ែត្រ ចំនួន 1ខ្សែ ចាប់ពីមជ្ឈមណ្ឌលស៊ូននឹងឆ្ពោះទៅសាលាក្រុងខេមរភូមិន្ទ និងពីសាលាក្រុងខេមរភូមិន្ទ ឆ្ពោះទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ សម្រាប់ឆ្នាំ2021។

## ១.៧. ការខារអខ្គភាពច្រកចេញ ចូលតែមួយ

| ល.រ | ឈ្មោះវិស័យ | ចំនួនសេវា/នាក់ | | ថវិកាសរុបរួម (គិតជារៀល) |
|---|---|---|---|---|
| | | នាក់ | ស្ត្រី | |
| 1 | នីត្យានុកូលកម្ម | 47 | 21 | 1,296,000 |
| 2 | ការងាររដ្ឋបាល | 55 | 23 | 33,322,700 |
| | -ប័ណ្ណព្រំដែន | 37 | 18 | 740,000 |
| | -ចាក់បំពេញអាចម៍ដីឯកជន | 06 | 02 | 4,800,000 |
| | -អនុញ្ញាតលើកផ្ទាំងប៉ាណូ | 12 | 03 | 27,782,700 |
| 3 | សុខាភិបាល | 16 | 08 | 5,470,000 |
| 4 | ទេសចរណ៍ | 64 | 33 | 4,223,000 |
| 5 | សាធារណការ និងដឹកជញ្ជូន | 296 | 48 | 60,292,000 |

| ល.រ | ឈ្មោះវិស័យ | ចំនួនសេវា/នាក់ | | ថវិកាសរុបរួម (គិតជារៀល) |
|---|---|---|---|---|
| | | នាក់ | ស្ត្រី | |
| | -សេវាដឹកជញ្ជូនតាមផ្លូវគោក | 278 | 41 | 58,932,000 |
| | -សេវាដឹកជញ្ជូនតាមផ្លូវទឹក | 18 | 07 | 1,360,000 |
| 6 | វប្បធម៌ និងវិចិត្រសិល្បៈ | 01 | 0 | 200,000 |
| 7 | ព័ត៌មាន | 68 | 31 | 50,200,000 |
| 8 | បរិស្ថាន | 0 | 0 | 0 |
| 9 | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 34 | 11 | 5,575,000 |
| 10 | រ៉ែ និងថាមពល | 31 | 18 | 3,250,000 |
| 11 | ពាណិជ្ជកម្ម | 0 | 0 | 0 |
| 12 | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់(ក)+(ខ) | 2,212 | 458 | 653,603,163 |
| | (ក) សំណង់ | 52 | 08 | 204,172,500 |
| | (ខ) សុរិយោដី | 2,160 | 450 | 449,430,663 |
| 13 | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 927 | 504 | 31,379,900 |
| 14 | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 84 | 13 | 3,840,000 |
| **សរុបរួម** | | **3,835** | **1,168** | **852,651,763** |

### ១.៨ ការងារគ្រប់គ្រងពលករ

គិតចាប់ពី ថ្ងៃទី2 ខែមេសា ឆ្នាំ2020 ដល់បច្ចុប្បន្ន មានពលករសរុបចំនួន 1,780នាក់ ស្រី 572នាក់ បានមកពីប្រទេសនានា ចូលមកខេត្តកោះកុង ក្នុងនោះមានករណីវិជ្ជមានកូវីដ-19 ចំនួន 47នាក់ ស្រី 20នាក់។

# ផ្នែកទី២

# ការងាររដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់

## ២.១. ការងាររដ្ឋបាលក្រុង ស្រុក

### ២.១.១. ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ដីកាដែលបានដាក់ចេញ | 28 |
| 2 | សេចក្តីសម្រេចដែលបានដាក់ចេញ | 132 |
| 3 | លិខិតរដ្ឋបាលដែលបានដាក់ចេញ | 7,921 |
| 4 | លិខិតដែលបានទទួល | 3,944 |
| 5 | សៀវភៅស្នាក់នៅ | 2,543 |

### ២.១.២. ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | សេចក្តីចម្លងសំបុត្រកំណើត | 1,013 |
| 2 | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | 10,140 |

| | | |
|---|---|---|
| 3 | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | 1,076 |
| 4 | សេចក្តីចម្លងសំបុត្រមរណភាព | 141 |

### ២.១.៣. ការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| **ក). ការផ្សព្វផ្សាយព័ត៌មាន** | | |
| 1 | វិទ្យុ | 0 |
| 2 | ទូរទស្សន៍ | 8 |
| 3 | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | 520 |
| 4 | ព្រឹត្តិបត្រព័ត៌មានទស្សនាវដ្តី សារព័ត៌មាន | 12 |
| 5 | ផ្សេងៗ | 2,141 |
| **ខ). ទំនាក់ទំនងសាធារណៈ** | | |
| 1 | សាធារណជនមកទំនាក់ទំនងសាលាក្រុង ស្រុក | 14,448 |
| 2 | គណៈប្រតិភូភ្ញៀវជាតិអន្តរជាតិ | 51 |

### ២.១.៤. កិច្ចប្រជុំគណៈអភិបាល

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | 57 |
| 2 | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល | 42 |

### ២.១.៥. កិច្ចប្រជុំក្រុមប្រឹក្សានិងគណៈកម្មាធិការ និងការរៀបចំវេទិកាសាធារណៈ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | 84 |
| 2 | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | 24 |
| 3 | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | 1 |
| 4 | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | 7 |
| 5 | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | 65 |
| 6 | ការរៀបចំវេទិកាសាធារណៈ | 13 |

### ២.១.៦. គម្រោងវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង |
|---|---|---|---|
| 1 | សេដ្ឋកិច្ច | 124 | 8,913,884,000 |
| 2 | សង្គមកិច្ច | 249 | 9,241,328,000 |
| 3 | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ | 97 | 11,901,660,000 |
| 4 | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 98 | 2,794,740,000 |
| **សរុប** | | **568** | **32,851,612,000** |

### ២.១.៧. ការអនុវត្តគម្រោងវិនិយោគក្រុង ស្រុក

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| 1 | សេដ្ឋកិច្ច | 124 | 92 | 00 | 32 |
| 2 | សង្គមកិច្ច | 249 | 205 | 00 | 44 |
| 3 | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ | 97 | 81 | 00 | 16 |
| 4 | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 98 | 57 | 00 | 41 |
| | **សរុប** | **568** | **435** | **00** | **133** |

### ២.១.៨. ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| 1 | សមាជិកក្រុមប្រឹក្សា | 80 | 17 |
| 2 | ប្រធានក្រុមប្រឹក្សា | 7 | 2 |
| 3 | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | 5 | 1 |
| 4 | អភិបាល | 7 | 0 |
| 5 | អភិបាលរង | 27 | 8 |
| 6 | នាយករដ្ឋបាល | 4 | 0 |
| 7 | នាយករងរដ្ឋបាល | 8 | 2 |
| 8 | ប្រធានការិយាល័យ និងអង្គភាព | 61 | 9 |
| 9 | អនុប្រធានការិយាល័យ និងអង្គភាព | 53 | 12 |
| 10 | មន្ត្រីការិយាល័យ | 85 | 23 |
| 11 | បុគ្គលិកកិច្ចសន្យា | 30 | 12 |

### ២.១.៩.ការអភិវឌ្ឍសមត្ថភាព

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ចំនួនវគ្គសិក្សា | 63 |
| 2 | ចំនួនសិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | 465 |
| 3 | ចំនួនសិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | 138 |

### ២.១.១០. ការសម្រុះសម្រួលទំនាស់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយរដ្ឋបាលក្រុង ស្រុក | 36 |
| 2 | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | 24 |
| | **សរុប** | 60 |

### ២.១.១១.កិច្ចការច្រកចេញចូលតែមួយ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | សេវាសរុបដែលបានផ្តល់ចប់សព្វគ្រប់ | 65,190 |
| 2 | ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា | 20,416 |

| | | |
|---|---|---|
| 3 | ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា | 7,783 |
| 4 | ចំណូលដែលទទួលបានពីការផ្តល់សេវា | 238,610,000 |
| 5 | ករណីបណ្តឹងដែលទទួលបានសរុប | 157 |
| 6 | ករណីបណ្តឹងដែលបានដោះស្រាយរួចជាស្ថាពរ | 147 |

**២.១.១២. ការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក**

| ល.រ | សូចនាករ | ផែនការប្រចាំឆ្នាំ | លទ្ធផលសម្រេច | |
|---|---|---|---|---|
| | | | ជាក់ស្តែង | % |
| 1 | ចំនួនកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ក្រុង ស្រុក | 84 | 24 | 29% |
| 2 | ចំនួនថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើផ្នែកសេវាសង្គម (រៀល) | 00 | 00 | 00% |
| 3 | ក្រុង ស្រុកបានចងក្រងទិន្នន័យអត្រានុកូលដ្ឋាន ដែលទទួលបានពីឃុំ សង្កាត់ | 84 | 24 | 29% |
| 4 | ចំនួនបេសកកម្មដែល គ.ក.ស.ក ក្រុង ស្រុកបានចុះគាំទ្រ និងផ្តល់សេវាសង្គម | 38 | 23 | 61% |
| 5 | ចំនួនឃុំសង្កាត់ដែល គ.ក.ស.ក ក្រុង ស្រុក បានចុះគាំទ្រ | 29 | 10 | 34% |
| 6 | ចំនួនវគ្គបណ្តុះបណ្តាលដែល គ.ក.ស.ក ក្រុង ស្រុកបានទទួល | 24 | 05 | 21% |

**២.១.១៣. ការអនុវត្តចំណូល និងចំណាយ**

| ល.រ | ការបរិយាយ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| 1 | ចំណូលសរុប | 9,223,400,000 | 7,534,122,260 | 82% |
| 2 | ចំណាយសរុប | 9,223,400,000 | 6,818,845,650 | 74% |

**២.១.១៤. ការគ្រប់គ្រងទ្រព្យសម្បត្តិ**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ទ្រព្យសម្បត្តិ ដែលបានទិញ ឬទទួល (ថ្មី) | 554 |
| 2 | ទ្រព្យសម្បត្តិ ដែលបានកាត់ចេញ | 58 |

## ២.២. ការិយាល័យរដ្ឋបាលឃុំ សង្កាត់

**២.២.១.ស្ថិតិក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិក**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| 1 | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | 80 | 26 |
| 2 | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានផ្លាស់ប្តូរ | 01 | 01 |
| 3 | មេឃុំ ចៅសង្កាត់ | 29 | 03 |
| 4 | ជំទប់ទី1 ចៅសង្កាត់រងទី1 | 29 | 03 |
| 5 | ជំទប់ទី2 ចៅសង្កាត់រងទី2 | 29 | 04 |
| 6 | ស្មៀនឃុំ សង្កាត់ | 28 | 03 |
| 7 | បុគ្គលិកកិច្ចសន្យា | 11 | 02 |
| 8 | មេភូមិ | 119 | 09 |
| 9 | អនុប្រធានភូមិ | 119 | 34 |

| | | | |
|---|---|---|---|
| 10 | សមាជិកភូមិ | 119 | 63 |
| 11 | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារដែលមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ | 06 | 06 |
| 12 | ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ | 25 | 09 |

### ២.២.២.ដីកា សេចក្តីសម្រេច និងលិខិត

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ដីកាដែលបានដាក់ចេញ | 229 |
| 2 | សេចក្តីសម្រេចដែលបានដាក់ចេញ | 159 |
| 3 | លិខិតរដ្ឋបាលដែលបានដាក់ចេញ | 12,132 |
| 4 | លិខិតដែលបានទទួល | 2,491 |

### ២.២.៣. កិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ និង គ.ក.ន.ក

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | 348 |
| 2 | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | 212 |
| 3 | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | 04 |
| 4 | កិច្ចប្រជុំ គ.ក.ន.ក | 348 |

### ២.២.៤. គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាឃុំ សង្កាត់

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង |
|---|---|---|---|
| 1 | សេដ្ឋកិច្ច | 52 | 4,635,586,762 |
| 2 | សង្គមកិច្ច | 24 | 64,600,200 |
| 3 | ធនធានធម្មជាតិ និងបរិស្ថាន | 9 | 368,500,000 |
| 4 | សេវាកម្មរដ្ឋបាល និងសន្តិសុខ | 13 | 12,700,000 |
| 5 | យេនឌ័រ | 18 | 9,630,000 |
| សរុប | | **116** | **5,091,016,962** |

### ២.២.៥. ការអនុវត្តគម្រោងឃុំ សង្កាត់

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| 1 | សេដ្ឋកិច្ច | 52 | 24 | 00 | 28 |
| 2 | សង្គមកិច្ច | 24 | 12 | 00 | 12 |
| 3 | ធនធានធម្មជាតិ និងបរិស្ថាន | 9 | 2 | 00 | 7 |
| 4 | សេវាកម្មរដ្ឋបាល និងសន្តិសុខ | 13 | 5 | 00 | 8 |
| 5 | យេនឌ័រ | 18 | 9 | 00 | 9 |
| សរុប | | **116** | **52** | **00** | **64** |

### ២.២.៦.ការអនុវត្តថវិកាឃុំ សង្កាត់

| ល.រ | ការបរិយាយ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| 1 | ចំណូលសរុប | 14,283,545,001 | 9,950,353,697 | 69.66% |
| 2 | ចំណាយសរុប | 14,283,545,001 | 10,766,030,359 | 75.37% |

### ២.២.៧.ការគ្រប់គ្រងទ្រព្យសម្បត្តិឃុំ សង្កាត់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ទ្រព្យសម្បត្តិឃុំ សង្កាត់ ដែលបានទិញ ឬទទួល (ថ្មី) | 272 |
| 2 | ទ្រព្យសម្បត្តិឃុំ សង្កាត់ដែលបានកាត់ចេញ | 14 |

### ២.២.៨.ការអភិវឌ្ឍសមត្ថភាព

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ចំនួនវគ្គសិក្សា | 92 |
| 2 | ចំនួនសិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | 425 |
| 3 | ចំនួនសិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | 163 |

### ២.២.៩.សកម្មភាពសេវាសង្គម

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីឃុំ សង្កាត់ | 12 |
| 2 | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់សម្រាប់កែលម្អអនាម័យ (ការលាងដៃនឹងសាប៊ូ) | 776 |
| 3 | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ | 10 |
| 4 | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ | 21 |
| 5 | គ្រួសារងាយរងគ្រោះដែលឃុំ សង្កាត់ចុះកំណត់អត្តសញ្ញាណ | 1966 |
| 6 | ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីឃុំ សង្កាត់ | 38 |

### ២.២.១០.ការសម្រុះសម្រួលទំនាស់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់ | 122 |
| 2 | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | 24 |

### ២.២.១១. ការងារអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | សំបុត្រកំណើត | 2,164 |
| 2 | សំបុត្របញ្ជាក់កំណើត | 2,307 |
| 3 | សេចក្តីចម្លងសំបុត្រកំណើត | 1,747 |
| 4 | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | 1,134 |
| 5 | សំបុត្រអាពាហ៍ពិពាហ៍ | 513 |
| 6 | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | 580 |
| 7 | សំបុត្រមរណភាព | 497 |
| 8 | សេចក្តីចម្លងសំបុត្រមរណភាព | 888 |

### ២.២.១២.ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| 1 | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី | 4,744 |
| 2 | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | 571 |
| 3 | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី) | 73,158 |

## ២.៣. បញ្ហាប្រឈមដែលរដ្ឋបាលក្រុង ស្រុកបានជួបប្រទះ

- **ស្រុកបូទុំសាគរ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | មន្ត្រីមានចំនួនតិច មិនសមស្របតាមរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក | ស្នើសុំមន្ត្រីបន្ថែម ដើម្បីបំពេញក្នុងរចនាសម្ព័ន្ធដែលខ្វះខាត |
| 2 | សមត្ថភាពមន្ត្រីមួយចំនួននៅមានកម្រិត ក្នុងការបំពេញការងារ | ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពដល់មន្ត្រីរាជការ |
| 3 | ប្រជាពលរដ្ឋមិនទាន់យល់ច្បាស់អំពីច្បាប់ភូមិបាល | ធ្វើការផ្សព្វផ្សាយអំពីច្បាប់ភូមិបាលជូនដល់ប្រជាពលរដ្ឋ |
| 4 | ការងារហិរញ្ញវត្ថុមានភាពស្មុគស្មាញ | ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាល |
| 5 | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្ត មិនបានផ្សព្វផ្សាយអំពីលិខិតបទដ្ឋានចេញថ្មី | ស្នើសុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្ត ធ្វើការផ្សព្វផ្សាយលិខិតបទដ្ឋានចេញថ្មី ឱ្យបានទូលំទូលាយ |
| 6 | ការរិភាជន៍ថវិកាពីថ្នាក់ជាតិមកយឺតយ៉ាវ | សូមថ្នាក់ជាតិទម្លាក់ថវិកាមកថ្នាក់ក្រោមជាតិឱ្យបានទាន់ពេលវេលា |

- **ស្រុកគិរីសាគរ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | ការយល់ដឹងរបស់មន្ត្រីនៅមានកម្រិត | ស្នើមានវគ្គបណ្តុះបណ្តាលអំពីការងាររដ្ឋបាលដល់មន្ត្រី |
| 2 | ពុំមានមន្ត្រីគ្រប់គ្រាន់សម្រាប់បម្រើការងារ | រង់ចាំក្រសួងមហាផ្ទៃអនុញ្ញាតឱ្យជ្រើសរើសមន្ត្រីបន្ថែម |
| 3 | ផ្លូវចូលតាមភូមិ និងចម្ការប្រជាពលរដ្ឋ ពិបាកក្នុងការធ្វើដំណើរ | សូមថ្នាក់លើជួយជំរុញក្រុមហ៊ុន ក្នុងការជួយជួសជុលផ្លូវ នៅតាមបណ្តាភូមិ ឃុំតាមការសន្យា |
| 4 | ការសាងសង់លំនៅឋាន និងសំណង់ផ្សេងៗរបស់ប្រជាពលរដ្ឋនៅបន្តសាងសង់មុនមានច្បាប់អនុញ្ញាត សំណង់តូចៗ នៅតែបន្តសាងសង់ ចូលចំណីផ្លូវសាធារណៈជាបន្តបន្ទាប់ | ជំរុញលោកមេឃុំសហការក្នុងការទប់ស្កាត់ការសាងសង់មិនទាន់មានច្បាប់ និងពន្យល់ណែនាំដល់ប្រជាពលរដ្ឋដើម្បីរួមគ្នា អនុវត្តតាមនីតិវិធីច្បាប់សំណង់ |
| 5 | ទំនាស់ដីធ្លីកើតមានជាបន្តបន្ទាប់ព្រោះម្ចាស់ដីមិនបានគ្រប់គ្រង់ដីរបស់ខ្លួនទៅតាមឯកសារដែលអន្តរក្រសួងបានបែងចែកជូនកន្លងមក | អាជ្ញាធរស្រុក ឃុំ ជំរុញការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ចូលរួមមកចុះបញ្ជីឱ្យបានគ្រប់គ្នា |
| 6 | ខ្វះបុគ្គលិកជាស្ត្រីផ្តល់សេវាផ្នែកពន្យារកំណើត | ស្នើការិយាល័យស្រុកប្រតិបត្តិផ្តល់បុគ្គលិកបន្ថែម |
| 7 | ពុំមានរថយន្តសង្គ្រោះ | ស្នើសុំការិយាល័យស្រុកប្រតិបត្តិផ្តល់រថយន្តសង្គ្រោះ |
| 8 | អនុវិទ្យាល័យព្រែកខ្សាច់ និងអនុវិទ្យាល័យព្រែកស្មាច់ និងសាលាបឋមសិក្សាហ៊ុនសែនកោះស្តេច ខ្វះអគារសិក្សា | ស្នើសុំរដ្ឋបាលខេត្ត និងមន្ទីរអប់រំ យុវជន និងកីឡា ជួយផ្តល់អគារសម្រាប់សិក្សា |

- **ស្រុកកោះកុង**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | មន្ត្រីមានចំនួនតិច មិនសមស្របតាមរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក | ស្នើសុំមន្ត្រីបន្ថែម ដើម្បីបំពេញក្នុងរចនាសម្ព័ន្ធដែលខ្វះខាត |
| 2 | សមត្ថភាពមន្ត្រីមួយចំនួននៅមានកម្រិត ក្នុងការបំពេញការងារ | ស្នើសុំឱ្យមានវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពដល់មន្ត្រីរាជការ |
| 3 | ដីដែលប្រជាពលរដ្ឋបានរស់នៅកាន់កាប់ និងអាស្រ័យផលជាក់ស្តែងមិនទាន់មានសិទ្ធិស្របច្បាប់លើដីធ្លី (ដីដែលបានវាស់វែងរួចមិនទាន់បានចេញប្លង់កម្មសិទ្ធិ បទបញ្ញា លេខ 01បប) | ស្នើសុំអង្គភាពពាក់ព័ន្ធជួយដោះស្រាយដល់ប្រជាពលរដ្ឋដែលបានរស់នៅកាន់កាប់ និងអាស្រ័យផលជាក់ស្តែងមានសិទ្ធិស្របច្បាប់លើដីធ្លី |
| 4 | អគារសិក្សានៅបឋមសិក្សាឡាំដាំ 01ខ្នង 05បន្ទប់ មានសភាពទ្រុឌទ្រោមខ្លាំង | ស្នើសុំសប្បុរសជន និងក្រសួងអប់រំ យុវជន និងកីឡាជួយដោះស្រាយ |
| 5 | សាលារៀននៅវត្តត្រពាំងរូង 01ខ្នង 03បន្ទប់ ប្រើប្រាស់សម្រាប់ទីចាត់ការ និងបណ្ណាល័យ ធ្វើពីឈើមានសភាពទ្រុឌទ្រោមខ្លាំង | ស្នើសុំសប្បុរសជន និងក្រសួងអប់រំ យុវជន និងកីឡាជួយដោះស្រាយ |
| 6 | សាលាឧបសម្ព័ន្ធអារឡាតាន់ 01ខ្នង 03បន្ទប់ ធ្វើពីឈើប្រក់ហ្វីប្រូ ជញ្ជាំងមានសភាពពុកខូច | ស្នើសុំសប្បុរសជន និងក្រសួងអប់រំ យុវជន និងកីឡាជួយដោះស្រាយ |
| 7 | សាលាមួយចំនួនខ្វះទឹកប្រើប្រាស់នៅរដូវប្រាំងដូចជាបឋមកោះស្រឡៅ អនុវិទ្យាល័យកោះស្រឡៅ បឋមកោះកាពិ បឋមឡាំដាំ បឋមអារឡាតាន់ ឧបសម្ព័ន្ធភ្នំមាស និងឧបសម្ព័ន្ធវាលតាកូ | ស្នើសុំស៊ីទែនទឹក និងជីកអណ្តូង |

- **ក្រុងខេមរភូមិន្ទ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | អគារធ្វើការងារតូចចង្អៀត | ស្នើសុំអគាររដ្ឋបាលស្តង់ដារថ្មី |
| 2 | ការសាងសង់លំនៅឋាន ផ្ទះល្វែង និងសំណង់ អគារផ្សេងៗរបស់ប្រជាពលរដ្ឋ នៅបន្តសាងសង់មុនមានច្បាប់អនុញ្ញាត | សហការជាមួយអាជ្ញាធរភូមិ សង្កាត់ ជួយទប់ស្កាត់ការសាងសង់មុនមានច្បាប់អនុញ្ញាត និងធ្វើការផ្សព្វផ្សាយអំពីច្បាប់ភូមិបាល និងសំណង់ |
| 3 | ប្រជាពលរដ្ឋមួយចំនួនបានចាក់ដីលុបអូរ ផ្លូវ សាធារណៈយកជាកម្មសិទ្ធិផ្ទាល់ខ្លួន | សហការជាមួយអាជ្ញាធរភូមិ សង្កាត់ ជួយទប់ស្កាត់សកម្មភាពទាំងនេះ និងពន្លឿនការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ |

- **ស្រុកមណ្ឌលសីមា**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | សមត្ថភាពការងារហិរញ្ញវត្ថុនៅមានកម្រិត | ស្នើសុំវគ្គបណ្តុះបណ្តាលបន្ថែម |
| 2 | មន្ត្រីមានចំនួនតិច មិនសមស្របតាមរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក | ស្នើសុំមន្ត្រីបន្ថែម ដើម្បីបំពេញក្នុងរចនាសម្ព័ន្ធដែលខ្វះខាត |
| 3 | ចំណេះដឹងពាក់ព័ន្ធការងារការិយាល័យច្រកចេញចូលតែមួយនៅមានកម្រិតសម្រាប់ផ្នែកជួរមុខ និងជួរក្រោយ | សូមមានវគ្គបណ្តុះបណ្តាលបន្ថែមពាក់ព័ន្ធការងារការិយាល័យច្រកចេញចូលតែមួយ |

| | | |
|---|---|---|
| 4 | ការយល់ដឹងរបស់ប្រជាពលរដ្ឋពីការិយាល័យច្រកចេញចូលតែមួយមិនទាន់ទូលំទូលាយ | រៀបចំផែនការសកម្មភាពផ្សព្វផ្សាយអំពីការងាររបស់ការិយាល័យច្រកចេញចូលតែមួយដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានក្នុងស្រុក |
| 5 | អាជីវករ សិប្បករ ដែលធ្លាប់ស្នើសុំសេវានៅមន្ទីរមិនទាន់យល់ដឹង និងជឿទុកចិត្តក្នុងការស្នើសុំសេវានៅការិយាល័យច្រកចេញចូលតែមួយ | រៀបចំផែនការសកម្មភាពផ្សព្វផ្សាយអំពីការងារការិយាល័យច្រកចេញចូលតែមួយដល់អាជីវករដែលធ្លាប់ស្នើសុំសេវានៅតាមមន្ទីរឱ្យគាត់ងាកមកសុំសេវានៅការិយាល័យច្រកចេញចូលតែមួយ |
| 6 | គុណភាពសិក្សានៅក្រោមបន្ទាត់ស្តង់ដារបស់ក្រសួងអប់រំ យុវជន និងកីឡា | -ប្រជុំជាមួយនាយក លោកគ្រូអ្នកគ្រូ ដើម្បីពង្រឹងការសិក្សារបស់សិស្សគ្រប់ភូមិសិក្សា<br>-លើកបញ្ហាការសិក្សារបស់សិស្សជូនដល់អង្គប្រជុំក្រុមប្រឹក្សាឃុំប្រចាំខែ |
| 7 | ខ្វះធនធានថវិកាក្នុងការផ្សព្វផ្សាយស្តីពីសិទ្ធិស្ត្រី និងកុមារ ច្បាប់អំពើហិង្សា ការរំលោភ និងចំណាកស្រុក | ស្នើសុំថវិកាបើកវគ្គផ្សព្វផ្សាយដល់ស្ត្រី និងកុមារនៅមូលដ្ឋានឱ្យបានគ្រប់ភូមិ |
| 8 | ខ្វះធនធានថវិកាក្នុងការផ្សព្វផ្សាយស្តីពីការពង្រឹងសមត្ថភាពដល់ស្ត្រី និងកុមារ និងកែប្រែឥរិយាបថតម្លៃគ្រួសារខ្មែរ | ស្នើសុំថវិកាបើកវគ្គផ្សព្វផ្សាយដល់ស្ត្រី និងកុមារនៅមូលដ្ឋានឱ្យបានគ្រប់ភូមិ |
| 9 | ការសាងសង់សំណង់លំនៅឋាន និងសំណង់ផ្សេងៗរបស់ពលរដ្ឋមិនបានរៀបចំការដ្ឋានទៅតាមច្បាប់សំណង់ | បន្តសហការជាមួយភូមិ ឃុំ ចុះណែនាំឱ្យរៀបចំការដ្ឋានឱ្យបានរៀបរយមុននឹងសាងសង់ និងផ្សព្វផ្សាយច្បាប់សំណង់ដល់ប្រជាពលរដ្ឋ |
| 10 | ទំនាស់ដីធ្លីនៅតែមានបន្ត | បន្តខិតខំដោះស្រាយនូវទំនាស់ទាំងនេះ |

- **ស្រុកស្រែអំបិល**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | ពុំមានមន្ត្រីគ្រប់គ្រាន់សម្រាប់បម្រើការងារ | ស្នើសុំមន្ត្រីបន្ថែម |
| 2 | សមត្ថភាពមន្ត្រីមួយចំនួន នៅមានកម្រិត | ផ្តល់វគ្គបណ្តុះបណ្តាល និងវគ្គបំប៉ន |
| 3 | ប្រជាពលរដ្ឋមិនសូវយល់ដឹងអំពីការស្នើសុំសេវានៅការិយាល័យច្រកចេញចូលតែមួយ និងពឹងអ្នករត់ការ | ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ |
| 4 | សេវាចាក់បំពេញអាចម៍ដីកម្មសិទ្ធិឯកជន មានភាពអនាធិបតេយ្យ និងមិនសុំច្បាប់អនុញ្ញាត | អនុវត្តវិធានការចំពោះម្ចាស់អាជីវកម្ម |
| 5 | អាជ្ញាធរពាក់ព័ន្ធក្នុងការផ្តល់សេវាមិនសូវសហការធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ជូនឯកសារ និងហួសសុពលភាពដែលច្បាប់បានកំណត់ | សូមឱ្យអាជ្ញាធរពាក់ព័ន្ធជួយចុះហត្ថលេខាលើឯកសារដែលបញ្ជូនពីច្រកចេញចូលតែមួយឱ្យបានលឿន |
| 6 | កសិករនៅខ្វះចំណេះដឹងអំពីបច្ចេកទេសដាំដុះដំណាំកសិកម្ម ពិសេសទៅលើដំណាំបន្លែ បង្គាផ្សេងៗ | សហការជាមួយអង្គការដៃគូរអភិវឌ្ឍន៍ និងមន្ត្រីជំនាញដើម្បីផ្តល់សេវាបច្ចេកទេសបន្ថែមទៀត |
| 7 | ទឹកសមុទ្រហូរចូល ផ្ទៃដីស្រែរបស់កសិករ ដោយខ្វះទំនប់ការពារទឹកប្រៃ មានដូចជានៅឃុំដងពែង ឃុំដីខក្រោម | សិក្សាគម្រោងទំនប់ការពារទឹកប្រៃ ជួយការពារដីស្រែកសិករ កុំឱ្យទឹកប្រៃហូរចូល (មន្ទីរធនធានទឹក និងឧតុនិយម) |
| 8 | ខ្វះថវិកា សម្រាប់ប្រើប្រាស់មធ្យោបាយធ្វើដំណើរចុះទៅបំពេញការងារ នៅតាមមូលដ្ឋានឆ្ងាយៗ | ស្នើសុំថវិកា បេសកកម្ម |

| | | |
|---|---|---|
| 9 | ប្រជាពលរដ្ឋលួចកាប់រុករានដីព្រៃ ត្រាយព្រំសម្គាល់ និង បោះបង្គោលព្រំ ដើម្បីយកដីធ្វើកម្មសិទ្ធិ ស្ថិតក្នុងតំបន់ការពារ | ចាត់មន្ត្រីឧទ្យានុរក្សចុះល្បាតតាមដានត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិជាប្រចាំ |
| 10 | ប្រជាពលរដ្ឋនៅបន្តលួចកាប់ព្រៃដុតធ្យូង ក្នុងតំបន់ការពារ | អប់រំ និងផ្សព្វផ្សាយ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ |
| 11 | ប្រជាពលរដ្ឋ បន្តបោះចោលសំរាម នៅតាមទីសាធារណៈ តាមដងព្រែក និងអូរ | អប់រំ និងផ្សព្វផ្សាយ អនុក្រឹត្យលេខ113 ស្តីពីការទុកដាក់សំណល់រឹង រាវ ទីប្រជុំជន ដល់ប្រជាពលរដ្ឋ |
| 12 | ប្រជាពលរដ្ឋមិនទាន់យល់ដឹងពីច្បាប់ជលផល | ផ្សព្វផ្សាយ អំពីច្បាប់ជលផល |
| 13 | ប្រជាពលរដ្ឋមិនសូវចូលរួមទប់ស្កាត់បទល្មើស | បន្តផ្សព្វផ្សាយ និងជំរុញបន្ថែម |
| 14 | បញ្ហាដីធ្លីមានការកាប់រំលោភយកដីរដ្ឋធ្វើជាកម្មសិទ្ធិឯកជន ព្រៃឈើត្រូវបានកាប់បំផ្លាញ | ស្នើសុំជួយទប់ស្កាត់ និងចាប់ឃាត់ជនល្មើស |
| 15 | ស្ត្រីនៅមូលដ្ឋាននៅតែ រងនូវអំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន | ស្នើសុំវគ្គបណ្តុះបណ្តាលផ្សេងៗដល់នារីក្នុងសហគមន៍ |
| 16 | ប្រជាពលរដ្ឋខាងក្រោយមណ្ឌលសុខភាពស្រែអំបិលបាន យកដីទីធ្លាមណ្ឌលសុខភាពចំពាក់កណ្តាលធ្វើជាផ្លូវប្រើប្រាស់ធ្វើឱ្យពិបាកក្នុងការផ្តល់សេវា | ស្នើសុំថ្នាក់ដឹកនាំមន្ទីរ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ជួយបង្កើតគណៈកម្មាការចុះដោះស្រាយឱ្យបានឆាប់ព្រោះស្រុកប្រតិបត្តិមិនមានលទ្ធភាពដោះស្រាយទេ |
| 17 | ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីឆ្នាំ1992-1994 ម្ចាស់មិនបានមកកាន់កាប់ និងគ្រប់គ្រងលើដីជាក់ស្តែងទេ ហើយប្រជាពលរដ្ឋបានមករស់នៅកាន់កាប់ និងអាស្រ័យផលលើដីទាំងស្រុង | ស្នើថ្នាក់លើជួយដោះស្រាយ ចំពោះប្រជាពលរដ្ឋរស់នៅសព្វថ្ងៃនៅលើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីឆ្នាំ1992-1994 ឱ្យប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់លើដីធ្លី ដែលបានរស់នៅបច្ចុប្បន្ន |
| 18 | ការិយាល័យ ដនសក ស្រុក មិនអាចអនុញ្ញាតច្បាប់សាងសង់ជូនប្រជាពលរដ្ឋបាន ដោយអ្នកស្នើសុំភាគច្រើន ស្ថិតនៅលើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីឆ្នាំ 1992-1994 | ពិនិត្យ និងរកដំណោះស្រាយដល់ប្រជាពលរដ្ឋដែលរស់នៅកាន់កាប់ និងអាស្រ័យផលជាក់ស្តែងមានសិទ្ធិស្របច្បាប់លើដីធ្លី |
| 19 | លំនៅឋានរបស់ប្រជាពលរដ្ឋស្ថិតនៅតាមបណ្តោយដងព្រែកស្រែអំបិលតាំងពីឆ្នាំ1979មក ជាលំនៅឋានមិនរៀបរយ ដែលច្បាប់កំពុងហាមឃាត់ | ស្នើថ្នាក់លើជួយដោះស្រាយករណីនេះ ព្រោះរដ្ឋបាលស្រុក ពុំមានលទ្ធភាពដោះស្រាយ |
| 20 | បញ្ហាគ្រឿងញៀន | ផ្សព្វផ្សាយ អប់រំ និងណែនាំពីផលប៉ះពាល់នៃគ្រឿងញៀន និងមានវិធានការច្បាប់ |
| 21 | បញ្ហាក្មេងទំនើង និងអំពើហិង្សា | ផ្សព្វផ្សាយ អប់រំ ណែនាំ និងមានវិធានការច្បាប់ |
| 22 | ប្រជាពលរដ្ឋខ្វះការយល់ដឹងពីអត្ថប្រយោជន៍ នៃការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ | ផ្សព្វផ្សាយ និងជំរុញឱ្យប្រជាពលរដ្ឋ បានយល់ដឹងពីអត្ថប្រយោជន៍នៃការប្រើប្រាស់អត្តសញ្ញាណប័ណ្ណ សៀវភៅ (ក2)និង(ក4) |

- **ស្រុកថ្មបាំង**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | ពុំមានមន្ត្រីគ្រប់គ្រាន់សម្រាប់បម្រើការងារ | ស្នើសុំមន្ត្រីបន្ថែម |
| 2 | ការធ្វើផែនការឃុំ និងកម្មវិធីវិនិយោគស្រុក ឃុំ មិនច្បាស់លាស់ | ស្នើសុំរដ្ឋបាលខេត្ត ផ្តល់វគ្គបណ្តុះបណ្តាលបន្ថែម |
| 3 | ស្មៀនឃុំមួយចំនួនមិនបានសហការក្នុងការជួយរៀបចំធ្វើផែនការ និងកម្មវិធីវិនិយោគឃុំ | ជំរុញរដ្ឋបាលឃុំ និងស្មៀន សហការរៀបចំផែនការ និងកម្មវិធីវិនិយោគ |
| 4 | សមត្ថភាពមន្ត្រីមួយចំនួន នៅមានកម្រិត | ស្នើសុំរដ្ឋបាលខេត្តសម្របសម្រួលវគ្គបណ្តុះបណ្តាលបន្ថែម |
| 5 | កសិករមួយចំនួនពុំទាន់យល់ដឹងអំពីបច្ចេកទេសកសិកម្ម និងដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើង ហើយនៅពេលមន្ត្រីជំនាញចុះបើកវគ្គអប់រំផ្សព្វផ្សាយបច្ចេកទេសកសិកម្ម នៅតាមបណ្តាភូមិ ឃុំ ពួកគាត់ពុំសូវយកចិត្តទុកដាក់ចូលរួម | សហការជាមួយអង្គការដៃគូ និងមន្ទីរកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទខេត្ត ចុះផ្តល់បច្ចេកទេសឱ្យបានញឹកញាប់ និងជំរុញឱ្យអាជ្ញាធរភូមិ ឃុំ កៀរគរកសិករចូលរួមក្នុងវគ្គអប់រំផ្សព្វផ្សាយ |
| 6 | ការសាងសង់លំនៅឋាន និងសំណង់ផ្សេងៗ នៅតែបន្តសាងសង់មុនមានច្បាប់អនុញ្ញាត | សហការជាមួយភូមិ ឃុំ ចុះទប់ស្កាត់ការសាងសង់សំណង់មុនច្បាប់អនុញ្ញាត |
| 7 | សិស្សមកចុះឈ្មោះមិនទាន់ពេលវេលានៅ ដើមឆ្នាំសិក្សា | នាយក នាយិកា លោកគ្រូ អ្នកគ្រូ ប្រជុំផ្សព្វផ្សាយពីការប្រមូលកុមារឱ្យចូលរៀនជាមួយគណៈកម្មការគ្រប់គ្រងសាលា មេភូមិ មាតា បិតា និងអាណាព្យាបាលសិស្ស |
| 8 | សិស្សបោះបង់ការសិក្សា | ប្រជុំផ្សព្វផ្សាយពីការប្រមូលកុមារឱ្យចូលរៀនជាមួយនាយក នាយិកា នៅតាមសាលានីមួយៗ |
| 9 | ខ្វះគ្រូបង្រៀន | ស្នើសុំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជួយដោះស្រាយ |

## ២.៤. បញ្ហាប្រឈមដែលរដ្ឋបាលឃុំ សង្កាត់បានជួបប្រទះ

- **ឃុំក្នុងស្រុកបូទុមសាគរ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | បញ្ហាភ្លើងឆេះព្រៃ កើតឡើងនៅរដូវប្រាំង | ស្នើសុំស្នងការនគរបាលខេត្ត ផ្តល់ឡានទឹក 01 គ្រឿង សម្រាប់ប្រចាំការនៅប៉ុស្តិ៍រដ្ឋបាល និងផ្សព្វផ្សាយជូនប្រជាពលរដ្ឋចូលរួមការពារភ្លើងឆេះព្រៃ |
| 2 | ប្រជាពលរដ្ឋពុំទាន់យល់ដឹងអំពីច្បាប់ចរាចរណ៍ | ផ្សព្វផ្សាយ អំពីច្បាប់ចរាចរណ៍ជូនប្រជាពលរដ្ឋតាមរយៈបើកវេទិកាសាធារណៈ ស្តីពីភូមិ ឃុំ សង្កាត់មានសុវត្ថិភាព |
| 3 | ខ្វះបណ្តាញអគ្គិសនី និងទឹកស្អាតប្រើប្រាស់ | ស្នើសុំមន្ទីររ៉ែ និងថាមពល និងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ពិនិត្យលទ្ធភាពដោះស្រាយ |

| | | |
|---|---|---|
| 4 | ខ្វះទីលានចាក់សំរាម | ស្នើសុំមន្ទីរបរិស្ថានខេត្ត ផ្តល់ទីតាំងដីសម្រាប់ធ្វើទីលានចាក់សំរាម |
| 5 | ផ្លូវ និងស្ពានមួយចំនួនមានការបាក់ស្រុត និងខូចខាតច្រើន | ស្នើសុំមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ជួយជួសជុលសាងសង់ |
| 6 | បញ្ហាបទល្មើសនេសាទបន្តកើតមានឡើងច្រើន | សហការជាមួយកម្លាំងជំនាញពាក់ព័ន្ធ ដើម្បីចុះបង្ក្រាបទប់ស្កាត់ការនេសាទខុសច្បាប់ |
| 7 | មានការកាប់រានរំលោភយកដីរដ្ឋធ្វើជាកម្មសិទ្ធិ | មន្ត្រីឧទ្យានុរក្សបន្តចុះល្បាតតាមដាន ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ជាប្រចាំ |
| 8 | ពុំមានរថយន្តសម្រាប់ដឹកជញ្ជូនអ្នកជំងឺ | ស្នើសុំមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត ផ្តល់រថយន្តពេទ្យ 01គ្រឿង |
| 9 | ខ្វះអគារសម្រាប់បុគ្គលិកពេទ្យស្នាក់នៅ ហើយមណ្ឌលសុខភាពខ្វះធ្មបជំនាញ | ស្នើសុំមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត ជួយដោះស្រាយ |
| 10 | ប្រជាពលរដ្ឋក្នុងភូមិអភិវឌ្ឍន៍ថ្មីមករស់នៅតាំងពីឆ្នាំ2016 ពុំទាន់មានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ | ស្នើសុំមន្ទីររៀបចំដែនដី នគរូនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជួយដោះស្រាយ |

- **ឃុំក្នុងស្រុកគិរីសាគរ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | អគារសាលាបឋមសិក្សាព្រែកស្មាច់ 01ខ្នង 05បន្ទប់ និងព្រះវិហារនៅវត្តពយដប៉ុនក្រុមហ៊ុនយូញៀនមិនទាន់ធ្វើសង (ឃុំកោះស្ដេច) | ស្នើរដ្ឋបាលខេត្ត ជួយជំរុញក្រុមហ៊ុនយូញៀនជួយសាងសង់ជាសំណង |
| 2 | ផ្លូវលំក្នុងភូមិព្រែកស្មាច់ និងភូមិពាមកាយ មានការខូចខាត (ឃុំកោះស្ដេច) | ស្នើរដ្ឋបាលខេត្ត ជួយជំរុញក្រុមហ៊ុនយូញៀនជួយសាងសង់ជាសំណង |

- **សង្កាត់ក្នុងក្រុងខេមរភូមិន្ទ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | ថវិកាសម្រាប់ធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់មានចំនួនតិចតួចនៅឡើយ | ស្នើសុំបន្ថែមថវិកាសម្រាប់ធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ |
| 2 | ថវិកាការងារសង្គមប្រកបដោយសមធម៌មានចំនួនតិច | ស្នើសុំបន្ថែមថវិកាការងារសង្គមប្រកបដោយសមធម៌ |
| 3 | មានអំពើហិង្សាក្នុងគ្រួសារ | ផ្សព្វផ្សាយអំពីច្បាប់អំពើហិង្សាក្នុងគ្រួសារ ដល់ប្រជាពលរដ្ឋ |
| 4 | ប្រជាពលរដ្ឋមួយចំនួនធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើ | បង្កើនការងារនៅក្នុងស្រុក |
| 5 | ប្រជាពលរដ្ឋមិនទាន់យល់ច្បាស់ពីសារៈសំខាន់ នៃការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងជំរុញឱ្យប្រជាពលរដ្ឋ មកចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ |
| 6 | សេវាសង្គមផ្សេងៗនៅមានកម្រិត | ស្នើឱ្យមានការគាំទ្រពីដៃគូ |

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 7 | បញ្ហាទំនាស់ដីធ្លី | បើកវគ្គបណ្តុះបណ្តាល និងចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ |

- **ឃុំក្នុងស្រុកមណ្ឌលសីមា**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | ទឹកសមុទ្រជោរខ្លាំង និងមានរលកបោក ធ្វើឱ្យខូចទំនប់ការពារទឹកប្រៃ ជិតដល់ផ្លូវកៅស៊ូ មុខវត្តប៉ាក់ខ្លង | ស្នើរដ្ឋបាលស្រុកជួយជួសជុលទំនប់ការពារទឹកប្រៃឡើងវិញ |
| 2 | ផ្លូវនៅភូមិ1 មុខផ្ទះលោក តូង ហាក់ ដល់ផ្លូវកៅស៊ូខាងក្រោយវិទ្យាល័យប៉ាក់ខ្លង ខូចខាតពិបាកធ្វើដំណើរ | ស្នើរដ្ឋបាលស្រុកជួយធ្វើផ្លូវនៅភូមិ1 |
| 3 | ទឹកភ្លៀងដក់តាមផ្លូវជាតិលេខ48 ចំណុចខាងលិចវត្តនាងកុក | ស្នើរដ្ឋបាលស្រុកជួយធ្វើលូរំដោះទឹក |
| 4 | ទឹកភ្លៀងដក់តាមផ្លូវកៅស៊ូនៅភូមិ2 ចំណុចមុខមណ្ឌលសុខភាពដល់មុខវិទ្យាល័យប៉ាក់ខ្លង | ស្នើរដ្ឋបាលស្រុកជួយធ្វើលូរំដោះទឹកនៅតាមផ្លូវភូមិ2 |
| 5 | ឃុំពាមក្រសោប ខ្វះផ្លូវបេតុងអាមេ 1ខ្សែ នៅភូមិ2 (ចាប់ពីកែងមុខផ្ទះ ស្រី សារ៉ុតដល់ផ្សារ) | ស្នើរដ្ឋបាលស្រុក ជួយសាងសង់ផ្លូវបេតុអាមេ1ខ្សែ ប្រវែង 295ម៉ែត្រ ទទឹង 08ម៉ែត្រ |
| 6 | ឃុំពាមក្រសោប ខ្វះផ្លូវបេតុងអាមេ 1ខ្សែ នៅភូមិ2 ( ចាប់ពីមុខផ្ទះលោក ទិត រិទ្ធ ដល់ផ្ទះ ស្រី សារ៉ុត) | រដ្ឋបាលឃុំ លើកផែនការប្រើប្រាស់មូលនិធិឃុំឆ្នាំ2021 សាងសង់ផ្លូវបេតុងអាមេ 01ខ្សែ ប្រវែង 338ម៉ែត្រ ទទឹង 05ម៉ែត្រ |
| 7 | ឃុំពាមក្រសោប ទំនប់ការពារទឹកប្រៃទាប ពេលទឹកប្រៃកើនឡើង ហូរចូលលំនៅដ្ឋានខូច ដំណាំកសិកម្ម និងការចិញ្ចឹមសត្វរបស់ប្រជាពលរដ្ឋ នៅភូមិ1 ភូមិ2 | ស្នើរដ្ឋបាលស្រុក និងសប្បុរសជន ជួយជួសជុលលើកទំនប់ការពារទឹកប្រៃឱ្យខ្ពស់ឡើងវិញ ប្រវែង 790ម៉ែត្រ |
| 8 | ឃុំពាមក្រសោប គ្រឹះជើងផ្លូវបេតុងមានជើងនៅភូមិ1 ទឹកហូរច្រោះខូច | រដ្ឋបាលឃុំ លើកផែនការសាងសង់ផ្លូវបេតុងមានជើង ប្រវែង 78ម៉ែត្រ |
| 9 | ឃុំពាមក្រសោប ផ្លូវបេតុងមានជើងចាស់ទ្រុឌទ្រោមនៅភូមិ2 កន្លែងទេសចរណ៍ | រដ្ឋបាលឃុំ លើកផែនការជួសជុលផ្លូវបេតុងមានជើង 01ខ្សែ ប្រវែង 669ម៉ែត្រ ទទឹង 1.2ម៉ែត្រ និងកៀរគររកប្រភពថវិកាពីសប្បុរសជន គាំទ្រអនុវត្ត |
| 10 | ឃុំពាមក្រសោប ខ្វះស្ពានឈើដើរឆ្លងពីផ្ទះមួយទៅផ្ទះមួយនៅភូមិ2 | រដ្ឋបាលឃុំ លើកផែនការសាងសង់ស្ពានឈើមានជើង ប្រវែង 450ម៉ែត្រ ទទឹង 01ម៉ែត្រ និងកៀរគររកប្រភពថវិកា ពីសប្បុរសជន គាំទ្រអនុវត្ត |
| 11 | ឃុំពាមក្រសោប ខ្វះផ្លូវបេតុងមានជើងដើរឆ្លងព្រែក នៅភូមិចាស់ពាមក្រសោប | រដ្ឋបាលឃុំ លើកផែនការជួសជុលបេតុងមានជើងឆ្លងព្រែក ប្រវែង 12ម៉ែត្រ ទទឹង 02ម៉ែត្រ និងកៀរគររកប្រភពថវិកាពីសប្បុរសជនគាំទ្រអនុវត្ត |
| 12 | ឃុំពាមក្រសោប ស្ថានភាពភូមិសាស្ត្រ ដីសើម ដីទាប ទឹកប្រៃកើនឡើងលិច ហូរច្រោះ ខូចផ្លូវក្រួសក្រហម នៅភូមិ1 | ស្នើរដ្ឋបាលស្រុក ជួយសាងសង់ផ្លូវក្រួសក្រហម 3ខ្សែ ប្រវែង 1,300ម៉ែត្រ ទទឹង 05ម៉ែត្រ និងកៀរគររកប្រភពថវិកាពីសប្បុរសជន គាំទ្រអនុវត្ត |

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 13 | ឃុំពាមក្រសោប ទឹកប្រៃកើនឡើងលិចទីតាំងក្នុងបរិវេណបេនឡាន និងខ្វះដំបូលបេនឡាន នៅភូមិ2 រៀងរាល់ឆ្នាំ | រដ្ឋបាលឃុំ លើកផែនការទិញដីចាក់បំពេញទីធ្លាក្នុងបរិវេណបេនឡាន និងធ្វើរោងដំបូលបេនឡាន និងកៀរគររកប្រភពថវិកាពីសប្បុរសជន គាំទ្រអនុវត្ត |
| 14 | ឃុំពាមក្រសោប ទឹកប្រៃកើនឡើងលិចទីតាំងក្នុងបរិវេណផ្សារ នៅភូមិ2 រៀងរាល់ឆ្នាំ | រដ្ឋបាលឃុំ លើកផែនការទិញដីចាក់បំពេញទីធ្លាក្នុងបរិវេណផ្សារ និងកៀរគររកប្រភពថវិកាពីសប្បុរសជន គាំទ្រអនុវត្ត |
| 15 | ឃុំពាមក្រសោប ខ្វះផែចតទូក 1កន្លែង នៅភូមិ2 នៅមុខទីស្នាក់ការដែនជម្រកសត្វព្រៃពាមក្រសោប | រដ្ឋបាលឃុំ លើកផែនការសាងសង់ផែចុះទូក 01 កន្លែង និងកៀរគររកប្រភពថវិកាពីសប្បុរសជន គាំទ្រអនុវត្ត |
| 16 | ឃុំពាមក្រសោប បទល្មើសលើដែនសហគមន៍ទាំងពីរនៅតែកើតមាន | រដ្ឋបាលឃុំ លើកផែនការផ្តល់មធ្យោបាយគាំទ្រពង្រឹងក្រុមល្បាតចុះល្បាតការពារដែនសហគមន៍ទាំងពីរសហការ ជាមួយមន្ទីរជំនាញ គាំទ្រ ចុះល្បាត4ដង/1ខែ |
| 17 | ឃុំពាមក្រសោប សាលាឧបសម្ព័ន្ធនៅភូមិ2(កោះកាង) ចាស់ទ្រុឌទ្រោម | រដ្ឋបាលឃុំលើកផែនការសាងសង់សាលាឧបសម្ព័ន្ធ សម្រាប់កុមាររៀន 01ខ្នង មាន 02 បន្ទប់ និងកៀរគររកប្រភពថវិកាពីសប្បុរសជន គាំទ្រអនុវត្ត |
| 18 | ឃុំពាមក្រសោប ប្រជាពលរដ្ឋចំនួន 150គ្រួសារ នៅតាមដងផ្លូវបេតុងមានជើង នៅភូមិ1 ខ្វះបណ្តាញអគ្គិសនីប្រើប្រាស់ | ស្នើរដ្ឋបាលស្រុក ជួយអន្តរាគមន៍ស្នើសុំក្រុមហ៊ុនអគ្គិសនី ដើរបង្គោលចំនួន 60បង្គោល ជូនប្រជាពលរដ្ឋ ចំនួន 150គ្រួសារ នៅភូមិ1 |

- **ឃុំក្នុងស្រុកកោះកុង**

| | | |
|---|---|---|
| 1 | ពុំទាន់មានផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ48 ទៅភូមិកោះអណ្តែត | ស្នើសុំមន្ទីរអភិវឌ្ឍន៍ជនបទជួយអន្តរាគមន៍ |
| 2 | ប្រជាពលរដ្ឋមួយចំនួន របស់ឃុំតាតៃក្រោម ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង | ស្នើសុំកាត់ដីទាំងនោះមកឱ្យឃុំតាតៃក្រោមគ្រប់គ្រងវិញ |
| 3 | កន្លែងចាក់សំរាមមានទីតាំងហើយ ប៉ុន្តែមិនទាន់រៀបចំរួចមិនអាចចាក់សំរាមបាន | ស្នើសុំមន្ទីរបរិស្ថានជួយអន្តរាគមន៍ |
| 4 | ប្រជាពលរដ្ឋខ្វះទឹកស្អាតប្រើប្រាស់ | ស្នើសុំមន្ទីរជំនាញសិក្សាជីកស្រះស្តុកទឹក |

- **ឃុំក្នុងស្រុកស្រែអំបិល**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | ប្រជាពលរដ្ឋខ្វះសំបុត្របញ្ជាក់កំណើតធ្វើអត្តសញ្ញាណប័ណ្ណ | បន្តការផ្តល់សំបុត្របញ្ជាក់កំណើតដល់អ្នកមិនទាន់មាន |
| 2 | ផ្លូវក្នុងឃុំខូចចាប់ពីគល់ស្ពានកំពង់ស្តាំដល់ឆ្នេរនេសាទ ខូចខាតខ្លាំង ពិបាកធ្វើដំណើរទៅមន្ទីរពេទ្យ និងទៅតំបន់ផ្សេងៗ ពេលខែប្រាំងហុយដីខ្លាំងប៉ះពាល់សុខភាព ប្រជា-ពលរដ្ឋជួសជុលបានស្អាត តែមួយរយៈពេលខ្លី | ស្នើសុំផ្លូវកៅស៊ូ 01ខ្សែ |

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 3 | ប្រជាពលរដ្ឋនៅតែបោះចោលសំរាមពាសវាលពាសកាល ដោយគ្មានសណ្តាប់ធ្នាប់ | ចុះណែនាំឬចុះផ្សព្វផ្សាយដល់ពួកគាត់ឱ្យចេះទុកដាក់សំរាមតាមការណែនាំ និងនៅកន្លែងមានសុវត្ថិភាព |
| 4 | ការទន្ទ្រានបោះបង្គោលហ៊ុមព័ទ្ធយកដីរដ្ឋនៅតែមានមួយចំនួនតូច | ជំរុញសមត្ថកិច្ចពាក់ព័ន្ធជួយធ្វើការទប់ស្កាត់ |

- **ឃុំក្នុងស្រុកថ្មបាំង**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| 1 | ផ្លែទុរេនខូចច្រើន នៅឃុំឫស្សីជ្រុំ | ស្នើរដ្ឋបាលស្រុក និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេក-ទេសដំណាំទុរេន |
| 2 | ពុំមានអគ្គិសនីប្រើប្រាស់ ក្នុងភូមិទឹកល្អក់ ឃុំជីផាត ឃុំតាទៃលើ និងឃុំជំនាប់ | ស្នើសុំរដ្ឋបាលស្រុក និងមន្ទីររ៉ែ និងថាមពលជួយដោះស្រាយ |
| 3 | នៅសាលាឃុំពុំមានសេវាទូរស័ព្ទប្រើប្រាស់ (ឃុំជំនាប់) | ស្នើសុំ រដ្ឋបាលខេត្ត ជួយដោះស្រាយ |
| 4 | ពុំមានស្ពានឆ្លងស្ទឹងអារ៉ែង នៅឃុំថ្មដូនពៅ | ស្នើសុំ រដ្ឋបាលខេត្ត ជួយដោះស្រាយ |
| 5 | ប្រជាពលរដ្ឋមិនបានទទួលប័ណ្ណកម្មសិទ្ធិ (ឃុំតាទៃលើ) | ស្នើសុំ រដ្ឋបាលខេត្ត ជួយដោះស្រាយ |
| 6 | ប្រជាពលរដ្ឋ 25% ខ្វះដីកសិកម្ម (ឃុំតាទៃលើ) | ស្នើសុំ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ជួយដោះស្រាយ |
| 7 | ប្រជាពលរដ្ឋអ៊ីរទាំដីហុយចូលផ្ទះ នៅឃុំឫស្សីជ្រុំ | ស្នើសុំ រដ្ឋបាលស្រុក ជួយដោះស្រាយ |
| 8 | ទិន្នផលកសិកម្មធ្លាក់ចុះនៅរដូវប្រាំងដោយគ្មានទឹកស្រោចស្រពនៅឃុំឫស្សីជ្រុំ | ស្នើសុំ រដ្ឋបាលស្រុក ជួយដោះស្រាយ |

# ផ្នែកទី៣

# ការងាររបស់មន្ទីរ អង្គភាពជំនាញ

## ៣.១. សេដ្ឋកិច្ច

### ៣.១.១. ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

#### ក. ការងារកសិកម្ម

- ការងារភ្ជួររាស់អនុវត្តបានសរុបចំនួន 9,168ហ.ត ក្នុងនោះមាន៖
  - ភ្ជួររាស់ដោយគ្រឿងចក្រ ចំនួន 8,661ហ.ត
  - ភ្ជួររាស់ដោយគោក្របីចំនួន 507ហ.ត
- សំណាបអនុវត្តបានសរុបចំនួន 230ហ.ត
- ការងារដាំដុះស្រូវ អនុវត្តបានសរុបចំនួន 9,827ហ.ត ក្នុងនោះមាន៖
  - ស្រូវស្រាល ចំនួន 2,936 ហ.ត (ព្រោះចំនួន 2,428ហ.ត)
  - ស្រូវកណ្តាលចំនួន 5,605 ហ.ត (ព្រោះចំនួន 4,090ហ.ត)
  - ស្រូវធ្ងន់ ចំនួន 627 ហ.ត (ព្រោះចំនួន 354ហ.ត)
  - ស្រូវចម្ការ ចំនួន 659 ហ.ត (បុកដាំ)

- ការងារច្រូតកាត់ស្រូវអនុវត្តបានសរុបចំនួន 9,827ហ.ត ទិន្នផលជាមធ្យម 2,777តោន/ហិកតា និងបរិមាណផលសរុបចំនួន 27,291,997តោន ក្នុងនោះមាន៖
    - ស្រូវស្រាល ចំនួន 2,936ហ.ត (បរិមាណផលសរុប 8,197,364តោន ទិន្នផលជាមធ្យម 2,792តោន/ហិកតា)
    - ស្រូវកណ្តាល ចំនួន 5,605ហ.ត (បរិមាណផលសរុប 15,600,275តោន ទិន្នផលជាមធ្យម 2,783 តោន/ហិកតា)
    - ស្រូវធ្ងន់ ចំនួន 627ហ.ត (បរិមាណផលសរុប 1,714,312តោន ទិន្នផលជាមធ្យម 2,734តោន/ហិកតា)
    - ស្រូវចម្ការ ចំនួន 659ហ.ត (បរិមាណផលសរុប 1,780,046តោន ទិន្នផលជាមធ្យម 2,701តោន/ហិកតា)
- ការងារដំណាំសាកបន្លែអនុវត្តបានសរុបចំនួន 283ហ.ត ក្នុងនោះ៖
    - ដំណាំបន្លែរដូវប្រាំងជាលក្ខណៈគ្រួសារ ចំនួន 106 ហ.ត
    - ដំណាំបន្លែរដូវវស្សាជាលក្ខណៈគ្រួសារ ចំនួន 177 ហ.ត
- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន 190ហ.ត ក្នុងនោះ៖
    - រដូវប្រាំងជាលក្ខណៈគ្រួសារ ចំនួន 13 ហ.ត
    - រដូវវស្សាជាលក្ខណៈគ្រួសារ ចំនួន 16 ហ.ត
    - រយៈពេលវែង ជាលក្ខណៈគ្រួសារ ចំនួន 161 ហ.ត
- ដំណាំសាកវប្បកម្មឈើហូបផ្លែអនុវត្តបានសរុបចំនួន 470ហ.ត ក្នុងនោះ៖
    - រដូវប្រាំងជាលក្ខណៈគ្រួសារ ចំនួន 75 ហ.ត
    - រដូវវស្សាជាលក្ខណៈគ្រួសារ ចំនួន 17 ហ.ត
    - រយៈពេលវែង ជាលក្ខណៈគ្រួសារ ចំនួន 378 ហ.ត
- ស្ថានភាពប៉ះពាល់ដោយសត្វល្អិតនៅក្នុងឆ្នាំ2021 នេះ មានសត្វខ្យងមាសបំផ្លាញដំណាំស្រូវ (ស៊ីបំផ្លាញកូនសំណាប និងស្រូវព្រោះខ្ចីៗ) របស់បងប្អូនប្រជាកសិករលើផ្ទៃដីចំនួន 10ហិកតា នៅភូមិបានទៀត ឃុំដងពែង ភូមិចំការក្រោម ឃុំស្រែអំបិល ស្រុកស្រែអំបិល ដោយមានកិច្ចសហការជាមួយការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានស្រុក បានចុះអន្តរាគមន៍លើផលប៉ះពាល់ និងស្តារបានទាំងស្រុងឡើងវិញ
- បរិមាណផ្លែដូង និងផលដំណាំនាំចេញ និងប្រើប្រាស់ក្នុងខេត្តសរុបបានចំនួន 9,277តោន និង 56,000ផ្លែ ក្នុងនោះ៖
    - ចេក 4,205តោន, ទុរេន 416តោន, អំពៅ 303តោន, សាវម៉ាវ 343តោន, បន្លែគ្រប់មុខចំនួន 955តោន ផ្លែបំពេញរាជ្យ 65តោន, ល្ហុង 2,277តោន, គ្រាប់ស្វាយចន្ទី 480តោន, ទៀបបារាំង 15តោន, រមៀត 01តោន, រំដេង 97តោន, គ្រាវ 02តោន, ស្លាខ្ចី 118តោន, ផ្លែដូង 56,000ផ្លែ
- ចលនាដឹកនាំសត្វ និង ផលិតផលមានដើមកំណើតពីសត្វ៖
    - ជ្រូកសាច់ ចំនួន 3,024 ក្បាល (នាំចូល)
    - កូនជ្រូក ចំនួន 2,500 ក្បាល (នាំចូល)
    - មាន់រស់ ចំនួន 11,752 ក្បាល (នាំចូល)
    - សាច់គ្រួច ចំនួន 175 ក្បាល (នាំចូល)
    - ប្រហិត ចំនួន 1,194 គ.ក្រ (នាំចូល)
    - ជ្រូករស់ ចំនួន 9,975 ក្បាល (នាំចេញ)
    - គោ ក្របី ចំនួន 25 ក្បាល (នាំចេញ)

- ការការពារសត្វសរុបចំនួន 74,301ក្បាល ក្នុងនោះ៖
    - គោ ចំនួន 4,375 ក្បាល (សាទឹក អុតក្តាមៈ គ្រប់បណ្តាក្រុង/ស្រុក)
    - ក្របី ចំនួន 3,888 ក្បាល (សាទឹក អុតក្តាមៈ គ្រប់បណ្តាក្រុង/ស្រុក)
    - ជ្រូក ចំនួន 48,244 ក្បាល (ជំងឺ 06មុខ៖ ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
    - ឆ្កែ/ឆ្មា ចំនួន 233 ក្បាល (ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
    - សត្វស្លាប ចំនួន 17,561 ក្បាល (ជំងឺ 03មុខ ៖ ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
- ការព្យាបាលសរុបចំនួន 1,156ក្បាល ក្នុងនោះ៖
    - គោ ចំនួន 358 ក្បាល (ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកស្រែអំបិល និងស្រុកថ្មបាំង)
    - ក្របី ចំនួន 229 ក្បាល (ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកស្រែអំបិល និងស្រុកថ្មបាំង)
    - ជ្រូក ចំនួន 374 ក្បាល (ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
    - ឆ្កែ ចំនួន 195 ក្បាល (ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
- សត្វងាប់ដោយជំងឺសរុបចំនួន 2,891ក្បាល ក្នុងនោះ៖
    - គោ ចំនួន 21 ក្បាល (ក្រុងខេមរភូមិន្ទ និងស្រុកស្រែអំបិល)
    - ក្របី ចំនួន 46 ក្បាល (ក្រុងខេមរភូមិន្ទ និងស្រុកស្រែអំបិល)
    - ជ្រូក ចំនួន 67 ក្បាល (ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
    - ឆ្កែ ចំនួន 93 ក្បាល (ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
    - សត្វស្លាប ចំនួន 2,664 ក្បាល (ស្រុកបូទុមសាគរ ស្រុកកោះកុង ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
- ស្ថិតិពិឃាដសត្វសរុបចំនួន 37,984ក្បាល ក្នុងនោះ៖
    - គោ ចំនួន 624 ក្បាល (ស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
    - ក្របី ចំនួន 401 ក្បាល (ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
    - ជ្រូក ចំនួន 8,791 ក្បាល (ស្រុកបូទុមសាគរ ស្រុកគិរីសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)
    - មាន់ ចំនួន 28,168 ក្បាល (ស្រុកបូទុមសាគរ ស្រុកគិរីសាគរ ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល)

– តារាងវឌ្ឍនភាពក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចៈ

| ល.រ | ឈ្មោះក្រុមហ៊ុន | ទីតាំង | ប្រភេទដំណាំ | ផ្ទៃដីសម្បទាន (ហ.ត) | អនុវត្តបាន (ហ.ត) | | |
|---|---|---|---|---|---|---|---|
| | | | | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| 1 | CAMAGRA INVESTMENT GROUP CO,.Ltd | ស្រុកកំពង់សិលា ខេត្តព្រះសីហនុ | ប្រេងខ្យល់ | 1,429 | 1,334 | ថែទាំ | 1,358 |
| | | ឃុំដងពែង ស្រុកស្រែអំបិល | អាកាស្យា | 4,096 | 1,380 | ថែទាំ | 1,409 |
| 2 | Koh Kong Plantation Co., Ltd | ឃុំដងពែង ស្រុកស្រែអំបិល | អំពៅ | 9,400 | 6,361 (ផ្អាកការដាំដុះ) | - | គ្មាន |
| 3 | Koh Kong Sugar Industry Co., Ltd | ឃុំដងពែង ស្រុកស្រែអំបិល | អំពៅ | 9,700 | 6,404 (ផ្អាកការដាំដុះ) | - | គ្មាន |
| 4 | Greenrich Group Co., Ltd | ឃុំត្រពាំងរូង ស្រុកកោះកុង | អាកាស្យា | 5,154 (កាត់ចេញរួច) | 5,877 (ផ្ទៃដីមុនកាត់ចេញ) | ថែទាំ | 5,877 (ផ្អាកដាំ និង ប្រមូលផលឆ្នាំ 2018) |
| 5 | Lim Long Co., Ltd | ឃុំជីខក្រោម ស្រុកស្រែអំបិល | កៅស៊ូ | 321 | 280 | ថែទាំ | 280 |
| 6 | CN Asia Agriculture Co., Ltd | ឃុំតានួន ស្រុកបូទុមសាគរ | កៅស៊ូ | 4,100 | 2,573 | ថែទាំ | 2,573 |
| 7 | Koh Kong Rubber Plantation Co., Ltd | ឃុំភ្ញីមាស ស្រុកគិរីសាគរ | កៅស៊ូ | 9,977 | 1,826 | ថែទាំ | 1,826 |

ផ្ទៃដីក្រុមហ៊ុន Greerich Group Co.,Ltd កាលពីមុនមានទំហំ 10,077ហិកតា ប៉ុន្តែក្រោយចេញអនុក្រឹត្យលេខ 46អនក្រ បក ចុះថ្ងៃទី2 ខែមីនា ឆ្នាំ2021 របស់រាជរដ្ឋាភិបាល បានកាត់ដីរបស់ក្រុមហ៊ុនចំនួន 4,923ហិកតា ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុក ជាទ្រព្យសម្បត្តិឯកជនកាន់កាប់ដោយរដ្ឋបាលខេត្តកោះកុង។ ដូចនេះផ្ទៃដីក្រុមហ៊ុននៅសល់ជាក់ស្តែងមានទំហំ 5,154ហិកតា

– ការងារកៅស៊ូ

ខេត្តកោះកុង ជាខេត្តមួយក្នុងចំណោម 25រាជធានី-ខេត្ត ដែលមានសក្តានុពលដល់ការដាំដុះដំណាំកៅស៊ូ និងដំណាំផ្សេងៗទៀត។ ក្នុងឆ្នាំ2021 នេះ មិនមានការដាំដុះដំណាំកៅស៊ូបន្តទេ ហើយចម្ការកៅស៊ូមួយចំនួនក៏ពុំសូវមានការយកចិត្តទុកដាក់ថែទាំសម្អាត ដែលនាំឱ្យបាត់បង់គុណភាព ជំងឺច្រើន ពិសេសខ្វះខាតកម្លាំងពលកម្មក្នុងការប្រមូលផល។ បច្ចុប្បន្នផ្ទៃដីដាំដុះកៅស៊ូទូទាំងខេត្តសរុបចំនួន 6,108ហិកតា ក្នុងនោះៈ ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចំនួន 4,679ហិកតា និងកៅស៊ូគ្រួសារ ចំនួន 1,429ហិកតា

– ការងារសហគមន៍កសិកម្ម សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ

ទូទាំងខេត្ត មានសហគមន៍កសិកម្ម សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ សរុបចំនួន 18សហគមន៍ គឺៈ

- សហគមន៍កសិកម្ម ចំនួន 03 សហគមន៍
- សហគមន៍នេសាទ ចំនួន 10 សហគមន៍
- សហគមន៍ព្រៃឈើ ចំនួន 05 សហគមន៍

– ការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម
  - ចុះអង្កេតកសិកម្ម ឆ្នាំ2020 ទៅលើគ្រួសារកសិករចំនួន 108គ្រួសារ នៅស្រុកថ្មបាំង ស្រុកមណ្ឌលសីមា ក្រុងខេមរភូមិន្ទ ស្រុកកោះកុង និងស្រុកស្រែអំបិល
  - ចុះតាមដានការអនុវត្តបច្ចេកទេសស្រូវពព្រោះ និងការលូតលាស់ដំណាំស្រូវ ចំនួន 05លើក លើគ្រួសារកសិករចំនួន 35គ្រួសារ នៅស្រុកបូទុមសាគរ ស្រុកថ្មបាំង និងស្រុកស្រែអំបិល
  - ចុះតាមដាន និងជំរុញការអនុវត្តបច្ចេកទេសស្រូវ និងចែកឯកសារសៀវភៅបច្ចេកទេសកសិកម្មមួយចំនួនដល់កសិករ ចំនួន 03លើក លើគ្រួសារកសិករចំនួន 37គ្រួសារ នៅស្រុកថ្មបាំង និងស្រុកស្រែអំបិល
  - ចុះយកសំណាកស្រូវ ដើម្បីស្ទង់ទិន្នផលស្រូវ ចំនួន 04លើក លើគ្រួសារកសិករចំនួន 16គ្រួសារ នៅស្រុកថ្មបាំង ស្រុកគិរីសាគរ និងស្រុកស្រែអំបិល
  - ចុះតាមដាន និងជំរុញការដាំដុះដំណាំបន្លែដល់កសិករ ចំនួន 03លើក លើគ្រួសារកសិករចំនួន 31គ្រួសារ នៅស្រុកថ្មបាំង និងស្រុកស្រែអំបិល
  - ចុះពិនិត្យទីតាំងដី ចែកជាតុចូលកសិកម្ម និងដំឡើងប្រព័ន្ធស្រោចស្រព សម្រាប់ត្រៀមទុកដំណើរការដាំបន្លែជូនកសិករ (ស្ត្រីក្រីក្រ) ចំនួន 03លើក លើគ្រួសារកសិករចំនួន 11គ្រួសារ នៅឃុំភ្ញីមាស ស្រុកគិរីសាគរ
  - ចុះអន្តរាគមន៍ព្យាបាលសត្វគោឈឺជំងឺដុំពកស្បែក (LSD) ចំនួន 02លើក លើសត្វគោឈឺចំនួន 21ក្បាល ព្រមទាំងបានចែកជូនថ្នាំព្យាបាល ថ្នាំសំលាប់មេរោគ និងវិធានការពារជំងឺ ដល់កសិករចិញ្ចឹមសត្វ នៅឃុំទួលគគីរ ស្រុកមណ្ឌលសីមា និងឃុំជីខលើ ស្រុកស្រែអំបិល
  - ចុះអធិការកិច្ចលើដេប៉ូលក់ដុំ-លក់រាយថ្នាំកសិកម្ម និងជីកសិកម្ម បានចំនួន 07លើក ស្មើនឹង 12ទីតាំង នៅស្រុកបូទុមសាគរ ក្រុងខេមរភូមិន្ទ ស្រុកស្រែអំបិល និងស្រុកថ្មបាំង
  - ចុះផ្ទៀងផ្ទាត់ទិន្នន័យស្ថិតិដំណាំកៅស៊ូគ្រួសារ ជាមួយអាជ្ញាធរមូលដ្ឋាន ចំនួន 06លើក នៅស្រុកស្រែអំបិល ស្រុកថ្មបាំង និងស្រុកបូទុមសាគរ មានអ្នកចូលរួមសរុប 33នាក់ ស្រី 06នាក់
  - ចុះធ្វើបច្ចុប្បន្នភាពលើបញ្ជីសំណួរអង្កេតដំណើរការអនុវត្ត ក្រោយធ្វើមហាសន្និបាត ព្រមទាំងប្រមូលទិន្នន័យ របស់សហគមន៍កសិកម្មសាមគ្គីធម៌ ស្ថិតនៅឃុំបឹងព្រាវ ស្រុកស្រែអំបិល និងសហគមន៍កសិកម្មម្រេចអារ៉ែង ស្ថិតនៅឃុំថ្មដូនពៅ ស្រុកថ្មបាំង មានអ្នកចូលរួមសរុបចំនួន 20នាក់ ស្រី 05នាក់
  - ចុះសម្របសម្រួល ដោះស្រាយទំនាស់រវាងអ្នកនេសាទសិប្បកម្ម និងអ្នកនេសាទលក្ខណៈគ្រួសារ នៅភូមិតាមាឃ ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ដែលមានអ្នកចូលរួមចំនួន 24នាក់ ស្រី 04នាក់
  - ចុះពិនិត្យទីតាំងវារីវប្បកម្ម ចំនួន 01កន្លែង នៅភូមិស្រែគ្រាវ ឃុំថ្មស ស្រុកបូទុមសាគរ មានស្រះចិញ្ចឹមត្រីទីឡាព្យា ចំនួន 01ស្រះ ដាក់ត្រីចំនួន 1,000ក្បាល និងត្រីអណ្តែតចំនួន 01ស្រះ ដាក់ត្រីចំនួន 1,000 ក្បាល
  - ចុះអង្កេតទូកនេសាទដោយប្រើប្រាស់កម្មវិធី SMART TOOL នៅតាមផែនេសាទ ចំនួន 04លើក លើទូកនេសាទចំនួន 260ទូក នៅឃុំថ្មស ស្រុកបូទុមសាគរ និងឃុំកោះស្តេច ស្រុកគិរីសាគរ
  - ចុះផ្សព្វផ្សាយ និងណែនាំបច្ចេកទេសកសិកម្មចំនួន 17លើក មានអ្នកចូលរួមចំនួន 297នាក់ ស្រី 120នាក់ ក្នុងនោះ រួមមាន៖

+ច្បាប់ស្តីពីការគ្រប់គ្រងជី-ថ្នាំកសិកម្មចំនួន 03លើក អ្នកចូលរួមចំនួន 58នាក់ ស្រី 31នាក់
+ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វចំនួន 01លើក អ្នកចូលរួមចំនួន 31នាក់ ស្រី 21នាក់
+ជំងឺជុំពកលើសត្វគោចំនួន 04លើក អ្នកចូលរួមចំនួន 102នាក់ ស្រី 43នាក់
+ការភ្ជួររាស់ដោយគ្រឿងយន្តកសិកម្មចំនួន 02លើក អ្នកចូលរួមចំនួន 10នាក់
+នីតិវិធីស្រង់ស្ថិតិគ្រឿងយន្តកសិកម្មចំនួន 06លើក អ្នកចូលរួមចំនួន 79នាក់ ស្រី 13នាក់
+ច្បាប់ស្តីពីជលផលចំនួន 01លើក អ្នកចូលរួមចំនួន 17នាក់ ស្រី 12នាក់

- បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មចំនួន 20វគ្គ មានអ្នកចូលរួមចំនួន 514នាក់ ស្រី 188នាក់ ក្នុងនោះរួមមាន៖
  +បច្ចេកទេសដំណាំចេក ចំនួន 01វគ្គ អ្នកចូលរួមចំនួន 25នាក់ ស្រី 10នាក់
  +បច្ចេកទេសដាំដុះដំណាំស្វាយចន្ទី ចំនួន 01វគ្គ អ្នកចូលរួមចំនួន 36នាក់ ស្រី 20នាក់
  +បច្ចេកទេសដាំបន្លែតាមប្រព័ន្ធដំណក់ទឹកចំនួន 02វគ្គ អ្នកចូលរួមចំនួន 20នាក់ ស្រី 10នាក់
  +បច្ចេកទេសកសិកម្មចម្រុះ ចំនួន 02វគ្គ អ្នកចូលរួមចំនួន 50នាក់ ស្រី 04នាក់
  +បច្ចេកទេសចិញ្ចឹមសត្វចំនួន 04វគ្គ អ្នកចូលរួមចំនួន 150នាក់ ស្រី 58នាក់
  +បច្ចេកទេសកែច្នៃចេកឆាប និងជ្រក់ផ្លែថាវចំនួន 01វគ្គ អ្នកចូលរួមចំនួន 25នាក់ ស្រី 14នាក់
  +ការផ្តល់អាហារូបត្ថម្ភដល់កុមារតូចៗ ចំនួន 03វគ្គ អ្នកចូលរួមចំនួន 50នាក់ ស្រី 20នាក់
  +ជួសជុល និងថែទាំគ្រឿងយន្តកសិកម្ម ចំនួន 01វគ្គ អ្នកចូលរួមចំនួន 25នាក់
  +បច្ចេកទេសដាំដុះ និងថែទាំកៅស៊ូចំនួន 02វគ្គ អ្នកចូលរួមចំនួន 50នាក់ ស្រី 17នាក់
  +ការធ្វើរបាយការណ៍ និងចុះបញ្ជីគណនេយ្យ(សហគមន៍)ចំនួន 01វគ្គ អ្នកចូលរួមចំនួន 23នាក់ ស្រី 09នាក់
  +ការធ្វើផែនការមុខរបរ(សហគមន៍)ចំនួន 01វគ្គ អ្នកចូលរួមចំនួន 25នាក់ ស្រី 14នាក់
  +ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសហគមន៍កសិកម្ម ចំនួន 01វគ្គ អ្នកចូលរួមចំនួន 25នាក់ ស្រី 12នាក់

– អនុវត្តកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (Agriculture Services Programme for Innovation Resilience Extension - ASPIRE) បាន៖
  - ចុះសម្របសម្រួលចងក្រងបង្កើតបណ្តុំអាជីវកម្ម រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងជ្រើសរើសគណៈកម្មការគ្រប់គ្រងបណ្តុំអាជីវកម្ម បានចំនួន 18បណ្តុំ (ចិញ្ចឹមត្រី ចិញ្ចឹមមាន់ បង្គាក្រៀម បន្លែ ឃ្មុំ សាវម៉ាវ) នៅស្រុកមណ្ឌលសីមា ក្រុងខេមរភូមិន្ទ ស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល មានអ្នកចូលរួមសរុបចំនួន 708នាក់ ស្រី 284នាក់
  - ចុះសម្របសម្រួលរៀបចំវេទិកាអ្នកពាក់ព័ន្ធចម្រុះ និងចុះកិច្ចសន្យារវាងអ្នកលក់ធាតុចូល អ្នកប្រមូលទិញ និងអ្នកផលិតបានចំនួន 18បណ្តុំអាជីវកម្ម នៅក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ដែលមានអ្នកចូលរួមសរុបចំនួន 708នាក់ ស្រី 284នាក់
  - ចុះសម្របសម្រួលរៀបចំផែនការអាជីវកម្ម ដល់សមាជិកបណ្តុំអាជីវកម្មបានចំនួន 18បណ្តុំ នៅស្រុកមណ្ឌលសីមា ក្រុងខេមរភូមិន្ទ ស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ដែលមានអ្នកចូលរួមសរុបចំនួន 708នាក់ ស្រី 284នាក់
  - ចុះសម្របសម្រួលរៀបចំគាំទ្រចែកធាតុចូលកសិកម្ម និងទុនសហវិនិយោគនៃបណ្តុំអាជីវកម្ម បានចំនួន 18បណ្តុំ នៅស្រុកមណ្ឌលសីមា ក្រុងខេមរភូមិន្ទ ស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ដែលមានអ្នកចូលរួម សរុបចំនួន 708នាក់ ស្រី 284នាក់

- បានសាងសង់មជ្ឈមណ្ឌលប្រមូលផ្តុំទិញ-លក់កសិផលរបស់កសិករចំនួន 06កន្លែង នៅស្រុកគិរីសាគរ ស្រុកស្រែអំបិល ស្រុកថ្មបាំង ស្រុកបូទុមសាគរ ស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ
- បានសាងសង់ផ្ទះសំណាញ់ចំនួន 06កន្លែង នៅស្រុកស្រែអំបិល ស្រុកគិរីសាគរ ស្រុកបូទុមសាគរ និងក្រុងខេមរភូមិន្ទ
- ចុះរៀបចំទិវាបង្ហាញផលិតផលរបស់បណ្តុំអាជីវកម្មបន្លែសុវត្ថិភាព ចំនួន 03លើក នៅស្រុកស្រែអំបិល និងស្រុកថ្មបាំង មានអ្នកចូលរួមសរុបចំនួន 150នាក់
- ចុះសម្របសម្រួលរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងផលិតផល និងទីផ្សារក្នុងបណ្តុំអាជីវកម្មសាវម៉ាវ ចំនួន 02លើក នៅស្រុកស្រែអំបិល និងស្រុកថ្មបាំង មានអ្នកចូលរួមសរុបចំនួន 100នាក់ ស្រី 37នាក់
- ចុះសម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី ដល់បណ្តុំអាជីវកម្មចិញ្ចឹមត្រី ចំនួន 06 បណ្តុំដែលមានអ្នកចូលរួមសរុបចំនួន 234នាក់ ស្រី 61នាក់
- ចុះបើកវគ្គបណ្តុះបណ្តាលការចិញ្ចឹមឃ្មុំតាមបែបធម្មជាតិ ចំនួន 02វគ្គ នៅឃុំជីខលើ និងជីខក្រោម ស្រុកស្រែអំបិល មានអ្នកចូលរួមសរុបចំនួន 89នាក់ ស្រី 27នាក់
- ចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពកសិករគំរូ ឱ្យក្លាយជាកសិករគ្រូ ចំនួន 03វគ្គ នៅស្រុកថ្មបាំង និងស្រុកស្រែអំបិល មានអ្នកចូលរួមសរុបចំនួន 141នាក់ ស្រី 60នាក់
- ចុះបង្ហាញពីបច្ចេកទេសធ្វើវ៉ាក់សាំងសត្វមាន់ ចំនួន 02វគ្គ នៅស្រុកស្រែអំបិល មានអ្នកចូលរួមសរុបចំនួន 93នាក់ ស្រី 40នាក់
- ចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ដល់បណ្តុំអាជីវកម្មចិញ្ចឹមមាន់ ចំនួន 04វគ្គ នៅឃុំស្រែ-អំបិល ស្រុកស្រែអំបិល មានអ្នកចូលរួមសរុបចំនួន 193នាក់ ស្រី 90នាក់
- ចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកែច្នៃបង្គាក្រៀម ដល់បណ្តុំអាជីវកម្មបង្គាក្រៀម ចំនួន 01វគ្គ នៅឃុំថ្មស ស្រុកបូទុមសាគរ មានអ្នកចូលរួមសរុបចំនួន 30នាក់ ស្រី 19នាក់

– សហការជាមួយអង្គការសង្គ្រោះកុមារ (Save The Children) និងអង្គការអភិវឌ្ឍទឹក និងទីផ្សារជនបទ(IDE) របស់គម្រោងស្ទៀរ (STEER) បាន៖
  - ចុះត្រួតពិនិត្យសហគ្រិនស្នើសុំទុនគាំទ្រអាជីវកម្មបានចំនួន 54សហគ្រិន និងបានសម្រេចផ្តល់ទុនអាជីវកម្ម ចំនួន 22សហគ្រិន នៅស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
  - ចុះត្រួតពិនិត្យ តាមដានកសិករគម្រោង ដើម្បីពង្រឹងផលិតកម្មកសិកម្ម ចំនួន 54លើក ទៅលើគ្រួសារកសិករចំនួន 384គ្រួសារ នៅស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកថ្មបាំង
  - ចុះរៀបចំធ្វើបទបង្ហាញអំពីដំណាំ (ស្វាយចន្ទី ត្រសក់ទ្រើង ឪឡឹក ខ្ទឹមបារាំង ម្ទេសហាវ៉ៃ ការ៉ុត ចេក ខាត់ណាផ្កា និងស្ពៃក្តោប) ជូនកសិករបានចំនួន 44គ្រួសារ នៅស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
  - ដឹកនាំកសិករទស្សនកិច្ចសិក្សាពីបទពិសោធន៍ និងបច្ចេកទេសកសិកម្ម ចំនួន 02លើក មានអ្នកចូលរួម ចំនួន 57នាក់ ស្រី 10នាក់ នៅស្រុកថ្មបាំង
  - ចុះត្រួតពិនិត្យ ណែនាំអំពីបច្ចេកទេស និងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ដល់ដេប៉ូលក់សម្ភារកសិកម្ម ចំនួន 12ដេប៉ូ នៅស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកថ្មបាំង
  - ចុះបើកវគ្គបណ្តុះបណ្តាលការគ្រប់គ្រង និងការប្រើប្រាស់សម្ភារកសិកម្ម ចំនួន 04វគ្គ មានអ្នកចូលរួមសរុប 106នាក់ ស្រី 44នាក់ នៅស្រុកស្រែអំបិល និងស្រុកបូទុមសាគរ

- ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការគ្រប់គ្រងក្រុមកសិករអ្នកផលិត ក្រុមថ្នាំ និងការសុំថ្នាំកសិកម្ម ចំនួន 01វគ្គ មានអ្នកចូលរួមសរុបចំនួន 23នាក់ ស្រី 04នាក់ នៅឃុំឫស្សីជ្រុំ ស្រុកថ្មបាំង
- ចុះសម្របសម្រួលវគ្គបណ្តុះបណ្តាលសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំកសិកម្ម លើផលិតកម្មដំណាំចេក ចំនួន 24វគ្គ នៅឃុំតាទៃលើ និងឃុំឫស្សីជ្រុំ ស្រុកថ្មបាំង មានអ្នកចូលរួមចំនួន 234នាក់ ស្រី 169នាក់
- ចុះបើកវគ្គបណ្តុះបណ្តាលអំពីសុវត្ថិភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ជី-ថ្នាំកសិកម្ម លើមុខដំណាំដែលមានតម្លៃខ្ពស់ ចំនួន 06វគ្គ នៅស្រុកស្រែអំបិល មានអ្នកចូលរួមចំនួន 110នាក់ ស្រី 58នាក់
- ចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំបន្លែ ចំនួន 32វគ្គ មានអ្នកចូលរួមសរុប 846នាក់ ស្រី 616 នាក់ នៅស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
- ចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំចេក ចំនួន 33វគ្គ មានអ្នកចូលរួមសរុប 370នាក់ ស្រី 256 នាក់ នៅស្រុកថ្មបាំង
- ចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំស្វាយចន្ទី ចំនួន 24វគ្គ មានអ្នកចូលរួមសរុប 280នាក់ ស្រី 256នាក់ នៅស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
- ចុះបើកវគ្គបណ្តុះបណ្តាលអំពីសុវត្ថិភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ជី-ថ្នាំកសិកម្ម លើមុខដំណាំ ដែលមានតម្លៃខ្ពស់ ចំនួន 08វគ្គ នៅថ្មបាំង និងស្រុកស្រែអំបិល មានអ្នកចូលរួមចំនួន 136នាក់ ស្រី 64នាក់
- ចុះបើកវគ្គបណ្តុះបណ្តាលអំពីការកត់ត្រាបញ្ជីស្នាមសម្រាប់ក្រុមកសិករអ្នកផលិត ចំនួន 29វគ្គ នៅស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល មានអ្នកចូលរួមចំនួន 454នាក់ ស្រី 262នាក់។

**ខ.ការងារខណ្ឌរដ្ឋបាលជលផល**

- អាជីវកម្មនេសាទទឹកសាបអនុវត្តបានចំនួន 455តោន
- អាជីវកម្មនេសាទសមុទ្រអនុវត្តបានចំនួន 49,335តោន (សិប្បកម្ម 43,853តោន, គ្រួសារ 5,482តោន)
- ផលនេសាទកែច្នៃអនុវត្តបានចំនួន 1,915តោន
- ទឹកត្រីអនុវត្តបានចំនួន 43,000លីត្រ
- ផលវារីវប្បកម្មអនុវត្តបានចំនួន 1,580តោន
- ចរាចរណ៍ផលនេសាទទៅតាមបណ្តារាជធានី/ខេត្តផ្សេងៗ និងនាំចេញទៅក្រៅប្រទេសដោយក្រុមហ៊ុន L.Y.P Group Co,Ltd របស់អ្នកឧកញ៉ា **លី យ៉ុងផាត់** មានចំនួន 36,140តោន ក្នុងនោះ ផលកែច្នៃចំនួន 1,770 តោន
- ផលនេសាទឆ្លងកាត់ខេត្តកោះកុង ពីវៀតណាម ទៅថៃ និង ពីថៃ ទៅវៀតណាម ដោយក្រុមហ៊ុន **ម៉ៅ ឈាងម៉ៃ** និងក្រុមហ៊ុន **ម៉េង ជង** មានចំនួន 1,465តោន ក្នុងនោះ ៖
  - ផលនេសាទនាំពីប្រទេសវៀតណាម ទៅប្រទេសថៃ មានចំនួន 905តោន
  - ផលនេសាទនាំពីប្រទេសថៃ ទៅប្រទេសវៀតណាម មានចំនួន 560តោន
- មេក្តាមពងដាក់ចូលធនាគារបានចំនួន 36ក្តាម ស្មើនឹង 3.7គីឡូក្រាម
- ដាំកូនកោងកាងបានចំនួន 1,000 ដើម
- លែងអណ្តើកសមុទ្រ(ក្រាស់) ចំនួន 01ក្បាល ទម្ងន់ 4.30គីឡូក្រាម ទៅក្នុងសមុទ្រវិញ ស្ថិតនៅភូមិអន់ឆ្អើត ឃុំជីខក្រោម ស្រុកស្រែអំបិល
- ចេញប្រតិបត្តិការបង្ក្រាបបទល្មើសជលផលចំនួន 139លើក និងជួបបទល្មើស 52ករណី ក្នុងនោះ ៖
  - ដកហូត និងបំផ្លាញចោលលបកន្ទុយកណ្តុរ ចំនួន 891ខ្សែ ប្រវែង 6,928ម៉ែត្រ ស្មើនឹង 21ករណី
  - ដកហូតឈ្នាងអូសកូនគ្រែងឈាម ចំនួន 61ឈ្នាង ស្មើនឹង 17ករណី
  - រុះរើបង្គោលស៊ុមគ្រែងឈាម ចំនួន 1,900ដើម ស្មើនឹង 03ករណី

- ដកហូតឧបករណ៍ឆក់ អាំងវឺតទ័រចំនួន 01គ្រឿង និងដងឆក់ចំនួន 02 ស្មើនឹង 01ករណី
- ឃាត់រថយន្តដឹកជញ្ជូនផលផលិតផលជលផលគ្មានលិខិតអនុញ្ញាត និងដកហូតកូនគ្រែងឈាម លែងចូលក្នុងព្រៃកធម្មជាតិវិញ ចំនួន 1,200គីឡូក្រាម ស្មើនឹង 02ករណី
- លបត្រីក្រឡា 0.5សង់ទីម៉ែត្រ ទំហំ អង្កត់ផ្ចិត 0.95 ម៉ែត្រ បណ្តោយ 223ម៉ែត្រ ចំនួន 01លប ស្មើនឹង 01ករណី
- លែងអណ្តើកហ្លួង ឬអណ្តើកសសៃចូលក្នុងព្រៃកធម្មជាតិវិញចំនួន 02ក្បាល ទម្ងន់ 22គីឡូក្រាម ស្មើនឹង 02ករណី
- របាំងសាច់អួនប្រវែង 06ម៉ែត្រ លូសាច់អួន 01មាត់ បង្គោលចំនួន 10ដើម ស្មើនឹង 01ករណី
- របាំងស្បៃមុងប្រវែង 06ម៉ែត្រ លូសាច់អួន 01មាត់ ប្រវែង 50ម៉ែត្រ បង្គោល 10ដើម ស្មើនឹង 01ករណី
- អប់រំណែនាំដល់ប្រជានេសាទឱ្យបញ្ឈប់ការនេសាទអូសកូនគ្រែងឈាមនៅតំបន់ទឹករាក់ ចំនួន 01ករណី
- ឧបករណ៍នេសាទដាយចំនួន 01 ដាក់តាមដងព្រែក និងបំផ្លាញចោលនៅនឹងកន្លែង ចំនួន 01ករណី
- ដកហូតបង្គោលស៊ីម៉ង់ត៍បោះហ៊ុមព័ទ្ធយកដីព្រៃកោងកាង ធ្វើជាកម្មសិទ្ធិបានចំនួន 110ដើម ស្មើនឹង 01ករណី។

## គ. ការងារខណ្ឌរដ្ឋបាលព្រៃឈើ

- ខណ្ឌរដ្ឋបាលព្រៃឈើកោះកុង បានធ្វើការថែទាំកូនឈើចម្រុះប្រភេទសរុបចំនួន 5,199ដើម
- សហគមន៍ព្រៃឈើ បានធ្វើការថែទាំកូនឈើគ្រញូង ដូងថែម កកោះ ធ្នឹកឧត្តម រយោង ស្តៅព្រៃ សរុបចំនួន 8,800ដើម
- ចែកកូនឈើចម្រុះប្រភេទចំនួន 255ដើម ជូនកសិករដាំអាស្រ័យផល
- ចុះពិនិត្យជាក់ស្តែងទីតាំងស្នើសុំចិញ្ចឹមសត្វព្រៃចំនួន 06ប្រភេទ រួមមាន៖ សត្វក្ងោក ចំនួន 05ក្បាល, សត្វកាំប្រម៉ា ចំនួន 05ក្បាល, សត្វឈ្លូស ចំនួន 02ក្បាល, សត្វក្តាន់ព្រៃង ចំនួន 02ក្បាល, សត្វសំពោច ចំនួន 04ក្បាល និងសត្វត្រដក់ ចំនួន 02ក្បាល ដែលមានទីតាំងស្ថិតនៅភូមិអូរជ្រៅ ឃុំបឹងព្រាវ ស្រុកស្រែអំបិល
- ចុះពិនិត្យទីតាំងស្នើសុំបង្កើតរោងសន្និធិអនុផលព្រៃឈើ (ផ្តៅ) ចំនួន 01កន្លែង ស្ថិតនៅភូមិប្រលាន ឃុំកណ្តោល ស្រុកបូទុមសាគរ របស់ឈ្មោះ **លិន លី** ភេទប្រុស អាយុ 62ឆ្នាំ មានទីលំនៅភូមិសុវណ្ណាបៃតង ឃុំកណ្តោល ស្រុកបូទុមសាគរ
- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ការដឹកជញ្ជូនឈើអារស្របច្បាប់របស់ក្រុមហ៊ុន **សៀ ម៉ុន** ពីខេត្តស្ទឹងត្រែង ចំនួន 52ម$^3$ (ឈើអារប្រភេទលេខ1) យកមកផ្គត់ផ្គង់តម្រូវការទីផ្សារប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងភូមិព្រះអង្គកែវ ឃុំដងពែង ស្រុកស្រែអំបិល
- សហការជាមួយក្រុមការងាររដ្ឋបាលព្រៃឈើថ្នាក់កណ្តាលបាន៖
  - ចុះពិនិត្យចម្ការឈើដាំ (ច័ន្ទក្រស្នា) របស់ក្រុមហ៊ុន **សុធី សុវិត្យា** ស្ថិតនៅឃុំដីឧក្រោម ស្រុកស្រែអំបិល ដែលបានធ្វើការដាំឈើច័ន្ទក្រស្នាចាប់តាំងពីឆ្នាំ2015 លើផ្ទៃដីទំហំ 300ហិកតា លាយចម្រុះជាមួយដើមឈើគ្រញូង ក្នុងគម្រោងចំនួន 1,000,000ដើម។ បច្ចុប្បន្នក្រុមហ៊ុនបានដាក់ពាក្យស្នើសុំទៅរដ្ឋបាលព្រៃឈើ ដើម្បីធ្វើការដកហូតឈើច័ន្ទក្រស្នាមួយចំនួន ចម្រាញ់យកប្រេងនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។ លទ្ធផលពិនិត្យ សិក្សាជាក់ស្តែងឃើញថា ដើមឈើច័ន្ទក្រស្នាចំនួនប្រមាណ 500,000ដើម មានអង្កត់ផ្ចិតទំហំ 15សង់ទីម៉ែត្រ ឡើងទៅ និងមានកម្ពស់ ពី 8-12ម៉ែត្រ ដែលអាចធ្វើការចម្រាញ់យកប្រេងបាន
  - ចុះពិនិត្យទីតាំងស្នើសុំថែរក្សាសត្វត្រចៀកកាំជាលក្ខណៈគ្រួសារចំនួន 02លើក លើទីតាំងចំនួន 25ទីតាំង ស្ថិតនៅឃុំអណ្តូងទឹក និងឃុំកណ្តោល ស្រុកបូទុមសាគរ។

- សហការជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងថ្នាក់ស្រុកបាន៖
  - ចុះបោះបង្គោលព្រំ និងវាស់វែងចុះបញ្ជីដីរដ្ឋ ដែលបានកាត់ឆ្វៀលចេញពីតំបន់ការពារធម្មជាតិ និងគម្របព្រៃឈើឆ្នាំ2002 ផ្ទៃដីទំហំ 1,233.77ហិកតា ក្នុងភូមិសាស្ត្រឃុំដងពែង ស្រុកស្រែអំបិល
  - ចុះពិនិត្យទីតាំងដីចំនួន 02កន្លែង ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ដែលស្នើសុំចុះបញ្ជីជាដីកម្មសិទ្ធិឯកជនរបស់ឈ្មោះ **ឡៅ ខេង** នៅក្នុងភូមិសាស្ត្រឃុំជ្រោយស្វាយ ផ្ទៃដីទំហំ 205ហិកតា និងក្នុងភូមិសាស្ត្រឃុំដងពែង ផ្ទៃដីទំហំ 159ហិកតា មានអ្នកចូលរួមសរុបចំនួន 21នាក់ ស្រី 01នាក់
  - ចុះពិនិត្យទីតាំងដី 01កន្លែង ទំហំ 80ហិកតា របស់លោក **គិត ទៀ** ដែលបានស្នើសុំចុះបញ្ជីជាដីកម្មសិទ្ធិឯកជន ស្ថិតនៅឃុំបឹងព្រាវ ស្រុកស្រែអំបិល មានអ្នកចូលរួមសរុបចំនួន 10នាក់
  - ចុះពិនិត្យទីតាំងដីស្នើសុំចុះបញ្ជីធ្វើប័ណ្ណកម្មសិទ្ធិ លើផ្ទៃដីដែលប្រជាពលរដ្ឋបានធ្វើការដាំឈើអាកាស្យាចំនួន 10.44ហិកតា ស្ថិតក្នុងភូមិសាស្ត្រភូមិព្រះអង្គកែវ ឃុំដងពែង ស្រុកស្រែអំបិល
  - ចុះពិនិត្យទីតាំងសំណើសុំចុះបញ្ជីដី និងធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំនួន 03ទីតាំង ស្ថិតក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង និងដីគម្របព្រៃឈើឆ្នាំ2002 នៅភូមិសាស្ត្រស្រុកស្រែអំបិល រួមមាន សំណើរបស់ឈ្មោះ **ហេង ហៃ** មានផ្ទៃដីទំហំ 37,678ម$^2$ ស្ថិតនៅភូមិកំពង់ស្ដាំ ឃុំជ្រោយស្វាយ, ឈ្មោះ **ប៉េង ឈន** មានផ្ទៃដីទំហំ 47.28ហិកតា ស្ថិតនៅភូមិចម្ការក្រោម ឃុំស្រែអំបិល និងឈ្មោះ **គា សុគង់** មានផ្ទៃដីទំហំ 200,000ម$^2$ ស្ថិតនៅឃុំបឹងព្រាវ ស្រុកស្រែអំបិល
  - ចុះពិនិត្យទីតាំងដីដែលបានកាត់ឆ្វៀលក្នុងតំបន់ការពារធម្មជាតិ ទំហំ 126,928.39ហិកតា និងដីស្ថិតក្នុងគម្របព្រៃឈើឆ្នាំ2002 ទំហំ 23,092ហិកតា តាមការស្នើសុំចុះបញ្ជីជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋក្នុងឃុំដីខលើ ឃុំដងពែង ឃុំស្រែអំបិល និងឃុំជ្រោយស្វាយ ស្រុកស្រែអំបិល
  - ចុះពិនិត្យទីតាំងដីចំនួន 04កន្លែង ស្នើសុំផ្ទេរសិទ្ធិកាន់កាប់ដី ដែលមិនទាន់បានចុះបញ្ជីកាន់កាប់អចលនវត្ថុរបស់ឈ្មោះ **សួន មាន** មានផ្ទៃដីសរុបទំហំ 2,570,043ម$^2$ (ស្ថិតក្នុងតំបន់កាត់ឆ្វៀលផ្ទៃដីទំហំ 23,092ហិកតា ដែលជាតំបន់ដីគម្របព្រៃឈើឆ្នាំ2002) ក្នុងនោះរួមមាន ក្បាលដីទី1 មានទំហំ 1,330,900ម$^2$ ស្ថិតនៅភូមិផ្លោង ឃុំបឹងព្រាវ, ក្បាលដីទី2 មានទំហំ 175,013ម$^2$ ស្ថិតនៅភូមិជ្រោយស្វាយកើត ឃុំជ្រោយស្វាយ, ក្បាលដីទី3 មានទំហំ 46,381ម$^2$ ស្ថិតនៅភូមិឈើនាង ឃុំជ្រោយស្វាយ និងក្បាលដីទី4 មានទំហំ 1,017,749ម$^2$ ស្ថិតនៅភូមិឈើនាង ឃុំជ្រោយស្វាយ
  - ចុះកំណត់ចំណុចនិយាមកា បោះបង្គោលព្រំដីតំបន់កាត់ឆ្វៀលជូនប្រជាពលរដ្ឋប្រើប្រាស់អាស្រ័យផលជាក់ស្តែង ចេញពីគម្របព្រៃឈើឆ្នាំ2002 និងដើម្បីការពារទប់ស្កាត់ការកាប់រានព្រៃហ៊ុមព័ទ្ធកាន់កាប់ដីពីជនខិលខូច នៅតំបន់ត្រពាំងធំ និងតំបន់ព្រៃបម្រុងស្នាច់ ក្នុងភូមិសាស្ត្រឃុំអណ្ដូងទឹក ស្រុកបូទុមសាគរបានចំនួន 43ចំណុច
  - ចុះបោះបង្គោលព្រំ និងវាស់វែងចុះបញ្ជីដីរដ្ឋ ដែលបានកាត់ឆ្វៀលចេញពីគម្របព្រៃឈើឆ្នាំ2002 ផ្ទៃដីចំនួន 184,911ហិកតា និងបោះបង្គោលព្រំដីបានចំនួន 24បង្គោល ក្នុងភូមិសាស្ត្រភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - ចុះពិនិត្យទីតាំងសំណើសុំចុះបញ្ជីដី និងធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន 05ទីតាំង មានផ្ទៃដីសរុបទំហំ 453.1627ហិកតា រួមមានសំណើរបស់ឈ្មោះ **សំ ស៊ី** មានផ្ទៃដីទំហំ 20ហិកតា ស្ថិតនៅភូមិតាចាត ឃុំទួលគគីរ, ឈ្មោះ **ផាន់ កណ្ណារី** មានផ្ទៃដីទំហំ 121.13ហិកតា ស្ថិតនៅភូមិតាចាត ឃុំទួលគគីរ, ឈ្មោះ **ងយ លក្ខិណា** មានផ្ទៃដីទំហំ 39,573ម$^2$ ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង, ឈ្មោះ **អ៊ុក សឿន** មានផ្ទៃដីទំហំ 80,854ម$^2$ ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង និង ឈ្មោះ **យូ សុខា** និងឈ្មោះ

**កែវ ម៉ាល័យ** មានផ្ទៃដីប្រមាណ 300ហិកតា ស្ថិតនៅចំណុច297 ភូមិកោះប៉ោ ឃុំប៉ាក់ខ្លង។ តាមការពិនិត្យពិភាក្សាលើសំណើសុំចុះបញ្ជីដីទាំង 05ទីតាំង ខាងលើ ឃើញថា មាន 02ទីតាំង គឺទីតាំងរបស់ឈ្មោះ **អ៊ុក សឿន** និងទីតាំងរបស់ឈ្មោះ **ងយ លក្ខិណា** គឺជាផ្ទៃដីស្ថិតក្នុងគម្របព្រៃឈើឆ្នាំ2002 គ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ

  - ចុះពិនិត្យធនធានព្រៃឈើនៅសេសសល់លើដីទំហំ 2,500ហិកតា ដែលត្រូវធ្វើការឈូសឆាយរៀបចំជាឡូត៍សម្រាប់បែងចែកជូនប្រជាពលរដ្ឋ នៅក្នុងភូមិសាស្ត្រស្រុកបូទុមសាគរ ជាលទ្ធផលពិនិត្យឃើញថា មានកូនឈើចម្រុះប្រភេទ អង្កត់ផ្ចិតពី 5ស.ម ដល់ 19ស.ម មានចំនួន 49,720ដើម និងអុសចម្រុះប្រភេទមានអង្កត់ផ្ចិតពី 20ស.ម ឡើងទៅ មានចំនួន 54,620ដើម។

- ចេញប្រតិបត្តិការបង្ក្រាបបទល្មើសបានចំនួន 16លើក ជួបបទល្មើស 20ករណី ក្នុងនោះ ៖
  - កាប់រានដីព្រៃក្នុងភូមិសាស្ត្រឃុំថ្មស ឃុំតានូន ឃុំកណ្តោល ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ចំនួន 04ករណី
  - បទល្មើសកាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ ដោយគ្មានលិខិតអនុញ្ញាត លើផ្ទៃដីព្រៃស្ទាច់ កាប់រានរួចទំហំប្រមាណ 11ហិកតា ចំនួន 02ករណី
  - បញ្ឈប់សកម្មភាពសាងសង់ផ្ទះដោយខុសច្បាប់របស់ប្រជាពលរដ្ឋចំនួន 01ខ្នង ទំហំ 6មx7ម រៀបខឿនថ្មសសរដែក ដំបូលប្រក់ស៊ីប្រូគ្មានជញ្ជាំង ក្នុងដីចម្ការឈើអាកាស្យារបស់រដ្ឋ ចំនួន 01ករណី
  - ដកបង្គោលហ៊ុមព័ទ្ធដីសរុបចំនួន 78បង្គោល ក្នុងនោះ៖ បង្គោលស៊ីម៉ង់ត៏ហ៊ុមព័ទ្ធដីព្រៃដោយខុសច្បាប់បានចំនួន 36ដើម និងបង្គោលកូនឈើហ៊ុមព័ទ្ធដី បានចំនួន 42ដើម ចំនួន 01ករណី
  - ចុះប្រតិបត្តិការបង្ក្រាបបទល្មើសដាក់ស្តែងសង់លំនៅឋានថ្មីលើដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន CAMAGRA ដោយគ្មានលិខិតអនុញ្ញាត ចំនួន 01ករណី
  - សហការជាមួយក្រុមអន្តរាគមន៍ចល័តបង្ក្រាបបទល្មើសសត្វព្រៃ របស់រដ្ឋបាលព្រៃឈើ បានចុះប្រតិបត្តិការបង្ក្រាបបទល្មើសធ្វើពាណិជ្ជកម្មសំណាកសត្វព្រៃ ដោយគ្មានលិខិតអនុញ្ញាត ចំនួន 01ករណី
  - បញ្ជូនសំណុំរឿងបទល្មើសព្រៃឈើ ទៅអយ្យការអមសាលាដំបូងខេត្តកោះកុង ពីបទកាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ ដោយគ្មានលិខិតអនុញ្ញាត ក្នុងភូមិសាស្ត្រឃុំត្រពាំងរូង ឃុំជ្រោយប្រស់ ស្រុកកោះកុង ប្រព្រឹត្តឡើងដោយមេខ្លោងឈ្មោះ **សោ សន**; **តង់ សុផាន់**; **យឿន ឌីម**; **សុង សុភឿន; ជា ផល្លា**; **ប៉ុល ម៉ុក**; **សុខ ចំរើន**; **ខាត់ សុខច័ន្ទ**។ វត្ថុតាងល្មើសរួមមាន៖ ផ្ទៃដីព្រៃកាប់រានរួចទំហំសរុបចំនួន 10.065ហិកតា ចំនួន 02ករណី
  - បទល្មើសប្រមូលផល អនុផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាត វត្ថុតាងល្មើសរួមមាន៖ ឈើអារប្រភេទលេខ2(កំញាណ គគីរខ្សាច់) ចំនួន 40សន្លឹក ស្មើនឹង 1ម$^3$416 (មួយម៉ែត្រគ្រីគុណបួនរយដប់ប្រាំមួយ) និងទូកភ្ជាប់ដោយម៉ាស៊ីន ចំនួន 01គ្រឿង ចំនួន 01ករណី
  - ចុះបង្ក្រាបបទល្មើសកាប់រានព្រៃ ដែលមានផ្ទៃដីទំហំប្រហែល 05ហិកតា នៅភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ចំនួន 01ករណី
  - ចងក្រងសំណុំរឿងបទល្មើសព្រៃឈើ ពីបទដាក់តាំងលំនៅឋានក្នុងដីចម្ការឈើរបស់រដ្ឋដោយគ្មានលិខិតអនុញ្ញាត បញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តកោះកុង ចំនួន 03ករណី
  - បង្ក្រាបបទល្មើសសន្និធិសត្វព្រៃ និងសំណាកសត្វព្រៃ ក្នុងក្រុមប្រភេទសត្វមានដោយបង្គួរ និងក្នុងក្រុមប្រភេទសត្វមានដោយកម្រ ដោយគ្មានលិខិតអនុញ្ញាត និងបានចងក្រងសំណុំរឿងនៃបទល្មើស និងបានបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តកោះកុង ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ចំនួន 01ករណី

- ក្រុមការងារចម្រុះបានធ្វើការឆែកឆេរទីតាំងសន្និធិ កែច្នៃផល អនុផលព្រៃឈើ ចំនួន 01កន្លែង ដោយគ្មានលិខិតអនុញ្ញាត នៅភូមិព្រែកស្មាច់ ឃុំកោះស្ដេច ស្រុកគិរីសាគរ ខេត្តកោះកុង ចំនួន 01ករណី
- ចុះស្រាវជ្រាវបង្ក្រាបបទល្មើសហ៊ុមព័ទ្ធកាន់កាប់ដីតាមដងព្រែក (ដីស្ថិតក្នុងគម្របព្រៃឈើឆ្នាំ2002) ដោយបានធ្វើការដកបង្គោលថ្មហ៊ុមព័ទ្ធកាន់កាប់ដីចំនួន 110បង្គោល និងធ្វើការរឹបអូសអន្ទាក់ដាក់ចាប់សត្វព្រៃ បានចំនួន 01ខ្សែ នៅភូមិអណ្ដូងទឹក ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ ចំនួន 01ករណី។

**៣.១.២. ការងារធនធានទឹក និងឧតុនិយម**

- បានជួសជុលថែទាំជាប្រចាំទំនប់ការពារទឹកប្រែកណ្ដោល ប្រវែង 6,200ម ស្ថិតក្នុងឃុំកណ្ដោល ស្រុកបូទុមសាគរ សម្រេចបាន 100%
- បានជួសជុលថែទាំជាប្រចាំទំនប់ការពារទឹកប្រែជីមាល ប្រវែង 3,489ម ស្ថិតក្នុងឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ សម្រេចបាន 100%
- បានជួសជុលថែទាំជាប្រចាំទំនប់ការពារទឹកប្រែជីត្រេះប្រវែង 7,800ម ស្ថិតក្នុងឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ សម្រេចបាន 100%
- បានជួសជុលសំណង់ទ្វារទឹកមុខ3 ស្ថិតក្នុងឃុំអណ្ដូងទឹក ស្រុកបុទុមសាគរ សម្រេចបាន 100%
- បានជួសជុលថែទាំជាប្រចាំទំនប់ការពារទឹកប្រែបឹងព្រាវ ប្រវែង 4,000ម ស្ថិតក្នុងឃុំបឹងព្រាវ ស្រុកស្រែអំបិល សម្រេចបាន 100%
- បានជួសជុលថែទាំជាប្រចាំទំនប់ការពារទឹកជ្រោយស្វាយ ប្រវែង 4,130ម ស្ថិតក្នុងឃុំជ្រោយស្វាយ ស្រុកស្រែអំបិល សម្រេចបាន 100%
- បានជួសជុលថែទាំប្រចាំទំនប់ការពារទឹកប្រែតានី ប្រវែង 2,000ម ស្ថិតក្នុងឃុំដីខលើ ស្រុកស្រែអំបិល សម្រេចបាន 100%
- បានជួសជុលទំនប់ការពារទឹកប្រែត្រៀក ប្រវែង 4,600ម ស្ថិតក្នុងឃុំស្រែអំបិល ស្រុកស្រែអំបិល សម្រេចបាន 100%
- បានស្ដារប្រឡាយដោះទឹកជំនន់តាមបណ្ដោយទំនប់ការពារទឹកប្រែត្រៀក ប្រវែង 4,250ម ស្ថិតក្នុងឃុំស្រែអំបិល ស្រុកស្រែអំបិល សម្រេចបាន 100%
- បានបន្តចុះពង្រឹងដល់កសិករអំពីការប្រើប្រាស់ទឹកសហគមន៍កណ្ដោល ស្ថិតក្នុងឃុំកណ្ដោល ស្រុកបូទុមសាគរ មានផ្ទៃដីស្រោចស្រពចំនួន 330ហិកតា មានកសិករទទួលផលចំនួន 265គ្រួសារ និងសហគមន៍ភូមិខ្លុង ឃុំស្រែអំបិល ស្រុកស្រែអំបិល មានផ្ទៃដីស្រោចស្រពចំនួន 535ហិកតា និងមានកសិករទទួលផលចំនួន 1,292 គ្រួសារ។

**៣.១.៣. ការងារអភិវឌ្ឍន៍ជនបទ**

- បានធ្វើបច្ចុប្បន្នភាពការគ្រប់គ្រងផ្លូវជនបទតាមប្រព័ន្ធព័ត៌មានវិទ្យា ក្នុងខេត្តកោះកុង បានចំនួន 72ខ្សែ ប្រវែង 368,244គ.ម ក្នុងស្រុកស្រែអំបិល ស្រុកបូទុមសាគរ ស្រុកកោះកុង ស្រុកថ្មបាំង និងស្រុកមណ្ឌលសីមា ខេត្តកោះកុង
- បានចុះរាប់ចរាចរណ៍យានយន្ត លើខ្សែផ្លូវចំនួន 06ខ្សែ ប្រវែងសរុប 81,5គ.ម នៅក្នុងស្រុកស្រែអំបិល ស្រុកថ្មបាំង និងស្រុកបូទុមសាគរ ខេត្តកោះកុង
- ការថែទាំផ្លូវជាលក្ខណៈខួប បានចំនួន 01ខ្សែ ប្រវែង 10,800ម៉ែត្រ ទទឹងខ្នងលើក្រាលក្រួសក្រហម 05ម៉ែត្រ និងសាងសង់លូ 02កន្លែង (លូមូល 01កន្លែង និងលូប្រអប់ 01កន្លែង) ស្ថិតនៅភូមិជីផាត និងភូមិជាំស្លា ឃុំជីផាត ស្រុកថ្មបាំង ខេត្តកោះកុង

- បានថែទាំផ្លូវជាលក្ខណៈប្រចាំ ចំនួន 09ខ្សែ ប្រវែងសរុប 27,400ម៉ែត្រ (ក្រាលក្រួសក្រហម ទទឹងខ្នងលើ 4 ម៉ែត្រ និង 5ម៉ែត្រ) ស្ថិតនៅឃុំបឹងព្រាវ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ និង ឃុំត្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង
- បានជួសជុលផ្លូវអន្តរាគមន៍បន្ទាន់ បានចំនួន 03ខ្សែ ប្រវែងសរុប 7,850ម៉ែត្រ មានទីតាំងដូចខាងក្រោម៖
  - ផ្លូវភូមិទួលគគីរក្រោម(ភ្ជាប់ពីផ្លូវធំទៅដល់វត្តទួលគគីរ) 01ខ្សែ ប្រវែង 3,000ម៉ែត្រ ទទឹងខ្នងលើ 4ម៉ែត្រ ស្ថិតនៅភូមិទួលគគីរក្រោម ឃុំទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង
  - ផ្លូវក្នុងភូមិទួលគគីរក្រោម (ភ្ជាប់ពីផ្លូវបេតុងមុខសាលាឃុំទួលគគីរ ទៅដល់ទំនប់) 01ខ្សែ ប្រវែង 1,500 ម៉ែត្រ ទទឹងខ្នងលើ 4ម៉ែត្រ ស្ថិតនៅភូមិទួលគគីរក្រោម ឃុំទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង
  - ផ្លូវភូមិជីមាល 01ខ្សែ ប្រវែង 3,350ម៉ែត្រ ទទឹងខ្នងលើក្រាលក្រួសក្រហម 4ម៉ែត្រ ស្ថិតនៅឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង
- បានសាងសង់ប្រព័ន្ធចែកចាយទឹកសហគមន៍ចំនួន 01កន្លែង នៅឃុំកណ្ដោល ស្រុកបូទុមសាគរ ខេត្តកោះកុង៖
  - ប្រព័ន្ធចែកចាយទឹកសាងសង់បាន 100%
  - ស្រះសហគមន៍បានជីកហើយជាស្ថាពរ 100%
  - ការដាំស្មៅជុំវិញស្រះហើយជាស្ថាពរ បាន 100%
  - ការធ្វើជណ្ដើរហើយជាស្ថាពរ 100%
- បានសាងសង់អណ្ដូងស្នប់ចំនួន 02កន្លែង ប្រព័ន្ធចែកចាយទឹក 01កន្លែង នៅឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង៖
  - អណ្ដូងស្នប់បានសាងសង់រួចជាស្ថាពរ 100%
  - ប្រព័ន្ធចែកចាយទឹកកំពុងសាងសង់បាន 100%
- បានផ្ដល់សម្ភារសម្រាប់សាងសង់បង្គន់អនាម័យចំនួន 133បង្គន់ ជូនដល់ប្រជាពលរដ្ឋ នៅភូមិសាលាម្នាង ភូមិបឹងព្រាវ ភូមិជ្រោយ និងភូមិផ្លោង ឃុំបឹងព្រាវ និងប្រជាពលរដ្ឋ ភូមិឈើនាង ភូមិភ្នំស្រឡៅ និងភូមិសារ៉ាយ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ចំនួន 133គ្រួសារ
- បានចុះណែនាំ និងជំរុញដល់គ្រួសារដែលទទួលបានសម្ភារ សម្រាប់សាងសង់បង្គន់អនាម័យក្នុងផែនការឆ្នាំ2021 ឱ្យសាងសង់បានគ្រប់គ្រួសារ និងប្រកបដោយបច្ចេកទេស
- បានចុះប្រជុំផ្សព្វផ្សាយអប់រំពីអនាម័យតាមសហគមន៍ នៅភូមិចំនួន 14ភូមិ ក្នុងឃុំកណ្ដោលស្រុកបូទុមសាគរ ឃុំបឹងព្រាវ និងឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង សរុបអ្នកចូលរួម ចំនួន 425នាក់ ស្រី 281នាក់
- បានចុះផ្សព្វផ្សាយទម្រង់លក្ខន្តិកៈ និងទម្រង់បទបញ្ជាផ្ទៃក្នុងសហគមន៍ជនជាតិដើមភាគតិច (ជង) នៅភូមិព្រែកស្វាយ និងភូមិកោះ និងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង បានចំនួន 01លើក
- បានចុះផ្សព្វផ្សាយទម្រង់លក្ខន្តិកៈ និងទម្រង់បទបញ្ជាផ្ទៃក្នុងសហគមន៍ជនជាតិដើមភាគតិច (ជង) នៅភូមិជំនាប់ និងភូមិច្រកឫស្សី និងឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង បានចំនួន 01លើក
- ចុះស្រង់ទិន្នន័យបច្ចុប្បន្នភាពចំនួនជនជាតិដើមភាគតិច(ជង) នៅឃុំជំនាប់ និងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង ចំនួន 01លើក
- បានសហការជាមួយអង្គការវ៉ាថា អនុវត្តគម្រោងឥណទានខ្នាតតូចគាំទ្រសុខភាពសហគមន៍ ផ្ដល់ប្រាក់កម្ចីដល់ភូមិគោលដៅចំនួន 10ភូមិ និងប្រជាពលរដ្ឋខ្ចីចំនួន 168គ្រួសារ ស្ត្រី 146គ្រួសារ ចែកចេញជា 42ក្រុម សរុបទឹកប្រាក់ចំនួន 168,000,000រៀល (មួយរយហុកសិបប្រាំបីលានរៀលគត់) ក្នុងស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ ខេត្តកោះកុង ។

### ៣.១.៤. ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានចុះចែកសេចក្តីជូនដំណឹងស្តីពីការចុះត្រួតពិនិត្យដៃបាញ់ប្រេង ប្រចាំឆ្នាំ2021 ដល់ម្ចាស់ស្ថានីយប្រេងឥន្ធនៈទូទាំងខេត្ត បានចំនួន 36ស្ថានីយ
- បានចុះត្រួតពិនិត្យវាយតម្លៃ លើដំណើរការផលិតកម្មរបស់រោងចក្រ មីកាសាស្ល៍ត (ខេមបូឌា) ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុង ដើម្បីពិនិត្យលទ្ធភាពក្នុងការផ្តល់សុពលភាពថ្មី លើវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការរោងចក្រ។ ជាលទ្ធផលឃើញថា រោងចក្រអនុវត្តបានល្អ គោរពច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ព្រមទាំងមានការរៀបចំចាត់ចែងគ្រប់គ្រងការងារបានល្អលើដំណើរការផលិតកម្ម ដូច្នេះមន្ទីរ បានសម្រេចបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ
- បានចុះត្រួតពិនិត្យសិប្បកម្មផលិតស្រាចេក និងប្រេងស្លឹកគ្រៃ ដែលផលិតដោយសមាគមស្ត្រីផលិតស្រាបុរាណ ស្ថិតនៅភូមិកណ្តាល ឃុំតាទៃលើ ស្រុកថ្មបាំង ខេត្តកោះកុង និងបានយកគំរូផលិតផលទៅពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងរៀបចំឯកសារដើម្បីស្នើសុំច្បាប់បង្កើតសិប្បកម្ម
- បានចុះត្រួតពិនិត្យលើដំណើរការផលិតកម្មរបស់រោងចក្រស៊ូហ្វី អ៊ីនដាស់ស្ទ្រី កោះកុង ខូអិលធីឌី ដែលផលិតស្ករស នៅស្រុកស្រែអំបិល និងក្រុមហ៊ុនខេមកូ ម៉ូតូ ខមភើនី ស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសកោះកុង បានចំនួន 02លើក ដើម្បីស្រង់ទិន្នន័យ និងធ្វើបច្ចុប្បន្នភាពស្ថានភាពរោងចក្រ និងពិនិត្យមើលលើការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ជាលទ្ធផលពិនិត្យឃើញថា រោងចក្រនៅស្រុកស្រែអំបិល បានផ្អាកដំណើរការផលិតកម្មជាបណ្តោះអាសន្ន (ប៉ុន្តែនៅមានបុគ្គលិកប្រចាំការប្រចាំថ្ងៃ) ដោយសារមានទំនាស់ដីធ្លី ខ្វះវត្ថុធាតុដើម និងជំងឺកូវីដ-19 និងក្រុមហ៊ុននៅតំបន់សេដ្ឋកិច្ចពិសេសកោះកុង កំពុងដំណើរការផលិតកម្មជាធម្មតា
- បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេងឥន្ធនៈ បានចំនួន 10លើក នៅទូទាំង 7 ក្រុង/ស្រុក បានចំនួន 35 មូលដ្ឋាន ដែលមានដៃបាញ់ប្រេងសរុបចំនួន 257ដៃ។ ជាលទ្ធផល ឃើញថាដៃបាញ់ប្រេងទាំងអស់ ស្របតាមបទប្បញ្ញត្តិបច្ចេកទេស អាចអនុញ្ញាតឱ្យធ្វើអាជីវកម្មបាន
- បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញវេចខ្ចប់ បានចំនួន 02លើក នៅស្រុកស្រែអំបិល និងក្រុងខេមរភូមិន្ទ ចំនួន 03មូលដ្ឋាន មានចំនួន 08ផលិតផល ។ ជាលទ្ធផល អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស
- បានចុះត្រួតពិនិត្យស្ថានភាពជាក់ស្តែងប្រភពទឹកនៅស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ខេត្តកោះកុង។ ជាលទ្ធផលឃើញថា ប្រភពទឹកនៅស្រុកទាំងពីរ អាចផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់ជូនប្រជាពលរដ្ឋនៅរដូវប្រាំង
- បានចុះពិនិត្យទុយោមេនាំទឹកមានការឆ្លុះធ្លាយ ដោយសារភ្លើងឆេះព្រៃនៅលើផ្លូវជាតិលេខ48 ស្ថិតនៅភូមិបឹង-យុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ធ្វើឱ្យការផ្គត់ផ្គង់ទឹកស្អាត ក្នុងក្រុងខេមរភូមិន្ទ ត្រូវផ្អាករយៈពេលខ្លី ហើយបានចេញសេចក្តីជូនដំណឹងភ្លាមៗតាមរយៈគេហទំព័រ Facebook Page របស់មន្ទីរ និងរដ្ឋបាលខេត្តកោះកុង និងបានណែនាំក្រុមហ៊ុន L.Y.P GROUP Co.,Ltd កាយដីកប់ទុយោមេនាំទឹក ចៀសវាងមានភ្លើងឆេះព្រៃដោយយថាហេតុ
- បានចុះត្រួតពិនិត្យសហគ្រាសធុនតូច តារាសាគរទឹកកក ដែលផលិតទឹកកកដើម និងទឹកកកអនាម័យ នៅឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ដើម្បីពិនិត្យលទ្ធភាព លើការដំឡើងគ្រឿងចក្រ គ្រឿងម៉ាស៊ីន ឧបករណ៍ បរិក្ខារ ដំណើរការខ្សែសង្វាក់ផលិតកម្ម ដើម្បីវាយតម្លៃលើការចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការសហគ្រាស សិប្បកម្ម។ ជាលទ្ធផលឃើញថា សហគ្រាស បានអនុវត្តតាមលក្ខណៈបច្ចេកទេស បទប្បញ្ញត្តិ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម អាចផ្តល់វិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការសហគ្រាស សិប្បកម្មតាមនីតិវិធីច្បាប់

- បានចុះត្រួតពិនិត្យស្ថានភាពទំនប់ស្ទាក់ទឹកជម្មជាតិ នៅតំបន់ជ្រោះតាប៉ន របស់ក្រុមហ៊ុន L.Y.P Group Co.,Ltd។ ជាលទ្ធផល ទឹកដែលនៅសល់ក្នុងទំនប់មានកម្ពស់ 28m ស្មើនឹង100% និងបានផ្តល់បទសម្ភាសជូនបណ្តាញអ្នកសារព័ត៌មានប្រចាំខេត្តកោះកុង (ទូរទស្សន៍ BTV and CNC) នៅទីតាំងតំបន់ជ្រោះតាប៉ន ស្តីពី៖
  - វឌ្ឍនភាពទំនប់ទឹកជ្រោះតាប៉ន និងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត
  - ការគ្រប់គ្រងស្ថិតិរោងចក្រ សហគ្រាស និងសិប្បកម្ម និងការផ្តល់សេវាសាធារណៈការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ក្នុងខេត្តកោះកុង
  - នីតិវិធីការត្រួតពិនិត្យដៃបាញ់ប្រេងតាមស្ថានីយប្រេងឥន្ធនៈ
- បានចុះត្រួតពិនិត្យដំណើរការបច្ចេកទេសខ្សែសង្វាក់ផលិតកម្ម និងផលិតផល ដើម្បីវាយតម្លៃលើការស្នើសុំច្បាប់បង្កើតសហគ្រាស សិប្បកម្ម និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការថ្មី/បន្ត បានចំនួន 07មូលដ្ឋាន (បានចំនួន 03 លើក) រួមមាន៖
  - សិប្បកម្មកិនភ្លីស័ង្កសី ជា គីមងួន ស្ថិតនៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង (បន្ត)
  - សិប្បកម្មផលិតទឹកពិសាជបសាច់ដុំ ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង (បន្ត)
  - សិប្បកម្មជួសជុលគ្រឿងម៉ាស៊ីនអគ្គិសនី និងម៉ាស៊ីនត្រជាក់ ស្ថិតនៅស្រុកមណ្ឌលសីមា ខេត្តកោះកុង (បន្ត)
  - សិប្បកម្មផលិតទឹកពិសាជប ស្ថិតនៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង (ថ្មី)
  - សិប្បកម្មផលិតនំប៉ុងភីសា ហ្សាវីដា ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង(ថ្មី)
  - សិប្បកម្មផលិតទឹកពិសាជប ស្ថិតនៅភូមិជីខ ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង (ថ្មី)
  - សិប្បកម្ម ផលិតល្បាយបេតុង ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ (ថ្មី)

  ជាលទ្ធផលមន្ទីរ បានឯកភាពទៅលើពាក្យស្នើសុំបង្កើតសហគ្រាស/សិប្បកម្ម និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការថ្មី/បន្ត ជូនម្ចាស់សិប្បកម្ម
- បានយកសំណាកផលិតផល ទៅវិភាគគុណភាពនៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (រាជធានីភ្នំពេញ) បានចំនួន 11មូលដ្ឋាន រួមមាន៖
  - ទឹកពិសាជប បានចំនួន 08មូលដ្ឋាន ស្មើនឹង 08ប៉ាន់គំរូ (ប្រភពទឹក ទឹកច្រោះរួច និងទឹកពិសាជប)
  - ផលិតផលស្រ្កាប់(Scrub) បានចំនួន 02មូលដ្ឋាន ស្មើនឹង 04ប៉ាន់គំរូ (ស្រ្កាប់មុខ និងស្រ្កាប់ខ្លួន)
  - ចំណីអាហារ បានចំនួន 01មូលដ្ឋាន ស្មើនឹង 03ប៉ាន់គំរូ (មាន់ស្លែខៀវ សាច់ចង្កាក់ និងស៊ុបហឺរចិន 08 លំដាប់)

  ជាលទ្ធផលអនុលោមតាមគុណភាពស្តង់ដារដែលបានកំណត់
- បានសហការជាមួយសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្រ្កាបការក្លែងបន្លំខេត្តកោះកុង ចុះត្រួតពិនិត្យ បច្ចេកទេស និងណែនាំអំពីផលប៉ះពាល់នៃការពុលស្រាស ស្រាថ្នាំ នៅតាមសិប្បកម្មស្រាស បានចំនួន 04ទីតាំង ស្ថិតក្នុងក្រុងខេមរភូមិន្ទ និងបានយកគំរូស្រាស ចំនួន 04គំរូ បញ្ជូនទៅវិភាគនៅមន្ទីរពិសោធន៍នៃអគ្គនាយកដ្ឋាន ក.ប.ប. ជាលទ្ធផលគឺ ស្រាស មានគុណភាពល្អ
- បានសហការជាមួយរដ្ឋបាលស្រុកបូទុមសាគរ ដើម្បីប្រជុំពិភាក្សាលើការអនុវត្តន៍មុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម នៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ នៅសាលាស្រុកបូទុមសាគរ។ ជាលទ្ធផលគឺរដ្ឋបាលស្រុក បានចូលរួមសហការអនុវត្តការងារបានយ៉ាងរលូន ព្រមទាំងបន្តការផ្សព្វផ្សាយលើការស្នើសុំចុះបញ្ជីសហគ្រាស/សិប្បកម្ម សម្រាប់ឆ្នាំបន្តបន្ទាប់ទៀត
- បានជួយរៀបចំប្រព័ន្ធទឹកស្អាតក្នុងមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-19 កម្រិតស្រាលចំនួន 02ទីតាំង រួមមាន៖
  - មជ្ឈមណ្ឌលតារីតុកា បន្ទប់ទឹក ចំនួន 20បន្ទប់ និងបង្គន់អនាម័យ ចំនួន 08បង្គន់
  - មជ្ឈមណ្ឌលស៊ូននឹង បន្ទប់ទឹក ចំនួន 78បន្ទប់ និងបង្គន់អនាម័យ ចំនួន 06បង្គន់

- បានទំនាក់ទំនងទៅម្ចាស់ស្ថានីយប្រេងឥន្ធនៈក្នុងស្រុកគិរីសាគរ ស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកកោះកុង បានចំនួន 10មូលដ្ឋាន ដើម្បីឱ្យម្ចាស់ស្ថានីយរៀបចំឯកសារដាក់ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេងឡើងវិញសម្រាប់ឆ្នាំ2021 នៅអង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត
- បានទំនាក់ទំនង ទៅម្ចាស់សិប្បកម្មទឹកពិសារដបក្នុងក្រុងខេមរភូមិន្ទបានចំនួន 03មូលដ្ឋាន ដើម្បីឱ្យម្ចាស់សិប្បកម្មយកសំណាកទឹកពិសាដប ជូនមន្ទីរ ដើម្បីរៀបចំយកទៅវិភាគគុណភាពទឹកនៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ (រាជធានីភ្នំពេញ)
- បានទំនាក់ទំនងទៅម្ចាស់សិប្បកម្មដែលមានវិញ្ញាបនបត្រចាស់ផុតសុពលភាព ដើម្បីឱ្យមកដាក់ពាក្យស្នើសុំបន្តវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ បានចំនួន 03មូលដ្ឋាន គឺៈ
    - សិប្បកម្មទឹកពិសាដប ភិផាតនា (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្ម យូ សុង ផលិតទឹកកកអនាម័យ (ស្ថិតនៅស្រុកគិរីសាគរ)
    - សិប្បកម្ម ជីវតឹកហោ កិនភ្លីស័ង្កសី (ស្ថិតនៅស្រុកស្រែអំបិល)
- បានចេញប្រកាសស្តីពីការបង្កើតរោងចក្រ និងសិប្បកម្ម ដោយច្រកចេញចូលតែមួយក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចំនួន 02មូលដ្ឋាន គឺ ៖
    - សហគ្រាសធុនតូចផលិតទឹកពិសាដប ធីភី (TP) (ស្ថិតនៅស្រុកបូទុមសាគរ)
    - សហគ្រាសធុនតូច វិសាលលីហ្សព្រែកខ្សាច់ ផលិតទឹកកកអនាម័យ (ស្ថិតនៅស្រុកគិរីសាគរ)
- បានចេញសេចក្តីសម្រេចបង្កើតសហគ្រាស សិប្បកម្ម ដោយយន្តការច្រកចេញចូលតែមួយរបស់មន្ទីរ បានចំនួន 10មូលដ្ឋាន គឺ ៖
    - សហគ្រាស សិប្បកម្ម សមាគមស្ត្រីផលិតស្រាបុរាណ (ស្ថិតនៅស្រុកថ្មបាំង)
    - សហគ្រាសធុនតូច ជ្រោយស្វាយ (ស្ថិតនៅស្រុកស្រែអំបិល)
    - សិប្បកម្មផលិតទឹកពិសាដប ជេននី (ស្ថិតនៅស្រុកបូទុមសាគរ)
    - សិប្បកម្មផ្កាធម្មជាតិ ផលិតស្ក្រាប់មុខ-ខ្លួន (Scrub) (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្មផលិតទឹកពិសាដប ម៉េងឃៀង (ស្ថិតនៅស្រុកថ្មបាំង)
    - សិប្បកម្ម ហ្វូតពិជនិក (FOOD PICNIC) (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្ម សញ្ញាបក្សីទេពមយូរ៉ា (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សហគ្រាសធុនមធ្យមភីអិលអឹមអ៊ីមផងអិចផត (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្មនំប៉័ងលីណា (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្មផលិតនំប៉័ង ភីសា ហ្វារីដា (ស្ថិតនៅក្រុងខេមរភូមិន្ទ)
- បានចុះបញ្ជីសហគ្រាស សិប្បកម្មដោយការិយាល័យច្រកចេញចូលតែមួយក្រុងខេមរភូមិន្ទ ចំនួន 04មូលដ្ឋាន គឺៈ
    - សិប្បកម្ម លី គឹមលន ជួលជុលកង់ម៉ូតូ (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្ម គង់ សុភី ផ្សារដែកកញ្ចក់ (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្មជា សារិទ្ធ បោះពុម្ពម្ពាងសិលា (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្មជួសជុល និងដំឡើងកាមេរ៉ា (ស្ថិតនៅក្រុងខេមរភូមិន្ទ)
- បានចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ សហគ្រាស សិប្បកម្ម (ថ្មី) ដោយច្រកចេញចូលតែមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចំនួន 01មូលដ្ឋាន គឺសហគ្រាសធុនតូចផលិតទឹកពិសាដប ធីភី (TP) (ស្រុកបូទុមសាគរ)

- បានចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ សហគ្រាស សិប្បកម្ម (ថ្មី) ដោយយន្តការច្រកចេញចូលតែមួយរបស់មន្ទីរ បានចំនួន 09មូលដ្ឋាន គឺ ៖
    - សិប្បកម្មសមាគមស្ត្រីផលិតស្រាបុរាណ (ស្រាចេក) (ស្ថិតនៅស្រុកថ្មបាំង)
    - សហគ្រាសធុនតូច ទឹកកកតារាសាគរ (ស្ថិតនៅស្រុកបូទុមសាគរ)
    - សិប្បកម្មផលិតទឹកពិសាជប ជេននី (ស្ថិតនៅស្រុកបូទុមសាគរ)
    - សិប្បកម្មផ្កាធម្មជាតិ ផលិតស្រ្កាប់មុខ-ខ្លួន (Scrub) (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្មផលិតទឹកពិសាជប ម៉េងឃៀង (ស្ថិតនៅស្រុកថ្មបាំង)
    - សិប្បកម្ម សញ្ញាបក្សីទេពមយូរ៉ា (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សហគ្រាសធុនមធ្យមភីអិលអឹមអ៊ីម អីមផតអិចផត (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្មនំប៉័ងលីណា (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្មផលិតនំប៉័ង ភីសា ហ្វារីដា (ស្ថិតនៅក្រុងខេមរភូមិន្ទ)
- បានចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ (បន្ត) ដោយយន្តការច្រកចេញចូលតែមួយរបស់មន្ទីរ បានចំនួន 04 មូលដ្ឋាន គឺ៖
    - សិប្បកម្មផលិតទឹកកកដើម-ទឹកកកអនាម័យ ស៊ាង សំអឿន (ស្ថិតនៅស្រុកបូទុមសាគរ)
    - សិប្បកម្មផលិតទឹកកកអនាម័យ យូ សុង (ស្ថិតនៅស្រុកគិរីសាគរ)
    - សិប្បកម្មកិនភ្លីស័ង្កសី ជា គីមងួន (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្មផលិតផលិតទឹកពិសាជប សាច់ដុំ (ស្ថិតនៅស្រុកមណ្ឌលសីមា)
- បានចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ សហគ្រាស សិប្បកម្ម (បន្ត) ដោយអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត បានចំនួន 01មូលដ្ឋាន គឺសិប្បកម្មជួលជុលអគ្គិសនី និងម៉ាស៊ីនត្រជាក់ (ស្ថិតនៅស្រុកមណ្ឌល-សីមា)
- បានចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ (បន្ត) ដោយការិយាល័យច្រកចូលចេញតែមួយក្រុងខេមរភូមិន្ទ បានចំនួន 02មូលដ្ឋាន គឺ៖
    - សិប្បកម្មជួសជុលគ្រឿងអេឡិចត្រូនិក សុខ ស៊ីហៀក (ស្ថិតនៅក្រុងខេមរភូមិន្ទ)
    - សិប្បកម្ម សុភ័ក្តឆ្លាក់ត្រា កៃច្នៃអាលុយមីញ៉ូម ដែក កញ្ចក់ (ស្ថិតនៅក្រុងខេមរភូមិន្ទ)
- បានចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ (ថ្មី) ដោយការិយាល័យច្រកចូលចេញតែមួយស្រុកមណ្ឌលសីមា បានចំនួន 01មូលដ្ឋានគឺ សិប្បកម្ម លី ហ៊ុង ធ្វើទ្វារ បង្អួចដែក (ស្ថិតនៅស្រុកមណ្ឌលសីមា)។

**៣.១.៥. ការងាររ៉ែ និងថាមពល**

- បានចុះពិនិត្យអាជីវកម្មធនធានរ៉ែ ខ្សាច់សំណង់ ដីក្រហម និងអាចម៍ដី ដើម្បីកំណត់សួយសារ នៅស្រុកស្រែអំបិល ស្រុកបូទុមសាគរ ស្រុកថ្មបាំង ស្រុកកោះកុង និងស្រុកមណ្ឌលសីមា ចំនួន 04លើក ជាលទ្ធផល បងប្អូនអាជីវករបានបង់ចំណូលសួយសារ(ស្វ័យប្រកាស) ចូលថវិការដ្ឋតាមរយៈធនាគារអេស៊ីលីដា និងធនាគារកាណាឌីយ៉ា
- បានចូលរួមសហការជាមួយរដ្ឋបាលខេត្ត និងមន្ទីរ អង្គភាព ជំនាញពាក់ព័ន្ធចុះត្រួតពិនិត្យការស្នើសុំចាក់ដីរបស់ប្រជាពលរដ្ឋដែលមានទីតាំងនៅសង្កាត់ស្ទឹងវែង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ចំនួន 07លើក និងនៅភូមិពាមក្រសោប1 ឃុំពាមក្រសោប បានចំនួន 03លើក និងនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ចំនួន 03លើក

- បានសហការជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធចំនួន 15លើក ក្នុងការចុះត្រួតពិនិត្យលើករដឹកជញ្ជូនអាចម៍ដីស្ពារបាតអាងទឹកស្អាតរបស់ក្រុមហ៊ុនLYP Group ជ្រោះតាប៉ន ចៀសវាងផលប៉ះពាល់ផ្លូវថ្នល់ ដោយបានកំណត់ដល់ពួកគាត់ ចូលរួមថែរក្សាបរិស្ថាន និងសោភ័ណភាពក្នុងក្រុងខេមរភូមិន្ទ
- បានទទួលពាក្យស្នើសុំធ្វើអាជីវកម្ម និងបានផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ( ខ្សាច់ ) មានចំនួន 08ទីតាំង៖
  - លោក កក់ សុនសេង មានទីតាំងស្ថិតនៅដងព្រែកស្រែអំបិល ឃុំស្រែអំបិល ស្រុកស្រែអំបិល
  - លោកស្រី ហ៊ិន សាវ មានទីតាំងស្ថិតនៅដងព្រែកកោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - លោកស្រី ង៉ូវ សុខ មានទីតាំងស្ថិតនៅដងព្រែកកោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - លោកស្រី ខេម ដាលីយ៉ា មានទីតាំងស្ថិតនៅ ដងព្រែកកោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - លោកស្រី ប៊ីវ ង៉ាម មានទីតាំងស្ថិតនៅដងព្រែកកោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - លោក ទុន ស៊ីដេត មានទីតាំងស្ថិតនៅដងព្រែកកោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - លោក ម៉េង សុភ័ណ្ឌ មានទីតាំងស្ថិតនៅភូមិស្ពានក្តារ ឃុំតាទៃលើ ស្រុកថ្មបាំង
  - លោក សៀង សំណាង មានទីតាំងស្ថិតនៅព្រែកកំពង់ក្លួ ឃុំអណ្តូង ទឹកស្រុកបូទុមសាគរ
- បានទទួលពាក្យស្នើសុំធ្វើអាជីវកម្ម និងបានផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ( ដីក្រហម )មានចំនួន 02ទីតាំង៖
  - លោក វ៉ាន់ឆៃ ផៃវង្ស មានទីតាំងស្ថិតនៅឃុំត្រពាំងរូង ស្រុកកោះកុង
  - លោក ស្រី ទុយ អូន មានទីតាំងនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។
- ការអនុវត្តចំណូល

| យថាប្រភេទចំណូល | ចំណូល | | ផ្សេងៗ |
|---|---|---|---|
| | US $ | រៀល | |
| សួយសារធនធានរ៉ែ | 261,396.00 | 00 | |
| ប្រាក់អត្ថប្រយោជន៍បន្ថែម | 00 | 00 | |
| កម្រៃផ្តល់អាជ្ញាប័ណ្ណ | 00 | 00 | |
| កម្រៃចុះបញ្ជីអាជ្ញាប័ណ្ណ | 00 | 00 | |
| កម្រៃពិនិត្យរៀបចំឯកសារ | 00 | 00 | |
| កម្រៃឈ្នួលដី | 150.00 | 00 | |
| មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន | 42,445.60 | 00 | |
| មូលនិធិរ៉ែសម្រាប់ការគ្រប់គ្រង និងកសាងសមត្ថភាព | 24,956.80 | 00 | |
| ប្រាក់ពិន័យអន្តរការណ៍ | 23,994.61 | 2,500,000 | |
| **សរុប** | **352,943.01** | **2,500,000** | |

- បានចុះត្រួតពិនិត្យបច្ចេកទេសពង្រីកបណ្តាញអគ្គិសនី របស់សេវាករអគ្គិសនី ចំនួន 20លើក៖
  - សេវាករ លោកស្រី ឆេង ទូច មានទីតាំងនៅស្រុកថ្មបាំង បានចំនួន 04លើក
  - ក្រុមហ៊ុនអគ្គិសនី ហេង ហ្វេមីលី នៅស្រុកបូទុមសាគរ បានចំនួន 03លើក
  - សេវាករ លោក សំរិទ្ធ សុទ្ធី នៅស្រុកស្រែអំបិល បានចំនួន 03លើក
  - សេវាករ លោកស្រី អាន់ សំឡាន នៅស្រុកគិរីសាគរ 02លើក

- ស្នាក់ការអគ្គិសនីកោះកុង បានចំនួន 08លើក នៅស្រុកមណ្ឌលសីមា 04លើក និងក្រុងខេមរភូមិន្ទ បានចំនួន 04លើក ជាលទ្ធផល ក្រុមហ៊ុន និងសេវាករអគ្គិសនី បានអនុវត្តរៀបចំខ្សែបណ្តាញអគ្គិសនីតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវ

– បានពិនិត្យការដាំបង្គោលអគ្គិសនីរបស់ក្រុមហ៊ុនអគ្គិសនីកោះកុង បានចំនួន 02លើក នៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង និងបានចំនួន 02លើក នៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ តាមសំណូមពរ របស់ប្រជាពលរដ្ឋ ដែលបានលើកក្នុងវេទិកាសាធារណៈនៅក្រុងខេមរភូមិន្ទ ជាលទ្ធផល ក្រុមហ៊ុនអគ្គិសនីកោះកុង បានដាក់បង្គោល ខ្សែបណ្តាញភ្ជាប់ចរន្តអគ្គិសនីជូនរួចរាល់

– បានចុះពិនិត្យកែតម្រូវបច្ចេកទេសការដំឡើងទីតាំងត្រង់ស្វូរ ដែលមានកំលាំង 250KVA និងបង្គោលបណ្តាញអគ្គិសនីក្រុមហ៊ុនអិលវ៉ាយភី គ្រុប (LYP Group Co.,ltd) ស្ថិតនៅភូមិ2 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ជាលទ្ធផល ប្តូរត្រង់ស្វូរ និងបង្គោលបណ្តាញអគ្គិសនីថ្មី ដើម្បីផ្គត់ផ្គង់គ្រប់តម្រូវការប្រើប្រាស់

– បានសហការជាមួយអគ្គិសនីកម្ពុជា (EDC) ដោះស្រាយផលប៉ះពាល់បង្គោល និងខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ លើដីរបស់ប្រជាពលរដ្ឋនៅ ភូមិស្មាច់មានជ័យ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ និងភូមិនាងកុក ភូមិកោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា សរុបចំនួន 39គ្រួសារ ជាលទ្ធផល បានដោះស្រាយរួចរាល់ ចំនួន 34 គ្រួសារ

– បានចុះពិនិត្យបណ្តាញអគ្គិសនីរបស់ក្រុមហ៊ុនអគ្គិសនីកោះកុង ដែលធ្លាក់តង់ស្យុងមិនគ្រប់ 220វ៉ុល តាមការស្នើសុំរបស់ប្រជាពលរដ្ឋចំនួន 96គ្រួសារ នៅចំណុចដើមខ្លឹម ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ជាលទ្ធផល ក្រុមហ៊ុនអគ្គិសនីកោះកុង បានធ្វើការកែសម្រួលបច្ចេកទេសដំឡើងតង់ស្យុងគ្រប់ 220វ៉ុល។

– បានចុះពិនិត្យទីតាំងស្នើសុំភ្ជាប់បណ្តាញអគ្គិសនី របស់ប្រជាពលរដ្ឋ នៅភូមិ1 និងភូមិ2 ឃុំពាមក្រសោប ស្រុកមណ្ឌលសីមា ខេត្តកោះកុង ជាលទ្ធផល ក្រុមហ៊ុនអគ្គិសនីកោះកុង បានធ្វើរបាយការណ៍ និងគម្រោងរួចរាល់ជូនអគ្គនាយកក្រុមហ៊ុន(អ្នកឧកញ៉ា លី យ៉ុងផាត់)ដើម្បីពិនិត្យ និងសម្រេច

– បានទទួលពាក្យស្នើសុំលិខិតអនុញ្ញាតបន្តដំណើរការស្ថានីយប្រេងឥន្ធនៈចំនួន 04មូលដ្ឋាន បញ្ជូនទៅអគ្គនាយកដ្ឋានប្រេងកាតក្រសួងរ៉ែ និងថាមពល ដើម្បីពិនិត្យ និងសម្រេច៖
  - លោកស្រី ថុង ណាត់ស្យា នៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
  - លោកស្រី លឹម ហ៊ា នៅភូមិ2 សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
  - លោកស្រី ឱន ស៊ុនណារី នៅភូមិអូរជ្រៅ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង
  - លោកស្រី ផា សុចិន្តា នៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង

– ស្ថានភាពវឌ្ឍនភាព ថាមពលអគ្គិសនីទូទាំងខេត្ត៖
  - ក្រុមហ៊ុនផ្គត់ផ្គង់ និងចែកចាយអគ្គិសនី មានចំនួន 10ក្រុមហ៊ុន
  - បណ្តាញអគ្គិសនីចូលដល់ភូមិ 104ភូមិ/119ភូមិ ស្មើនឹង 87.39%
  - អគ្គិសនីប្រើប្រាស់ទូទាំងខេត្តប្រជាជនមានចំនួន 22,081ខ្នងផ្ទះ

– វារីអគ្គិសនី (ផលិតកម្មថាមពលក្នុងខេត្ត និងបន្ទុកនៃការប្រើប្រាស់អគ្គិសនី)៖
  - វារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា មានអនុភាព 338MW
  - វារីអគ្គិសនីស្ទឹងតាតៃ នៅឃុំឫស្សីជ្រុំ ស្រុកថ្មបាំង មានអនុភាព 246MW
  - វារីអគ្គិសនីគីរីរម្យ3 នៅឃុំដងពែង ស្រុកស្រែអំបិល មានអនុភាព 18MW
  - ក្រុមហ៊ុនអគ្គិសនីធ្យូងថ្ម (រ៉ូយ៉ាល់ គ្រុប ខូអិលជីឌី) មានអនុភាព 700MW កំពុងសាងសង់ មានទីតាំងភូមិថ្មស និងភូមិចម្លងគោ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង

- វិស័យប្រេងកាត
  - ស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ ទូទាំងខេត្តកោះកុង សរុបចំនួន 47ទីតាំង
  - អាជីវកម្មលក់ និងប្តូរប្រេងម៉ាស៊ីនទូទាំងខេត្តកោះកុង សរុបចំនួន 06ទីតាំង
  - អាជីវកម្មឧស្ម័នឥន្ធនៈ (ហ្គាស) ខ្នាតតូច ទូទាំងខេត្តកោះកុង សរុបចំនួន 12ទីតាំង

### ៣.១.៦. ការងារពាណិជ្ជកម្ម

- បានចេញលិខិតអនុញ្ញាតច្បាប់ប្រកបអាជីវកម្ម-សេវាកម្មសរុប និងលោហៈធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្កា សរុប 64មូលដ្ឋាន ក្នុងនោះ៖
  - ការិយាល័យច្រកចេញចូលតែមួយ ក្រុងខេមរភូមិន្ទ ចំនួន 31មូលដ្ឋាន
  - ការិយាល័យច្រកចេញចូលតែមួយ ស្រុកមណ្ឌលសីមា ចំនួន 10មូលដ្ឋាន
  - ការិយាល័យច្រកចេញចូលតែមួយ ស្រុកស្រែអំបិល ចំនួន 23មូលដ្ឋាន
- ក្រុមហ៊ុន/សហគ្រាសពាណិជ្ជកម្ម ចុះបញ្ជីសរុបចំនួន 39 ក្នុងនោះ៖
  - ក្រុមហ៊ុនបើកថ្មី ចំនួន 20
  - សហគ្រាសឯកបុគ្គលបើកថ្មី ចំនួន 19
- លិខិតគោលការណ៍ចុះបញ្ជីសរុបចំនួន 09 ក្នុងនោះ៖
  - សាខាក្រុមហ៊ុនបើកថ្មី ចំនួន 02
  - ប្តូរនាមករណ៍សាខាក្រុមហ៊ុន ចំនួន 04
  - ប្តូរនាយកសាខាក្រុមហ៊ុន ចំនួន 01
  - ប្តូរទីស្នាក់ការសាខាក្រុមហ៊ុន ចំនួន 02
- បានផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួល ការងារចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន-សហគ្រាស រួមមាន៖
  - ការងារចុះបញ្ជីពាណិជ្ជកម្មថ្មី សរុបចំនួន 04សហគ្រាស
    +ផ្ទះសំណាក់ វ៉ាយស៍មូន កោះកុង អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
    +តាតៃ ស្ពារ ឡែប៉ ឡូដ៍ អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ភូមិអន្លង់វ៉ាក ឃុំតាតៃក្រោម ស្រុកកោះកុង
    +ផ្ទះសំណាក់ កូឡា សុវណ្ណដុល្លា អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ភូមិអូរជ្រៅ ឃុំបឹងព្រាវ ស្រុកស្រែអំបិល
    +កោះស្នេហ៍ ឡុង ប៊ិច រីសត អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
  - ការងារបំពេញប្រតិវេទន៍ប្រចាំឆ្នាំ សរុបចំនួន 03ក្រុមហ៊ុន៖
    +ក្រុមហ៊ុន ឫទ្ធី ហ្គាប៉ែធម៉ិន ឯ.ក អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
    +ក្រុមហ៊ុន បៀរធិធា ឯ.ក អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ភូមិព្រៃក្រលាខាងកើត ឃុំទូកមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត
    +ក្រុមហ៊ុន PTSV CO., LTD. អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ភូមិ2 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
  - ការងារផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួលការចុះបញ្ជីពាណិជ្ជកម្មថ្មី ដល់អតិថិជនចំនួន 02រូប
- បានសហការជាមួយ សភាពាណិជ្ជកម្មខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រៀមរៀបចំផ្សារផលិតផលចុងសប្តាហ៍ខេត្តកោះកុង ដែលប្រព្រឹត្តទៅពីថ្ងៃទី25-26 ខែធ្នូ ឆ្នាំ2021 នៅមុខបរិវេណផ្សារកោះកុងថ្មី។ ផលិតផលដែលដាក់

តាំងបង្ហាញ ជាផលិតផលសក្តានុពលក្នុងខេត្ត រួមមាន៖ បង្គាក្រៀម កាពិ ទឹកត្រីបុកកោះកុង ទឹកឃ្មុំតំបន់ឆ្នេរ ទឹកខ្លឹមច័ន្ទក្រស្នា ស្រាចេក នំចាក បន្លែសុវត្ថិភាព មាន់ស្រែ ត្រី ផ្លែឈើ ។ល។

- បានតាមដានស្រង់តម្លៃទំនិញសំខាន់ៗទាំង 30មុខ ជារៀងរាល់ថ្ងៃ នៅក្នុងផ្សារដងទង់ ក្រុងខេមរភូមិន្ទ ផ្ញើជូនក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលខេត្ត
- បានធ្វើរបាយការណ៍ ស្តីពីសន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារ ចំនួន 119មុខ ផ្ញើជូននាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នៃក្រសួងពាណិជ្ជកម្ម
- បានតាមដានការផ្គត់ផ្គង់ និងតម្រូវការផលិតផលក្នុងស្រុកចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ (អង្ករ សាច់មាន់ សាច់ទា ស៊ុតមាន់ ស៊ុតទា សាច់គោ សាច់ជ្រូក ទឹកត្រី....) ដើម្បីធ្វើរបាយការណ៍ជូនអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស រៀងរាល់ថ្ងៃចន្ទ និងថ្ងៃព្រហស្បតិ៍
- បានតាមដានទិន្នន័យព័ត៌មានទីផ្សារសាច់មាន់ សាច់ទា និងស៊ុតមាន់ ស៊ុតទា ប្រចាំខែជូនអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម
- បានចុះចែកសេចក្តីជូនដំណឹងស្តីពីតម្លៃលក់រាយប្រេងឥន្ទនៈ ចំនួន 02លើក តាមស្ថានីយ និងដេប៉ូលក់រាយប្រេងឥន្ទនៈ សរុបចំនួន 20ស្ថានីយ/ដេប៉ូ ក្នុងនោះមាន៖
    - ក្រុងខេមរភូមិន្ទ ចំនួន 03ស្ថានីយ និង 05ដេប៉ូ
    - ស្រុកមណ្ឌលសីមា ចំនួន 02ដេប៉ូ
    - ស្រុកកោះកុងចំនួន 01ស្ថានីយ
    - ស្រុកបូទុមសាគរចំនួន 01ដេប៉ូ
    - ស្រុកស្រែអំបិលចំនួន 01ស្ថានីយ និង 07ដេប៉ូ
- បានតាមដានតម្លៃលក់រាយប្រេងឥន្ទនៈតាមស្ថានីយ និងដេប៉ូក្នុងក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា ជារៀងរាល់ថ្ងៃ ជាលទ្ធផល បានពិនិត្យឃើញថា អាជីវករមិនបានលក់លើសពីតម្លៃដែលក្រសួងបានកំណត់ឡើយ
- បានសហការជាមួយសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្រ្កាបការក្លែងបន្លំខេត្តចំនួន 21លើក៖
    - ចុះត្រួតពិនិត្យគុណភាព តម្លៃទំនិញសំខាន់ៗ និងសុវត្ថិភាពចំណីអាហារ ចំនួន 16លើក ក្នុងនោះ ៖
      +ក្រុងខេមរភូមិន្ទ ចំនួន 10 លើក
      +ស្រុកមណ្ឌលសីមា ចំនួន 06 លើក
    - ចុះត្រួតពិនិត្យ និងចែកខិតប័ណ្ណស្តីពីការយល់ដឹងពីករណីពុលស្រាស និងផលប៉ះពាល់សុខភាព ព្រមទាំងបានយកគំរូស្រា ស នៅតាមសិប្បកម្មស្រា ស ស្ថិតក្នុងក្រុងខេមរភូមិន្ទ ចំនួន 04ទីតាំង ដើម្បីយកទៅវិភាគនៅមន្ទីរពិសោធន៍ នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្រ្កាបការក្លែងបន្លំ ចំនួន 01លើក
    - ចុះយកសំណាកគំរូអាល់កុល នៅតាមហាងលក់ទំនិញ និងឱសថស្ថាន ក្នុងក្រុងខេមរភូមិន្ទ បានចំនួន 06គំរូ យកមកវិភាគនៅស្នាក់ការសាខា ក.ប.ប ខេត្ត។ ជាលទ្ធផលក្រុមការងារ បានរកឃើញ និងបានដកហូតអាល់កុលក្លែងក្លាយ (មេតាណុល) ចំនួន 54ដបតូច ស្មើនឹង 26លីត្រ និង 01កាន ស្មើនឹង 10 លីត្រ សរុបចំនួន 36លីត្រ យកមករក្សាទុកនៅស្នាក់ការសាខា ក.ប.ប ខេត្ត ដើម្បីកម្ទេចចោលតាមនីតិវិធីច្បាប់ ចំនួន 01លើក
    - ចុះត្រួតពិនិត្យ និងយកសំណាកគំរូអាល់កុល ចំនួន 07គំរូ យកមកវិភាគនៅទីស្នាក់ការសាខា ក.ប.ប ខេត្តតាមបណ្តាហាងលក់ទំនិញ និងឱសថស្ថានមួយចំនួនជុំវិញផ្សារដងទង់ក្នុងក្រុងខេមរភូមិន្ទ ចំនួន 01លើក

    ○ ចុះត្រួតពិនិត្យ បរិមាណ និងតម្លៃនៃការលក់រាយប្រេងឥន្ធនៈ ចំនួន 02លើក នៅតាមស្ថានីយ ដេប៉ូលក់រាយប្រេងឥន្ធនៈក្នុងស្រុកស្រែអំបិល ស្រុកបូទុមសាគរ ស្រុកកោះកុង ស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ
- បានតាមដានស្ថានភាពជួញដូរតាមច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម ប្រចាំសប្តាហ៍ ដើម្បីរាយការណ៍ជូនអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម។

**៣.១.៧. សាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត**

- បានចុះអង្កេត ត្រួតពិនិត្យ គុណភាព សុវត្ថិភាព ផលិតផលទំនិញដែលចរាចរលើទីផ្សារ និងតាមដានតម្លៃទំនិញសំខាន់ៗមួយចំនួនតាមបណ្តាក្រុង ស្រុកក្នុងខេត្តកោះកុង សរុបបានចំនួន 23ផ្សារ និងបានចុះត្រួតពិនិត្យបរិមាណ និងតម្លៃលក់រាយប្រេងឥន្ធនៈ តាមបណ្តាស្ថានីយ/ដេប៉ូ ទូទាំងខេត្តកោះកុង

  **លទ្ធផល៖**

    ○ បានធ្វើតេស្តបឋមលើសំណាកគំរូ ផលិតផលម្ហូបអាហារ បន្លែ ផ្លែឈើ និងគ្រឿងសមុទ្រ សរុបចំនួន 79គំរូ ពុំមានរកឃើញសារជាតុគីមីហាមឃាត់ក្នុងគំរូនោះឡើយ
    ○ បានរកឃើញសារជាតុគីមីហាមឃាត់(មេតាណុល)នៅក្នុងអាល់កុលលាងដៃសម្លាប់មេរោគ ចំនួន 03គំរូ នៃសំណាកអាល់កុលចំនួន 53គំរូ នៅតាមហាងលក់ទំនិញ និងឱសថស្ថាន ជុំវិញផ្សារដងទង់ ស្ថិតក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ មន្ត្រីជំនាញបានដកហូតអាល់កុលក្លែងក្លាយ(មេតាណុល)ចំនួន 576 លីត្រ និងបានធ្វើពិធីបំផ្លាញចោលនាថ្ងៃទី25 ខែឧសភា ឆ្នាំ2021 ដោយមានការចូលរួមពីលោកព្រះរាជអាជ្ញារង និងអង្គភាពពាក់ព័ន្ធ ស្របតាមនីតិវិធីច្បាប់រួចរាល់
    ○ បានដកហូតផលិតផលទំនិញចំរុះ ខូចគុណភាព និងហួសកាលបរិច្ឆេទប្រើប្រាស់ សរុបចំនួន 34.5 គីឡូក្រាម
    ○ បានពិន័យអន្តរការណ៍ក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ចំនួន 07ករណី (ស្ថានីយ/ដេប៉ូប្រេងឥន្ធនៈចំនួន 06ករណី និងហាងលក់ទំនិញ 01ករណី) ចូលថវិកាជាតិសរុបចំនួន 10,300,000រៀល (ដប់លាន បីរយពាន់ រៀលគត់)
    ○ បានចុះអង្កេតជាប្រចាំនូវតម្លៃតាមសេចក្តីជូនដំណឹងស្តីពីតម្លៃលក់រាយប្រេងឥន្ធនៈរបស់ក្រសួងពាណិជ្ជកម្ម តាមស្ថានីយ/ដេប៉ូចែកចាយទូទាំងខេត្តកោះកុង គឺលក់ត្រឹមត្រូវ តាមសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម ហើយស្ថានីយ/ដេប៉ូចែកចាយ មួយចំនួន ក៏បានលក់ក្នុងតម្លៃទាបជាងសេចក្តីជូនដំណឹងរបស់ក្រសួង ផងដែរ
    ○ បានផ្សព្វផ្សាយប្រកាសអន្តរក្រសួងលេខ 338 ស្តីពីនីតិវិធីពិន័យអន្តរការណ៍លើបទល្មើស នឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដល់អាជីវករលក់ដូរ និងម្ចាស់ស្ថានីយ/ដេប៉ូ សរុបចំនួន 73ច្បាប់
    ○ បានផ្សព្វផ្សាយខិតប័ណ្ណអប់រំស្តីពីផលប៉ះពាល់សុខភាពនៃសារជាតុអាបេស្តុស (ASBESTOS) ដល់អាជីវករលក់គ្រឿងសំណង់បានចំនួន 15ទីតាំង
    ○ បានចុះត្រួតពិនិត្យ និងណែនាំអំពីផលប៉ះពាល់នៃការពុលស្រាស ស្រាថ្នាំ នៅតាមសិប្បកម្មស្រាស បានចំនួន 04ទីតាំង ស្ថិតក្នុងក្រុងខេមរភូមិន្ទ និងបានយកគំរូស្រាស ចំនួន 04គំរូ បញ្ជូនទៅវិភាគនៅមន្ទីរពិសោធន៍នៃអគ្គនាយកដ្ឋាន ក.ប.ប. (លទ្ធផលគឺ ស្រាស មានគុណភាពល្អ) និងបានចែកខិតប័ណ្ណ "យល់ដឹងអំពីការពុលស្រាស ស្រាថ្នាំ និងផលប៉ះពាល់សុខភាព" បានចំនួន 70សន្លឹក
    ○ បានបិទផ្ទាំងរូបភាព(ដើម្បីសុខភាព)តាមតូបក្នុងផ្សារ និងចែកចាយជូនអាជីវករលក់ដូរ ចំនួន 190សន្លឹក។

### ៣.១.៨. ការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចំណូលថវិកាពីមន្ទីរជំនាញមានចំនួន 1,265,404,377 ៛
- ចំណាយថវិការបស់មន្ទីរជំនាញមានចំនួន 59,230,288,047 ៛
- ការប្រមូលចំណូលមិនមែនសារពើពន្ធមានចំនួន 403,868,750 ៛
- ចំណូលថវិកាពីក្រុង ស្រុក មានចំនួន 7,534,122,260 ៛
- ចំណាយថវិការបស់ក្រុង ស្រុក មានចំនួន 6,818,845,650 ៛។

### ៣.១.៩. ការងារគយ និងរដ្ឋាករ

- ចំណូលប្រមូលបានសរុបចំនួន 108,558,174,200រៀល ស្មើនឹង 94.98% នៃផែនការប្រចាំឆ្នាំ ប្រៀបធៀបនឹងឆ្នាំ2020 ចំនួន 135,609,010,345រៀល
- បានសហការជាមួយកម្លាំងជើងទឹកនៃនាយកដ្ឋានបង្ការ និងបង្រ្កាបបទល្មើស និងការិយាល័យគយ និងរដ្ឋាករចាំយាម ដើម្បីទប់ស្កាត់ទោចក្រយានយន្តនាំចូលល្មើសច្បាប់ពីប្រទេសថៃ
- បានសហការជាមួយកងកម្លាំងប្រដាប់អាវុធខេត្តកោះកុង ដើម្បីទប់ស្កាត់ទំនិញល្មើសនៅផ្លូវជាតិលេខ48 ចំណុចអណ្ដូងទឹក
- បានចេញបង្រ្កាបអំពើរត់គេចពន្ធទាំងនៅសាខា និងបណ្ដាការិយាល័យក្រោមឱវាទទទួលបានលទ្ធផល ចំនួន 2,907ករណី
- ទំនិញផ្សេងៗដែលបង្រ្កាបបានក្នុងឆ្នាំ2021 មាន៖
  - ទោចក្រយានយន្ត ចំនួន 1,079 គ្រឿង
  - រថយន្តចង្កូតស្តាំ ចំនួន 03គ្រឿង
  - OYSTER SAUCE (150ML ×24) ចំនួន 810គ.ក្រ
  - រ៉ឺម៉កសណ្ដោងម៉ូតូទឹកចំនួន 01គ្រឿង
  - Sweetened Flavoured Milk (48 × 125 ML) ចំនួន 900លីត្រ
  - Mackerel In Tomato Sauce ចំនួន 1,700គ.ក្រ។

### ៣.១.១០. ការងារពន្ធដារ

- បានប្រមូលពន្ធសរុប ដើម្បីបែងចែកទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចំនួន 13,688,640,284រៀល ស្មើនឹង 179.55% នៃផែនការប្រចាំឆ្នាំ ក្នុងនោះ៖
  - ចំណូលបង់ចូលថវិកាថ្នាក់ជាតិចំនួន 5,433,490,540រៀល ស្មើនឹង 121.01% នៃផែនការឆ្នាំ
  - ចំណូលបង់ចូលថវិកាថ្នាក់ក្រោមជាតិចំនួន 8,257,705,337រៀល ស្មើនឹង 263.41% នៃផែនការឆ្នាំ។

### ៣.១.១១. ការងារធនាគារ

- ចំណូលជាប្រាក់រៀលសរុបចំនួន 74,017,700,700រៀល បើប្រៀបធៀបទៅនឹងឆ្នាំមុនកើនឡើង 37.44%
- ចំណូលជាប្រាក់ដុល្លារសរុបចំនួន 71,711,249ដុល្លារ បើប្រៀបធៀបទៅនឹងឆ្នាំមុនកើនឡើង 21.70%
- ចំណាយជាប្រាក់រៀលសរុបចំនួន 126,613,873,500រៀល បើប្រៀបធៀបទៅនឹងឆ្នាំមុនកើនឡើង 19.58%
- ចំណាយជាប្រាក់ដុល្លារសរុបចំនួន 40,685,330ដុល្លារ បើប្រៀបធៀបទៅនឹងឆ្នាំមុនថយចុះ 34.32%។
- ប្តូរប្រាក់រៀល ចាស់ រហែក ទក់ សរុបចំនួន 16,029,500,000រៀល។
- អាជ្ញាប័ណ្ណមានសុពលភាពដើមគ្រាសរុបចំនួន 48ច្បាប់
- អាជ្ញាប័ណ្ណបន្តសុពលភាពចំនួន 44ច្បាប់
- អាជ្ញាប័ណ្ណអស់សុពលភាពចំនួន 48ច្បាប់
- អាជ្ញាប័ណ្ណមានសុពលភាពចុងគ្រាសរុបចំនួន 44ច្បាប់។

### ៣.១.១២. ការងាររតនាគារ

- ចំណូលសរុបមានចំនួន 284,834លានរៀល ក្នុងនោះ ចំណូលពីអគ្គនាយដ្ឋានរតនាគារជាតិចំនួន 146,836 លានរៀល និងចំណូលមូលដ្ឋានចំនួន 137,998លានរៀល
- ចំណាយសរុបមានចំនួន 284,275លានរៀល ក្នុងនោះ ចំណាយពីអគ្គនាយដ្ឋានរតនាគារជាតិចំនួន 136,910 លានរៀល និងចំណាយមូលដ្ឋានចំនួន 147,365លានរៀល។

### ៣.១.១៣. ការងារទេសចរណ៍

- អំពីស្ថិតិទេសចរមកកម្សាន្ត និងស្នាក់នៅក្នុងខេត្ត
  - ភ្ញៀវទេសចរជាតិស្នាក់នៅ និងតាមរមណីយដ្ឋាន 227,693នាក់ ថយចុះ 194,651នាក់ ស្មើនឹង 46% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ2020
  - ភ្ញៀវទេសចរអន្តរជាតិស្នាក់នៅ និងតាមរមណីយដ្ឋាន 1,554នាក់ ថយចុះ 36,196នាក់ ស្មើនឹង 95% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ2020
    - ➢ សរុបភ្ញៀវជាតិ-អន្តរជាតិ ចំនួន 229,247នាក់ ថយចុះ 230,847នាក់ ស្មើនឹង 50% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ2020
- អំពីស្ថិតិទេសចរមកកម្សាន្តតាមសហគមន៍
  - ភ្ញៀវទេសចរជាតិតាមសហគមន៍ 53,102នាក់ ថយចុះ 81,501នាក់ ស្មើនឹង 59%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ2020
  - ភ្ញៀវទេសចរអន្តរជាតិតាមសហគមន៍ 756នាក់ ថយចុះ 2,601នាក់ ស្មើនឹង 77% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ2020
    - ➢ សរុបភ្ញៀវជាតិ អន្តរជាតិតាមសហគមន៍ ចំនួន 53,858នាក់ ថយចុះ 84,102នាក់ ស្មើនឹង 61% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ2020
- បានចុះស្រង់ស្ថិតិអាជីវកម្ម សេវាកម្មទេសចរណ៍ទាំងអស់ទូទាំងខេត្តបានចំនួន 362កន្លែង ក្នុងនោះមាន៖
  - សណ្ឋាគារ ចំនួន 14កន្លែង (ស្មើនឹង 477បន្ទប់) កើនឡើង 02កន្លែង (ស្មើនឹង 37បន្ទប់)
  - ផ្ទះភ្ញៀវ ចំនួន 113កន្លែង (ស្មើនឹង 1,218បន្ទប់) កើនឡើង 01កន្លែង (ស្មើនឹង 25បន្ទប់)
  - ភោជនីយដ្ឋាន-អាហារដ្ឋាន ចំនួន 133កន្លែង (ស្មើនឹង 4,909កៅអី) ថយចុះ 12កន្លែង (ស្មើនឹង 422 កៅអី)
  - ក្លឹបកម្សាន្ត ចំនួន 01 (ស្មើនឹង 50កៅអី)
  - ខារ៉ាអូខេ ចំនួន 28កន្លែង (ស្មើនឹង 89បន្ទប់)
  - បៀហ្គាឌិន ចំនួន 05កន្លែង (ស្មើនឹង 250កៅអី)
  - ម៉ាស្សាសុខភាព ចំនួន 36កន្លែង (ស្មើនឹង 100គ្រែ)
  - ក្លឹបបុកប៊ីយ៉ែ ចំនួន 02កន្លែង (ស្មើនឹង 10តារាង)
  - សហគមន៍ទេសចរណ៍ ចំនួន 05កន្លែង
  - រមណីយដ្ឋានទេសចរណ៍ ចំនួន 03កន្លែង (ស្មើនឹង 107បន្ទប់) ថយចុះ 01កន្លែង (ស្មើនឹង 37បន្ទប់)
  - ហាងកាហ្វេ ចំនួន 16កន្លែង (ស្មើនឹង 245កៅអី)
  - ដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវទឹក ចំនួន 03កន្លែង (ស្មើនឹង 30កៅអី)
  - ដឹកជញ្ជូនភ្ញៀវទេសចរតាមផ្លូវគោក ចំនួន 02កន្លែង (ស្មើនឹង 08កៅអី)
  - កីឡាមុជទឹក ចំនួន 01កន្លែង

- ក្រៅពីអាជីវកម្ម សេវាកម្មទេសចរណ៍ខាងលើ ខេត្តកោះកុងក៏នៅមានតំបន់ទេសចរណ៍ជាច្រើនទៀត ដែលអាចឱ្យភ្ញៀវទេសចរជាតិ អន្តរជាតិទៅកម្សាន្តដូចជា៖ តំបន់កោះកុងក្រៅ តំបន់ប្រជុំកោះស្តេច ទឹកជ្រោះតំណាក់ក្បូន តំបន់វារីអេគ្គិសនី ទឹកធ្លាក់កោះប៉ោ តំបន់កសិទេសចរណ៍ស្រុកថ្មបាំង ឆ្នេរចម្លងគោ ជាដើម ។

– ក្នុងឆ្នាំ2021 ការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត ការិ-យាល័យ និងយន្តការច្រកចេញចូលតែមួយក្រុង ស្រុក បានបន្តអាជ្ញាប័ណ្ណដល់អាជីវកម្មសេវាកម្មទេសចរណ៍មានចំនួន 140កន្លែង ក្នុងនោះមាន៖

- រៀបចំឯកសារបន្តអាជ្ញាប័ណ្ណទេសចរណ៍ជូនក្រសួងទេសចរណ៍
  +សណ្ឋាគារ មានចំនួន 05 កន្លែង
- អង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត
  +សណ្ឋាគារ មានចំនួន 08 កន្លែង
  +ផ្ទះសំណាក់ មានចំនួន 35 កន្លែង
  +ម៉ាស្សា មានចំនួន 02 កន្លែង
  +ដឹកជញ្ជូនផ្លូវទឹក មានចំនួន 01 កន្លែង
  +ខារ៉ាអូខេ មានចំនួន 04 កន្លែង
  +បៀរហ្គាឌិន មានចំនួន 03 កន្លែង
  +ភោជនីយដ្ឋាន អាហារដ្ឋាន មានចំនួន 10 កន្លែង
  +ប្តូរឈ្មោះអាជីវកម្ម មានចំនួន 02 កន្លែង
- ការិយាល័យច្រកចេញចូលតែមួយក្រុងខេមរភូមិន្ទ
  +ផ្ទះសំណាក់ មានចំនួន 01 កន្លែង
  +ភោជនីយដ្ឋាន-អាហារដ្ឋានទេសចរណ៍ មានចំនួន 03 កន្លែង
  +ភោជនីយដ្ឋាន-អាហារដ្ឋានក្នុងស្រុក មានចំនួន 05 កន្លែង
  +ម៉ាស្សា មានចំនួន 09 កន្លែង
  +ផ្ទះជួលបន្ទប់ស្នាក់នៅមានចំនួន 07 កន្លែង
  +ហាងលក់គុយទាវ កាហ្វេ មានចំនួន 01កន្លែង
  +ស្នូកឃ័រ មានចំនួន 02 កន្លែង
  +តូបអាហារ មានចំនួន 01 កន្លែង
  +ខារ៉ាអូខេ មានចំនួន 01 កន្លែង
- ការិយាល័យច្រកចេញចូលតែមួយស្រុកស្រែអំបិល
  +ភោជនីយដ្ឋាន អាហារដ្ឋាន មានចំនួន 09 កន្លែង
  +ផ្ទះជួលបន្ទប់ស្នាក់នៅមានចំនួន 04 កន្លែង
  +ផ្ទះសំណាក់ មានចំនួន 02 កន្លែង
  +ភោជនីយដ្ឋាន-អាហារដ្ឋានក្នុងស្រុក មានចំនួន 01 កន្លែង
  +ស្នូកឃ័រ មានចំនួន 01 កន្លែង
- ការិយាល័យច្រកចេញចូលតែមួយស្រុកមណ្ឌលសីមា
  +ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ មានចំនួន 12 កន្លែង
  +ម៉ាស្សា មានចំនួន 01 កន្លែង

+ផ្ទះជួលបន្ទប់ស្នាក់នៅ មានចំនួន 01 កន្លែង
+ផ្ទះសំណាក់ មានចំនួន 04 កន្លែង

- យន្តការច្រកចេញចូលតែមួយស្រុកបូទុមសាគរ

+ផ្ទះសំណាក់ មានចំនួន 04 កន្លែង
+ផ្ទះជួលបន្ទប់ស្នាក់នៅ មានចំនួន 01 កន្លែង

- បានសហការជាមួយអង្គភាពសម្របសម្រួលគម្រោងក្រសួងទេសចរណ៍ (PCU) បើកវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំផ្សព្វផ្សាយ បានចំនួន 02លើក ដែលមានសិក្ខាកាមចូលរួមសរុបចំនួន 88នាក់ ស្រី 54នាក់
- បានចូលរួមសហការជាមួយរដ្ឋបាលក្រុងខេមរភូមិន្ទ ចុះណែនាំដល់ប្រជាពលរដ្ឋនៅសង្កាត់ស្ទឹងវែង និងសង្កាត់ដងទង់ អំពីការថែរក្សាអនាម័យបរិស្ថាន ការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ចៀសវាង បោះសំរាមពាសវាលពាសកាល ជាពិសេសបោះចូលក្នុងព្រែក
- បានសហការជាមួយរដ្ឋបាលក្រុងខេមរភូមិន្ទ ចុះត្រួតពិនិត្យលើការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ នៅតាមបណ្តាអាជីវកម្មទេសចរណ៍ក្នុងក្រុងខេមរភូមិន្ទ បានចំនួន 24ទីតាំង ក្នុងនោះមាន៖
    - សណ្ឋាគារ 01 ទីតាំង ទទួលបានឡាបិល 01ទីតាំង
    - ផ្ទះភ្ញៀវ 16 ទីតាំង ទទួលបានឡាបិល 15ទីតាំង
    - ភោជនីយដ្ឋាន អាហារដ្ឋាន 07 ទីតាំង ទទួលបានឡាបិល 06ទីតាំង
- បានសហការជាមួយរដ្ឋបាលក្រុងខេមរភូមិន្ទ ចុះពង្រឹងវិធាន ការបិទផ្អាកអាជីវកម្មKTV ក្លឹបកំសាន្ត (ខារ៉ាអូខេ វង្គសាល ឌីស្កូតែក និងបៀហ្គាឌិន) និងការត្រួតពិនិត្យឱ្យបានម៉ឺងមាត់ជាប់ជាប្រចាំ តាមសេចក្តីជូនដំណឹង លេខ 069 សជណ.អគឱ របស់ក្រសួងទេសចរណ៍ ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-19 ពិសេសព្រឹត្តិការណ៍សហគមន៍ 20កុម្ភៈ ឆ្នាំ2021
- បានចុះផ្សព្វផ្សាយវិធានការការពារជំងឺកូវីដ-19 និងលិខិតនានារបស់រដ្ឋបាលខេត្ត ពាក់ព័ន្ធនឹងបញ្ហាជំងឺកូវីដ-19 នៅក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា ចំនួន 05លើក
- បានចុះធ្វើបច្ចុប្បន្នភាពត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍លើសេវាកម្មស្នាក់នៅ និងភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ក្នុងក្រុងខេមរភូមិន្ទ បានចំនួន 10ទីតាំងអាជីវកម្ម
- បានចុះវាយតម្លៃលើ "វិធានសុវត្ថិភាពប្រតិបត្តិស្តង់ដារអប្បបរមា (SOP) តាមគន្លងប្រក្រតីភាពថ្មី" សម្រាប់សណ្ឋាគារ ផ្ទះសំណាក់ ក្នុងក្រុងខេមរភូមិន្ទ បានចំនួន 04ទីតាំង មានដូចជា៖
    - សណ្ឋាគារ តាថាំង
    - សណ្ឋាគារ កោះកុងស៊ីធី
    - សណ្ឋាគារ អាស៊ាន
    - សណ្ឋាគារ ថាន់ តាយ។

### ៣.១.១៤. ការងារផែនការ

- បានសម្របសម្រួលរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កម្មវិធីវិនិយោគ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ទិន្នន័យមូលដ្ឋាន កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមដានត្រួតពិនិត្យវាយតម្លៃអាហារូបត្ថម្ភ កិច្ចសហប្រតិបត្តិការ ស្ថិតិ ការងារពាក់ព័ន្ធនិងប្រជាជន និងការអភិវឌ្ឍ
- បានអនុវត្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រជុំទី14 និងតាមការស្នើសុំ សរុបចំនួន 8,782គ្រួសារ ក្នុងនោះ៖ ក្រ1 ចំនួន 3,317គ្រួសារ និង ក្រ2 ចំនួន 5,465គ្រួសារ
    - ប្រជុំជន សរុបចំនួន 426គ្រួសារ , ក្រ1 ចំនួន 235គ្រួសារ , ក្រ2 ចំនួន 191គ្រួសារ

- ជនបទ សរុបចំនួន 7,354គ្រួសារ , ក្រ1 ចំនួន 2,502គ្រួសារ , ក្រ2 ចំនួន 4,852គ្រួសារ
- តាមការស្នើសុំ (OD ID-Poor) សរុបចំនួន 1,002គ្រួសារ , ក្រ1 ចំនួន 580 គ្រួសារ , ក្រ2 ចំនួន 422គ្រួសារ

- បានចុះតាមដានការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមការស្នើសុំ តាមបណ្តាឃុំ-សង្កាត់ចំនួន04 មាន៖ ឃុំជីខក្រោម ក្នុងស្រុកស្រែអំបិល ឃុំកណ្តោល ឃុំអណ្តូងទឹក ក្នុងស្រុកបូទុមសាគរ និងសង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ជាមួយមេឃុំ ចៅសង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់ទាំងអស់ និងអ្នកកាន់តាប្លេត (Tablet) ដើម្បីសាកល្បង OD-IDPoor App តាមដានត្រួតពិនិត្យថ្មី និងប្រមូលជាតុចូលសម្រាប់កែលម្អនីតិវិធីថ្មី សម្រាប់ឆ្នាំ2022
- ការចុះបញ្ជីអង្គភាពសេដ្ឋកិច្ច និងគូសផែនទីមណ្ឌលជំរឿនសហគ្រាស ឆ្នាំ2021 បានអនុវត្តទូទាំងខេត្ត ចំនួន 119ភូមិ និងភូមិឧបសម្ព័ន្ធចំនួន 01 ស្មើនឹង 7,536សហគ្រាស
- ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ2021 បានអនុវត្តទូទាំងខេត្ត ចំនួន 26ភូមិ ស្មើនឹង 780គ្រួសារ
- ការអង្កេតកសិកម្មកម្ពុជា ឆ្នាំ2021 បានអនុវត្តទូទាំងខេត្ត ចំនួន 25ភូមិ ស្មើនឹង 1,436គ្រួសារ
- ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ2021 បានអនុវត្តចំនួន 05ក្រុង/ស្រុក រួមមាន៖ ស្រុកបូទុមសាគរ ស្រុកគិរីសាគរ ស្រុកស្រែអំបិល ស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ មាន 17ភូមិ ស្មើនឹង 510គ្រួសារ
- បានសម្ភាសតាមរយៈទូរស័ព្ទសមាជិកគ្រួសារដែលមានជំងឺកូវីដ-19 និងសមាជិកគ្រួសារដែលស្លាប់ដោយសារជំងឺកូវីដ-19 បានចំនួន 124គ្រួសារ
- បានទទួលសៀវភៅទិន្នន័យមូលដ្ឋានភូមិ ឃុំ-សង្កាត់ ក្រុង-ស្រុក បានចំនួន 07ក្រុង-ស្រុក 26ឃុំ និង 03 សង្កាត់ ស្មើនឹង 119ភូមិ
- បានបញ្ចូលទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យឃុំ សង្កាត់ CDB8 (UPDATE 2021) បានចំនួន 07ក្រុង-ស្រុក 26ឃុំ និង 03សង្កាត់ ស្មើនឹង 119ភូមិ
- បានផលិតឯកសារស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ2021 របស់ខេត្ត រួចរាល់ និងបានបោះពុម្ពជាសៀវភៅបាន ចំនួន 50ក្បាល
- បានផលិតឯកសារពិន្ទុវិស័យថ្នាក់ខេត្ត និងបានបោះពុម្ពជាសៀវភៅបានចំនួន 50ក្បាល។

### ៣.១.១៥. ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

- បានបញ្ជូនបញ្ញើក្នុង និងក្រៅប្រទេសសរុបចំនួន 225បញ្ញើ ស្មើនឹង 336.61គ.ក្រ
- បានទទួលបញ្ញើក្នុង និងក្រៅប្រទេសបានចំនួន 600បញ្ញើ ស្មើនឹង 886.18 គ.ក្រ
- បានតាមដានត្រួតពិនិត្យសារជាតុញៀនតាមបញ្ញើប្រៃសណីយ៍របស់សាខាប្រៃសណីយ៍កម្ពុជាខេត្តកោះកុង ជាប្រចាំ (គ្មានអ្វីគួរឱ្យសង្ស័យថាមានបង្កប់ទៅដោយសារជាតុញៀនទេ)
- បានចុះត្រួតពិនិត្យ និងជូនដំណឹងឱ្យសាខាក្រុមហ៊ុនក្នុងខេត្ត មកសុំលិខិតអនុញ្ញាតបន្តអាជីវកម្មបើក សេវាកម្មបញ្ញើឆាប់រហ័សក្នុងខេត្ត និងចែកប្រកាសរួមលេខ 498 សហវ.ប្រក ចុះថ្ងៃទី08 ខែឧសភា ឆ្នាំ2018 របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន 02ក្រុមហ៊ុន គឺ សាខាក្រុមហ៊ុន Best Express និងសាខាក្រុមហ៊ុន Soriya Express នៅភូមិ2 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
- បានចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ 15 ប.ទ សជណ ចុះថ្ងៃទី10 ខែមីនា ឆ្នាំ2021 ស្តីពីការបញ្ឈប់ ការធ្វើអាជីវកម្មលើវិស័យប្រៃសណីយ៍គ្មានអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតជូនសាខាអាជីវកម្មចំនួន 05ទីតាំង (សាខា Vireak Buntham ,J&T Kerry, Soriya, Best)
- បានចុះត្រួតពិនិត្យទីតាំងសេវាបញ្ញើឆាប់រហ័សក្នុងខេត្តបានចំនួន 05លើក ៖
    - លើកទី1៖ ក្នុងខែមេសា ឆ្នាំ2021 បានចុះពិនិត្យទីតាំងសេវាបញ្ញើឆាប់រហ័សក្នុងខេត្តចំនួន 03ទីតាំង គឺ (1)សាខាក្រុមហ៊ុន Best Express (2)សាខាក្រុមហ៊ុន Soriya Express នៅភូមិ2 សង្កាត់ស្មាច់មានជ័យ

ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ជាលទ្ធផលសាខាក្រុមហ៊ុនទាំង2 គ្មានលិខិតអនុញ្ញាត និងឈប់ដំណើរការ និង (3)សាខាក្រុមហ៊ុនវីរៈប៊ុនថាំ ក្នុងឃុំកោះស្ដេច ស្រុកគិរីសាគរ ខេត្តកោះកុង ជាលទ្ធផល ពុំមានលិខិតអនុញ្ញាត មន្ត្រីជំនាញបានឱ្យមកបំពេញបែបបទស្នើសុំលិខិតអនុញ្ញាតបើកសេវាប្រៃសណីយ៍ពីមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត

- លើកទី2៖ ក្នុងខែឧសភា ឆ្នាំ2021 បានចុះពិនិត្យទីតាំងសេវាបញ្ញើឆាប់រហ័សក្នុងខេត្តចំនួន 03ទីតាំង គឺ (1) សាខាក្រុមហ៊ុន Best Express (2)សាខាក្រុមហ៊ុន Soriya Express ស្ថិតនៅភូមិ2 សង្កាត់ស្មាច់-មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង បានបិទទ្វារ មិនទាន់ដំណើរការឡើងវិញ និង(3)សាខាក្រុមហ៊ុន Kerry Express ស្ថិតក្នុងភូមិ1 សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង បានផ្ដល់ព័ត៌មាន និងជូនឯកសារពាក្យស្នើសុំលិខិតអនុញ្ញាត បន្តអាជីវកម្ម នៅដើមខែមិថុនា ឆ្នាំ2021
- លើកទី3៖ ក្នុងខែមិថុនា ឆ្នាំ2021 បានចុះត្រួតពិនិត្យទីតាំងសេវាបញ្ញើឆាប់រហ័សក្នុងខេត្តចំនួន 02ទីតាំង គឺ (1)សាខាក្រុមហ៊ុន Vireak Buntham Express នៅច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង មិនទាន់មានលិខិតអនុញ្ញាតសុំបើកបញ្ញើប្រៃសណីយ៍ មន្ត្រីជំនាញបានណែនាំឱ្យមកសុំលិខិតអនុញ្ញាតពីប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត និង (2)សាខាក្រុមហ៊ុន Kerry Express ស្ថិតនៅភូមិ1 សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង បានសុំលិខិតអនុញ្ញាតបន្តអាជីវកម្មបញ្ញើសេវាប្រៃសណីយ៍សម្រាប់ឆ្នាំ2021 ពីមន្ទីរប្រៃសណីយ៍ និងទូរគមនា-គមន៍ខេត្តរួចហើយ
- លើកទី4៖ ក្នុងខែកក្កដា - កញ្ញា ឆ្នាំ2021 បានចុះត្រួតពិនិត្យទីតាំងសេវាបញ្ញើឆាប់រហ័សក្នុងខេត្តចំនួន 03ទីតាំង គឺ (1)សាខាក្រុមហ៊ុនកាពីតូល ស្ថិតនៅភូមិ2 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ទើបលើកស្លាកយីហោ លក់សំបុត្រឡានក្រុង និងសេវាកម្មបញ្ញើឆាប់រហ័ស តែមិនទាន់ដំណើរការ និងគ្មានបុគ្គលិក (2)សាខាក្រុមហ៊ុន Selfie Exprees បើកធ្វើអាជីវកម្មបញ្ញើឆាប់រហ័ស នៅភូមិ2 សង្កាត់ស្មាច់មានជ័យ និង (3)សាខាក្រុមហ៊ុន Selfie Exprees នៅភូមិ4 សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មន្ត្រីជំនាញបានណែនាំឱ្យទៅសុំអាជ្ញាប័ណ្ណនៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងសុំលិខិតអនុញ្ញាតប្រចាំឆ្នាំពីមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តទើបអាចបើកបម្រើសេវាកម្មបញ្ញើប្រៃសណីយ៍បាន
- លើកទី5៖ ក្នុងខែតុលា - ធ្នូ ឆ្នាំ2021 បានចុះត្រួតពិនិត្យទីតាំងសេវាបញ្ញើឆាប់រហ័សក្នុងខេត្តចំនួន 02 ទីតាំង គឺ (1)សាខាក្រុមហ៊ុន CE Exprees និង (2)ក្រុមហ៊ុន JET"S Express បើកធ្វើអាជីវកម្មបញ្ញើឆាប់រហ័ស នៅភូមិ3 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដែលពុំមានលិខិតអនុញ្ញាត មន្ត្រីជំនាញ បានណែនាំឱ្យមកធ្វើលិខិតអនុញ្ញាតនៅមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត

- បានចេញលិខិតអនុញ្ញាតបើកអាជីវកម្មសាលបម្រើអ៊ិនធឺណែតកាហ្វេជូនអតិថិជន ចំនួន 03កន្លែង
- បានចេញលិខិតអនុញ្ញាតបើកហាងលក់ទូរស័ព្ទដៃចំនួន 26គ្រឿង
- បានចេញលិខិតអនុញ្ញាតប្រើប្រាស់ហ្វ្រេកង់វិទ្យុទាក់ទង ICOM ចំនួន 27គ្រឿង
- បានចុះត្រួតពិនិត្យ និងចែកលិខិតលេខ 291 ប.ទ ខកក របស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត និងលិខិតលេខ 110 របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ស្ដីពីចំណាត់ការលើអាជីវករដែលលក់ និងចែកចាយស៊ីមកាតគ្រប់ប្រព័ន្ធដោយមិនទទួលយកឯកសារសម្គាល់ឬអត្តសញ្ញាណប័ណ្ណ ជូនអាជីវករក្នុងខេត្ត បានចំនួន 39ទីតាំង

- បានចុះពិនិត្យ និងណែនាំការអូសខ្សែកាប្លិ៍អុបទិច ឱ្យបំពាក់លើបង្គោលឱ្យបានត្រឹមត្រូវរបស់ប្រតិបត្តិករទូរស័ព្ទ បានចំនួន 03លើក
- បានចុះពិនិត្យខ្សែកាប្លិ៍អូសឆ្លងកាត់ច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម (កាស៊ីណូកោះកុង) តែពុំមានស្លាកសម្គាល់ មានចំនួន 04ខ្សែ
- បានចុះស្រង់ស្ថិតិទីតាំងបង្គោលអង់តែន និងវិទ្យុម៉ៃក្រូវ៉េវ កំណត់និយាមកា បានចំនួន 47បង្គោល មានម៉ៃក្រូវ៉េវ ចំនួន 86គ្រឿង
- បានចុះត្រួតពិនិត្យបង្គោលអង់តែន របស់ក្រុមហ៊ុនទូរស័ព្ទ ដែលបានសាងសង់រួចនៅក្នុងគម្រោង (USO) នៅក្នុងខេត្ត មានចំនួន 10បង្គោល និងម៉ៃក្រូវ៉េវ ចំនួន 17គ្រឿង
- បានចុះស្រង់ព័ត៌មានកំណត់ទីតាំងនិយាមកា របស់ស្ថាប័នរដ្ឋ និងឯកជន ក្នុងខេត្តកោះកុង សរុបបានចំនួន 181 ទីតាំង ក្នុងនោះ៖
    - ស្រុកបូទុមសាគរ ចំនួន 25ទីតាំង
    - ស្រុកគិរីសាគរ ចំនួន 17ទីតាំង
    - ស្រុកកោះកុង ចំនួន 24ទីតាំង
    - ក្រុងខេមរភូមិន្ទ ចំនួន 27ទីតាំង
    - ស្រុកមណ្ឌលសីមា ចំនួន 23ទីតាំង
    - ស្រុកស្រែអំបិល ចំនួន 32ទីតាំង
    - ស្រុកថ្មបាំង ចំនួន 33ទីតាំង ។

**៣.១.១៦. ការងារមុខងារសាធារណៈ**

- គិតត្រឹមថ្ងៃទី22 ខែធ្នូ ឆ្នាំ2021 តាមតារាងទូទាត់បៀវត្សប្រចាំខែធ្នូ មន្ត្រីរាជការស៊ីវិលនៅខេត្តកោះកុង មានចំនួន 2,640នាក់ ស្រី 941នាក់ ដូចខាងក្រោម៖
    - ចំនួនរាយតាមប្រភេទក្របខ័ណ្ឌ៖

| | | | | |
|---|---|---|---|---|
| + ក្របខ័ណ្ឌប្រភេទ "ក" | ចំនួន | 593 | នាក់ | (ស្ត្រី 141 នាក់) |
| + ក្របខ័ណ្ឌប្រភេទ "ខ" | ចំនួន | 1,002 | នាក់ | (ស្ត្រី 342 នាក់) |
| + ក្របខ័ណ្ឌប្រភេទ "គ" | ចំនួន | 1,045 | នាក់ | (ស្ត្រី 458 នាក់) |

    - ចំនួនមន្ត្រីរាជការរាយតាមមុខតំណែង៖

| | | | | |
|---|---|---|---|---|
| + អភិបាលខេត្ត | ចំនួន | 01 | នាក់ | (ស្ត្រី 01 នាក់) |
| + អភិបាលរងខេត្ត | ចំនួន | 06 | នាក់ | (ស្ត្រី 00 នាក់) |
| + នាយករដ្ឋបាល | ចំនួន | 01 | នាក់ | (ស្ត្រី 00 នាក់) |
| + នាយករងរដ្ឋបាល | ចំនួន | 03 | នាក់ | (ស្ត្រី 01 នាក់ ) |
| + អភិបាលក្រុង/ស្រុក | ចំនួន | 07 | នាក់ | (ស្ត្រី 00 នាក់) |
| + អភិបាលរងក្រុង/ស្រុក | ចំនួន | 26 | នាក់ | (ស្ត្រី 08 នាក់) |
| + ប្រធានមន្ទីរ | ចំនួន | 23 | នាក់ | (ស្ត្រី 02 នាក់) |
| + អនុប្រធានមន្ទីរ | ចំនួន | 55 | នាក់ | (ស្ត្រី 15 នាក់) |
| + ប្រធានសាលាដំបូង | ចំនួន | 01 | នាក់ | (ស្ត្រី 00 នាក់) |
| + អនុប្រធានសាលាដំបូង | ចំនួន | 01 | នាក់ | (ស្ត្រី 00 នាក់) |
| + ចៅក្រម | ចំនួន | 05 | នាក់ | (ស្ត្រី 01 នាក់) |

+ ព្រះរាជអាជ្ញា ចំនួន 01 នាក់ (ស្ត្រី 00 នាក់)
+ ព្រះរាជអាជ្ញារង ចំនួន 02 នាក់ (ស្ត្រី 00 នាក់)
+ ក្រឡាបញ្ជី ចំនួន 09 នាក់ (ស្ត្រី 02 នាក់)
+ ប្រធានលេខាធិការដ្ឋាន ចំនួន 01 នាក់ (ស្ត្រី 00 នាក់)
+ អនុប្រធានលេខាធិការដ្ឋាន ចំនួន 02 នាក់ (ស្ត្រី 00 នាក់)
+ នាយកទីចាត់ការ/ប្រធានអង្គភាព/ផ្នែក ចំនួន 09 នាក់ (ស្ត្រី 00 នាក់)
+ នាយករងទីចាត់ការ/អនុប្រធានអង្គភាព/ផ្នែក ចំនួន 18 នាក់ (ស្ត្រី 02 នាក់)
+ ប្រធានការិយាល័យ ចំនួន 122 នាក់ (ស្ត្រី 26 នាក់)
+ អនុប្រធានការិយាល័យ ចំនួន 152 នាក់ (ស្ត្រី 54 នាក់)
+ នាយករដ្ឋបាលក្រុង/ស្រុក ចំនួន 04 នាក់ (ស្ត្រី 00 នាក់)
+ នាយករងរដ្ឋបាលក្រុង/ស្រុក ចំនួន 08 នាក់ (ស្ត្រី 02 នាក់)
+ ប្រធានការិយាល័យក្រុង/ស្រុក ចំនួន 61 នាក់ (ស្ត្រី 09 នាក់)
+ អនុប្រធានការិយាល័យក្រុង/ស្រុក ចំនួន 53 នាក់ (ស្ត្រី 12 នាក់)
+ មន្ត្រី ចំនួន 2,071 នាក់ (ស្ត្រី 806 នាក់)
+ សហព័ទ្ធមន្ត្រីរាជការស៊ីវិល ចំនួន 759 នាក់
+ កូនមន្ត្រីរាជការស៊ីវិល ចំនួន 1,857 នាក់
+ មន្ត្រីជាប់កិច្ចសន្យា ចំនួន 268 នាក់ (ស្រី 133 នាក់)

- បានត្រួតពិនិត្យលើសំណើបៀវត្សមន្ត្រីរាជការ មន្ត្រីកិច្ចសន្យា តាមបណ្តាមន្ទីរ/អង្គភាព ក្នុងខេត្ត
- បានចុះពិនិត្យមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា នៅតាមបណ្តាក្រុង ស្រុក ទាំង7
- បានត្រួតពិនិត្យទិដ្ឋាការលើសំណើសុំឯកសារពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលប្រចាំខែ ជូនមន្ទីរ អង្គភាពជុំវិញខេត្ត ដូចខាងក្រោម៖

| ល.រ | បរិយាយ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| 1 | ក្របខ័ណ្ឌថ្មី | 82 | |
| 2 | តាំងស៊ប់ | 148 | |
| 3 | ប្តូរប្រភេទក្របខ័ណ្ឌ | 00 | |
| 4 | តែងតាំង/ប្តូរប្រាក់មុខងារ | 97 | |
| 5 | ឡើងថ្នាក់/និយ័តកម្មថ្នាក់ | 406 | |
| 6 | ឡើងឋានន្តរស័ក្តិ | 05 | |
| 7 | បញ្ចូលកូន | 144 | |
| 8 | បញ្ចូលប្រពន្ធ | 30 | |
| 9 | ចូលនិវត្តន៍ | 10 | |
| 10 | ផ្ទេរចូល | 13 | |
| 11 | ផ្ទេរចេញ | 37 | |
| 12 | នៅក្រៅក្របខ័ណ្ឌដើម | 01 | |
| 13 | ទំនេរគ្មានបៀវត្ស | 04 | |

| | | | |
|---|---|---|---|
| 14 | លុបឈ្មោះ | 09 | |
| 15 | ប្តូរកន្លែងការងារ | 03 | |
| 16 | មន្ត្រីនៅតំបន់ដាច់ស្រយាល | 1,495 | |
| 17 | ចូលបម្រើការងារវិញ | 05 | |
| 18 | រំលឹកប្រាក់ | 01 | |
| 19 | ថ្នាក់ពីរពេល | 103 | |
| 20 | ថ្នាក់គួបពីរកម្រិត | 111 | |
| 21 | ថ្នាក់គួបបីកម្រិត | 17 | |
| **សរុបរួម** | | **2,721** | |

### ៣.២. សង្គមកិច្ច

### ៣.២.១. ការងារអប់រំ

- បានរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង 27 ធ្នូ 2021 បេក្ខជនសរុបចំនួន 971 នាក់ ស្រី 508នាក់ មាន 02មណ្ឌល គឺមណ្ឌលប្រឡងវិទ្យាល័យចំណេះទូទៅ បច្ចេកទេសតេជោ សែន កោះកុង និងមណ្ឌលប្រឡងជាស៊ីម ស្មាច់មានជ័យ ក្នុងនោះ បេក្ខជនអវត្តមានសរុបចំនួន 78នាក់ ស្រី 35នាក់
- បានចុះពិនិត្យតាមដាន/វាយតម្លៃ/ណែនាំ លើការងារបច្ចេកទេស និងការងាររដ្ឋបាល របស់ការិយាល័យជំនាញមន្ទីរទាំង10 ដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញចំនួន 43លើក
- ចូលរួមវគ្គសិក្ខាសាលាផ្សេងៗ របស់ថ្នាក់ដឹកនាំ និងការិយាល័យជំនាញដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ចំនួន 24លើក និងរៀបចំបើកវគ្គសិក្ខាសាលាផ្សេងៗ ចំនួន 02លើក
- បើកវគ្គសិក្ខាសាលាបំប៉នផ្សេងៗ ដល់មន្ត្រីគ្រប់គ្រង មន្ត្រីជំនាញបច្ចេកទេស និងនាយក/នាយិកា ចំនួន 13លើក
- ចូលរួមទិវា និងវេទិកាផ្សេងៗ ដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ចំនួន 07លើក
- ចូលរួមសន្និបាត ការងារផ្សេងៗ តាមប្រព័ន្ធអនឡាញ ចំនួន 02លើក
- ដឹកនាំក្រុមកីឡាករចូលរួមប្រកួតកីឡាផ្សេងៗ ចំនួន 06លើក
- ចូលរួមជាគណៈកម្មការប្រឡង និងគណៈកម្មការផ្សេងៗ ចំនួន 03លើក
- ផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការប្រឡងជ្រើសរើសផ្សេងៗ និងការងារជំនាញការិយាល័យមន្ទីរចំនួន 25 ច្បាប់ និងទទួលពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសចូលក្របខ័ណ្ឌគ្រូបង្រៀន ចំនួន 782នាក់ ស្រី 444នាក់
- ចូលរួមបំផុសចលនាកាយរឹទ្ធិជាតិកម្ពុជា ដល់ក្រុមសិស្សកាយរឹទ្ធិ
- ចូលរួមយុទ្ធនាការផ្សព្វផ្សាយផ្សេងៗ ចំនួន 02លើក
- បោះពុម្ពសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (បណ្តោះអាសន្ន)ឆ្នាំ2021 សម្រាប់សិស្សថ្នាក់ទី9 សរុបចំនួន 1,394 នាក់ ស្រី 698នាក់
- សមិទ្ធផលសំខាន់ៗដែលទទួលបាន និងកំពុងសាងសង់ ក្នុងឆ្នាំ2021៖
    - អគារសិក្សាអនុវិទ្យាល័យ ចំនួន 01ខ្នង 02ជាន់ ស្មើនឹង 10បន្ទប់ (អគារថ្មី) កំពុងសាងសង់ ជាអំណោយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
    - អគារសិក្សាបឋមសិក្សា ចំនួន 01ខ្នង ស្មើនឹង 04បន្ទប់ (អគារថ្មី) ប្រើប្រាស់ថវិការបស់អង្គការ(UWS)
    - អគារស្នាក់នៅគ្រូ ចំនួន 01ខ្នង ស្មើ 04បន្ទប់(អគារថ្មី) ប្រើប្រាស់ថវិកាក្រសួងអប់រំ យុវជន និងកីឡា (ADB)
    - ផ្លូវបេតុង ចំនួន 01ខ្សែ ប្រវែង 937ម៉ែត្រ ប្រើប្រាស់ថវិការបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត។

### ៣.២.២. ការងារសុខាភិបាល

- បានសហការជាមួយរដ្ឋបាលស្រុកស្រែអំបិល ចុះផ្ដាកជាបន្ទាន់នូវអាជីវកម្មផ្ដល់សេវា "បន្ទប់ពិគ្រោះ និងព្យាបាលជំងឺទូទៅ វាលសែនសុខ" របស់លោកវេជ្ជ. ឈុំ ម៉ុងឆេង ស្ថិតនៅភូមិវាលខាងជើង ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង
- មន្ទីរពេទ្យបង្អែកខេត្តកោះកុង បានដាក់ឱ្យដំណើរការអគារថ្មី ព្រមទាំងសម្ភារបរិក្ខារថ្មី ដែលជាអំណាយរបស់រាជរដ្ឋាភិបាលថៃ និងកាកបាទក្រហមថៃ សម្រាប់ផ្ដល់សេវាសង្គ្រោះបន្ទាន់ និងសេវាវះកាត់តូច
- បានអមដំណើរ**លោកជំទាវ ឱ វណ្ណឌីន រដ្ឋលេខាធិការក្រសួងសុខាភិបាល** ក្នុងពិធីប្រគល់ថវិកាដ៏ថ្លៃថ្លារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចំនួន 3,000,000រៀល និងគ្រឿងឧបភោគបរិភោគមួយចំនួន ជូនលោកយាយ **ហុង ឡាច** ដែលមានអាយុ 100ឆ្នាំ រស់នៅភូមិ2 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដែលបានស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-19
- បានចូលរួមក្នុងពិធីបិទយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-19 ជុំទី1 ជូនប្រជាពលរដ្ឋដែលមានអាយុចាប់ពីអាយុ 18ឆ្នាំ ឡើង ក្រោមអធិបតីភាព **លោកជំទាវ ឱ វណ្ណឌីន រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-19** ក្នុងក្របខ័ណ្ឌទូទាំងប្រទេស **ឯកឧត្ដម នាយឧត្ដមសេនីយ៍ ម៉ុន លើត រដ្ឋលេខាធិការក្រសួងការពារជាតិ** និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** និង**លោកជំទាវ មិថុនា ភូថង អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-19 ខេត្តកោះកុង**
- បានអមដំណើរ លោកជំទាវ **ឱ វណ្ណឌីន** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-19 ក្នុងក្របខ័ណ្ឌទូទាំងប្រទេស និង**លោកជំទាវ មិថុនា ភូថង អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-19 ខេត្តកោះកុង** អញ្ជើញផ្ដល់អំណោយសប្បុរសធម៌ **សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាថវិកាចំនួន 3,000,000រៀល និងគ្រឿងឧបភោគបរិភោគមួយចំនួនទៀត ជូនលោកយាយ **សុខ សារឿន** អាយុ 101ឆ្នាំ ស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-19 ស្ថិតនៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង
- បានទទួលម៉ាស៊ីនបច្ចេកវិទ្យាទំនើប អាចផលិតអុកស៊ីហ្សែនក្នុង 01ថ្ងៃបានចំនួន 10ធុងធំៗ ស្មើនឹង 40លីត្រ ដែលជាអំណោយរបស់ **ឯកឧត្ដមឧត្ដមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ** ដែលបានផ្ដល់ជូនតាមរយៈ**លោកជំទាវ មិថុនា ភូថង អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-19 ខេត្តកោះកុង**
- បានចូលរួមពិធីចុះហត្ថលេខាប្រគល់សម្ភារ បរិក្ខារវេជ្ជសាស្ត្រក្រោមជំនួយរបស់ទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិ-ថៃ (TICA) លើគម្រោងកិច្ចសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិ-ថៃ លើវិស័យសុខាភិបាលខេត្តកោះកុង និងខេត្តត្រាតប្រទេសថៃ
- បានចូលរួមក្នុងកិច្ចការពារបង្ការជំងឺឆ្លង ពិសេសជំងឺកូវីដ-19 និងត្រៀមរថយន្តសង្គ្រោះ ក្នុងពិធីចុះសួរសុខទុក្ខ សំណេះសំណាល និងចែកអំណោយដល់បងប្អូនប្រជាពលរដ្ឋចំនួន 1,102គ្រួសារ មកពីឃុំថ្មស តានូន កោះស្ដេច និងឃុំភ្ញីមាស ស្រុកគិរីសាគរ និងបូទុមសាគរ ក្រោមអធិបតីភាព **សម្ដេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានខេត្តកោះកុង**

- បានចូលរួមក្នុងកិច្ចការពារបង្ការជំងឺឆ្លង ពិសេសជំងឺកូវីដ-19 ក្នុងពិធីបូកសរុបលទ្ធផលការងារសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះឈ្នះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានក្រុមការងាររដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង**
- បានចូលរួមបរិច្ចាគឈាមក្នុងកម្មវិធី "ផ្តល់ឈាម ផ្តល់ក្តីស្រលាញ់" នៅស្រុកស្រែអំបិល
- ក្រុមការងារចត្តាឡីស័កប្រចាំការនៅច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម បានអនុវត្តដូចខាងក្រោម៖
  - បានពិនិត្យកម្តៅលើអ្នកបើកបររថយន្តដឹកទំនិញចំនួន 56,646នាក់
  - បាញ់ថ្នាំសម្លាប់មេរោគលើរថយន្តដឹកទំនិញចេញ-ចូល 55,353គ្រឿង
  - ពិនិត្យកម្តៅអ្នកធ្វើដំណើរចេញពីប្រទេសកម្ពុជា សរុបចំនួន 1,298នាក់ ស្រី 451នាក់
  - ពិនិត្យកម្តៅអ្នកធ្វើដំណើរចូលមកប្រទេសកម្ពុជាសរុបចំនួន 139នាក់ ស្រី 42នាក់
  - សពជនជាតិខ្មែរបញ្ជូនមកពីប្រទេសថៃចំនួន 05នាក់ ស្រី 03នាក់
- ក្រុមការងារឆ្លើយតបបន្ទាន់ជំងឺឆ្លងរាតត្បាតរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកោះកុង បានចុះយកសំណាកករណីសង្ស័យជំងឺកូវីដ-19 សរុបចំនួន 138,517នាក់ ស្រី 48,336នាក់ ជាលទ្ធផល វិជ្ជមានសរុបចំនួន 5,989នាក់ ស្រី 3,424នាក់ ក្នុងនោះ រួមមាន៖
  - កំពុងសម្រាកព្យាបាល ចំនួន 06នាក់ ស្រី 04នាក់
  - ព្យាបាលជាសះស្បើយ ចំនួន 5,918នាក់ ស្រី 3,377នាក់
  - ករណីស្លាប់ដោយជំងឺកូវីដ-19 ចំនួន 65នាក់ ស្រី 41នាក់
- ការងារចាក់វ៉ាក់សាំងកូវីដ-19
  - អាយុ 18ឆ្នាំឡើង
    +ចាក់ដូសទី1 បានសរុបចំនួន 47,568នាក់ ស្រី 14,348នាក់
    +ចាក់ដូសទី2 បានសរុបចំនួន 44,740នាក់ ស្រី 21,579នាក់
  - ដូសទី3 ឬដូសជំរុញ អាយុ 18ឆ្នាំឡើង
    +ចាក់បានសរុបចំនួន 6,591នាក់ ស្រី 2,119នាក់
  - កុមារអាយុ 12ឆ្នាំ ដល់ក្រោម 18ឆ្នាំ
    +ចាក់ដូសទី1 បានសរុបចំនួន 15,564នាក់ ស្រី 7,522នាក់
    +ចាក់ដូសទី2 បានសរុបចំនួន 15,116នាក់ ស្រី 7,334នាក់
  - កុមារអាយុ 6ឆ្នាំ ដល់ 12ឆ្នាំ
    +ចាក់ដូសទី1 បានសរុបចំនួន 16,261នាក់ ស្រី 7,977នាក់
    +ចាក់ដូសទី2 បានសរុបចំនួន 15,704នាក់ ស្រី 7,721នាក់
  - កុមារអាយុ 5ឆ្នាំ
    +ចាក់ដូសទី1 បានសរុបចំនួន 1,994នាក់ ស្រី 943នាក់
    +ចាក់ដូសទី2 បានសរុបចំនួន 1,446នាក់ ស្រី 730នាក់
- បានពិនិត្យ និងពិគ្រោះជំងឺជូនប្រជាពលរដ្ឋ សរុបចំនួន 66,005ករណី ក្នុងនោះជំងឺករណីថ្មីមានចំនួន 59,168ករណី
- អ្នកជំងឺសម្រាកពេទ្យមានចំនួន 7,773នាក់
- បានវះកាត់ករណីសម្រាកពេទ្យចំនួន 199ករណី
- ស្ត្រីបានមកពិនិត្យផ្ទៃពោះមុនសម្រាលចំនួន 13,806ដង

- ស្ត្រីសម្រាលកូនចំនួន 2,912នាក់
- ស្ត្រីពន្យារកំណើតបន្តចំនួន 4,321នាក់
- ស្ត្រីបានមកពិនិត្យផ្ទៃពោះក្រោយសម្រាលកូនចំនួន 3,679ដង
- ផ្តល់ថ្នាំបង្ការជំងឺផ្សេងៗដល់កុមារចំនួន 33,872ដូស
- ផ្តល់ថ្នាំបង្ការជំងឺតេតាណុសដល់ស្ត្រីមានផ្ទៃពោះចំនួន 4,043ដូស
- បានផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យចំណីអាហារចំពោះអាហារដ្ឋាន បើកថ្មីចំនួន 02កន្លែង
- បានបន្តសុពលភាពការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យចំណីអាហារចំពោះអាហារដ្ឋាន ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ចំនួន 04កន្លែងគឺៈ ភោជនីដ្ឋាន KKN1 KKN2 KKN3 និង KKN4
- បានបន្តសុពលភាពដល់ឱសថស្ថាន ហ៊ុយ វឌ្ឍនៈ 01កន្លែង ស្ថិតនៅភូមិ3 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- បានផ្តល់លិខិតអនុញ្ញាតដល់ឱសថស្ថានចំពោះការបន្តសុពលភាព ឱសថស្ថានព្រះវិហារ ស្ថិតនៅភូមិ3 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- មូលដ្ឋានសេវាឯកជនសុខាភិបាល

| ល.រ | ប្រភេទសេវា | ស្ថិតិបច្ចុប្បន្នភាព | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | សរុប | មានច្បាប់ | អត់ច្បាប់ | |
| 1 | ឱសថស្ថាន | 13 | 13 | 00 | |
| 2 | អគារលក់ឱសថបុរាណ | 01 | 01 | 00 | |
| 3 | បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ | 29 | 29 | 00 | |
| 4 | បន្ទប់ថែទាំជំងឺ | 34 | 34 | 00 | |
| 5 | បន្ទប់ពិគ្រោះព្យាបាលជំងឺទូទៅ | 36 | 36 | 00 | |
| 6 | បន្ទប់ពិគ្រោះជំងឺមាត់-ធ្មេញ | 06 | 06 | 00 | |
| **សរុបប្រភេទសេវា** | | **119** | **119** | **00** | |

### ៣.២.៣. ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម 2ឆ្នាំ គ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-19 ទូទាំងខេត្ត មានចំនួនដូចខាងក្រោម៖

  ក.ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម 2ឆ្នាំ៖
  - ស្ត្រីមានផ្ទៃពោះ 1,182នាក់
  - ស្ត្រីសម្រាលកូន 545នាក់
  - កុមារអាយុក្រោម 2ឆ្នាំ 2,481នាក់

  ថវិកាចំណាយសរុប 255,520,000រៀល

  ខ.គ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-19 មានចំនួនដូចខាងក្រោម៖
  - ក្រកម្រិត (ក្រ1) 4,990គ្រួសារ
  - ក្រកម្រិត (ក្រ2) 7,380គ្រួសារ

  ថវិកាចំណាយសរុបចំនួន 14,721,074,000រៀល

គ.ចំពោះថវិកាបើកជូនអ្នកស្លាប់ដោយសារជំងឺកូវីដ-19 ក្នុងព្រឹត្តិការណ៍ 20 កុម្ភៈ ឆ្នាំ2021 ដែលជាកញ្ចប់ថវិកាកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ បើកតាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចែកចេញជា 03លើក មានដូចខាងក្រោម៖

- លើកទី1 ចំនួន 01នាក់ 760,000៛
- លើកទី2 ចំនួន 07នាក់ 4,731,000៛
- លើកទី3 ចំនួន 21នាក់ 14,916,500៛

ថវិកាចំណាយសរុប 20,407,500៛

- បានជួបសួរសុខទុក្ខ ស្ត្រីរងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្មមកពីប្រទេសម៉ាឡេស៊ីជាមួយអង្គការ IGM International ចំនួន 02នាក់ស្រី
- បានទទួលពលករខ្មែរដែលត្រូវបានអាជ្ញាធរថៃបញ្ជាឱ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ ចំនួន 02នាក់ស្រី
- បានសហការជាមួយទីប្រឹក្សាទទួលបន្ទុកកិច្ចការ កុងស៊ុល នៅស្ថានទូតកម្ពុជា នៃទីក្រុងបាងកក បានបញ្ជូនពលករខ្មែរដែលគ្រោះថ្នាក់ចរាចរណ៍ (បាក់ជើងទាំងពីរ) នៅក្នុងប្រទេសថៃឱ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ ចំនួន 01នាក់ស្រី
- បានចុះសិក្សាប៉ាន់ប្រមាណស្តីពីការគ្រប់គ្រងគណនីសម្រាប់អ្នកទទួលផលពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-19 ចំនួន 09គ្រួសារ
- បានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់កម្មវិធីអែប (App) និងតាប្លែត (Tablet) សម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម 2ឆ្នាំ ចំនួន 07ក្រុង/ស្រុក
- បានចុះត្រួតពិនិត្យលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម 2ឆ្នាំ និងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនរងគ្រោះ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-19 ចំនួន 05ឃុំ និង 03សង្កាត់
- បានទំនាក់ទំនងទៅ ឃុំ-សង្កាត់ ដើម្បីស្រង់ព័ត៌មានពីបញ្ជីឈ្មោះអ្នកស្លាប់ ដោយសារជំងឺកូវីដ-19 ក្នុងព្រឹត្តិការណ៍សហគមន៍ 20 កុម្ភៈ ឆ្នាំ2021 ចំនួន 26នាក់ ស្រី 18នាក់
- បានចុះបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា ជូនដល់ក្រុមគ្រួសារអ្នកស្លាប់ដោយសារជំងឺកូវីដ-19 ក្នុងព្រឹត្តិការណ៍សហគមន៍ 20 កុម្ភៈ ឆ្នាំ2021 ចំនួន 22គ្រួសារ
- បានធ្វើការអង្កេតរហ័សក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម 2ឆ្នាំ ចំនួន 106នាក់ (អ្នកទទួលបន្ទុកកម្មវិធី 14នាក់, ស្ត្រីមានផ្ទៃពោះ 30នាក់, អាណាព្យាបាលកុមារអាយុ 0-6ខែ 30នាក់ អាណាព្យាបាលកុមារអាយុ 6-23ខែ 30នាក់ និងមន្ត្រីសង្គមកិច្ច 03នាក់
- បានផ្តល់កាតរឹងជូនដល់ឃុំ សង្កាត់ដើម្បីផ្តល់ជូនអ្នកទទួលផល ចំនួន 494កាត
- បានសហការជាមួយអង្គការ រតនៈអន្តរជាតិ ដើម្បីសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សពីប្រទេសចិនឱ្យមករស់នៅក្នុងសហគមន៍វិញ ចំនួន 01នាក់ស្រី
- បានផ្តល់អំណោយជូនដល់គ្រួសារដែលកំពុងជួបការលំបាកក្នុងអំឡុងពេលកូវីដ-19 ជាប់ធ្វើចត្តាឡីស័កនៅតាមផ្ទះ ចំនួន 200គ្រួសារ
- បានចុះអង្កេតរហ័សជនអនាថា ចំនួន 24នាក់ ស្រី 15នាក់
- បានឧបត្ថម្ភថវិកាដល់ជនអនាថាដែលបានទទួលមរណភាពចំនួន 02នាក់ ទឹកប្រាក់សរុប 400,000រៀល

- បានសហការប្រគល់-ទទួលទារិកា ដែលត្រូវបានឪពុក-ម្តាយ បោះបង់ចោលនៅប្រទេសថៃ ពីទីប្រឹក្សាកិច្ចការកុងស៊ុលនៅស្ថានទូតកម្ពុជាក្នុងទីក្រុងបាងកកប្រចាំនៅប្រទេសថៃ ចំនួន 01នាក់
- បានចុះសួរសុខទុក្ខ និងតាមដានកុមារដែលបានសមាហរណកម្មពីមណ្ឌលថែទាំមករស់នៅជាមួយគ្រួសារវិញ ចំនួន 05នាក់ ស្រី 03នាក់
- បានចុះសួរសុខទុក្ខ និងចូលរួមកម្មវិធីចែកកង់ដល់កុមារក្រីក្រ និងកុមារកំព្រា ចំនួន 16នាក់ ស្រី 05នាក់
- បានចុះសួរសុខទុក្ខ និងតាមដានពីការថែទាំកុមារដែលត្រូវគ្រួសារធម៌សុំកូនយកទៅចិញ្ចឹម ចំនួន 04នាក់ស្រី
- បានសហការជាមួយអង្គការមិត្តសម្លាញ់ ដើម្បីចុះបិទករណីកុមារដែលបានសុំយកមកចិញ្ចឹមដោយបានតាមដានអស់រយៈពេល 2ឆ្នាំ ចំនួន 02នាក់ ស្រី 01នាក់
- បានចុះសួរសុខទុក្ខ ផ្តល់ថវិកា និងគ្រឿងឧបភោគបរិភោគ ដល់កុមាររងគ្រោះដោយអំពើរំលោភសេពសន្ថវៈ ចំនួន 01នាក់ស្រី
- បានសហការជាមួយអង្គការយូនីសេហ្វ (UNICEF) ដើម្បីផ្តល់ស្បៀងសង្គ្រោះបន្ទាន់ដល់គ្រួសារក្រីក្រក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងជំងឺកូវីដ-19 ចំនួន 11នាក់ ស្រី 06នាក់
- បានប្រឹក្សាយោបល់ និងសួរសុខទុក្ខស្តីពីកិច្ចការពារកុមារដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងដោយមិត្តភក្តិជាអ្នកប្រព្រឹត្ត ចំនួន 04នាក់ ស្រី 03នាក់
- បានសហការជាមួយមន្ត្រីសុខាភិបាល ដើម្បីចុះសួរសុខទុក្ខ និងផ្តល់កញ្ចប់ឧបត្ថម្ភដល់កុមារ និងស្ត្រីមានផ្ទៃពោះដែលសម្រាកព្យាបាលនិងធ្វើចត្តាឡីស័កដោយមានការឧបត្ថម្ភពីអង្គការយូនីសេហ្វ(UNICEF) ចំនួន 95នាក់ ស្រី 20នាក់
- បានចុះប៉ាន់ប្រមាណគ្រួសារកុមារកំព្រាក្រីក្ររស់នៅជាមួយជីដូនចាស់ជរាដែលមានគោលបំណងស្នើសុំទុកដាក់កុមារឱ្យស្នាក់នៅមណ្ឌលកុមារកំព្រា ដើម្បីមើលថែទាំជំនួស ចំនួន 02នាក់ ស្រី 01នាក់
- បានសហការជាមួយមន្ត្រីពន្ធនាគារ ដើម្បីចុះបំពេញទម្រង់ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងច្បាប់ដែលបានប្រព្រឹត្តបទល្មើស (អំពើហិង្សា) ចំនួន 03នាក់ស្រី
- បានចុះធ្វើអធិការកិច្ច លើជនមានពិការភាព ដែលបម្រើការងារ នៅក្នុងរោងចក្រ យ៉ាហ្សាគិ (YAZAKI) ចំនួន 32នាក់ ស្រី 22នាក់
- បានចុះទៅតំបន់សេដ្ឋកិច្ចពិសេស ដើម្បីផ្តល់ជូននូវឯកសារ និងសេចក្តីជូនដំណឹងស្តីពីលក្ខខណ្ឌនៃការចុះបញ្ជីការអនុវត្តកាតព្វកិច្ចរបស់វិស័យឯកជនលើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ចំនួន 03ក្រុមហ៊ុន
- បានចូលរួមប្រគល់ផ្ទះចំនួន 01ខ្នង គ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួនជាអំណោយរបស់មូលនិធិជនពិការ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកោះកុង ជូនដល់ជនមានពិការភាព 01នាក់
- បានចែកអំណោយ សប្បុរសធម៌ ដល់ជនមានពិការភាពក្រីក្រនៅតាមសហគមន៍ ដែលមានប័ណ្ណសមធម៌ចំនួន 15គ្រួសារ នៅក្នុងក្រុងខេមរភូមិន្ទ
- បានចុះរាប់ប្រាក់ក្នុងហិបរបស់មូលនិធិជនពិការនៅតាមវត្តអារាម ភោជនីយដ្ឋាន ផ្ទះសំណាក់ និងរមណីយដ្ឋាននានាក្នុងខេត្តកោះកុង ចំនួន 03លើក សរុប 08ទីតាំង ដែលមានទឹកប្រាក់សរុប 4,217,500រៀល
- បានចុះធ្វើបច្ចុប្បន្នភាពនូវរចនាសម្ព័ន្ធសមាគមមនុស្សចាស់នៅសង្កាត់ទាំងបីនៃក្រុងខេមរភូមិន្ទ ចំនួន 03លើក មានសមាសភាព 11នាក់ ស្រី 02នាក់
- បានចុះសួរសុខទុក្ខផ្សព្វផ្សាយពីជំងឺកូវីដ-19 និងបានផ្តល់អំណោយមួយចំនួនដល់ជនចាស់ជរាគ្មានទីពឹង និងអ្នកផ្ទុកមេរោគអេដស៍ ចំនួន 08នាក់ ស្រី 07នាក់

- បានចុះតាមដានការធ្វើបច្ចុប្បន្នភាពនូវចេនាសម្ព័ន្ធសមាគមមនុស្សចាស់តាមភូមិ ក្នុងសង្កាត់ទាំងបី នៃក្រុងខេមរភូមិន្ទ ខេត្តកោះកុង ចំនួន 06លើក មានសមាសភាព 11នាក់ ស្រី 06នាក់
- បានចុះសួរសុខទុក្ខជនចាស់ជរាគ្មានទីពឹង និងអ្នកផ្ទុកជំងឺអេដស៍រស់នៅក្នុងមណ្ឌលជីវិតថ្មី (វត្តថ្មី) ចំនួន 12នាក់ ស្រី 05នាក់
- បានចុះសួរសុខទុក្ខគ្រួសាររងផលប៉ះពាល់ដោយជំងឺកូវីដ-19 ចំនួន 08នាក់ ស្រី 08នាក់
- បានធ្វើបច្ចុប្បន្នភាពចេនាសម្ព័ន្ធសមាគមមនុស្សចាស់ នៅឃុំតាទៃលើ ស្រុកថ្មបាំង ខេត្តកោះកុង ចំនួន 02 លើក មានសមាសភាព 08នាក់ ស្រី 02នាក់
- បានស្នើសុំលុបឈ្មោះសពនិវត្តជនចំនួន 06នាក់
- បានទទួលប្រកាសលុបឈ្មោះសពនិវត្តជនចំនួន 09នាក់ ចេញពីបញ្ជីបើកប្រាក់សោធនប្រចាំខែ
- បានលុបឈ្មោះកូនរបស់និវត្តជនដែលលើសអាយុចំនួន 29នាក់ ចេញពីបញ្ជីបើកប្រាក់ប្រចាំខែ
- បានទទួលលិខិតឱ្យបន្តឧបត្ថម្ភប្រាក់របបគោលនយោបាយជូនអ្នកនៅក្នុងបន្ទុកសពចំនួន 07នាក់
- បានបើកផ្តល់ប្រាក់សោធនសល់ក្នុងគណនីធនាគារជូនគ្រួសារសពនិវត្តជនចំនួន 03នាក់
- បានធ្វើបច្ចុប្បន្នភាពជូននិវត្តជនចំនួន 06នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន 05នាក់
- បានរំលឹកប្រាក់សោធនលំអៀងកែកាំប្រាក់ជូននិវត្តជនចំនួន 01នាក់
- បានបើកប្រាក់ជូនអ្នកនៅក្នុងបន្ទុកសពនិវត្តជន ប្រពន្ធចំនួន 36នាក់ និងកូនចំនួន 07នាក់
- បានបើកប្រាក់ជូនអ្នកនៅក្នុងបន្ទុកសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ប្រពន្ធចំនួន 06នាក់
- បានបើកប្រាក់ជូនកូនកំព្រារបស់សពមន្ត្រីរាជការចំនួន 10នាក់
- បានបើកប្រាក់ជូនគ្រួសារសពរបស់និវត្តជនចំនួន 11នាក់
- បានទទួលលិខិតផ្ទេរនិវត្តជនចូលថ្មីចំនួន 10នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន 14នាក់
- បានរៀបចំលិខិតស្នើសុំលុបឈ្មោះសពនិវត្តជនចំនួន 04នាក់
- បានសហការជាមួយក្រុមការងារបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) ថ្នាក់កណ្តាល ចុះបើកផ្តល់របបសន្តិសុខសង្គមរបស់សពជូនគ្រួសារសពនិវត្តជនចំនួន 04នាក់ និងបើកប្រាក់របស់សពនិវត្តជនសល់ក្នុងគណនីចំនួន 06នាក់
- បានបំពេញតាមទម្រង់បែបបទសម្រាប់ទទួលសោធនក្នុងបរិបទកូវីដ-19 ចំនួន 06នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន 06នាក់
- បានរំលឹកសាច់ប្រាក់តាមនីតិវិធីជូននិវត្តជនផ្ទេរចូលថ្មីចំនួន 02នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន 05នាក់
- និវត្តជនទទួលមរណភាពចំនួន 10នាក់។

### ៣.២.៤. ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ

- ក្នុងឆ្នាំ2021 នេះ ស្ថិតិសហគ្រាស គ្រឹះស្ថានក្នុងខេត្តសរុបចំនួន 72 ដែលមានកម្មករនិយោជិតកំពុងបម្រើការងារសរុបចំនួន 13,284នាក់ ស្រី 8,134នាក់ ក្នុងនោះមានៈ
    - កម្មករនិយោជិតខ្មែរចំនួន 12,658នាក់ ស្រី 7,901នាក់
    - ពលករបរទេសចំនួន 626នាក់ ស្រី 233នាក់
- ចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក (ចេញ-ចូល) បានចំនួន 21សហគ្រាស គ្រឹះស្ថានរួមមានៈ
    - ចលនាចេញ 4,918នាក់ ស្រី 3,273នាក់
    - ចលនាចូល 4,803នាក់ ស្រី 3,367នាក់។
- បានផ្តល់សៀវភៅការងារជនកម្ពុជា ចំនួន 60ក្បាល

- បានផ្តល់ប័ណ្ណការងារពលករបរទេសចំនួន 153ប័ណ្ណ
- សហគ្រាសស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេសចំនួន 15សហគ្រាស
- បានចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានរបស់ មីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក សាខាអណ្តូងទឹក (PRASAC MFI PLC)
- បានចុះទិដ្ឋាការបទបញ្ជាផ្ទៃក្នុងសហគ្រាស របស់មីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក សាខាអណ្តូងទឹក (PRASAC MFI PLC)
- បានចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក (កម្មករនិយោជិតចាប់ពី 8-100នាក់) ចំនួន 11គ្រឹះស្ថាន រួមមាន៖
    - គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក សាខាស្រុកស្រែអំបិល (PRASAC MFI PLC)
    - គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក សាខាអណ្តូងទឹក (PRASAC MFI PLC)
    - គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាខេត្តកោះកុង (AMK MFI PLC)
    - គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ សាខាខេត្តកោះកុង (HATTHA BANK PLC)
    - គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ដាប់ប៊ែល យូប៊ី ហ្វាយនែន សាខាស្រុកស្រែអំបិល (WB FINANCE CO.,LTD)
- រោងចក្រ ក្នុងខេត្ត បានអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងចំនួន 04រោងចក្រ មាន៖
    - រោងចក្រ មីកាសាស្ព័ត ខេមបូឌា (MIKASA SPORT CAMBODIA)
    - រោងចក្រ ហាណា (HANA)
    - រោងចក្រ 99 អ៊ីមប្រយឌើរី (99 EMBROIDERY)
    - រោងចក្រ យ៉ាហ្សាគី (YAZAKI)
    - ចំនួនកូនជាងដែលត្រូវហ្វឹកហ្វឺនមានចំនួន 151នាក់ ស្រី 133នាក់
- បានចុះអធិការកិច្ចការងារជនបរទេសជាមួយនគរបាលអន្តោប្រវេសន៍ចំនួន 11គោលដៅ បានពិនិត្យឃើញជនបរទេសចំនួន 572នាក់ ស្រី 170នាក់ ក្នុងនោះ៖
    - ជនបរទេសដែលមានប័ណ្ណ និងសៀវភៅការងារចំនួន 534នាក់ ស្រី 160នាក់
    - ជនបរទេសដែលគ្មានប័ណ្ណ និងសៀវភៅការងារចំនួន 38នាក់ ស្រី 10នាក់
- ក្រុមហ៊ុនចំនួន 03 បានបិទលែងដំណើរការមានដូចជា៖
    - តាតៃ រីសត TATAI RESORT (ម្ចាស់បានលក់ឱ្យទៅថៅកែថ្មី)
    - ទឹម រិន ខមផេននី (TIM RIN COMPANY) ទទួលម៉ៅការសំណង់ (គ្មានកម្មករនិយោជិតបម្រើការងារ)
    - អង្គការ វីសិនហ្វាន់(VISION FUN)ស្រុកស្រែអំបិល (បញ្ចប់អាណត្តិ)។
- បានផ្តល់លិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោងចំនួន 02គ្រឹះស្ថាន៖
    - ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាខេត្តកោះកុង (ACLEDA BANK PLC) ចំនួន 06លើក
    - ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាស្រុកស្រែអំបិល(ACLEDA BANK PLC) ចំនួន 05លើក
- បានចុះសង្កេតការណ៍ ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកចំនួន 08សហគ្រាស គ្រឹះស្ថាន មាន៖
    - រោងចក្រខេខេអិន (KKN)
    - រោងចក្រយ៉ាហ្សាគី (YAZAKI)
    - ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ សាខាខេត្តកោះកុង (ABA BANK PLC)
    - ធនាគារស្ថាបនា សាខាខេត្តកោះកុង (SATHAPANA BANK PLC)
    - ធនាគារ ស្ថាបនា សាខាស្រុកស្រែអំបិល (SATHAPANA BANK PLC)

- ធនាគារអេស៊ីលីដា សាខាស្រុកស្រែអំបិល (ACLEDA BANK PLC)
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាខេត្តកោះកុង (AMK MFI PLC)
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ សាខាស្រុកស្រែអំបិល (AMK MFI PLC)

ជាលទ្ធផលជ្រើសរើសបាន ប្រតិភូបុគ្គលិកពេញសិទ្ធិចំនួន 114នាក់ និងប្រតិភូបុគ្គលិកជំនួយចំនួន 115 នាក់។

**៣.២.៥. ការងារវប្បធម៌ និងវិចិត្រសិល្បៈ**

- មន្ត្រីជំនាញភ្លេងពិណពាទ្យចេញប្រគំចំនួន 05លើក នៅសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ 03លើក និងនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា 02លើក
- មន្ត្រីជំនាញភ្លេងប្រពៃណីចេញប្រគំ ចំនួន 02លើក ស្ថិតនៅភូមិ4 សង្កាត់ដងទង់ 01លើក និងនៅភូមិ3 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ 01លើក
- បានចុះត្រួតពិនិត្យច្បាប់អនុញ្ញាតអាជីវកម្ម និងណែនាំដល់អាជីវករមានច្បាប់អនុញ្ញាតហួសសុពលភាពឱ្យមកធ្វើច្បាប់អនុញ្ញាតនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុងខេមរភូមិន្ទចំនួន 03លើក
- បានចុះត្រួតពិនិត្យអាជីវកម្មរោងកាហ្វេរីដេអូ អំពីការហាមចាក់រឿងអាសអាភាសចំនួន 05កន្លែង នៅសង្កាត់ដង់ទង់ 04កន្លែង និងសង្កាត់ស្មាច់មានជ័យ 01កន្លែង ក្រុងខេមរភូមិន្ទ
- បានចុះស្រង់ស្ថិតិហាងកាហ្វេរីដេអូបើកថ្មីចំនួន 02កន្លែង ស្ថិតនៅភូមិ1 សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទឱ្យមកសុំធ្វើច្បាប់អនុញ្ញាតនៅការិយាល័យច្រកចេញចូលតែមួយរដ្ឋបាលក្រុងខេមរភូមិន្ទ
- បានចុះត្រួតពិនិត្យការធ្វើអាជីវកម្មលក់ និងជួល CD VCD DVD និងណែនាំឱ្យបន្តធ្វើច្បាប់អនុញ្ញាត ស្ថិតនៅភូមិ2 សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ
- បានចុះត្រួតពិនិត្យច្បាប់អនុញ្ញាតអាជីវកម្ម និងណែនាំដល់អាជីវករមានច្បាប់អនុញ្ញាតហួសសុពលភាពឱ្យមកធ្វើច្បាប់អនុញ្ញាតនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុងខេមរភូមិន្ទបាន 04លើក
- បានចុះស្រង់ស្លាកសញ្ញាដែលលើកថ្មីចំនួន 08កន្លែង ស្ថិតនៅសង្កាត់ដងទង់ 07កន្លែង និងសង្កាត់ស្មាច់មានជ័យ 01កន្លែង ក្នុងក្រុងខេមរភូមិន្ទ
- ក្រុមឆ្មាំបានចុះបោសសម្អាតស្ថានីយមាន ៖
  - ស្ថានីយវាលផ្លេកប្រណាក ស្ថិតនៅភូមិជំនាប់ ឃុំជំនាប់ ស្រុកថ្មបាំង បាន 02លើក
  - ស្ថានីយអូរកើ ស្ថិតនៅភូមិជាំស្លា ឃុំជីផាត ស្រុកថ្មបាំង បាន 05លើក
  - ស្ថានីយភ្នំពែល ស្ថិតនៅឃុំជីផាត ស្រុកថ្មបាំង បាន 01លើក
  - ស្ថានីយរូងជំនាង ស្ថិតនៅភូមិទំពាំឃ្លៃ ឃុំប្រឡាយ ស្រុកថ្មបាំង បាន 02លើក
- បានសហការជាមួយអាជ្ញាធរចំនួន 02ស្រុក ៖
  - ស្រុកមណ្ឌលសីមា ចុះបោះបង្គោលបន្ថែមព័ទ្ធជុំវិញបរិវេណរមណីយដ្ឋានទីលានទាត់សីយុនឆាង យុនផែន ក្នុងភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - ស្រុកបូទុមសាគរ ចុះបោះបង្គោលកំណត់ព្រំដីបុរាណស្ថានអណ្ដូងមួយរយ ស្ថិតក្នុងភូមិអណ្ដូងទឹក ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ
- ធ្វើប្លង់កម្មសិទ្ធិរដ្ឋ បុរាណដ្ឋានទីលានទាត់សីយុនឆាង យុនផែន ក្នុងភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា និងបុរាណដ្ឋានអណ្ដូងមួយរយ ក្នុងភូមិអណ្ដូងទឹក ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង

- បានចុះត្រួតពិនិត្យស្ថានីយចំនួន 02កន្លែង ដែលមានស្ថានភាពនៅល្អប្រសើរពុំមានអ្វីប៉ះពាល់ ដល់វត្ថុសិល្បៈ និងស្ថានីយ ដូចជា ៖
    - រមណីយដ្ឋានទីលានទាត់សីយុនធាង យុនផែន ស្ថិតក្នុងឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
    - ស្ថានីយភ្នំពែល ស្ថិតក្នុងភូមិព្រែកស្វាយ ឃុំថ្មដូនពៅ ស្រុកថ្មបាំង
- ភ្ញៀវចូលទស្សនាការតាំងពិព័រណ៍បង្ហាញវត្ថុសិល្បៈដែលស្រង់ពីសំពៅលិច និងវត្ថុដែលមាននៅតាមជួរភ្នំក្រវាញ មានចំនួន 29នាក់ ស្រី 10នាក់
- បានចេញច្បាប់អនុញ្ញាត តាមរយៈការិយាល័យច្រកចេញចូលតែមួយរដ្ឋបាលក្រុងខេមរភូមិន្ទ មាន៖
    - បានចេញច្បាប់អនុញ្ញាតអាជីវកម្មលើកស្លាកយីហោចំនួន 15កន្លែង (សង្កាត់ស្មាច់មានជ័យចំនួន 08 សង្កាត់ដងទង់ចំនួន 04 និងសង្កាត់ស្ទឹងវែងចំនួន 03)
    - ចេញច្បាប់អនុញ្ញាតអាជីវកម្មអ៊ុតសក់ចំនួន 04កន្លែង (សង្កាត់ស្មាច់មានជ័យចំនួន 01 សង្កាត់ដងទង់ចំនួន 03)
- បានចេញច្បាប់អនុញ្ញាតអាជីវកម្មបណ្ណាគារចំនួន 01កន្លែង ក្នុងសង្កាត់ស្មាច់មានជ័យ តាមរយៈអង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត។

**៣.២.៦. ការងារកិច្ចការនារី**

- បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពី តួនាទី ភារកិច្ច របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ ចំនួន 01លើក ក្នុងគោលបំណង ដើម្បីពង្រឹងការអនុវត្តតួនាទីភារកិច្ចរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ក្រុង/ស្រុក (គ.ក.ស.ក) និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (គ.ក.ន.ក) ជាពិសេសក្នុងការអនុវត្តសេវាសង្គមទាំង4 តាមឃុំ/សង្កាត់ការរៀបចំផែនការសកម្មភាព និងផែនការថវិកា មានអ្នកចូលរួមសរុប 35នាក់ ស្រី 19នាក់ នៅសាលប្រជុំសាលាក្រុងខេមរភូមិន្ទ
- បានចុះផ្សព្វផ្សាយស្តីពី ឯកសារកំណែទម្រង់ថ្មីៗ ដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង/ស្រុក ចំនួន 07លើក ក្នុងគោលបំណង តាមដាន វាយតម្លៃ ការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង/ស្រុក ដើម្បីពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងការផ្តល់សេវាសង្គមជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យកាន់តែប្រសើរឡើង
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការសកម្មភាព និងផែនការថវិកា ឆ្នាំ2022 របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ចំនួន 01លើក ដើម្បីជានាប្រសិទ្ធភាពនៃការអនុវត្តតួនាទី ភារកិច្ច និងការពង្រឹងការងារសេវាសង្គមនៅថ្នាក់មូលដ្ឋានឱ្យកាន់តែប្រសើរ
- បានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងអាជ្ញាធរមូលដ្ឋាន ចុះប្រជុំពិភាក្សា ជាមួយកសិករក្រីក្រចំនួន 11គ្រួសារ ចំនួន 02លើក "**ស្តីពីការផ្តល់បច្ចេកទេសដាំដំណាំត្រសក់ទ្រើងតាមបែបបច្ចេកទេសទំនើប**" ដោយបានចុះពិនិត្យមើលទីតាំងដី ប្រភពទឹក ចែកគ្រាប់ពូជ ជី និងបច្ចេកទេសដាំ ដើម្បីឱ្យពួកគាត់បានចាប់ដំណើរការដាំដុះ នៅភូមិតានី និងភូមិភ្ញីមាស ឃុំភ្ញីមាស ស្រុកគិរីសាគរ
- បានចុះប្រជុំតាមដានវាយតម្លៃ លទ្ធផលការងារដាំដំណាំត្រសក់ទ្រើង របស់កសិករស្ត្រីក្រីក្រទាំង 11គ្រួសារ នៅភូមិតានី និងភូមិភ្ញីមាស ឃុំភ្ញីមាស ស្រុកគិរីសាគរ ចំនួន 01លើក។ ជាលទ្ធផល ការដាំដុះលើកទី1 កសិករទាំង 11គ្រួសារ ទទួលបានផលល្អទាំងអស់ ផលដែលទទួលបាន មានឈ្មួញទៅទិញដល់កន្លែង ប៉ុន្តែបន្ទាប់ពីប្រមូលផលលើកទី1ហើយ ត្រូវដាំដុះឡើងវិញជាលើកទី2 បន្តដាំដុះបានតែ 02គ្រួសារ ទេ ចំណែក 09គ្រួសារទៀត មានបញ្ហាដី និងលិចទឹក ធ្វើឱ្យពួកគាត់មិនអាចបន្តការដាំដុះឡើងវិញបាន

- បានសហការជាមួយអាជ្ញាធរ ចុះផ្សព្វផ្សាយជ្រើសរើសស្ត្រីក្រីក្រ ដើម្បីទទួលការបណ្តុះបណ្តាលជំនាញធ្វើអំបោស ចំនួន 02លើក នៅភូមិស្មាច់មានជ័យ សង្កាត់ស្មាច់មានជ័យ និងភូមិ4 សង្កាត់ដងទង់ ក្នុងគោលបំណង បង្កើន កម្រិតជីវភាពស្ត្រីក្នុងសហគមន៍ឱ្យកាន់តែប្រសើរជាងមុន។ បន្ទាប់មកក្រុមការងារបានបន្តផ្សព្វផ្សាយបន្ថែមដល់ប្រជាពលរដ្ឋ អំពីវិធីបង្ការ ការពារ ទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-19 ដោយអនុវត្ត 3ការពារ 3កុំ តាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល មានអ្នកចូលរួមសរុបចំនួន 54នាក់ ស្រី 50នាក់
- បានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើអំបោសស្មៅគ្រែងដល់ស្ត្រីក្រីក្រ និងស្ត្រីរងគ្រោះដោយអំពើហិង្សា មកពីភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ចំនួន 03នាក់ សង្កាត់ស្ទឹងវែង ចំនួន 03នាក់ និងសង្កាត់ស្មាច់មានជ័យ ចំនួន 06នាក់ សរុបចំនួន 12នាក់ នៅមន្ទីរកិច្ចការនារីខេត្ត។ គោលបំណង គឺដើម្បីផ្តល់ជំនាញដល់ស្ត្រីក្រីក្រ និងស្ត្រីដែលរងគ្រោះដោយអំពើហិង្សា ក្នុងការបង្កើនប្រាក់ចំណូលក្នុងគ្រួសារបានមួយផ្នែក និងរួមចំណែកកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ
- បានចុះសម្ភាសជាមួយសមាគមស្ត្រីផលិតស្រាបុរាណ (ស្រាចេក) នៅឃុំតាទៃលើ ស្រុកថ្មបាំង ចំនួន 02លើក និងក្រុមស្ត្រីដាំបន្លែ (ត្រសក់ ស្ពៃក្តោប ស្ពៃបូកគោ ខាត់ណា ផ្កាខាត់ណា...) នៅឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ចំនួន 01លើក ក្នុងគោលបំណង ដើម្បីផលិតជាព្រឹត្តិបត្រនារីរតនៈ កម្មវិធីវិទ្យុនាទីនារីរតនៈ និងវីដេអូអប់រំខ្លី ស្តីពីស្នាដៃស្ត្រី សម្រាប់ចាក់ផ្សាយតាមវិទ្យុជាតិ និងផេករបស់ក្រសួងកិច្ចការនារី។ ក្នុងកិច្ចសម្ភាសន៍នេះដែរ យើងសង្កេតឃើញថាការផលិតស្រាចេក និងការដាំដំណាំ របស់ពួកគាត់ទទួលបានលទ្ធផលល្អជាងមុន ពួកគាត់បានចងក្រងគ្នាជាក្រុម ពេលប្រមូលផលម្តងៗលក់ក្នុងតម្លៃមួយដូចគ្នា និងមានអ្នកចាំទទួលទិញជាប្រចាំផងដែរ។
- បានរៀបចំវគ្គបណ្តុះបណ្តាលកាត់ដេរ និងសម្អាងកាយ ដល់ស្ត្រី ក្មេងស្រីក្រីក្រ យុវវ័យបោះបង់ការសិក្សា និងស្ត្រីដែលរងគ្រោះដោយអំពើហិង្សាផ្សេងៗ ចំនួន 02វគ្គ មានអ្នកចូលរួមសរុបចំនួន 96នាក់(ស្រី)
- បានសហការជាមួយសាខាកាកបាទក្រហមកម្ពុជាខេត្ត អាជ្ញាធរសង្កាត់ទាំង3 នៃក្រុងខេមរភូមិន្ទ រដ្ឋបាលស្រុកស្រែអំបិល និងស្រុកមណ្ឌលសីមា ចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការបង្ការ ទប់ស្កាត់ និងការការពារពីជំងឺឆ្លងនានា ជាពិសេសជំងឺកូវីដ-19 តាមរយៈការបង្ហាញផ្ទាំងរូបភាព ណែនាំពីការធ្វើអនាម័យខ្លួន ការលាងសំអាតដៃ ជាមួយសាប៊ូ ដែល ឬ អាកុលជាដើម បានចំនួន 06លើក៖ នៅភូមិទួលគគីរក្រោម ឃុំទួលគគីរ ស្រុកមណ្ឌលសីមា, ភូមិព្រាំង ឃុំដងពែង ស្រុកស្រែអំបិល និងភូមិតានី ភូមិភ្ញីមាស ឃុំភ្ញីមាស ស្រុកគិរីសាគរ ភូមិព្រែកស្វាយ ភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង, ភូមិ2 ភូមិ4 សង្កាត់ដងទង់, ភូមិ2 ភូមិ3 ភូមិស្មាច់មានជ័យ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ មានអ្នកចូលរួមសរុប 332នាក់ ស្រី 249នាក់
- បានសហការជាមួយក្រសួងកិច្ចការនារី រៀបចំវេទិកាផ្សព្វផ្សាយស្តីពីការលើកកម្ពស់ការចូលរួមរបស់អ្នកម្តាយ ដើម្បីទប់ស្កាត់ការប្រើប្រាស់ និងចែកចាយគ្រឿងញៀន ដល់ប្រជាពលរដ្ឋ ចំនួន 01លើក នៅភូមិ1 ភូមិ2 និងភូមិប៉ាក់ខ្លង ស្រុកមណ្ឌលសីមា មានអ្នកចូលរួមសរុប 123នាក់ ស្រី 75នាក់ នៅវត្តសមុទ្ធារាម(វត្តប៉ាក់ខ្លង)
- បានចុះប្រមូលព័ត៌មាន ជួបពិភាក្សាជាមួយមេធាវីស្ម័គ្រចិត្ត គ្រួសារជនរងគ្រោះដោយករណីរំលោភ សេពសន្ថវៈ និងកំពុងបន្តដំណើរការដោះស្រាយតាមនីតិវិធីច្បាប់ ចំនួន 06ករណី ដែលកើតឡើងនៅស្រុកមណ្ឌលសីមា ស្រុកកោះកុង ស្រុកគិរីសាគរ ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល។ ជាលទ្ធផល បានឡើងសវនាការបញ្ចប់រឿង 02ករណី និង 04ករណីទៀត កំពុងដំណើរការតាមនីតិវិធីច្បាប់
- បានបើកវគ្គផ្សព្វផ្សាយស្តីពី ច្បាប់ទប់ស្កាត់ការរំលោភបំពានផ្លូវភេទ អំពើហិង្សា និងការធ្វើចំណាកស្រុក ដោយសុវត្ថិភាព ដល់ស្ត្រី និងក្មេងស្រីបោះបង់ការសិក្សា ចំនួន 01លើក ក្នុងគោលបំណងឱ្យស្ត្រី និងក្មេងស្រី ទទួលបានចំណេះដឹងទាក់ទងនឹងច្បាប់ទប់ស្កាត់ ការរំលោភបំពានផ្លូវភេទ អំពើហិង្សាផ្សេងៗ និងការធ្វើចំណាកស្រុក

ដោយសុវត្ថិភាព ពេលដែលគាត់ជួបបញ្ហាទាំងនោះ គាត់ដឹងពីទីកន្លែងដែលត្រូវទៅរកសេវាផ្នែកច្បាប់ជួយបានទាន់ពេលវេលា មានអ្នកចូលរួមសរុប 24នាក់ ស្រី 23នាក់ នៅមន្ទីរកិច្ចការនារីខេត្ត

- បានសម្របសម្រួល ករណីអំពើហិង្សា ចំនួន 07ករណី
- បានសម្របសម្រួល ករណីរំលោភសេពសន្ថវៈចំនួន 05ករណី
- បានសហការជាមួយអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធ ចុះសួរសុខទុក្ខ នាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន ជូនដល់គ្រួសារស្ត្រីក្រីក្រ ចាស់ជរា កុមារ ដែលកំពុងធ្វើចត្តាឡីស័កតាមខ្នងផ្ទះ និងជនរងគ្រោះដោយអំពើហិង្សាផ្សេងៗ ចំនួន 11លើក (ស្រុកកោះកុង ចំនួន 01លើក, សង្កាត់ស្ទឹងវែង ចំនួន 03លើក សង្កាត់ដងទង់ ចំនួន 03លើក និងសង្កាត់ស្មាច់មានជ័យ ចំនួន 04លើក)
- បានរៀបចំជាអាហារ និងភេសជ្ជៈ ចែកជូនក្រុមគ្រូពេទ្យដែលពួកគាត់លះបង់កម្លាំងកាយ កម្លាំងចិត្ត ក្នុងបេសកកម្មព្យាបាល និងការពារ ការរីករាលដាលនៃជំងឺកូវីដ-19 ដល់ប្រជាពលរដ្ឋក្នុងខេត្ត ចំនួន 02លើក ។

### ៣.២.៧. ការងារព័ត៌មាន

- អ្នកសារព័ត៌មាន ចូលមកយកព័ត៌មាននៅខេត្តកោះកុងចំនួន 53រូប
- បានសហការជាមួយរដ្ឋបាលខេត្ត ចុះពិនិត្យទីតាំងដំឡើងប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្មចំនួន 05ទីតាំង រួមមានៈ
  - ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) ដែលមានទីតាំងស្ថិតនៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
  - ធនាគារហត្ថា ម.ក សាខាខេត្តកោះកុង ដែលមានទីតាំងស្ថិតនៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរ-ភូមិន្ទ ខេត្តកោះកុង
  - គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ស្ថិតក្នុងភូមិ2 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
  - អាជីវកម្ម សំ វីរៈ លក់គ្រឿងអគ្គិសនី ស្ថិតក្នុងភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
  - អាជីវកម្ម សំ វីរៈ ដីឡូតិ៍ និងផ្ទះវីឡាកូនកាត់ ស្ថិតក្នុងភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
- បានដឹកនាំក្រុមការងារ ចុះចែកសេចក្តីជូនដំណឹង និងជំរុញអតិថិជនឱ្យទៅទទួលដាក់ពាក្យស្នើសុំបើក និងបន្តសុពលភាពអាជ្ញាប័ណ្ណលើវិស័យព័ត៌មាន នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត ក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុងបានចំនួន 35ទីតាំង
- បានដឹកនាំក្រុមការងារ ចុះផលិតបទយកការណ៍ ស្តីពីដំណាំត្រសក់ទ្រើងរបស់ប្រជាកសិករនៅឃុំភ្ញីមាស ស្រុកគិរីសាគរ ខេត្តកោះកុង
- អតិថិជនបានមកទទួលសេវាស្នើសុំបើក និងបន្តសុពលភាពអាជីវកម្មនៅអង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្តចំនួន 68សេវា
- ការថតវីដេអូ សរុបបានចំនួន 260ព័ត៌មាន បានផ្សាយ ៖
  - តាមរយៈទូរទស្សន៍ជាតិកម្ពុជា (ទទក) បានចំនួន 92ព័ត៌មាន
  - តាមរយៈទូរទស្សន៍បាយ័នបានចំនួន 168ព័ត៌មាន
- អំពីការផ្សាយតាមរយៈផេកហ្វេសប៊ុករបស់មន្ទីរព័ត៌មានខេត្ត
  - ផ្សាយព័ត៌មានដែលបានចុះយកក្នុងខេត្តចំនួន 204ព័ត៌មាន
  - ផ្សាយប្រសាសន៍សម្តេចតេជោ **ហ៊ុន សែន** និងព័ត៌មានផ្សេងៗបន្តចំនួន 204លើក
  - ផ្សាយសេចក្តីជូនដំណឹង និងលិខិតបទដ្ឋានផ្សេងៗចំនួន 217លើក

- ឆ្លើយឆ្លងព័ត៌មានពេលព្រឹក និងរាយការណ៍គ្រឿងញៀនតាមវិទ្យុសាគរកោះកុង
  - ព័ត៌មានតាម WhatsApp ជូនលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន 268លើក
  - ព័ត៌មានតាមហ្វេសប៊ុកចំនួន 38លើក
  - ឆ្លើយឆ្លងព័ត៌មានទទក ព័ត៌មានពេលព្រឹកចំនួន 31លើក
- ផ្សាយបន្តផ្ទាល់ពីវិទ្យុជាតិ
  - ព័ត៌មានជាតិបានចំនួន 500ព័ត៌មាន
  - ព័ត៌មានអន្តរជាតិបានចំនួន 203ព័ត៌មាន
  - កម្មវិធីសន្ទនាមតិ "ជីវិតយើងសង្គមយើង" បានចំនួន 230លើក
- ព័ត៌មានផ្សាយរបស់វិទ្យុសាគរកោះកុង
  - ព្រឹត្តិការណ៍សំខាន់ៗចំនួន 35
  - សន្និសីទសារព័ត៌មានចំនួន 08 ព័ត៌មាន
  - ព័ត៌មានពេលព្រឹករយៈពេល 30នាទីចំនួន 1,311ព័ត៌មាន
  - ព័ត៌មានខ្លីៗ ៖

    +ព័ត៌មានក្នុងខេត្តបានចំនួន 119ព័ត៌មាន

    +ព័ត៌មានថតផ្សាយជាសំឡេងបានចំនួន 119ព័ត៌មាន

    +ព័ត៌មានជាតិបានចំនួន 280ព័ត៌មាន

    +ព័ត៌មានអន្តរជាតិបានចំនួន 276ព័ត៌មាន
  - សេចក្តីជូនដំណឹងផ្សេងៗចំនួន 153អត្ថបទ
  - នាទីព្រះពុទ្ធសាសនាចំនួន 930ម៉ោង
  - នាទីកម្សាន្តមរតកដើមរួមមាន អាយ៉ៃ យីកេ ល្ខោនបាសាក់ និងល្ខោននិយាយបានចំនួន 345ម៉ោង
  - កម្មវិធីការយល់ដឹង នឹងរួមគ្នាទប់ស្កាត់ការចម្លងវីរុសកូវីដ-19 បានចំនួន 2 ម៉ោង
- **ផ្សព្វផ្សាយសារអប់រំ និងស្ប៉ត**
  - សារអប់រំ និងស្ប៉តស្តីពីគ្រោះថ្នាក់នៃគ្រឿងញៀនបានចំនួន 9,600លើក
  - សារអប់រំ និងស្ប៉តស្តីពី ពិសាគ្រឿងស្រវឹងសូមកុំបើកបរបានចំនួន 9,600លើក
  - សារអប់រំអំពីបញ្ហាជំងឺអេដស៍បានចំនួន 3,450លើក
  - សារអប់រំអំពីជំងឺគ្រុនចាញ់បានចំនួន 3,450លើក
  - ស្ប៉តសុខភាព (ញ៉ាំសាប) បានចំនួន 1,725លើក
  - ស្ប៉តស្តីពី ការបញ្ឈប់អំពើហិង្សាលើស្ត្រីបានចំនួន 3,450លើក
  - ស្ប៉តអប់រំអំពីវិធីការពារជំងឺកូវីដ-19 បានចំនួន 5,175លើក
  - សារអប់រំស្តីពី ការជួញដូរមនុស្សបានចំនួន 2,160លើក
- **ទីភ្នាក់ងារសារព័ត៌មានកម្ពុជា**
  - បញ្ជូនព័ត៌មានជូនអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជានៃក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយតាម APP ចំនួន 193ព័ត៌មាន ។

### ៣.២.៨. ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

- បានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ចំនួន 03ករណី ៖

- ○ លោកស្រី អេត ឈីវ មានទីលំនៅបច្ចុប្បន្ន ភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង បានដាក់ពាក្យស្នើសុំជួយអន្តរាគមន៍ និងសម្របសម្រួលករណី ឈ្មោះ ម៉ៃ សុខឃីម ទីលំនៅបច្ចុប្បន្នភូមិតាចាត ឃុំទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង មករំលោភទន្ទ្រានកាន់កាប់ដីរបស់គាត់ដែលមានទំហំ 10,5ហិកតា ស្ថិតនៅភូមិតាចាត ឃុំទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង
- ○ លោក នួន ប៉ាត់ មានទីលំនៅបច្ចុប្បន្ន ភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង បានដាក់ពាក្យស្នើសុំឱ្យជួយអន្តរាគមន៍លើដីទំនាស់ ដែលមានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង (ក្រោយត្រូវបានតុលាការចេញដីកា ចាប់ខ្លួនលោក នួន ប៉ាត់)។ ក្រុមការងារកំពុងស្រាវជ្រាវឯកសារពាក់ព័ន្ធចុះអន្តរាគមន៍ និងសម្របសម្រួល
- ○ លោក ឃួន ឈីវ និង លោក ទៀង ឃិន មានទីលំនៅបច្ចុប្បន្ន ភូមិថ្មស ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង តំណាងប្រជាពលរដ្ឋចំនួន 59គ្រួសារ បានដាក់ពាក្យស្នើសុំឱ្យជួយអន្តរាគមន៍លើដី ដែលមានទីតាំងនៅភូមិចំការលើ ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង

- បានអង្កេតស្រាវជ្រាវបណ្តឹងសមត្ថកិច្ចមន្ទីរ មានចំនួន 02ករណីៈ
  - ○ បានចុះពិនិត្យអង្កេតស្រាវជ្រាវទីតាំងដីក្នុងករណីវិវាទដីធ្លីរវាង ឈ្មោះ អេត ឈីវ ប្តឹងតវ៉ាទៅលើឈ្មោះ ម៉ៃ សុខឃីម បានរំលោភទន្ទ្រានកាន់កាប់ដី ស្ថិតនៅភូមិតាចាត ឃុំទួលគគីរ ស្រុកមណ្ឌលសីមា ខេត្តកោះកុង (ដោយសារពាក់ព័ន្ធជាមួយរដ្ឋបាលស្រុកមណ្ឌលសីមា ដូច្នេះមន្ទីរបានបញ្ជូនទៅរដ្ឋបាលស្រុកដោះស្រាយតាមនីតិវិធី
  - ○ កំពុងស្រាវជ្រាវឯកសារពាក់ព័ន្ធចុះអន្តរាគមន៍ និងសម្របសម្រួលករណីលើដីទំនាស់របស់ លោក នួន ប៉ាត់ ជាមួយ លោក ឃិន ហាន មានទីតាំងស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
- បានចូលរួមកិច្ចប្រជុំ និងចូលរួមពិធីផ្សេងៗមានចំនួន 161លើក។

**៣.២.៩. ការងារធម្មការ និងសាសនា**

- បានចុះផ្សព្វផ្សាយនូវលិខិតជូនដំណឹង ស្តីពីការអនុវត្តកាតព្វកិច្ចពាក់ម៉ាស និងរក្សាគម្លាតសុវត្ថិភាព នៅទីសាធារណៈ និងឯកជនដែលមានមនុស្សច្រើននៅបណ្តាវត្ត និងវិហារស្នាក់ការថ្វាយបង្គំបានចំនួន 07លើក
- បានសម្របសម្រួលជូនព្រះមន្ត្រីសង្ឃខេត្តទាំងពីរគណៈ ចូលរួមចាក់វ៉ាក់សាំងការពារជំងឺកូវីដ-19 បានចំនួន 05លើក
- បានចូលរួមជាមួយក្រុមការងារសាងសង់ជួសជុលទីលានផ្នូរយុទ្ធជនខេត្តកោះកុង ចុះត្រួតពិនិត្យ រៀបចំកន្លែងប្រារព្ធពិធីសម្ពោធបើកការដ្ឋានសាងសង់ និងបញ្ចុះបឋមសិលាទីលានផ្នូរយុទ្ធជនខេត្តកោះកុង ចំនួន 02លើក
- បានអំពាវនាវបន្តដល់ព្រះមន្ត្រីសង្ឃទាំងពីរគណៈ តំណាងគ្រីស្ទបរិស័ទ្ធ គណៈអ៊ីម៉ាំ គណៈចលនា និងសម្ព័ន្ធយុវជនមូស្លីមកម្ពុជាខេត្តកោះកុង ចូលរួមបរិច្ចាគថវិកាសរុបចំនួន 17,077,000រៀល និងគ្រឿងឧបភោគបរិភោគមួយចំនួនទៀត ដើម្បីសាងសង់អគារផលិតអ៊ុកស៊ីហ្សែន សម្រាប់ជួយសង្គ្រោះអ្នកជំងឺកូវីដ-19
- បានសហការជាមួយរដ្ឋបាលខេត្ត និមន្តព្រះមន្ត្រីសង្ឃទាំងពីរគណៈ ចំនួន 09អង្គ ចូលរួមពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី68 នៃទិវាបុណ្យឯករាជ្យជាតិ 9 វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ នៅបរិវេណស្តូប ខេត្តកោះកុង
- បានប្រគល់វិញ្ញាបនបត្របញ្ជាក់ការសិក្សា និងសៀវភៅកម្រង អត្ថបទឧទ្ទេសាចារ្យដល់ លោកអាចារ្យទាំង 03រូប ដែលបានចូលរៀនវគ្គបណ្តុះបណ្តាល តួនាទី ភារកិច្ច ក្រមសីល ធម៌អាចារ្យខ្មែរជំនាន់ទី36 ដែលជាធម្មទានរបស់ឯកឧត្តម ឈិត សុខុន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា នៅមន្ទីរធម្មការ និងសាសនាខេត្ត

- បានចូលរួមពិនិត្យស្ថានភាពព្រះសង្ឃចំនួន 55អង្គ ដែលនិមន្តពីវត្តទេពនិមិត្តហៅវត្តថ្មី មកគង់ដាច់ដោយឡែកនៅវត្តសាគរាម ហៅវត្តពាមក្រសោប ស្ថិតនៅក្នុងឃុំពាមក្រសោប ស្រុកមណ្ឌលសីមា តាមការរៀបចំរបស់ព្រះលក្ខណ៍មុនី ក្នុងគោលបំណងការពារការឆ្លងជំងឺកូវីដ-19 ជាយថាហេតុ
- បាននាំយកទេយ្យទាន និងទៀនចំណាំព្រះវស្សាសម្រាប់ប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់លោកជំទាវ **តៅ តឿន ទៀ បាញ់** និងលោកជំទាវ **ឈួង ចាលីក ប៊ុន លើត** ប្រគេនព្រះសង្ឃបានចំនួន 05វត្ត
- បានចូលរួមពិធីប្រកាសព្រះចៅអធិការស្តីទី ដើម្បីបន្តគ្រប់គ្រងវត្តសាគរាម ហៅវត្តពាមក្រសោប ស្ថិតក្នុងឃុំពាមក្រសោប ស្រុកមណ្ឌលសីមា ចំនួន 01លើក
- បានសហការជាមួយលោកមេឃុំតាតៃក្រោម នាំយកទៀនចំណាំព្រះវស្សា និងទេយ្យទាន ទៅប្រគេនចំនួន 02វត្ត រួមមាន៖ វត្តតាតៃក្រោម ស្ថិតក្នុងភូមិអន្លង់វ៉ាក់ និងវត្តកោះអណ្តែត ស្ថិតនៅភូមិកោះអណ្តែត ឃុំតាតៃក្រោម ស្រុកកោះកុង
- បានចូលរួមក្នុងពិធីបន្លឺសំឡេងស្គរ ជួងកងរំពង ក្រោមប្រធានបទ"សូមពិភពលោក រួចផុតពីជំងឺរាតត្បាតកូវីដ-19 និងអំពើជួញដូរមនុស្ស" បានចំនួន 04វត្ត
- បានចុះពិនិត្យសាលាពុទ្ធិកបឋមសិក្សា និងការសិក្សាសមណសិស្ស បានចំនួន 03លើក
- បានចូលរួមរៀបចំកិច្ចសាសនៈវិធី និងអមដំណើរថ្នាក់ដឹកនាំខេត្ត ក្នុងកម្មពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ បានចំនួន 14លើក
- បានសហការជាមួយសាលាគណខេត្តទាំងពីរគណៈ និងគណៈអ៊ីម៉ាំខេត្ត រៀបចំប្រារព្ធពិធីគោរព ព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** គម្រប់ខួប 9ឆ្នាំ បានចំនួន 03កន្លែង គឺ៖វត្តទេពនិមិត្ត ហៅវត្តថ្មី និងវត្តជោតញ្ញាណ នៅសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ និងវិហារភូមិ4 (វិហារឥស្លាម) ស្ថិតនៅភូមិ4 សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ
- បានទទួលការចាត់តាំងជាតំណាងរបស់ថ្នាក់ដឹកនាំខេត្ត នាំយកត្រៃកបិន ព្រមទាំងថវិកា ក្នុងពិធីបុណ្យកឋិនទាន បានចំនួន 02លើក
- បានសម្របសម្រួលបូជាសពអ្នកស្លាប់ដោយសារជំងឺកូវីដ-19 បានចំនួន 28នាក់ ស្រី 15នាក់
- បានចុះពិនិត្យ និងសម្របសម្រួលក្នុងការចាត់ចែងបញ្ចុះសពសាសនិកឥស្លាម បានចំនួន 02នាក់
- បានចុះពិនិត្យទីតាំង និងធ្វើការឈូសឆាយសម្រាប់កសាងឈាបនដ្ឋានសម្រាប់បូជាសពស្លាប់ដោយសារជំងឺកូវីដ-19 បានចំនួន 05លើក
- បានចុះទទួលឡសម្រាប់បូជាសពអ្នកស្លាប់ដោយជំងឺកូវីដ-19 ស្ថិតនៅទីតាំងភូមិទួលគគីរលើ ឃុំទួលគគីរ ស្រុកមណ្ឌលសីមា
- បានសម្របសម្រួលទទួលមឈូស ចំនួន 120 តម្កល់ទុក នៅវត្តសាលាម្នាង ស្រុកស្រែអំបិល ចំនួន 50មឈូស និងនៅវត្តជោតញ្ញាណចំនួន 70មឈូស
- បានចូលរួមចុះពិនិត្យទីតាំងត្រៀមសាងសង់ឈាបនដ្ឋានបូជាសពស្លាប់ដោយជំងឺកូវីដ-19 ចំនួន 03កន្លែង មានស្រុកមណ្ឌលសីមា ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
- បានចុះឃាត់សកម្មភាពរែអង្គាស់តាមទីសាធារណៈចំនួន 02លើក
- បានចូលរួមសហការជាមួយសាលាគណទាំងពីរគណៈ ផ្សព្វផ្សាយសេចក្តីជូនដំណឹងរបស់ក្រសួងធម្មការ និងសាសនាស្តីពីការវាយគង ជួង រគាំង ទូងស្គរ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-19 ចំនួន 02 លើក
- បានផ្សព្វផ្សាយបន្ត មេរៀនទូរសិក្សាបឋមសិក្សា របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ចំនួន 50លើក។

### ៣.២.១០ ការងារសាលាដំបូង

- **ផ្នែកចៅក្រមស៊ើបសួរ**
  - សំណុំរឿងសល់ពីមុនចំនួន 49រឿង
  - សំណុំរឿងចូលថ្មីចំនួន 333រឿង
  - សំណុំរឿងចាត់ការរួចចំនួន 292រឿង
  - សំណុំរឿងកំពុងចាត់ការចំនួន 90រឿង។
- **ផ្នែកចៅក្រមជំនុំជំរះ**
  - សំណុំរឿងសល់ពីមុនចំនួន 08រឿង
  - សំណុំរឿងចូលថ្មីចំនួន 287រឿង
  - សំណុំរឿងចាត់ការរួចចំនួន 304រឿង
  - សំណុំរឿងកំពុងចាត់ការចំនួន 22រឿង។
- **ផ្នែកតុលាការរដ្ឋប្បវេណី**
  - សំណុំរឿងសល់ពីមុនចំនួន 97រឿង
  - សំណុំរឿងចូលថ្មីចំនួន 170រឿង
  - សំណុំរឿងចាត់ការរួចចំនួន 146រឿង
  - សំណុំរឿងកំពុងចាត់ការចំនួន 121រឿង។

### ៣.២.១១. ការងារអយ្យការអមសាលាដំបូង

- សំណុំរឿងសល់ពីមុនចំនួន 28រឿង
- សំណុំរឿងចូលថ្មីចំនួន 479រឿង
- សំណុំរឿងចាត់ការរួចចំនួន 438រឿង
- សំណុំរឿងកំពុងចាត់ការចំនួន 08រឿង ។

## ៣.៣. ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ៣.៣.១. ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

- បានទទួលកម្រៃសេវាសាធារណៈ **(អង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត) ដូចខាងក្រោម៖**

  **ក-ការងារសំណង់ សរុបចំនួន 217,112,300៛**
  - បានទទួលគម្រោងស្នើសុំ ចំនួន 64 គម្រោង
  - បានអនុម័ត ចំនួន 53 គម្រោង

  **ខ-ការងារសុរិយោដី សរុបចំនួន 436,490,863៛**
  - បានទទួលគម្រោងស្នើសុំ ចំនួន 2,166 គម្រោង
  - បានអនុម័ត ចំនួន 2,292 គម្រោង

  **សរុបកម្រៃសេវាទទួលបានប្រចាំឆ្នាំមានចំនួន 653,603,163៛។**
- ការចុះកិច្ចសន្យា និងចាប់ឆ្នោតទទួលយកដីឡូតិ៍របស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងវិនិយោគរបស់ក្រុមហ៊ុនយូញៀនទទួលបានលទ្ធផលដូចខាងក្រោម៖
  - ក្រុមគ្រួសារប្រភេទ1 គ្រួសារអះអាងមានចំនួន 247គ្រួសារ គ្រួសារជាក់ស្តែងចំនួន 243គ្រួសារ បានចុះកិច្ចសន្យាចំនួន 110គ្រួសារ បានចាប់ឆ្នោតចំនួន 106គ្រួសារ នៅសល់ចំនួន 133គ្រួសារ

- ក្រុមគ្រួសារប្រភេទ2 គ្រួសារអះអាងមានចំនួន 255គ្រួសារ គ្រួសារដាក់ស្តែងចំនួន 217គ្រួសារ បានចុះកិច្ចសន្យាចំនួន 199គ្រួសារ បានចាប់ឆ្នោតចំនួន 199គ្រួសារ នៅសល់ចំនួន 18គ្រួសារ
- ក្រុមគ្រួសារប្រភេទ3 គ្រួសារអះអាងមានចំនួន 831គ្រួសារ គ្រួសារដាក់ស្តែងចំនួន 797គ្រួសារ បានចុះកិច្ចសន្យាចំនួន 792គ្រួសារ បានចាប់ឆ្នោតចំនួន 790គ្រួសារ នៅសល់ចំនួន 05គ្រួសារ
- បច្ចុប្បន្នមន្ទីរបានបញ្ចូលទិន្នន័យសរុបបានចំនួន 1,625ក្បាលដី ក្នុងនោះ ក្បាលដីត្រូវបែងចែកចំនួន 1,333ក្បាលដី និងក្បាលដីរក្សាទុកចំនួន 292ក្បាលដី

- ការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ
  - បំពេញទម្រង់បែបបទបាន ចំនួន 4,382 ក្បាលដី
  - គូសក្រាហ្វិកបាន ចំនួន 4,376 ក្បាលដី
  - ចេញលេខក្បាលដីបាន ចំនួន 4,488 ក្បាលដី
  - វាស់វែងបាន ចំនួន 4,488 ក្បាលដី
  - បញ្ចូលទិន្នន័យបាន ចំនួន 4,937 ក្បាលដី
  - បានប្រកាសតំបន់ធ្វើវិនិច្ឆ័យបានចំនួន 12ភូមិ ស្មើនឹង 01សង្កាត់ 03ឃុំ 01ស្រុក 01ក្រុង
  - បានបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យចំនួន 05ភូមិ ស្មើនឹង 2,711ក្បាលដី
  - បានចេញប័ណ្ណចំនួន 4ភូមិ ស្មើនឹង 2,941ប័ណ្ណ
  - បានចែកប័ណ្ណរួចចំនួន 2,261 ប័ណ្ណ
- ការងារចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ បានចំនួន 111ប័ណ្ណ
- ការចុះបញ្ជីដីរដ្ឋ
  - កំពុងវាស់វែងដីជូនក្រុមហ៊ុន Royal Group Co.,Ltd មានទំហំ 8,631ហិកតា
  - កំពុងវាស់វែងដីជូនក្រុមហ៊ុន GREEN RICH Co.,Ltd មានទំហំ 10,077ហិកតា
  - កំពុងវាស់វែងដីជូនក្រុមហ៊ុន SINOMEXIM Investment Co.,Ltd មានទំហំ 4,280ហិកតា
  - បានវាស់វែង និងចេញប័ណ្ណក្នុងតំបន់ការពារធម្មជាតិ ក្នុងដែនជម្រកសត្វព្រៃពាមក្រសោប តំបន់ចីរភាព និងតំបន់សហគមន៍ចំនួន 03ប័ណ្ណ ស្មើនឹង 3,547.7391ហិកតា
  - បានចេញវិញ្ញាបនបត្រសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុដីសម្បទានសង្គមកិច្ចបានចំនួន 01ក្បាលដី ស្ថិតនៅភូមិដីមាស ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង
- ការងារចុះបញ្ជីដីបន្ត
  - អចលនវត្ថុចុះបញ្ជីជាប្រព័ន្ធ
    + ចុះបញ្ជីផ្ទេរសិទ្ធិបានចំនួន 651ក្បាលដី
    + ចុះបញ្ជីប្រាតិភោគបានចំនួន 344ក្បាលដី
  - អចលនវត្ថុចុះបញ្ជីដាច់ដោយដុំ
    + ចុះបញ្ជីផ្ទេរសិទ្ធិបានចំនួន 09ក្បាលដី
    + ចុះបញ្ជីប្រាតិភោគបានចំនួន 75ក្បាលដី។

**៣.៣.២. ការងារបរិស្ថាន និងអនាម័យ**

- បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើគម្រោងនានា ដូចខាងក្រោម៖
  - គម្រោងសាងសង់ផ្លូវបេតុងអាមេ និងដាក់លូមូលកាត់ផ្លូវទោលនៅក្រុងខេមរភូមិន្ទ ចំនួន 07គម្រោង

- ○ គម្រោងសាងសង់ផ្លូវបេតុងអាមេ ប្រឡាយដោះទឹក 01កន្លែង លូមូលភ្លោះ 01កន្លែង លូមូលទោល 02 កន្លែង នៅស្រុកស្រែអំបិល សរុបចំនួន 10គម្រោង
  - ○ គម្រោងសាងសង់បេតុងអាមេ ផ្លូវក្រាលក្រួសក្រហម និងដាក់លូមូលភ្លោះ 03កន្លែង នៅស្រុកថ្មបាំង សរុបចំនួន 03គម្រោង
  - ○ គម្រោងសាងសង់ផ្លូវបេតុងអាមេ កំពង់ផែ 01កន្លែង អគាររដ្ឋបាលស្រុក 01ទីតាំង នៅស្រុកកោះកុង សរុបចំនួន 07គម្រោង
  - ○ គម្រោងសាងសង់ផ្លូវបេតុងអាមេនៅស្រុកគិរីសាគរ ចំនួន 02គម្រោង
  - ○ គម្រោងសាងសង់ផ្លូវបេតុងអាមេ ផ្លូវក្រាលក្រួសក្រហម 01ខ្សែ ដាក់លូទោល 03កន្លែង នៅស្រុកបូទុម-សាគរ សរុបចំនួន 09គម្រោង
  - ○ គម្រោងសាងសង់ផ្លូវបេតុងអាមេ នៅស្រុកមណ្ឌលសីមា ចំនួន 01គម្រោង
- បានត្រួតពិនិត្យការបំពុលបរិស្ថាន៖
  - ○ អាជីវកម្មខ្សាច់សំណង់ ចំនួន 07ទីតាំង
  - ○ សំណង់ផ្ទះចិញ្ចឹមសត្វត្រចៀកកាំចំនួន 04ទីតាំង
  - ○ អាជីវកម្មប្រមូលទិញសំណល់អេតចាយ ចំនួន 02ទីតាំង
- បានចុះបង្ក្រាបបទល្មើសតាមតំបន់ការពារធម្មជាតិ ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖
  - ○ កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តកោះកុងចំនួន 123ករណី
  - ○ ពិន័យអន្តរការណ៍លើការប្រមូលដឹកជញ្ជូនផល-អនុផលធនធានធម្មជាតិ ចំនួន 37ករណី
  - ○ ចាប់ឃាត់ឈើប្រណិតចំនួន 4,626គីឡូក្រាម + 2.300ម$^3$ និង75ដុំ ឈើអារ 26.38ម$^3$ និង 337សន្លឹក ឈើមូល 253ដើម ឈើម៉ែតាប់ 02ដុំ ឈើដើមគគីរខ្យាច់ 51ដើម វល្លិ៍ល្មៀត 1,475គីឡូក្រាម រថយន្ត 12 គ្រឿង គោយន្ត 03គ្រឿង ម៉ូតូ 12គ្រឿង រទេះ 02គ្រឿង អាប៊ុល 01គ្រឿង អេស្កាវ៉ាទ័រ 01គ្រឿង រណារយន្ត 390គ្រឿង កាំភ្លើងកែច្នៃចំនួន 60ដើម មេក្រូបំពង់សំឡេង 03គ្រឿង កាំបិត 03ដើម ពូថៅ 01ដើម អាគុយ 01គ្រឿង ឧបករណ៍ឆក់ត្រី 01គ្រឿង ធ្យូង 130បាវ សាច់សត្វព្រៃ 77.7គីឡូក្រាម និងសត្វពពូល ងាប់ 11ក្បាល
  - ○ រុះរើអន្ទាក់សត្វព្រៃចំនួន 14,651ខ្សែ មងចាប់សត្វព្រៃ 15,541ម៉ែត្រ លបកន្ទុយកណ្តុរ 03ដៃ បន្ទឹង 105 លបដាក់សត្វព្រៃ 03ដៃ និង 180ម៉ែត្រ អង្គប់ចាប់សត្វព្រៃ 02គ្រឿង ផ្លែសន្ទូចចាប់សត្វកន្ធាយ 66ផ្លែ លបដាក់សត្វព្រៃ 07 ខ្ទម 173ខ្ទម បង្គោលរបងចាប់យកដីព្រៃធ្វើជាកម្មសិទ្ធិ 980ដើម ឡធ្យូង 15ឡ កូន ដើមដូង 107ដើម កូនដើមចេក 408ដើម កូនដើមទុរេន 13ដើម ដើមទាបបារាំង 27ដើម កូនដើមប័រ 10 ដើម កូនដើមស្វាយចន្ទី 15ដើម កូនដើមស្វាយ 15ដើម ដើមខ្នុរ 05ដើម ដើមម្នាស់ 20ដើម
  - ○ បោះស្លាកហាមកាប់រុករានព្រៃយកដីធ្វើជាកម្មសិទ្ធិចំនួន 774ស្លាក
  - ○ លែងសត្វព្រៃក្នុងព្រៃធម្មជាតិវិញ ចំនួន 145ក្បាល
  - ○ ប្រទះការលោប និងបាញ់ថ្នាំពណ៌ កាប់គាស់ ឆ្ការដុត ឈូសឆាយព្រៃយកដីធ្វើជាកម្មសិទ្ធិខុសច្បាប់ចំនួន 71ករណី (ឧទ្យានជាតិបុទុមសាគរចំនួន 13ករណី ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល 11ករណី ដែនជម្រក សត្វព្រៃតាតៃ 11ករណី ដែនជម្រកសត្វព្រៃពាមក្រសោប 12ករណី តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង 07ករណី ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង 10ករណី របៀងអភិរក្សជីវៈចម្រុះចំនួន 07ករណី)
  - ○ ធ្វើកិច្ចសន្យា និងអប់រំផ្សព្វផ្សាយផ្នែកច្បាប់ចំនួន 136ករណី (ដែនជម្រកសត្វព្រៃតាតៃ 26ករណី ដែន ជម្រកសត្វព្រៃពាមក្រសោប 26ករណី ដែនជម្រកសត្វព្រៃភ្នំសំកុស 02ករណី ឧទ្យានជាតិបុទុមសាគរ

28ករណី ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល 17ករណី ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង 25ករណី តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង 11ករណី និងតំបន់របៀងអភិរក្សជីវៈចម្រុះចំនួន 01ករណី)

- ○ បានពន្លត់ភ្លើងឆេះព្រៃចំនួន 22ករណី (8ករណី ឃុំឫស្សីជ្រុំ 03ករណី ឃុំជ្រោយប្រស់ 02ករណី ឃុំអណ្តូងទឹក 04ករណី ឃុំត្រពាំងរូង 04ករណី ឃុំដងពែង 01ករណី ឃុំទួលគគីរ)
- ○ ដាំស្តារព្រៃឈើដូចជាដើមក្រញូង ដើមស្តៅព្រៃ ដើមធ្នឹកឧត្តម ដើមកកោះ ដើមដូងចែមចំនួន 210ដើម។

**៣.៣.៣. ការងារសាធារណការ និងកែលម្អសោភ័ណភាព**

- ការងារថែទាំជាប្រចាំកំណាត់ផ្លូវជាតិលេខ48 ក្រាលកៅស៊ូ DBST ប្រវែង 155.58គ.ម ពីចំការហ្លួង ដល់ច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម ចាប់ពីគ.ម 000+000 ដល់គ.ម 159+460 អនុវត្តបាន 100%
- ការដ្ឋានការងារថែទាំប្រចាំកំណាត់ផ្លូវខេត្តលេខ 1483 ក្រាលកៅស៊ូ DBST (ស្រែអំបិល) ពី គ.មលេខ 000+000 ដល់ គ.មលេខ 008+340 មានប្រវែងសរុប 8.34 គ.ម អនុវត្តបាន 100%
- ការដ្ឋានការងារថែទាំប្រចាំកំណាត់ផ្លូវខេត្ត 1489អា ក្រាលកៅស៊ូ DBST (ប៉ាក់ខ្លង) ពី គ.ម 000+000 ដល់ គ.ម008+630 មានប្រវែងសរុប 8.63គ.ម អនុវត្តបាន 100%
- ការដ្ឋានការងារថែទាំជាប្រចាំកំណាត់ផ្លូវខេត្តលេខ 1485អា ក្រាលដីល្បាយថ្ម (ថ្មស) ពី គ.មលេខ000+000ដល់ គ.មលេខ 033 + 600 មានប្រវែងសរុប 27.08គ.ម អនុវត្តបាន 100%
- ការដ្ឋានការងារថែទាំប្រចាំកំណាត់ផ្លូវខេត្តលេខ 1486 ក្រាលដីល្បាយថ្ម (ថ្មបាំង)ពី គ.ម លេខ000+000 ដល់ គ.មលេខ 038+200 មានប្រវែងសរុប 38.20គ.ម អនុវត្តបាន 100%
- ការដ្ឋានការងារថែទាំប្រចាំកំណាត់ផ្លូវខេត្តលេខ 1489 ក្រាលដីល្បាយថ្ម (ទួលគគីរ) ពី គ.ម លេខ000+000 ដល់ គ.មលេខ 012+400 មានប្រវែងសរុប 12.400គ.ម អនុវត្តបាន 100%
- ការងារថែទាំជាប្រចាំកំណាត់ផ្លូវជាតិលេខ 1485អា(ថ្មី) ក្រាលកៅស៊ូ DBST (ឃុំថ្មស) ចាប់ពីគ.ម 015+200 ដល់ គ.ម 020+500 ដែលមានប្រវែងសរុប 5.30 គីឡូម៉ែត្រ 93.26%
- ការងារថែទាំជាប្រចាំកំណាត់ផ្លូវជាតិលេខ 48-5 វិថីសាយកូថង ក្រាលកៅស៊ូ DBST ពីអូរម្កាក់ ឃុំអណ្តូងទឹក ដល់ឃុំកោះស្តេច ចាប់ពីគ.ម 000+000 ដល់ គ.ម 059+550 ដែលមានប្រវែងសរុប 46.44គីឡូម៉ែត្រ អនុវត្តបាន 100%
- គម្រោងកាត់ជួសជុលផ្លូវជាតិលេខ48-5 វិថីសាយកូថង (61) ចន្លោះ គ.ម 01+780 ដល់គ.ម 49+030 កាត់ជួសជុលក្រាលកៅស៊ូបាចថ្មពីរជាន់ DBST ប្រវែង 4,110ម ស្មើនឹងទំហំ 54.510$ម^2$ សម្រេចបាន 95%
- គម្រោងជួសជុលលើកំណាត់ផ្លូវខេត្តលេខ 1485អា (ឃុំថ្មស) ត្រង់គ.ម 28+600 ដល់គ.ម 30+600 ដោយក្រាលកៅស៊ូបាចថ្មពីរជាន់ DBST ប្រវែង 2,000ម ទទឹង 8ម សម្រេចបាន 47.86%
- ចុះបញ្ជីយានយន្ត ចំនួន 380គ្រឿង
- ការងារផ្ទេរកម្មសិទ្ធិយានយន្ត
  - ○ ផ្ទេរកម្មសិទ្ធិយានយន្តក្នុងខេត្ត ចំនួន 72គ្រឿង
  - ○ ផ្ទេរកម្មសិទ្ធិយានយន្តក្រៅខេត្ត ចំនួន 73គ្រឿង
- ការងារទុតិយតា-តតិយតាយានយន្ត
  - ○ ប័ណ្ណសម្គាល់ ចំនួន 10ប័ណ្ណ
  - ○ ស្លាកសម្គាល់ ចំនួន 05ស្លាក
  - ○ ប្តូរព័ត៌មាន ចំនួន 02គ្រឿង

- ការងារប័ណ្ណបើកបរយានយន្ត
  - ផ្តល់ប័ណ្ណបើកបរ ចំនួន 132ប័ណ្ណ
  - ការប្តូរ ពន្យារ ទុតិយតា-តតិយតា ចំនួន 73ប័ណ្ណ
- ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ចំនួន 750គ្រឿង
- បានចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតយានដ្ឋានជួសជុលយានយន្ត ចំនួន 01កន្លែង
- ការងារដឹកជញ្ជូនផ្លូវសមុទ្រ និងកំពង់ផែ
  - ចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់ជលយានយន្ត ចំនួន 10កន្លែង
  - ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម ចំនួន 07កន្លែង
  - ផ្ទេរកម្មសិទ្ធិជលយានយន្តចំនួន 05គ្រឿង
  - ចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានយន្តចំនួន 77គ្រឿង
- ការងារត្រួតពិនិត្យយានយន្តកែច្នៃ
  - រថយន្តត្រឹមត្រូវ ចំនួន 352គ្រឿង
  - រថយន្តហួសសុពលភាពធៀក ចំនួន 31គ្រឿង
  - ប្រើប័ណ្ណបើកបរខុសប្រភេទយានយន្ត ចំនួន 17នាក់
  - គ្មានប័ណ្ណបើកបរ ចំនួន 03នាក់
  - រថយន្តដឹកដីអត់គ្របតង់ ចំនួន 06គ្រឿង
  - រថយន្តគ្របតង់មិនត្រឹមត្រូវ ចំនួន 04គ្រឿង
  - មិនមានឯកសារត្រួតពិនិត្យ ចំនួន 02គ្រឿង
  - ប្រើប័ណ្ណហួសសុពលភាព ចំនួន 05នាក់
  - មិនមានអាជីវកម្ម ចំនួន 06គ្រឿង។

### ៣.៤. រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

#### ៣.៤.១. ការងារអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព

**១.ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត ៖**

**ក. ការពង្រឹងតួនាទី និងភារកិច្ច ៖** បានបែងចែកកម្លាំងប៉ុស្តិ៍នីមួយៗ ជាពីរក្រុមគឺ **ក្រុម (ក)** និង**ក្រុម (ខ)** ផ្លាស់ប្តូរវេនគ្នាប្រចាំការនៅស្នាក់ការប៉ុស្តិ៍ ដើម្បីទទួលជួបប្រជាពលរដ្ឋ ផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ តាមសំណូមពរ និងទាន់ពេលវេលា និងចេញល្បាតការពារជានាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងភូមិសាស្ត្ររបស់ខ្លួន និងធ្វើការងារសហគមន៍ សម្រេចបានលទ្ធផលល្អប្រសើរជាបន្តបន្ទាប់នូវជំនឿទុកចិត្តពីប្រជាពលរដ្ឋកាន់តែច្រើនឡើង។

**២.សភាពការណ៍បទល្មើស និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. សភាពការណ៍បទល្មើសព្រហ្មទណ្ឌ ៖** ក្នុងឆ្នាំ2021 នេះ បទល្មើសព្រហ្មទណ្ឌបានកើតឡើងចំនួន 43លើក បើធៀបនឹងឆ្នាំ2020 (ថយ 08លើក) គឺ បទល្មើសឧក្រិដ្ឋ 08លើក (កើនឡើង 04លើក) និងបទល្មើសមជ្ឈឹម 35 លើក (ថយចុះ 12លើក) បណ្តាលឱ្យស្លាប់មនុស្ស 03នាក់, របួស 20នាក់, រងគ្រោះ 23នាក់ បាត់ម៉ូតូ 06គ្រឿង និងសម្ភារផ្សេងៗមួយចំនួន

បទល្មើសដែលបានកើតឡើងទាំងអស់ខាងលើ កម្លាំងជំនាញបានខិតខំតស៊ូគ្រប់មធ្យោបាយ ដោយមានការសហការល្អពីសមត្ថកិច្ចពាក់ព័ន្ធ និងចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ ធ្វើឱ្យលទ្ធផលបង្ក្រាបទទួលបានល្អគួរជាទីមោទនៈ គឺ ចំនួន 42/43ករណី (ស្មើ 98% នៃចំនួនបទល្មើសដែលបានកើតឡើង) ឃាត់ខ្លួនជនសង្ស័យបានចំនួន 67នាក់ និងដកហូតវត្ថុតាង ម៉ូតូ 09គ្រឿង កាំបិត 06ដើម និងសម្ភារ មាស ប្រាក់មួយចំនួន

➢ មុខសញ្ញាសង្ស័យ 67នាក់ខាងលើ តេស្តទឹកនោមរកសារធាតុញៀន (វិជ្ជមាន 18នាក់) ។

➢ អនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់សាលាដំបូងខេត្ត សម្រេចបានចំនួន 07ដីកា ឃាត់ខ្លួន 07នាក់។

**ខ. បទល្មើសគ្រឿងញៀន៖** កម្លាំងជំនាញបង្ក្រាបបទល្មើសគ្រឿងញៀនបាន 49ករណី ឃាត់ខ្លួនជនសង្ស័យ 108នាក់ ស្រី 06នាក់ និងគ្រោះថ្នាក់ចរាចរណ៍ ស្លាប់ 01នាក់ប្រុស ក្នុងនោះ៖

– ជួញដូរ-ចែកចាយ និងរក្សាទុកនូវសារធាតុញៀនខុសច្បាប់ចំនួន 33ករណី រួមមាន នៅក្នុងស្រុកបូទុមសាគរ 03ករណី, ស្រុកគិរីសាគរ 02ករណី, ក្រុងខេមរភូមិន្ទ 19ករណី, ស្រុកមណ្ឌលសីមា 01ករណី និងស្រុកស្រែអំបិល 08ករណី ឃាត់ខ្លួនសរុបចំនួន 81នាក់ ស្រី 05នាក់

– រក្សាទុក និងប្រើប្រាស់នូវសារធាតុញៀនខុសច្បាប់ចំនួន 16ករណី រួមមាន នៅក្នុងស្រុកគិរីសាគរ 01ករណី, ក្រុងខេមរភូមិន្ទ 07ករណី និងស្រុកមណ្ឌលសីមា 08ករណី ឃាត់ខ្លួនសរុបចំនួន 27នាក់ ស្រី 01នាក់

➢ ដកហូតវត្ថុតាង ថ្នាំញៀន ប្រភេទ Heroin 212.04គ.ក្រ, ICE 230.52ក្រាម, Wy 428គ្រាប់ ស្មើនឹង 38.52ក្រាម, ម៉ូតូ 17គ្រឿង, រថយន្ត 02គ្រឿង, ទូក 01គ្រឿង, ទូរស័ព្ទ 54គ្រឿង, ជញ្ជីងថ្លឹងថ្នាំញៀន 01, សម្ភារវេចខ្ចប់ និងឧបករណ៍ជក់ថ្នាំញៀនមួយចំនួន

➢ មុខសញ្ញាទាំងអស់ខាងលើ បានបំពេញសំណុំរឿងបញ្ជូនតាមនីតិវិធីច្បាប់។

**គ. ល្បែងស៊ីសងខុសច្បាប់ ៖** កម្លាំងជំនាញបានបង្ក្រាបល្បែងជល់មាន់ 05លើក ឃាត់ខ្លួនម្ចាស់ទីតាំងបញ្ជូនទៅសាលាដំបូងខេត្ត 01នាក់ប្រុស (ក្នុងក្រុងខេមរភូមិន្ទ) ដកហូតវត្ថុតាង មាន់ជល់ 02ក្បាល ស៊ុមក្រុងមាន់ 45ស៊ុម និង ម៉ូតូ 11គ្រឿង ក្នុងនោះ នៅស្រុកបូទុមសាគរ 03លើក ស្រុកគិរីសាគរ 01លើក និងក្រុងខេមរភូមិន្ទ 01លើក។ ចំណែកអ្នកលេងល្បែងទាំងនេះ បានរត់គេចខ្លួនអស់ ហើយកម្លាំងជំនាញកំពុងបន្តការស្រាវជ្រាវ។

**ឃ. បទល្មើសផ្សេងៗ ៖** ការប្រើប្រាស់អាវុធ គ្រឿងផ្ទុះខុសច្បាប់ ពុំមានអ្វីកត់សម្គាល់។

➢ *វិធានការបង្ការ* ៖ កម្លាំងជំនាញនៅតាមបណ្តាប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ចុះធ្វើការអប់រំ ណែនាំប្រជាពលរដ្ឋក្នុងតំបន់ណាដែលមានការសង្ស័យថាមានយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះសល់ពីសម័យសង្គ្រាមឱ្យមានការប្រុងប្រយ័ត្ន ហើយបើបានប្រទះឃើញត្រូវរាយការណ៍ជូនកម្លាំងសមត្ថកិច្ច ដើម្បីមានវិធានការការពារ។ ដាក់ស្តែងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះសល់ពីសម័យសង្គ្រាម ដែលសមត្ថកិច្ចបានទទួលព័ត៌មានពីប្រជាពលរដ្ឋចំនួន 06លើក មានចំនួន 27គ្រាប់ និងអាវុធកែច្នៃ 01ដើម បានប្រគល់ជូនអង្គភាព ស៊ីម៉ាក់ និង ហេឡូត្រាស់ យកទៅកម្ទេចចោល

– ថ្ងៃទី30/10/2021 នៅភូមិជីត្រេះ ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ មានក្មេងប្រុស 03នាក់ ពេលកំពុងឃ្វាលក្របី បានប្រទះឃើញយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះសល់ពីសម័យសង្គ្រាម ប្រភេទត្បាល់ 60មីលីម៉ែត្រ 01គ្រាប់ ក៏នាំគ្នាយកមកគប់លេង បណ្តាលឱ្យផ្ទុះរងរបួសជើងទាំង 03នាក់។

**៣. សភាពការណ៍សណ្តាប់ធ្នាប់ និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. សភាពការណ៍គ្រោះថ្នាក់ចរាចរណ៍ ៖** បានកើតឡើងចំនួន 19លើក បើធៀបនឹងឆ្នាំ2020 (ថយ 10លើក ស្មើនឹង 34% ) បណ្តាលឱ្យមនុស្សស្លាប់ 19នាក់ របួស 14នាក់ ខូចម៉ូតូ 19គ្រឿង និងរថយន្ត 10គ្រឿង

➢ *វិធានការបង្ការ ៖* បានបញ្ចុះកម្លាំងជំនាញសហការជាមួយកម្លាំងពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយអប់រំណែនាំដល់អ្នកបើកបរយានយន្តគ្រប់ប្រភេទ នៅតាមទីប្រជុំជន តាមដងផ្លូវកែងសំខាន់ៗ និងចុះអប់រំអាជីវករលក់ដូរជុំវិញផ្សារ លក់ដូរអមសងខាងផ្លូវឱ្យរៀបចំអីវ៉ាន់លក់ដូរឱ្យមានសណ្តាប់ធ្នាប់ល្អ សំដៅកាត់បន្ថយការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ជាយថាហេតុ។

**៤. បទល្មើសជួញដូរមនុស្ស ជួញដូរផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ និងក្មេងទំនើង និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. បទល្មើសជួញដូរមនុស្ស និងជួញដូរផ្លូវភេទ ៖** ក្នុងឆ្នាំ2021 នេះ បង្ក្រាបបទល្មើសរំលោភសេពសន្ថវៈចំនួន 05លើក កើតឡើងក្នុងឃុំប៉ាក់ខ្លង 01លើក, ឃុំជីខលើ 02លើក ឃុំបឹងព្រាវ 01លើក ឃុំស្រែអំបិល 01លើក និងរំលោភសម្លាប់ នៅក្នុងឃុំត្រពាំងរូង 01លើក ឃាត់ខ្លួនជនសង្ស័យសរុបចំនួន 05នាក់ប្រុស

កម្លាំងជំនាញបានសហការជាមួយអាជ្ញាធរមូលដ្ឋានចុះបិទផ្សព្វផ្សាយសេចក្តីណែនាំលេខ 016ស.ណ.នរបស់ស្នងការដ្ឋាននគរបាលខេត្ត និងខ្លឹមសារច្បាប់ស្តីពីការបង្ការ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទដល់គោលដៅ ផ្ទះសំណាក់ សណ្ឋាគារជាបន្តបន្ទាប់ ។

**ខ. អំពើហិង្សាក្នុងគ្រួសារ ៖** ចំនួន 03លើក រួមមាន៖

– នៅភូមិត្រពាំងរូង ឃុំត្រពាំងរូង ស្រុកកោះកុង 01លើក ដោយការប្រច័ណ្ឌ ហើយប្តីបានវាយប្រពន្ធ បណ្តាលឱ្យរងរបួសស្នាម

– នៅភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ 01លើក បង្កឡើងដោយកូនប្រុស ជាមុខសញ្ញាប្រើប្រាស់ថ្នាំញៀន បានយកពូថៅកាប់បំផ្លាញសសរផ្ទះរបស់ឪពុកម្តាយ និងគំរាមកាប់ម្តាយ និងប្អូនស្រី

– នៅក្នុងភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ 01លើក បង្កឡើងដោយប្តីបានវាយប្រពន្ធ-កូន បណ្តាលឱ្យរងរបួសស្នាម

➢ សង្ស័យទាំង 03នាក់ ត្រូវបានកម្លាំងនគរបាលឃាត់ខ្លួន បំពេញសំណុំរឿងបញ្ជូនតាមនីតិវិធីច្បាប់។

**គ. សកម្មភាពក្មេងទំនើង ៖** កម្លាំងជំនាញបង្ក្រាបបានចំនួន 05លើក នៅក្នុងក្រុងខេមរភូមិន្ទ 04លើក និងនៅក្នុងស្រុកមណ្ឌលសីមា 01លើក ឃាត់ខ្លួន 11នាក់ប្រុស បង្កសកម្មភាពវាយតប់គ្នា និងវាយបំផ្លាញទ្រព្យសម្បត្តិឪពុក-ម្តាយ បានបំពេញសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្ត ចាត់ការបន្ត

➢ *វិធានការការពារ៖* បានពង្រឹងកម្លាំងនៅថ្នាក់មូលដ្ឋាន ចុះល្បាតត្រួតពិនិត្យឃ្លាំមើលជាប្រចាំក្នុងមូលដ្ឋាន ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពបង្កឡើងដោយក្មេងទំនើង ឬ ជនទំនើង។

**៥. ការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព ៖**

គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រុង ស្រុក បានខិតខំយកចិត្តទុកដាក់ពិនិត្យ និងដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការតាមយន្តការផ្សះផ្សាជូនប្រជាពលរដ្ឋជាបន្តបន្ទាប់ ដាក់ស្តែងក្នុងឆ្នាំនេះ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងរដ្ឋបាលខេត្តកោះកុង បានធ្វើពិធីចាប់ឆ្នោតប្រគល់ដីឡូត៍ជូនប្រជាពលរដ្ឋរស់នៅក្នុងស្រុកបូទុមសាគរ និងស្រុកគិរីសាគរ ជាបន្តបន្ទាប់ ដែលរងផលប៉ះពាល់ជាមួយគម្រោងវិនិយោគអភិវឌ្ឍន៍ក្រុមហ៊ុនយូញៀន

ថ្ងៃទី20 ខែតុលា ឆ្នាំ2021 អាជ្ញាធរស្រុកថ្មបាំង បានដឹកនាំក្រុមការងារចុះបោះបង្គោលព្រំប្រទល់ដី រវាងដីការពារធនធានធម្មជាតិ និងដីកាត់ឆ្វៀលជូនប្រជាពលរដ្ឋ ចំនួន 57នាក់ ស្រី 10នាក់ ដែលប្រជាពលរដ្ឋទាំងនេះ បានតវ៉ាថាក្រុមការងារចុះវាស់វែងបោះបង្គោលព្រំដីតាមអនុក្រឹត្យលេខ30 ធ្វើឱ្យចូលដល់ដីអាស្រ័យផលរបស់ពួកគាត់។

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ ៖**

រដ្ឋបាលខេត្ត ក្រុង ស្រុក ក៏ដូចជាមន្ទីរ អង្គភាពជុំវិញខេត្ត បានយកចិត្តទុកដាក់ខ្ពស់អំពីបញ្ហាសុខភាព អនាម័យ និងបរិស្ថាន សំដៅធ្វើឱ្យទីក្រុងស្អាត រមណីយដ្ឋានល្អ ដើម្បីទាក់ទាញភ្ញៀវទេសចរជាតិ-អន្តរជាតិ មកកម្សាន្តក្នុងខេត្តកោះកុង ដែលជាប្រភពចំណូលរបស់ប្រជាពលរដ្ឋ ។

**៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព ៖**

**ក. សភាពការណ៍គ្រោះមហន្តរាយ ៖** កើតឡើង 37លើក បើធៀបនឹងឆ្នាំ2020 (កើនឡើង 20លើក) គឺ ៖

– ករណីអគ្គិភ័យ 05លើក ឆេះផ្ទះ 04ខ្នង ឆេះតូប 01តូប ខូចខាតសម្ភារប្រើប្រាស់មួយចំនួន

– ខ្យល់ព្យុះ 32លើក របើកដំបូលផ្ទះ 310ខ្នង និងរលំផ្ទះ 03ខ្នង

➢ *ឆ្លើយតប* ៖ គ្រោះថ្នាក់ទាំង 37លើកនេះ កម្លាំងជំនាញនៅថ្នាក់មូលដ្ឋានបានចុះជួយអន្តរាគមន៍ដល់កន្លែងកើតហេតុ និងក្រុមការងារសាខាកាកបាទក្រហមកម្ពុជា ខេត្ត ក្រុង ស្រុក ចុះសាកសួរសុខទុក្ខ និងផ្តល់អំណោយដល់គ្រួសារ រងគ្រោះជាបន្តបន្ទាប់

➢ *វិធានការទប់ស្កាត់* ៖ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល បានចុះបំផុសអប់រំប្រជាពលរដ្ឋឱ្យមានការប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់អគ្គិភ័យ ខ្យល់កន្ត្រាក់ និងទឹកជំនន់ ។ល។

**ខ. ឆ្លើយតបរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព ៖** ស្ថិតក្នុងដំណាក់កាលដែលពិភពលោកកំពុងជួបវិបត្តិការរីករាលដាល នៃជំងឺកូវីដ-19 គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត បានកសាងផែនការបញ្ចុះកម្លាំងសហការជាមួយអង្គភាពពាក់ព័ន្ធដែលកំពុងឈរជើងប្រតិបត្តិការក្នុងភូមិសាស្ត្រខេត្តកោះកុង ដោយបានបែងចែកកម្លាំងល្បាត និងឈរជើងនៅតាមច្រកធម្មជាតិ និងនៅតាមបណ្តោយឆ្នេរសមុទ្រមានដងព្រែកធំ-តូចជាច្រើន ដើម្បីការពារប្រជាពលករលបលួចឆ្លងដែនចូលដោយពុំបានអនុវត្តវិធានការតាមជំនាញសុខាភិបាលត្រឹមត្រូវ ឱ្យមកអនុវត្តវិធានសុខាភិបាល។ ឆ្នាំ2021 នេះ កងកម្លាំងសមត្ថកិច្ចឃាត់ពលករត្រឡប់មកពីប្រទេសថៃ តាមរបៀងព្រៃភ្នំ តាមសមុទ្រ និងតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ប្រគល់ជូនអាជ្ញាធរដាក់ឱ្យធ្វើចត្តាឡីស័កសរុបចំនួន 1,170នាក់ ស្រី 356នាក់ បានបញ្ចប់ធ្វើចត្តាឡីស័ក ចំនួន 1,138នាក់ ស្រី 348នាក់ កំពុងបន្តដាក់ឱ្យធ្វើចត្តាឡីស័ក ចំនួន 32នាក់ ស្រី 08នាក់ និងឃាត់ខ្លួនមេខ្យល់ លួចនាំពលករឆ្លងដែនដោយខុសច្បាប់ ចំនួន 15នាក់ប្រុស ជនជាតិខ្មែរ បានបំពេញសំណុំរឿងបញ្ជូនទៅសាលាដំបូង ខេត្តចាត់ការបន្ត ចំនួន 13នាក់ និងបានធ្វើកិច្ចសន្យាអប់រំណែនាំចំនួន 02នាក់ ។

**៣.៤.២. ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍**

- **សភាពការណ៍សន្តិសុខនៅតាមព្រំដែន៖**

ខេត្តកោះកុង ព្រំដែនខាងលិច មាន 01ឃុំប៉ាក់ខ្លង របស់ស្រុកមណ្ឌលសីមា ជាប់ព្រំប្រទល់ជាមួយស្រុកខ្លងយ៉ៃ ខេត្តត្រាត ប្រទេសថៃ ហើយមានខ្សែបន្ទាត់ព្រំដែនប្រវែង 53គីឡូម៉ែត្រ (ចាំយាម"ខេត្តកោះកុង"ដល់អូរវំដេង"ខេត្តពោធិ៍សាត់")ក្នុងនោះប្រវែង 19គីឡូម៉ែត្រ(ចាំយាម-គីរីវង្ស) ទទួលខុសត្រូវកិច្ចប្រតិបត្តិការដោយវរសេនាតូចនគរបាលការពារព្រំដែន លេខ827 ចំណុះស្នងការដ្ឋាននគរបាលខេត្តកោះកុង និងប្រវែង 34គីឡូម៉ែត្រ ទទួលខុសត្រូវដោយកម្លាំងកងយោធពលខេមរភូមិន្ទ។ ក្នុងឆ្នាំ2021 នេះ មានសន្តិសុខ សុវត្ថិភាពពេញលេញ កងកម្លាំង និងអាជ្ញាធរនៃប្រទេសទាំងពីរ មានកិច្ចសហប្រតិបត្តិការល្អ ប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកជាធម្មតា ប៉ុន្តែច្រកទ្វារព្រំដែនត្រូវបានបិទ ដើម្បីបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-19។

អង្គភាពវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ827 បានសហការជាមួយកងយោធពលខេមរភូមិន្ទឈរជើងការពារ រក្សាបូរណភាពទឹកដីតាមខ្សែបន្ទាត់ព្រំដែនបានយ៉ាងល្អប្រសើរ ហើយមានទីបញ្ជាការស្ថិតនៅចំណុចនិយាមការ ¬WGS.84¦ 273343E.1288343N មានក្របខ័ណ្ឌសរុបចំនួន 190នាក់ ស្រី 14នាក់ មានផ្នែកជំនាញ 05 ផ្នែក ប៉ុស្តិ៍ការពារព្រំដែន 04ប៉ុស្តិ៍ និងប៉ុស្តិ៍សង្កេតការណ៍ 04ប៉ុស្តិ៍ ឈរជើងប្រតិបត្តិការនៅចន្លោះបង្គោលសីមាព្រំដែនចំនួន 03 គឺ ៖

- បង្គោលសីមាលេខ 71 (ធំ)ចំណុច N=1303543.6047m-E=270125.0873m ស្ថិតក្នុងភូមិគីរីវង្ស
- បង្គោលសីមាលេខ 72 ចំណុច N=1289148.2949m-E=272748.4114m ស្ថិតនៅចំណុចប៉ុស្តិ៍ពយ ក្នុងភូមិចាំយាម
- បង្គោលសីមាលេខ 73 (តូច)ចំណុច N=1289149.2410m-E=271831.7540m ស្ថិតនៅមាត់សមុទ្រក្នុងភូមិចាំយាម។ បង្គោលទាំង 3នេះ ស្ថិតក្នុងភូមិសាស្ត្រឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ជាប់ព្រំប្រទល់ស្រុកខ្លងយ៉ៃខេត្តត្រាតប្រទេសថៃ

- សភាពការណ៍ក្រៅភូមិសាស្ត្រ មានចំនួន 60លើក រួមមាន៖
  - ទាហានថៃ ប្រដាប់ដោយអាវុធធន់ M16 អាវុធខ្លី និងវិទ្យុទាក់ទង ដើរល្បាតតាមបណ្តោយព្រំដែនមុខភូមិសាស្ត្រ ប៉ុស្តិ៍ពយ ប៉ុស្តិ៍វង់កាបៈ ប៉ុស្តិ៍207 និងប៉ុស្តិ៍គិរីវង្ស បានជួបកម្លាំងយើងកំពុងដើរល្បាត ចំនួន 54លើក ។
  - ទាហានថៃប្រើប្រាស់ឧទ្ធម្ភាគចក្រ 01គ្រឿង មកចុះចតដាក់ស្បៀងឱ្យកងកម្លាំងរបស់គេតាមបណ្តោយព្រំដែន ចំនួន 04លើក

○ ប្រតិភូថៃ ចំនួន 25នាក់ បានចុះត្រួតពិនិត្យភូមិសាស្ត្រតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តត្រាត ចាប់ពីថ្ងៃទី21 ដល់ 23 ខែធ្នូ ឆ្នាំ2020 ចំនួន 01លើក

○ ថ្ងៃទី30/12/2020 មានឧទ្ធម្ភាគចក្រថៃ 02គ្រឿង មកចុះចតចំណុចបង្គោលសីមាលេខ73 ចំនួន 01លើក ដឹកមេបញ្ជាការរបស់គេមកសួរសុខទុក្ខកងបញ្ជាការការពារព្រំដែនច័ន្ទបុរី-ត្រាត និងត្រួតពិនិត្យបង្គោលសីមាលេខ73 និង លេខ71 ។

– កិច្ចប្រតិបត្តិការ ៖

○ បានចេញល្បាតម្ចាស់ការតាមខ្សែបន្ទាត់ព្រំដែន ចំនួន 217លើក (ក្នុង មួយលើកៗ ប្រើប្រាស់កម្លាំងពី 07 ទៅ 09នាក់) អាវុធគ្រប់ដៃ និងសហការល្បាតជាមួយកងយុទ្ធពលខេមរភូមិន្ទ 21លើក។ បានចូលរួមសហការជាមួយសមត្ថកិច្ចមូលដ្ឋាន ចុះការពារសន្តិសុខ សុវត្ថិភាពក្នុងពិធីបុណ្យផ្សេងៗ និងការពារគណៈប្រតិភូជាតិ-អន្តរជាតិ ដែលបានឆ្លងកាត់តំបន់កំពុងឈរជើង ទទួលបានសុវត្ថិភាពល្អ។ បានចូលរួមជាមួយអាជ្ញាធរ និងសមត្ថកិច្ចមូលដ្ឋាន ក្នុងការអនុវត្តគោល នយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ជាប់ជាប្រចាំ

○ ថ្ងៃទី11/12/2021 បានចាត់តាំងកម្លាំងចូលរួមការបារក្រុមការងាររុករកបង្គោលសីមាព្រំដែនកម្ពុជា-ថៃ ទៅដំឡើងម៉ាស៊ីន GPS ដើម្បីរកទិន្នន័យនិយាមកាដាក់លាក់នៅចំណុចតម្រុយបង្គោលសីមាលេខ 71-72 និង 73 ចំនួន 01លើក

○ បានបញ្ចុះកម្លាំង 13គោលដៅ នៅតាមច្រករបៀងធម្មជាតិព្រៃភ្នំដើម្បីឃ្លាំមើលពលករលួចឆ្លងដែនខុសច្បាប់ ដាក់ស្ដែងកម្លាំងយើងឃាត់ពលករខ្មែរលួចឆ្លងដែនចេញ-ចូលចំនួន 52លើក(ចេញទៅថៃ 06លើក និងត្រឡប់មកពីថៃ 46លើក) មានពលករចំនួន 146នាក់ ស្រី 37នាក់ បានប្រគល់ឱ្យអាជ្ញាធរយកទៅដាក់ក្នុងមណ្ឌលធ្វើចត្តាឡីស័ក ដើម្បីបង្ការការរាតត្បាតនៃជំងឺកូវីដ-19។

– ***សភាពការណ៍អង្គការ សមាគម និងសាសនា៖*** អង្គការក្រៅរដ្ឋាភិបាលកំពុងប្រតិបត្តិការក្នុងខេត្ត មាន 11អង្គការ មានបុគ្គលិកបម្រើការងារ ចំនួន 141នាក់ ស្រី 13នាក់ និងសមាគម 11សមាគម មនុស្សរួម 2,928នាក់ ហើយមានសកម្មភាពគួរកត់សម្គាល់ចំនួន 07លើក រួមមាន ៖

○ អង្គការសហគមន៍កសិករកម្ពុជា CCFC មកពីភ្នំពេញចំនួន 02នាក់ប្រុស ចុះមកបង្រៀនអំពីការតស៊ូមតិក្នុងសហគមន៍ 01លើក ដល់ក្រុមសកម្មជនតវ៉ាដីធ្លី ក្នុងឃុំជីខលើ ស្រុកស្រែអំបិល

○ អង្គការអាដហុក ប្រចាំខេត្តកោះកុង ដឹកនាំដោយលោក ថោង ច័ន្ទតារា បានចុះទៅភូមិតាផង ឃុំដងពែង ស្រុកស្រែអំបិល ប្រមូលប្រជាពលរដ្ឋចំនួន 25នាក់ ស្រី 20នាក់ ធ្វើពិធីប្រារព្ធសិទ្ធិមនុស្ស 10ធ្នូ 01លើក ប៉ុន្តែដើម្បីបង្ការការឆ្លងនៃជំងឺកូវីដ-19 អាជ្ញាធរមិនអនុញ្ញាតឱ្យធ្វើឡើយ ប្រជាពលរដ្ឋក៏រំសាយអស់

○ មានអង្គការជំនួយព្រះវិហារសាទីម៉ាក (DCA) អង្គការសម្ព័ន្ធបេសកកម្ម (MA) និងអង្គការជំនួយរបស់ប្រជាពលរដ្ឋន័រវេស (NPA) បានចុះមកឃុំជីខលើ ស្រុកស្រែអំបិល 01លើក ធ្វើពិធីផ្ដល់ជំនួយសម្ភារស្បៀងអាហារ ដើម្បីគាំទ្រជីវភាពកសិករដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-19 នៅក្នុងស្រុកស្រែអំបិល និងស្រុកបូទុមសាគរ ចំនួន 190គ្រួសារ ក្នុងមួយគ្រួសារៗ ទទួលបានអង្ករ 50គ.ក្រ និងត្រីខ 06កំប៉ុង

○ អង្គការសកម្មភាពប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ (PAD) បានចុះមកភូមិធ្នង់ ឃុំកណ្ដោល ស្រុកបូទុសាគរ ចែកស្រូវពូជចំនួន 100គ.ក្រ និងពូជមាន់ 02ក្បាល ជូនដល់សកម្មជនតវ៉ាដីធ្លីចំនួន 117គ្រួសារ

○ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានឃាត់ខ្លួនប្រជាពលរដ្ឋ 02នាក់ប្រុស ពីបទទន្ទ្រានយកដីរដ្ឋធ្វើកម្មសិទ្ធិ នៅក្នុងភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង។ ជនសង្ស័យត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តចាត់ការបន្ត

○ អង្គការលីកាដូ បាននាំយកគ្រឿងឧបភោគបរិភោគចែកជូនប្រជាពលរដ្ឋ និងចាស់ជរា ដែលស្ថិតក្នុងតំបន់បិទខ្ទប់ បង្ការការឆ្លងរីករាលដាលនៃជំងឺកូវីដ-19 ចំនួន 65គ្រួសារ មកពី 3ឃុំ ក្នុងស្រុកស្រែអំបិល (ឃុំដងពែង ឃុំជីខលើ និងឃុំជីខក្រោម) ដោយក្នុង 01គ្រួសារទទួលបានអង្ករ 25គ.ក្រ ត្រី សាច់ បន្លែ សាប៊ូ ម៉ាស់ និងអាល់កុលមួយចំនួន

○ អង្គការសមធម៌ (EC) មានសមាជិក 03នាក់ (ជនបរទេស 01នាក់) បាននាំយកពូជដំណាំមកផ្តល់ជូន និងបង្រៀនអំពីបច្ចេកទេសដាំដុះ ដល់ប្រជាពលរដ្ឋចំនួន 18នាក់ ស្រី 07នាក់ រស់នៅភូមិជីខ ឃុំជីខលើ ស្រុកស្រែអំបិល។

- **សកម្មភាពសហគមន៍-ពលរដ្ឋតវ៉ាផ្សេងៗ ៖**

○ សកម្មភាពសហគមន៍ប្រជាពលរដ្ឋប្រមូលផ្តុំតវ៉ាបញ្ហាដីធ្លី នៅក្នុងស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកគិរីសាគរ បានប្រមូលផ្តុំគ្នានៅថ្នាក់មូលដ្ឋានចំនួន 39លើក ដើម្បីសុំឱ្យអាជ្ញាធរជួយពន្លឿនការដោះស្រាយបញ្ហាចាស់ៗដែលដោះស្រាយពុំទាន់ចប់តាមការចង់បានរបស់ពួកគាត់ និងសកម្មជនតវ៉ាដីធ្លីទាំងនេះដែរបានឡើងមកប្រមូលផ្តុំគ្នានៅមុខសាលាដំបូងខេត្ត ដើម្បីគាំទ្រតំណាងរបស់គាត់ ដែលត្រូវបានតុលាការកោះហៅឱ្យចូលខ្លួនមកបំភ្លឺករណីបរិហាកេរ្តិ៍អ្នកដទៃ និងកាប់ទន្រ្ទានដីព្រៃរបស់រដ្ឋ ចំនួន 07លើក

រាល់ការប្រមូលផ្តុំរបស់សកម្មជនខាងលើ អធិការដ្ឋាននគរបាលក្រុង ស្រុក បានបញ្ចុះកម្លាំងសហការជាមួយកម្លាំងពាក់ព័ន្ធ ការពារសន្តិសុខ សណ្តាប់ធ្នាប់ ដោយពុំមានអ្វីកើតឡើងគួរឱ្យកត់សម្គាល់ឡើយ ។

- **សភាពការណ៍គ្រោះថ្នាក់សង្គម៖** គ្រោះថ្នាក់ផ្សេងៗ 39លើក ស្លាប់ 39នាក់ របួស 02នាក់។

### ៣.៤.៣. ការងារគ្រប់គ្រងពន្ធនាគារ

- ជនជាប់ឃុំជាក់ស្តែងមានចំនួន 651នាក់ ស្រី 47នាក់ ដោយចែកចេញជា៖
  - ជនត្រូវចោទចំនួន 39នាក់ ស្ត្រី 01នាក់
  - ជនជាប់ចោទចំនួន 65នាក់ ស្ត្រី 07នាក់
  - ពិរុទ្ធជនចំនួន 119នាក់ ស្ត្រី 06នាក់
  - ទណ្ឌិតចំនួន 428នាក់ ស្ត្រី 33នាក់

  ក្នុងនោះមាន៖
  - ជនជាតិបរទេសចំនួន 15នាក់ ស្ត្រី 03នាក់ (វៀតណាម 10នាក់ ស្ត្រី 03នាក់ ថៃ 03នាក់ប្រុស និងចិន 02នាក់ប្រុស)
  - អនីតិជនចំនួន 41នាក់ ស្ត្រី 05នាក់
  - ស្ត្រីមានផ្ទៃពោះចំនួន 00នាក់
  - កូនតាមម្តាយចំនួន 03នាក់ស្ត្រី
- ជនជាប់ឃុំចូលថ្មីមានចំនួន 262នាក់ ស្ត្រី 19នាក់ អនីតិជន 37នាក់
- ជនជាប់ឃុំត្រូវបានដោះលែងមានចំនួន 272នាក់ ស្ត្រី 39នាក់ អនីតិជន 30នាក់ ស្ត្រី 05នាក់ ។

### ៣.៤.៤. ការងារគ្រប់គ្រងជនអន្តោប្រវេសន៍

- **ការគ្រប់គ្រងការចេញ-ចូលប្រទេស ៖**

○ នាវិកជាជនបរទេសចូលចំនួន 241នាក់ ស្រី 89នាក់ មាន 01សញ្ជាតិ ថៃ ស្មើនឹងជលយានយន្ត 39គ្រឿង អូសសាឡង់ 168គ្រឿង និងចេញវិញចំនួន 250នាក់ ស្រី 84នាក់ មាន 01សញ្ជាតិថៃ ស្មើនឹងជលយានយន្ត 38គ្រឿង អូសសាឡង់ 155គ្រឿង

○ នាវិកកម្ពុជាចូលចំនួន 4,828នាក់ប្រុស ជលយានយន្ត 218គ្រឿង និងចេញវិញ 4,828នាក់ ជលយានយន្ត 218គ្រឿង ។

- **ការគ្រប់គ្រងការស្នាក់នៅរបស់ជនបរទេស ៖**

○ ការិយាល័យជំនាញគ្រប់គ្រងជនបរទេស សហការជាមួយអធិការដ្ឋាននគរបាលក្រុងស្រុក និងប៉ុស្តិ៍នគរបាលរដ្ឋបាល ផ្សព្វផ្សាយសេចក្តីណែនាំលេខ 028.ស.ណ.ន របស់ក្រសួងមហាផ្ទៃ និងសេចក្តីណែនាំលេខ 0183.ស.ណ.ន របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងបានភ្ជាប់កម្មវិធីតាមប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា (FPCS) ជូនដល់តំណាង ឬម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ក្រុមហ៊ុន បានចំនួន 194គោលដៅ

○ ការគ្រប់គ្រងវត្តមានស្នាក់នៅរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត ៖ ស្នាក់នៅរយៈពេលខ្លី 2,107នាក់ ស្រី 617នាក់ មាន 45សញ្ជាតិ និងរយៈពេលវែងចំនួន 873នាក់ ស្រី 208នាក់ មាន 31សញ្ជាតិ

○ ការគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត ៖ បានទទួលពាក្យស្នើសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ពីជនបរទេសអន្តោប្រវេសន្ត ចំនួន 129គ្រួសារ មនុស្សរួម 269នាក់ ស្រី 131នាក់ អាយុ 18ឆ្នាំឡើង 215នាក់ ស្រី 97នាក់ ស្មើនឹង 02 សញ្ជាតិ (វៀតណាម-មីយ៉ាន់ម៉ា) រួមមាន៖

+ ជនបរទេសអន្តោប្រវេសន្ត ទើបគ្រប់អាយុស្នើសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកដំបូង ចំនួន 02នាក់ ប្រុស ស្មើនឹង 01សញ្ជាតិ (វៀតណាម)

+ ជនបរទេសអន្តោប្រវេសន្ត ស្នើសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី1 ចំនួន 111គ្រួសារ មនុស្សរួម 240នាក់ ស្រី 107នាក់ អាយុ 18ឆ្នាំឡើង 189នាក់ ស្រី 85នាក់ ស្មើនឹង 02សញ្ជាតិ(វៀតណាម-មីយ៉ាន់ម៉ា)

+ ជនបរទេសអន្តោប្រវេសន្ត ស្នើសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី2 ចំនួន 18គ្រួសារ មនុស្សរួម 27នាក់ ស្រី 14នាក់ អាយុ 18ឆ្នាំឡើង 24នាក់ ស្រី 12នាក់ ស្មើនឹង 01សញ្ជាតិ (វៀតណាម)

+ សរុបថវិកាអាករបានពីប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ 215នាក់x250,000រៀល=53,750,000រៀល បានបញ្ជូនពាក្យស្នើសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ និងថវិកាទៅនាយកដ្ឋានជនបរទេសអន្តោប្រវេសន្តរួចរាល់

○ បានទទួលប្រកាសទទួលស្គាល់ជនបរទេសអន្តោប្រវេសន៍ (1ប្រ.ក) និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ពីនាយកដ្ឋានអន្តោប្រវេសន្តចំនួន 180នាក់ ស្រី 80នាក់ ស្មើនឹង 180ប័ណ្ណ មាន 03សញ្ជាតិ (វៀតណាម មីយ៉ាន់ម៉ា តង់ហ្សានៀរ)។

○ បានដាក់សំណើសុំគោលការណ៍ កូនជនបរទេសអន្តោប្រវេសន្ត ចំនួន 15នាក់ ស្រី 06នាក់ ទទួលសិទ្ធិជាជនបរទេសអន្តោប្រវេសន្តស្របច្បាប់ ទៅនាយកដ្ឋានអន្តោប្រវេសន៍

○ កម្លាំងជំនាញអធិការដ្ឋាននគរបាលស្រុកគិរីសាគរ បានដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេស 02នាក់ស្រី ស្មើនឹង 02សញ្ជាតិ (វៀតណាម និងថៃ) មាន 05ឯកសារ ដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅស្នាក់នៅ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត និងលិខិតអនុញ្ញាតផ្លាស់ប្តូរលំនៅឋាន

○ ការគ្រប់គ្រងជនបរទេសជាអ្នកវិនិយោគ និងហត្ថពលករបរទេស ៖ ក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស ធ្វើការត្រួតពិនិត្យពលករបរទេសចំនួន 39គោលដៅ មានពលករខ្មែរចំនួន 10,248នាក់ ស្រី 6,582នាក់ និងពលករជនបរទេសចំនួន 568នាក់ ស្រី 160នាក់ ក្នុងនោះពលករបរទេស ប្រើប្រាស់ទិដ្ឋាការប្រភេទ E ចំនួន 520នាក់ ប្រភេទ C ចំនួន 48នាក់ (មានប័ណ្ណការងារ និងសៀវភៅការងារ 520នាក់ គ្មានប័ណ្ណការងារ និងសៀវភៅការងារ 48 នាក់ «ប្រើប្រាស់ទិដ្ឋាការ C »)។

- **សភាពការណ៍ជនបរទេស**

○ **ជនបរទេសល្មើសច្បាប់អន្តោប្រវេសន៍ ៖** ចំនួន 04លើក រួមមាន ៖

+ ជនជាតិថៃ 02នាក់ស្រី (លិខិតឆ្លងដែនគ្មានទិដ្ឋាការ) បានបញ្ជូនចេញតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម

+ ជនជាតិចិន 05នាក់ប្រុស វៀតណាម 03នាក់ស្រី និងអាល្លឺម៉ង់ 01នាក់ប្រុស (គ្មានលិខិតឆ្លងដែន) បានបញ្ជូនទៅស្នាក់ការត្រៀមបណ្តេញចេញ នៅខេត្តព្រះសីហនុ

○ **ជនបរទេសប្រព្រឹត្តបទល្មើសផ្សេងៗ ៖** ចំនួន 03លើក រួមមាន ៖

+ ជនជាតិថៃ 01នាក់ប្រុស លួចម៉ូតូ 01គ្រឿង នៅព្រំដែនចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា និងដកហូតវត្ថុតាង ម៉ូតូ 01គ្រឿង ជនសង្ស័យត្រូវបានឃាត់ខ្លួន

+ ជនជាតិចិន 01នាក់ប្រុស រំលោភលើទំនុកចិត្ត (ដកប្រាក់ក្នុងក្រុមហ៊ុនរកស៊ីជាមួយជនរងគ្រោះ យកទៅចាយមិនព្រមសង) នៅភូមិតានូន ឃុំតានូន ស្រុកបូទុមសាគរ (ជនសង្ស័យត្រូវបានឃាត់ខ្លួន)

+ ជនជាតិថៃ 02នាក់ប្រុស ជួញដូរ និងរក្សាទុកនូវសារធាតុញៀនខុសច្បាប់ ប្រភេទ Heroin នៅភូមិចម្ការក្រោមឃុំស្រែអំបិល ស្រុកស្រែអំបិល (ជនសង្ស័យត្រូវបានឃាត់ខ្លួន)

○ **ជនបរទេសរងគ្រោះដោយបទល្មើសផ្សេងៗ ៖** ពុំមាន។

○ **ជនបរទេសរងគ្រោះដោយឧប្បទ្ទវហេតុផ្សេងៗ ៖** ចំនួន 05លើក ស្លាប់ 04ប្រុស របួស 01នាក់ប្រុស រួមមាន ៖

+ ជនជាតិចិន 03នាក់ ស្លាប់ដោយគាំងបេះដូង 01នាក់ ស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ 01នាក់ របួស 01នាក់

+ កាណាដា 01នាក់ ស្លាប់ដោយជំងឺរ៉ាំរ៉ៃ

+ ម៉ាឡេស៊ី 01នាក់ ស្លាប់ដោយជំងឺលើសឈាម

○ **ទទួលពាក្យបណ្តឹងពីជនបរទេស** ៖ (ពុំមាន)។

### ៣.៥. ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង

តាមរយៈសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦ នៃរដ្ឋសភា និងដោយមានកិច្ចសហការជាមួយរដ្ឋបាលមូលដ្ឋានគ្រប់លំដាប់ថ្នាក់ បានធ្វើឱ្យការរក្សាសន្តិសុខសណ្តាប់ធ្នាប់ ការងារសេដ្ឋកិច្ច សង្គម និងការដោះស្រាយបញ្ហា មានភាពល្អប្រសើរ។ សមិទ្ធផលដែលសម្រេចបានអាស្រ័យដោយក្រុមការងារគ្រប់ថ្នាក់ បានយកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានឆន្ទៈមុតមាំក្នុងការអនុវត្តបទបញ្ជា សេចក្តីណែនាំ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ជាមួយកិច្ចសហការគាំទ្រទៅវិញទៅមក ក្នុងគោលដៅច្បាស់លាស់ ធ្វើឱ្យការដោះស្រាយបញ្ហាផ្សេងៗជូនប្រជាពលរដ្ឋ នៅតាមមូលដ្ឋានទទួលបានលទ្ធផលល្អប្រសើរ។ ទន្ទឹមនឹងនេះ រដ្ឋបាលខេត្ត បានពុះពារជម្នះបញ្ហាប្រឈមជាច្រើនដោយមានការឧបត្ថម្ភគាំទ្រពី **សម្តេចពិជ័យសេនា** ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ព្រមទាំងក្រុមការងារខេត្ត ក្រុង ស្រុក និងអាជ្ញាធរមូលដ្ឋាន ធ្វើឱ្យរដ្ឋបាលខេត្តអាចអនុវត្តបានដោយជោគជ័យនូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរបស់ខ្លួន រួមជាមួយនឹងការសម្រេចបាននូវសមិទ្ធផល សំខាន់ៗជាច្រើន។

#### ១-អំពីស្ថានភាព និងសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាល

**១.១-តារាងអំពីសមាសភាពក្រុមការងាររាជរដ្ឋាភិបាល**

| សមាសភាព | សរុប | ស្រី | សមាសភាពក្រុមការងារ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | ថ្នាក់ជាតិ | | ថ្នាក់ក្រោមជាតិ | | |
| | | | សរុប | ស្រី | សរុប | ស្រី | |
| ក្រុងខេមរភូមិន្ទ | ៣៨ | ១៤ | ០៨ | ០០ | ៣០ | ១៤ | |
| ស្រុកមណ្ឌលសីមា | ៣៦ | ១០ | ០៦ | ០០ | ៣០ | ១០ | |

| | | | | | | |
|---|---|---|---|---|---|---|
| ស្រុកថ្មបាំង | ៣៩ | ០១ | ១០ | ០១ | ២៩ | ០០ | |
| ស្រុកគិរីសាគរ | ៣៨ | ០៣ | ០៩ | ០១ | ២៩ | ០២ | |
| ស្រុកបូទុមសាគរ | ៥២ | ០៣ | ២៤ | ០១ | ២៨ | ០២ | |
| ស្រុកស្រែអំបិល | ៥៨ | ០៣ | ២៨ | ០២ | ៣០ | ០១ | |
| ខេត្តកោះកុង | ៩៥ | ០៧ | ៩៤ | ០៦ | ០១ | ០១ | |
| **សរុបទូទាំងខេត្ត** | **៣៥៦** | **៤១** | **១៧៩** | **១១** | **១៧៧** | **៣០** | |

**២-សកម្មភាពសំខាន់ៗ ដែលក្រុមការងាររាជរដ្ឋាភិបាលអនុវត្តបាន**

**២.១- ការរៀបចំកិច្ចប្រជុំផ្ទៃក្នុង**

ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ បានបើកកិច្ចប្រជុំដើម្បីត្រួតពិនិត្យ និងពិភាក្សាលើលទ្ធផលការងារ បញ្ហាដីធ្លី ការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះឈ្នះ ខេត្តកោះកុង ការជួសជុលសាងសង់ទីលានផ្នូរសពយុទ្ធជន កិច្ចការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការអភិវឌ្ឍក្នុងមូលដ្ឋាន និងកិច្ចប្រជុំផ្សេងៗទៀត ចំនួន ៥២០លើក មានអ្នកចូលរួមចំនួន ៩.៤៥០នាក់ ស្រី ១៧៤នាក់។

**២.២- ការរៀបចំវេទិកាសាធារណៈ**

ដោយសារវិបត្តិជំងឺកូវីដ-១៩ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ពុំបានរៀបចំវេទិកាសាធារណៈឡើយ។

**២.៣- ការចូលរួមសកម្មភាពក្នុងព្រឹត្តិការណ៍នានានៅមូលដ្ឋាន**

ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ បានចុះបើកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ចូលរួមក្នុងពិធីបើកការដ្ឋាន និងសម្ពោធសមិទ្ធផលនានា ព្រមទាំងចុះធ្វើការជួសជុលសាងសង់ទីលានផ្នូរសពយុទ្ធជន ជាពិសេស ការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះឈ្នះ ខេត្តកោះកុង ចុះសិក្សាស្រាវជ្រាវទីតាំងប្រវត្តិសាស្ត្រតស៊ូរបស់ **សម្តេចពិជ័យសេនា** និងទីតាំងតំបន់អភិវឌ្ឍវិស្សមកាល **សម្តេចពិជ័យសេនា** ចំនួន ៥៣លើក មានអ្នកចូលរួមចំនួន ៧.៧០៣នាក់ ស្រី ៣.៨៤៥នាក់។

**២.៤- ក្រុមការងារបានចុះជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋ**

ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ បានចូលរួមសកម្មភាពនានា នៅតាមមូលដ្ឋានដើម្បីជួបសំណេះសំណាល សួរសុខទុក្ខ នាំយកអំណោយចែកជូនប្រជាពលរដ្ឋ ចុះផ្សព្វផ្សាយអំពីជំងឺកូវីដ-១៩ ចុះដោះស្រាយបញ្ហាដីធ្លី ចុះពិនិត្យមើលការស្ថាបនានានា ចុះបណ្តុះបណ្តាលអំពីបច្ចេកទេសដាំដំណាំកសិកម្ម ការចិញ្ចឹមសត្វ ការកែច្នៃផលិតផល ចូលរួមពិធីបុណ្យសាសនា ជួយច្រូតកាត់ប្រមូលផល ចុះចែកអត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ប័ណ្ណក្រីក្រ ជូនប្រជាពលរដ្ឋ និងសកម្មភាពនានា ផ្សេងទៀតសរុបចំនួន ៥៦២លើក មានអ្នកចូលរួមសរុបចំនួន ១៣.០៧៨នាក់ ស្រី ៦.២១២នាក់។

| សកម្មភាព | ចំនួន (ដង) | សមាសភាពក្រុមការងារ | | | | សរុប | | ប្រជាពលរដ្ឋ | |
|---|---|---|---|---|---|---|---|---|---|
| | | ថ្នាក់ជាតិ | | ថ្នាក់ក្រោមជាតិ | | សរុប | ស្រី | សរុប | ស្រី |
| | | សរុប | ស្រី | សរុប | ស្រី | | | | |
| ការរៀបចំកិច្ចប្រជុំផ្ទៃក្នុង | ៥២០ | ១៥០ | ១៥ | ៤៥៥ | ៦៧ | ៩៤៥០ | ១៧៤០ | ៣៤០ | ៩២ |
| ការរៀបចំវេទិកាសាធារណៈ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ការចូលរួមសកម្មភាពក្នុងព្រឹត្តិការណ៍នានានៅមូលដ្ឋាន | ៥៥៣ | ៨៥ | ៥ | ២៦៤ | ៤០ | ៧៧០៣ | ៣៨៤៥ | ៧៣៥៤ | ៣៨០០ |
| ក្រុមការងារបានចុះជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋ | ៥៦២ | ៧៨ | ៧ | ១៩៥ | ៥៨ | ៤៤៣០ | ២១៩៣ | ៣៩៧២ | ២០៨០ |
| សរុប | ១៦៣៥ | ៣១៣ | ២៧ | ៩១៤ | ១៦៥ | ២១៥៨៣ | ៧.៧៣៨ | ១១៦៦៦ | ៥៩៧២ |

**៣-លទ្ធផលនៃការរៀបចំវេទិកាសាធារណៈ**

**៣.១-តារាងបញ្ហាប្រឈម**

– (ទិន្នន័យឆ្នាំ២០២០)

| ប្រភេទ នៃបញ្ហា | ចំនួនករណី | ភាគរយ % | បានដោះស្រាយ % | កំពុងដោះស្រាយ % | មិនទាន់បានដោះស្រាយ % | ស្នើទៅថ្នាក់ជាតិ % | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| សំណើ | ៣១ | ២៦,៧២% | ៤១,៩៤% | ២៩,០៣% | ២៩,០៣% | 00% | |
| សំណូមពរ | ២៩ | ២៥% | ៦៨,៩៧% | ២៤,១៤% | ០៦,៩០% | 00% | |
| កង្វល់ | ១៣ | ១១,២១% | ៤៦,១៥% | ៣៨,៤៦% | ១៥,៣៨% | 00% | |
| ទំនាស់ | ៤៣ | ៣៧,០៧% | ៣០,២៣% | ៣៧,២១% | ៣០,២៣% | ២,៣៣% | |
| **សរុប** | **១១៦** | **100%** | | | | | |

**៣.២-តារាងប្រភេទ នៃជំណោះស្រាយ តាមវិស័យគិតជាភាគរយខ្ពស់**

– (ទិន្នន័យឆ្នាំ២០២០)

| ល.រ | ប្រភេទនៃជំណោះស្រាយ បញ្ហាប្រឈមតាមវិស័យ | សរុបករណី | ភាគរយ (%) | បានដោះស្រាយ% | កំពុងដោះស្រាយ% | មិនទាន់បានដោះស្រាយ% | ផ្ញើទៅថ្នាក់ជាតិ% |
|---|---|---|---|---|---|---|---|
| ១ | វិស័យអភិវឌ្ឍន៍ជនបទ | ១២ | ១០,៣៤ | ៥០ | ៣៣,៣៣ | ១៦,៦៧ | 0 |
| ២ | វិស័យធនធានទឹក និងឧតុនិយម | ៧ | ៦,០៣ | ៨៥,៧១ | 0 | ១៤,២៩ | 0 |
| ៣ | វិស័យគ្រប់គ្រងរដ្ឋបាលដីធ្លី | ៥១ | ៤៣,៩៧ | ៣១,៣៧ | ៣៩,២២ | ២៧,៤៥ | ១,៩៦ |
| ៤ | វិស័យអប់រំយុវជន និងកីឡា | 0 | 0 | 0 | 0 | 0 | 0 |
| ៥ | វិស័យអគ្គិសនី | ១១ | ៩,៤៨ | ៤៥,៤៥ | ៤៥,៤៥ | ៩ | 0 |
| ៦ | វិស័យសន្តិសុខសណ្តាប់ធ្នាប់មូលដ្ឋាន | ៥ | ៤,៣១ | ៤០ | ៦០ | 0 | 0 |
| ៧ | ការផ្តល់សេវាគ្រប់ប្រភេទ និងអភិបាលកិច្ច | ១ | ០,៨៦ | ១០០ | 0 | 0 | 0 |
| ៨ | ទឹកស្អាត និងអនាម័យជនបទ | ៣ | ២,៥៩ | 0 | ១០០ | 0 | 0 |
| ៩ | វិស័យសុខាភិបាល | ២ | ១,៧២ | ៥០ | 0 | ៥០ | 0 |
| ១០ | វិស័យសាធារណការ និងដឹកជញ្ជូន | ១៨ | ១៥,៥២ | ២៧,៧៨ | ២៧,៧៨ | ៤៤,៤៤ | 0 |
| ១១ | វិស័យកសិកម្ម ជលផល និងព្រៃឈើ | ២ | ១,៧២ | ៥០ | ៥០ | 0 | 0 |
| ១២ | វិស័យសេដ្ឋកិច្ច | 0 | 0 | 0 | 0 | 0 | 0 |
| ១៣ | វិស័យបរិស្ថាន | ៣ | ២,៥៩ | ៦៦,៦៧ | ៣៣,៣៣ | 0 | 0 |
| ១៤ | វិស័យធម្មការ និងសាសនា | 0 | 0 | 0 | 0 | 0 | 0 |
| ១៥ | វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | 0 | 0 | 0 | 0 | 0 | 0 |
| ១៦ | វិស័យរ៉ែ និងថាមពល | ១ | ០,៨៦ | ១០០ | 0 | 0 | 0 |
| ១៧ | វិស័យសង្គមកិច្ច | 0 | 0 | 0 | 0 | 0 | 0 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៨ | វិស័យពាណិជ្ជកម្ម | 0 | 0 | 0 | 0 | 0 | 0 |
| ១៩ | វិស័យទេសចរណ៍ | 0 | 0 | 0 | 0 | 0 | 0 |
| ២០ | វិស័យការងារ | 0 | 0 | 0 | 0 | 0 | 0 |
| | សរុប | ១១៦ | | | | | |

**៤-បញ្ហាប្រឈម**

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានខាងលើ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ បានជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចតទៅ ៖

- បញ្ហាជំងឺកូវីដ-១៩ នៅតែជាក្តីកង្វល់របស់រដ្ឋបាលខេត្ត ក្រុង ស្រុក ទោះបីជាស្ថានភាព មានភាពធូរស្រាលយ៉ាងណាក្តី
- នៅតាមក្រុង ស្រុក បញ្ហាខ្វះខាតបណ្តាញទឹកស្អាត អគ្គិសនី ហេដ្ឋារចនាសម្ព័ន្ធ អនាម័យ និងទីតាំងចាក់សំរាម
- មានការញុះញង់គាំទ្រពីមជ្ឈដ្ឋានខាងក្រៅ ឱ្យប្រជាពលរដ្ឋប្រមូលផ្តុំតវ៉ាបញ្ហាដីធ្លី បង្កឱ្យមានអសន្តិសុខ និងអស្ថិរភាព នៅក្នុងមូលដ្ឋាន
- ប្រជាពលរដ្ឋ មួយចំនួនធំពុំទាន់បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី ដែលក្រុមយុវជន **សម្តេចតេជោ** បានវាស់វែងរួច តាមបទបញ្ជាលេខ ០១ បប នៅឡើយ
- បញ្ហាទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍ឯកជន
- បញ្ហាប្រជាពលរដ្ឋចូលកាប់ទន្ទ្រានដីរដ្ឋធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន នៅតែបន្តកើតមាននៅមូលដ្ឋាន
- ដោយសារវិបត្តិជំងឺកូវីដ-១៩ ធ្វើឱ្យក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ ពុំបានរៀបចំវេទិកាសាធារណៈឡើយ។

**៥-សំណូមពរ**

ដោយមានបញ្ហាប្រឈមដូចបានរាយការណ៍ខាងលើ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ សូមសំណូមពរ ដូចតទៅ ៖

- បន្តឧបត្ថម្ភគាំទ្រលើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩
- ដោះស្រាយបញ្ហាកង្វះបណ្តាញទឹកស្អាត អគ្គិសនី ហេដ្ឋារចនាសម្ព័ន្ធ អនាម័យ និងទីតាំងចាក់សំរាម តាមក្រុង ស្រុក
- ជួយគាំទ្រចំពោះការចាត់វិធានការតាមផ្លូវច្បាប់ ចំពោះមេខ្លោងដឹកនាំការប្រមូលផ្តុំ បង្កឱ្យមានអសន្តិសុខ និងអស្ថិរភាពក្នុងមូលដ្ឋាន
- ជំរុញក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក រៀបចំវេទិកាសាធារណៈ ឱ្យបានញឹកញាប់ ដើម្បីក្តាប់បានសំណើ សំណូមពរ បញ្ហា និងក្តីកង្វល់នានា របស់ប្រជាពលរដ្ឋ និងចូលរួមអភិវឌ្ឍមូលដ្ឋាន
- ជួយដោះស្រាយបញ្ហាប្រឈមនានា ដែលបានកើតឡើងនៅតាមបណ្តាក្រុង ស្រុក។

**៦-សេចក្តីសន្និដ្ឋាន**

ក្នុងឆ្នាំ២០២១ នេះ ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត បានរៀបចំរចនាសម្ព័ន្ធ ដឹកនាំ គ្រប់គ្រង ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន ព្រមទាំងបានអនុវត្តការងារ ស្របតាមការបែងចែក តួនាទីភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត។ ជាមួយគ្នានេះ អង្គភាពច្រកចេញចូលតែមួយ ការិយាល័យ

ប្រជាពលរដ្ឋ បានបន្តផ្តល់សេវាជូនប្រជាពលរដ្ឋ និងដំណោះស្រាយរាល់ពាក្យបណ្តឹងនានា កាន់តែឆាប់រហ័ស ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងទំនួលខុសត្រូវ ដើម្បីជានានិរន្តរភាពនៃថ្នាក់រដ្ឋបាលមួយនេះ។

ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ធ្វើឱ្យការអភិវឌ្ឍក្នុងមូលដ្ឋានមានសន្ទុះកើនឡើងយឺត ទន្ទឹមនឹងតម្រូវការនៅមូលដ្ឋានមានកាន់តែច្រើន ដូចនេះរដ្ឋបាលខេត្តចាំបាច់នឹងកៀរគរប្រភពធនធានបន្ថែមទៀត ទាំងការស្នើសុំអន្តរាគមន៍ថវិកាពីថ្នាក់ជាតិ ស្ថាប័ននៅថ្នាក់ក្រោមជាតិ និងសប្បុរសជនដើម្បីបង្កើនមូលនិធិអភិវឌ្ឍ សម្រាប់ជាប្រយោជន៍ ឆ្លើយតបនឹងសេចក្តីត្រូវការចាំបាច់នានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋានបានកាន់តែប្រសើរឡើង និងដើម្បីបន្តជំរុញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងគោលនយោបាយកំណែទម្រង់ជំស៊ីជម្រៅរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦ នៃរដ្ឋសភា កាន់តែទទួលបានផ្លែផ្កាថែមទៀត។

ដោយឡែក តាមរយៈសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងដោយមានកិច្ចសហការជាមួយរដ្ឋបាលមូលដ្ឋានគ្រប់លំដាប់ថ្នាក់ បានធ្វើឱ្យការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ការងារសេដ្ឋកិច្ច សង្គម និងការដោះស្រាយបញ្ហានានា មានភាពល្អប្រសើរ។ សមិទ្ធផលដែលសម្រេចបាន អាស្រ័យដោយក្រុមការងារគ្រប់ថ្នាក់ បានយកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានឆន្ទៈមុតមាំក្នុងការអនុវត្តបទបញ្ជា សេចក្តីណែនាំ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ជាមួយកិច្ចសហការគាំទ្រទៅវិញទៅមក ក្នុងគោលដៅច្បាស់លាស់ ធ្វើឱ្យការដោះស្រាយបញ្ហាផ្សេងៗជូនប្រជាពលរដ្ឋ នៅតាមមូលដ្ឋានទទួលបានលទ្ធផលល្អប្រសើរ។

**៧-ទិសដៅសម្រាប់អនុវត្តបន្ត**

ទន្ទឹមនឹងលទ្ធផលការងារសម្រេចបានខាងលើ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង គ្រប់លំដាប់ថ្នាក់ សហការជាមួយរដ្ឋបាលខេត្ត ក្រុង ស្រុក បានដាក់ចេញនូវទិសដៅសម្រាប់អនុវត្តដូចតទៅ ៖

- បន្តពង្រឹងផ្សព្វផ្សាយ និងត្រៀមលក្ខណៈក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩
- បន្តចុះសួរសុខទុក្ខប្រជាពលរដ្ឋ ដើម្បីដោះស្រាយ និងស្វែងយល់អំពីកង្វល់នានា នៅក្នុងមូលដ្ឋាន
- រៀបចំវេទិកាសាធារណៈនៅតាមក្រុង ស្រុក ដើម្បីដោះស្រាយ និងប្រមូលចងក្រងរាល់សំណួរ និងសំណូមពរទាំងអស់របស់ប្រជាពលរដ្ឋ
- ប្រមូលចងក្រងរាល់សំណួរ និងសំណូមពរទាំងអស់របស់ប្រជាពលរដ្ឋ ដែលមានការពាក់ព័ន្ធជាមួយនឹងក្រសួង ស្ថាប័នសាមី ដែលក្រុមការងារ និងអាជ្ញាធរមូលដ្ឋានក្រុង ស្រុក ខេត្ត ពុំមានសមត្ថកិច្ច និងលទ្ធភាពដោះស្រាយ ដើម្បីផ្តល់ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ រាជរដ្ឋាភិបាល មានវិធានការដោះស្រាយជូនប្រជាពលរដ្ឋទាន់ពេលវេលា និងសមស្រប
- ជំរុញការដោះស្រាយឱ្យកាន់តែសកម្មថែមទៀតនូវសំណើ សំណូមពរចាំបាច់របស់ប្រជាពលរដ្ឋ
- បន្តពង្រឹងការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ជាពិសេសទប់ស្កាត់ឱ្យបានទាន់ពេលវេលានូវការប្រមូលផ្តុំខុសច្បាប់
- ជំរុញការផ្តល់សេវារដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ជូនប្រជាពលរដ្ឋឱ្យកាន់តែមានគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆាប់រហ័ស
- ខិតខំស្វែងរកកិច្ចសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជំរុញការអភិវឌ្ឍនៅតាមមូលដ្ឋានលើគ្រប់វិស័យ ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធ
- បន្តខិតខំដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើង នៅតាមក្រុង ស្រុក ឃុំ សង្កាត់
- រៀបចំផលិតប័ណ្ណកម្មសិទ្ធិ (បប ០១) ជាង ១០.០០០ប័ណ្ណ ឱ្យបានរួចរាល់ក្នុង ដំណាច់ខែមីនា ឬ ដើមខែមេសា ឆ្នាំ២០២២ ខាងមុខនេះ ដើម្បីផ្តល់ជូនប្រជាពលរដ្ឋ

- រៀបចំចុះបញ្ជីដាច់ដោយដុំ ដែលអនុវត្តនៅក្នុងក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ហើយនឹងបន្តនៅតាមបណ្តាស្រុកផ្សេងទៀត នៅពេលដែលការចុះបញ្ជីជាប្រព័ន្ធរបស់ក្រុង ស្រុកណាមួយដែលកំពុងតែអនុវត្តនេះ បានបញ្ចប់ ឬ ជិតនឹងបញ្ចប់
- រៀបចំចុះបញ្ជីដីរដ្ឋ មានដូចជាៈ ដីសម្បទានសង្គមកិច្ចសម្រាប់អតីតយុទ្ធជន ដីទីលានចាក់សំរាម ដី និងអគារសាធារណៈផ្សេងៗ និងដីបម្រុងរបស់រដ្ឋ មានជាកម្មសិទ្ធិរបស់រដ្ឋបាលខេត្ត និងតំបន់ការពារដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំចុះបញ្ជីដាច់ដោយដុំ ឬបំពេញបន្ថែមតាមការស្នើសុំរបស់ប្រជាពលរដ្ឋ ដើម្បីពន្លឿននៃការចេញប័ណ្ណកម្មសិទ្ធិជូនពួកគាត់
- បន្តពិនិត្យដោះស្រាយ និងវាស់វែងដីធ្លីជូនប្រជាពលរដ្ឋ ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង។

## ផ្នែកទី៤
## បញ្ហាប្រឈម និងដំណោះស្រាយ

### ៤.១. រដ្ឋបាលខេត្ត

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | ដំណោះស្រាយ |
|---|---|---|
| 1. ការងាររដ្ឋបាល | | |
| 1 | ពុំមានមន្ត្រីគ្រប់គ្រាន់ដើម្បីជួយការងារក្នុងទីចាត់ការរដ្ឋបាល | ជំរុញលើកទឹកចិត្តមន្ត្រីដែលមានស្រាប់ឱ្យខិតខំបំពេញការងារ និងស្នើសុំជ្រើសរើសបន្ថែម |
| 2. ការងារផែនការ និងការគាំទ្រមូលដ្ឋាន | | |
| 1 | មន្ត្រីហេដ្ឋារចនាសម្ព័ន្ធមិនទាន់យល់ដឹងលើបច្ចេកទេសនៃការសាងសង់ និងការត្រួតពិនិត្យផ្លូវក្រាលកៅស៊ូអាសេ | ស្នើក្រសួងមហាផ្ទៃរៀបចំវគ្គបណ្តុះបណ្តាល |
| 2 | រដ្ឋបាលឃុំ សង្កាត់ មានភាពយឺតយ៉ាវក្នុងការផ្តល់ទិន្នន័យមូលទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ដែលធ្វើឱ្យដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (2022-2024) មិនស្របតាមពេលកំណត់ | ស្នើដល់រដ្ឋបាលក្រុង ស្រុកជួយសម្របសម្រួល |
| 3 | ផែនការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សមត្ថភាពនានាដែលបានគ្រោងសម្រាប់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ មិនទាន់អាចដំណើរការបាន ដោយសារបញ្ហាជំងឺកូវីដ-19 | វគ្គបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សមត្ថភាពនានានឹងធ្វើឡើងវិញនៅពេលដែលបញ្ហាជំងឺកូវីដ-19 ត្រូវបានធូរស្រាល និងមានការអនុញ្ញាតឱ្យអនុវត្តសកម្មភាព |
| 4 | ការគាំទ្រការរៀបចំគម្រោងអភិវឌ្ឍន៍នៅថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់ មានភាពយឺតយ៉ាវ ដោយសារបញ្ហាជំងឺកូវីដ-19 | សហការជាមួយរដ្ឋបាលក្រុង ស្រុក និងឃុំសង្កាត់ ដើម្បីពន្លឿនការរៀបចំសិក្សាលទ្ធភាពគម្រោង និងកិច្ចលទ្ធកម្ម បើទោះបីជារដ្ឋបាលនីមួយៗកំពុងមមាញឹកនឹងការដោះស្រាយបញ្ហាជំងឺកូវីដ-19 ក៏ដោយ |
| 3. ការគ្រប់គ្រងធនធានមនុស្ស | | |
| 1 | ការអនុវត្តការងាររដ្ឋបាលលើកិច្ចការគ្រប់គ្រងបុគ្គលិកពុំ | ស្នើសុំឱ្យមានកិច្ចប្រជុំឆ្លុះបញ្ចាំងលើកិច្ចការរដ្ឋបាល |

| | | |
|---|---|---|
| | សូវមានភាពស៊ីសង្វាក់គ្នា ជាមួយនឹងមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត | នៃរដ្ឋបាលថ្នាក់ក្រោមជាតិ |
| 2 | រដ្ឋបាលក្រុង ស្រុក បញ្ជូនរបាយការណ៍ ឬឯកសារពាក់ព័ន្ធនឹងការងារបុគ្គលិក មានការយឺតយ៉ាវ | ស្នើសុំឱ្យមានកិច្ចប្រជុំឆ្លុះបញ្ចាំងលើកិច្ចការរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| **4. ការងារអន្តរវិស័យ** | | |
| 1 | ក្រុមហ៊ុនមួយចំនួន ទទួលសិទ្ធិសម្បទានដីពីរាជរដ្ឋាភិបាល ដើម្បីវិនិយោគ ហើយមានទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋ (ទំនាស់រ៉ាំរ៉ៃ) | -ស្នើឱ្យក្រុមហ៊ុនបន្តសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីដែលនៅសេសសល់បន្តទៀតជូនប្រជាពលរដ្ឋ<br>-ពង្រឹងការសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីសម្របសម្រួល និងដោះស្រាយទៅតាមលិខិតបទដ្ឋានគតិយុត្ត |
| **5. ការងារហិរញ្ញវត្ថុ** | | |
| 1 | សមត្ថភាពមន្ត្រីក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំនៅមានកម្រិត | ស្នើរៀបចំវគ្គផ្សព្វផ្សាយអំពីនីតិវិធីក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំ ឱ្យស្របតាមកម្មវិធី |
| **6. ការងារលទ្ធកម្ម** | | |
| 1 | ពុំមាន | ពុំមាន |
| **7. ការងារអង្គភាពច្រកចេញ ចូលតែមួយ** | | |
| 1 | ទម្រង់ពាក្យស្នើសុំសេវា និងឯកសារភ្ជាប់មិនទាន់មានការឯកភាពគ្នាជាស្តង់ដាររួមក្នុងក្របខ័ណ្ឌទូទាំងប្រទេស | ស្នើសុំក្រសួងមហាផ្ទៃ ជួយរៀបចំទម្រង់ពាក្យ និងឯកសារភ្ជាប់ឱ្យមានឯកភាពគ្នាជាស្តង់ដាររួមក្នុងក្របខ័ណ្ឌទូទាំងប្រទេស |
| 2 | ខ្វះមន្ត្រី (មន្ត្រីជួរមុខ និងមន្ត្រីវិស័យសាធារណការ និងដឹកជញ្ជូន) | ស្នើសុំរដ្ឋបាលខេត្ត ជួយបន្ថែមមន្ត្រី (មន្ត្រីជួរមុខ និងមន្ត្រីវិស័យសាធារណការ និងដឹកជញ្ជូន) |
| 3 | ខ្វះម៉ាស៊ីនសម្រាប់សម្លាប់មេរោគកូវីដ-19 តាមរយៈឯកសារសុំសេវា | ស្នើសុំម៉ាស៊ីនកម្តៅឯកសារ សម្រាប់សម្លាប់មេរោគកូវីដ-19 |
| 4 | មន្ត្រីជួរមុខ 03រូប ក្នុងអង្គភាពមិនមានឋានៈ ដូចមន្ត្រី ក្នុងទីចាត់ការផ្សេងទៀត | ស្នើសុំលើកទឹកចិត្តមន្ត្រីជួរមុខ 03រូប បន្ថែមលើតួនាទីបច្ចុប្បន្ន (អនុប្រធានការិយាល័យណាមួយ) |
| 5 | នីតិវិធីនៃការផ្តល់សេវារដ្ឋបាល មិនទាន់ច្បាស់លាស់ និងប្រើប្រាស់ស្តង់ដាររួមគ្រប់រាជធានី ខេត្តនៅឡើយ | ស្នើសុំក្រសួងមហាផ្ទៃរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីនៃការផ្តល់សេវារដ្ឋបាលគ្រប់រាជធានី ខេត្ត |

**៤.២. មន្ទីរ អង្គភាពជំនាញ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | ដំណោះស្រាយ |
|---|---|---|
| **1. មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | |
| 1 | កសិករនៅតំបន់ជាប់ព្រំដែននៅតែប្រើប្រាស់ថ្នាំកសិកម្មដែលមានស្លាកសញ្ញាព័ត៌មានជាភាសាបរទេសនៅឡើយ | ចុះអប់រំ ណែនាំដល់កសិករ និងអាជីវករ ឱ្យលក់ទិញថ្នាំ-កសិកម្មដែលមានលេខបញ្ជិកា និងមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ |
| 2 | ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយចំនួន កើតមានទំនាស់ដីធ្លីរ៉ាំរ៉ៃជាមួយប្រជាពលរដ្ឋ ធ្វើឱ្យមានការរាំងស្ទះក្នុងការដាំដុះ | ស្នើសុំក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច ជួយពន្លឿនក្នុងការដោះស្រាយទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃជាមួយប្រជាពលរដ្ឋ |

| | | |
|---|---|---|
| 3 | ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយចំនួននៅតែមិនទាន់បានចុះបញ្ជីដីរដ្ឋនៅឡើយ | ជំរុញឱ្យក្រុមហ៊ុនមួយចំនួនជួយពន្លឿនក្នុងការចុះបញ្ជីដីរដ្ឋឱ្យបានឆាប់រហ័ស |
| 4 | ការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារមានការថយចុះដោយសារតម្លៃជ័រកៅស៊ូចុះថោក | ផ្សព្វផ្សាយបច្ចេកទេសដាំដុះ ថែទាំ និងស្វែងរកទីផ្សារកៅស៊ូជូនប្រជាកសិករ |
| 5 | ថវិកា បច្ចេកទេស និងចំណេះដឹង សម្រាប់ពង្រីកមុខរបរសហគមន៍កសិកម្មនៅមានកម្រិត | ចុះពង្រឹងសមត្ថភាព បច្ចេកទេស និងចំណេះដឹង ព្រមទាំងស្វែងរកអង្គការដៃគូនានា ដើម្បីគាំទ្រដល់ដំណើរការសហ-គមន៍កសិកម្ម |
| 6 | ការលួចប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់របស់ប្រជានេសាទ នៅតែបន្តកើតមាន | -បង្កើនការផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋាននានា នៅតាមបណ្តាមូលដ្ឋានភូមិ-ឃុំ ដែលមានប្រជានេសាទ<br>-សហការជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍នេសាទចុះអប់រំប្រជានេសាទឱ្យពួកគាត់បោះបង់ចោលនូវមុខរបរខុសច្បាប់ ហើយងាកមកចូលរួមថែរក្សា ការពារធនធានជលផលឱ្យមាននិរន្តរភាព |
| 7 | ដីចម្ការឈើអាកាស្យានៅតែមានការរំលោភទន្ទ្រានកាន់កាប់ពីសំណាក់ប្រជាពលរដ្ឋ នៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ | ស្នើសុំកិច្ចសហការពីមន្ត្រីជំនាញ អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ និងបង្ក្រាបការរំលោភទន្ទ្រានកាន់កាប់ដីចម្ការឈើអាកាស្យា |
| **2. មន្ទីរធនធានទឹក និងឧតុនិយម** | | |
| 1 | ខ្វះមន្ត្រីបំពេញការងារ (រដ្ឋបាល បច្ចេកទេស និងភ្នាក់ងារធនធានទឹក) ប្រចាំការនៅតាមបណ្តាស្រុក | ស្នើសុំក្រសួងផ្តល់មន្ត្រីជំនាញបច្ចេកទេសបន្ថែម ដើម្បីមកបម្រើការងារនៅតាមបណ្តាស្រុក |
| 2 | ខ្វះខាតសម្ភារគ្រឿងចក្រ ដែលបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការងារជួសជុលសាងសង់ហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រ | ស្នើសុំគ្រឿងចក្របន្ថែមពីក្រសួងធនធានទឹក និងឧតុនិយមយកមកបំពេញការងារ |
| 3 | នៅតាមតំបន់ទំនប់ច្រើនមានជនខិលខូចលួចបើកទ្វារទឹកឱ្យទឹកប្រៃចូលដីស្រែកសិករដើម្បីចាប់ត្រី ជាហេតុនាំឱ្យខូចខាតដំណាំស្រូវ | សហការជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍ ដើម្បីមានវិធានការការពារ និងទប់ស្កាត់រាល់សកម្មភាពបំផ្លិចបំផ្លាញផលប្រយោជន៍របស់កសិករ |
| 4 | ឈ្មួញរកស៊ីដឹកដីលក់ តែងបើករថយន្តធំៗដឹកដីឆ្លងកាត់តាមបណ្តោយទំនប់ទាំងប្រាំង និងវស្សាបណ្តាលឱ្យមានការប្រេះឈម និងការបាក់ស្រុតទ្វារទឹក និងតួទំនប់ការពារទឹកប្រៃ ធ្វើឱ្យទឹកប្រៃហូរចូលដីស្រែកសិករ | ស្នើសុំអាជ្ញាធរមូលដ្ឋានសហការផ្សព្វផ្សាយ និងទប់ស្កាត់រាល់សកម្មភាពទាំងនេះ |
| **3. មន្ទីរអភិវឌ្ឍន៍ជនបទ** | | |
| 1 | ការប្រែប្រួលអាកាសធាតុធ្វើឱ្យប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងទីប្រជុំជន និងទីជនបទ ជាពិសេសនៅរដូវប្រាំង បណ្តាលឱ្យប្រកពទឹករីងស្ងួត និងនៅរដូវវស្សា មានគ្រោះទឹកជំនន់ បណ្តាលឱ្យខូចផ្លូវ និងអណ្តូងទឹក ស្រះទឹក ជាដើម។ល។ | សិក្សាបញ្ហាប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ រៀបចំប្រព័ន្ធគ្រប់គ្រង និងចែកចាយទឹក នៅតាមសហគមន៍មូលដ្ឋាន |
| 2 | តម្រូវការអភិវឌ្ឍន៍ក្នុងមូលដ្ឋានមានច្រើន តែថវិកាគាំទ្រនៅមានកម្រិត | ប្រឹងប្រែងកៀរគរដៃគូអភិវឌ្ឍន៍ ដើម្បីចូលរួមគាំទ្រវិស័យអភិវឌ្ឍន៍ជនបទខេត្តកោះកុងឱ្យកាន់តែច្រើន |

| | | |
|---|---|---|
| 3 | ការដឹកលើសទម្ងន់កំណត់ ធ្វើឱ្យផ្លូវជនបទរងការខូចខាត និងកំណើនយានយន្ត បើកលើសល្បឿនកំណត់បណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍កើនឡើង | ផ្សព្វផ្សាយដល់អាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ ដែលជាអ្នកទទួលផលផ្ទាល់ ចូលរួមទប់ស្កាត់ការដឹកលើសទម្ងន់ និងថែរក្សាកំណាត់ខ្សែផ្លូវឱ្យមានគុណភាពប្រើប្រាស់បានយូរ |
| 4 | ការវិភាជន៍ថវិកាសម្រាប់ការងារហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន ដូចជា ការកសាង និងជួសជុលអណ្តូងស្នប់ ផ្លូវជនបទ បង្គន់អនាម័យ នៅមានកម្រិត | ស្នើសុំបន្ថែមថវិកាជួយគាំទ្រសកម្មភាពអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័នជនបទ តាមរយៈការលើកផែនការប្រចាំឆ្នាំទៅក្រសួងអភិវឌ្ឍន៍ជនបទ |
| **4. មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** | | |
| 1 | ការរីករាលដាលនៃជំងឺកូវីដ-19 ធ្វើឱ្យរាំងស្ទះដល់ការចុះត្រួតពិនិត្យតាមរោងចក្រ សហគ្រាស សិប្បកម្ម ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្ម តាមបក្រុង ស្រុក | រង់ចាំស្ថានភាពជំងឺកូវីដ-19 មានភាពធូរស្រាល ក្រុមការងារនឹងរៀបចំអនុវត្តការងារ តាមផែនការកំណត់ |
| 2 | មានមូលដ្ឋានសហគ្រាស/សិប្បកម្មមួយចំនួន នៅតាមក្រុងស្រុក មិនទាន់មានច្បាប់ ឬចុះបញ្ជីសហគ្រាសសិប្បកម្មនៅឡើយ | -សហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីជំរុញឱ្យសុំច្បាប់អនុញ្ញាត<br>-ធ្វើលិខិតអញ្ជើញម្ចាស់សហគ្រាស/សិប្បកម្ម ដើម្បីណែនាំអំពីនីតិវិធីនៃការស្នើសុំច្បាប់ផលិតកម្ម<br>-បន្តផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយ អំពីការដាក់ពាក្យស្នើសុំច្បាប់បើកផលិតកម្ម និងបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការផលិតកម្ម |
| 3 | ការពង្រីកបណ្តាញចែកចាយទឹកស្អាតជូនប្រជាពលរដ្ឋមិនទាន់បានគ្រប់គ្រាន់តាមតម្រូវការប្រើប្រាស់ | - ជំរុញឱ្យក្រុមហ៊ុនខិតខំពង្រីកបណ្តាញចែកចាយទឹកស្អាតជូនប្រជាពលរដ្ឋឱ្យបានគ្រប់គ្រាន់<br>- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋដែលមិនទាន់មានបណ្តាញទឹកប្រើប្រាស់ឱ្យដាក់ពាក្យស្នើសុំទឹកស្អាតពីក្រុមហ៊ុន ហើយមន្ទីរនឹងជួយសម្របសម្រួលលើពាក្យស្នើសុំតភ្ជាប់បណ្តាញទឹកទៅក្រុមហ៊ុន |
| 4 | ក្រុមការងារពុំទាន់អាចចុះផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ម្ចាស់រោងចក្រ សហគ្រាស សិប្បកម្ម អាជីវកម្ម សេវាកម្ម និងម្ចាស់ស្ថានីយប្រេងឥន្ធនៈ អំពីច្បាប់ស្តីពីស្តង់ដារកម្ពុជា ច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងកំឡុងពេលវិបត្តិជំងឺកូវីដ-19 | រង់ចាំស្ថានភាពជំងឺកូវីដ-19 មានភាពធូរស្រាល ក្រុមការងារនឹងចុះផ្សព្វផ្សាយបន្តដល់អ្នកពាក់ព័ន្ធ |
| **5. មន្ទីររ៉ែ និងថាមពល** | | |
| 1 | នៅមានអាជីវកម្មស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈមួយចំនួនតូច ពុំទាន់មានច្បាប់អនុញ្ញាតត្រឹមត្រូវ | បន្តចុះណែនាំ ជំរុញដល់អាជីវករឱ្យមកសុំលិខិតអនុញ្ញាតដំណើរការអាជីវកម្ម |
| 2 | ក្រុមហ៊ុនចែកចាយថាមពលអគ្គិសនី មួយចំនួនតូច ពុំទាន់បំពាក់ប្រអប់ការពារកុងទ័រឱ្យបានគ្រប់ចំនួនកុងទ័រ | បន្តជំរុញ និងណែនាំដល់ក្រុមហ៊ុនឱ្យបំពាក់ប្រអប់ការពារកុងទ័រឱ្យបានគ្រប់ចំនួន |
| 3 | ការពង្រីកបណ្តាញអគ្គិសនី របស់ក្រុមហ៊ុន និងសេវាករមួយចំនួនតូច មានការយឺតយ៉ាវជូនដល់ប្រជាពលរដ្ឋ | បន្តជំរុញដល់ក្រុមហ៊ុន សេវាករអគ្គិសនី ឱ្យពង្រីកបណ្តាញឱ្យបានឆាប់រហ័សជូនប្រជាពលរដ្ឋប្រើប្រាស់ |
| 4 | អាជីវករធ្វើអាជីវកម្មដឹកដីក្រហម និងខ្សាច់សំណង់មួយចំនួនតូច នៅតែពុំបានគ្របត្រឹមត្រូវតាមបច្ចេកទេស | បន្តសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធចុះណែនាំ និងផាកពិន័យតាមច្បាប់ |

| | | |
|---|---|---|
| **6. មន្ទីរពាណិជ្ជកម្ម** | | |
| 1 | អាជីវករមួយចំនួន ពុំបានមកសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម នៅការិយាល័យ និងយន្តការច្រកចេញចូលតែមួយក្រុង ស្រុក | ចាត់មន្ត្រីចូលរួមសហការជាមួយការិយាល័យ និងយន្តការច្រកចេញចូលតែមួយក្រុង ស្រុក ដើម្បីចុះផ្សព្វផ្សាយ និងជំរុញអាជីវករឱ្យមកសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម |
| **7. សាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត** | | |
| 1 | ការរីករាលដាលនៃជំងឺឆ្លងកូវីដ-19 មន្ត្រីជំនាញ ពិបាកក្នុងការចុះត្រួតពិនិត្យទំនិញតាមទីផ្សារ | មន្ត្រីជំនាញបានចុះអនុវត្តការងារដោយការប្រុងប្រយ័ត្នខ្ពស់ និងគោរពតាមវិធានការសុខាភិបាលជានិច្ច ដើម្បីការពារសុវត្ថិភាពមន្ត្រីពីជំងឺកូវីដ-19 |
| 2 | អាជីវករមួយចំនួនតូច លក់រាយប្រេងឥន្ធនៈតាមស្ថានីយដេប៉ូ មានការយឺតយ៉ាវក្នុងការប្តូរថ្លៃ នៅពេលចេញសេចក្តីជូនដំណឹងស្តីពីតម្លៃលក់រាយប្រេងឥន្ធនៈ | មន្ត្រីជំនាញបានពន្យល់ណែនាំដល់អាជីវករលក់រាយប្រេងឥន្ធនៈ ទាំងអស់ក្នុងខេត្ត ត្រូវគោរពតាមសេចក្តីជូនដំណឹងស្តីពីតម្លៃលក់រាយប្រេងឥន្ធនៈរបស់ក្រសួងពាណិជ្ជកម្ម យ៉ាងយូរត្រឹមថ្ងៃបន្ទាប់ នៃការជូនដំណឹង។ ករណីម្ចាស់ស្ថានីយ/ដេប៉ូ ណាល្មើសនឹងត្រូវ ផាកពិន័យតាមច្បាប់ជាធរមាន |
| **8. ការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | |
| 1 | កិច្ចលទ្ធកម្មរបស់ក្រុង ស្រុក អនុវត្តមានការយឺតយ៉ាវ និងរបាយការណ៍ចំណូលចំណាយយឺតយ៉ាវ | បន្តជូនដំណឹង និងជំរុញដល់អង្គភាពពាក់ព័ន្ធអនុវត្តឱ្យបានលឿន |
| 2 | ប្រជាជន និងមន្ត្រីមួយចំនួនដែលរស់នៅលើដីរបស់មន្ទីរ អង្គភាពរដ្ឋ មិនទាន់បានដោះស្រាយរួចរាល់ | បន្តស្វែងរកនីតិវិធីដោះស្រាយ |
| 3 | ការរៀបចំបញ្ជីសារពើភណ្ឌរបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ មួយចំនួន យឺតយ៉ាវ | ជូនដំណឹងដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ជំរុញធ្វើឱ្យបានលឿន |
| **9. ការងារគយ និងរដ្ឋាករ** | | |
| 1 | ពិបាកក្នុងការប្រមូលចំណូល ដោយសារបញ្ហាជំងឺកូវីដ-19 ផ្លូវ48 មានសភាពបត់បែន ឡើងចុះច្រើន, ទូកដឹកទំនិញមានការថយចុះ | បន្តខិតខំពង្រឹងការប្រមូលពន្ធជូនរដ្ឋឱ្យបានគ្រប់ និងលើសផែនការ |
| **10. ការងារពន្ធដារ** | | |
| 1 | ការរីករាលដាលនៃការឆ្លងជំងឺកូវីដ-19 បានធ្វើឱ្យប៉ះពាល់វិស័យអាជីវកម្មដែលមានសកម្មភាពសេវាកម្មការស្នាក់នៅ និងអាហារសកម្មភាពអចលនទ្រព្យ និងអាហារ៉ែណនីហរ័ណ | បានសិក្សាពីផលប៉ះពាល់ដល់ផែនការការប្រមូលចំណូលពន្ធរបស់សាខាពន្ធដារខេត្តកោះកុង សម្រាប់ឆ្នាំ2021 |
| 2 | ការរីករាលដាលនៃការឆ្លងជំងឺកូវីដ-19 បានធ្វើឱ្យប៉ះពាល់ដល់ការមកដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធរបស់អ្នកជាប់ពន្ធ | ផ្សព្វផ្សាយ និងជំរុញអ្នកជាប់ពន្ធឱ្យប្រើប្រាស់ សេវាកម្មអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការបង់ប្រាក់ពន្ធ និងការដាក់លិខិតប្រកាស |
| 3 | សហគ្រាសដែលមានសកម្មភាពអាជីវកម្ម ទិញ លក់ប្រេងឥន្ធនៈ ទិញលក់គ្រឿងទេស និងផ្ទះសំណាក់កើតថ្មី មួយចំនួន ស្ថិតក្នុងស្រុកស្រែអំបិល មណ្ឌលសីមា និងស្រុកកោះកុង មិនទាន់បានចុះបញ្ជីពន្ធដារ នៅឡើយ | បង្កើតក្រុមការងារនៃសាខាពន្ធដារខេត្តកោះកុង ដើម្បីចុះផ្សព្វផ្សាយ និងជំរុញដល់ម្ចាស់សហគ្រាស ស្តីពីកាតព្វកិច្ចនៃការចុះបញ្ជីពន្ធដារ |

| | | |
|---|---|---|
| 4 | ម្ចាស់អចលនទ្រព្យមួយចំនួនធំមិនបានប្រកាសបង់ពន្ធ លើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ សម្រាប់ឆ្នាំ2021 បានទាន់ពេលវេលា | ផ្សព្វផ្សាយជូនម្ចាស់អចលនទ្រព្យស្ដីពីការពន្យារពេល ការប្រកាសបង់ពន្ធលើអចលនទ្រព្យ និងដីធ្លីមិនបានប្រើប្រាស់សម្រាប់ឆ្នាំ2021 រហូតដល់ថ្ងៃទី31 ខែតុលា ឆ្នាំ2021 |
| 5 | ម្ចាស់រថយន្តមួយចំនួនមានភាពយឺតយ៉ាវក្នុងការប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ2021 ឱ្យបានទាន់ពេលវេលា | បានបន្តការទទួលបង់ពន្ធ និងបានផាកពិន័យលើរថយន្តដែលបានមកប្រកាសពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ2021មិនទាន់ពេលវេលា |
| **11. ការិយាល័យធនាគារ** | | |
| 1 | អាជីវករប្ដូរប្រាក់មួយចំនួនខ្វះការសហការ ក្នុងការអនុវត្ត | ផ្សព្វផ្សាយពន្យល់បន្ថែមអំពីនីតិវិធីផ្សេងៗមុននឹងប្រកបអាជីកម្មប្តូរប្រាក់ |
| 2 | អតិថិជនមកប្តូរប្រាក់ មិនបានរៀបចំក្រដាសប្រាក់ឱ្យបានត្រឹមត្រូវតាមប្រភេទ មិនមានប័ណ្ណបែងចែកប្រភេទប្រាក់មកភ្ជាប់ជាមួយ និងចង់បានប្រភេទប្រាក់តាមចិត្ត | ណែនាំអតិថិជនពីនិតិវិធីនៃការប្តូរប្រាក់ និងផ្តល់ប័ណ្ណបែងចែកប្រភេទប្រាក់ជូនអតិថិជន |
| 3 | ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានធ្វើការបង់ប្រាក់មានចំនួនច្រើន ក្នុងពេលតែមួយ | ស្នើសុំមន្ត្រីបុគ្គលិកមកពីការិយាល័យផ្សេងៗមកជួយរាប់សាច់ប្រាក់ |
| 4 | ការបើកសាច់ប្រាក់ មិនមានសាច់ប្រាក់គ្រប់គ្រាន់នៅក្នុងគណនី | ជូនដំណឹងដល់ម្ចាស់គណនីឱ្យបានដឹង និងពន្យល់ណែនាំពីនីតិវិធីក្នុងការបើកសាច់ប្រាក់ |
| **12. ការិយាល័យរតនាគារ** | | |
| 1 | ឃុំ សង្កាត់ មួយចំនួនតូចយករបាយការណ៍ទទួលស្គាល់ការបិទបញ្ជីថវិកាឆ្នាំ2020 មករតនាគារមានការយឺតយ៉ាវ | បន្តទំនាក់ទំនងឃុំ សង្កាត់ ក៏ដូចជាអង្គភាពដែលពាក់ព័ន្ធដើម្បីជួយពន្លឿនការផ្ទៀងផ្ទាត់របាយការណ៍ឱ្យបានទាន់ពេលវេលា |
| 2 | មន្ទីរ អង្គភាព និងអាជ្ញាធរក្រុង ស្រុក ឃុំ សង្កាត់ មួយចំនួនតូចធ្វើការទូទាត់បុរេប្រទានប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំខ្មែរ និងបុណ្យភ្ជុំបិណ្ឌមានការយឺតយ៉ាវ | ស្នើសុំមន្ទីរ អង្គភាព និងអាជ្ញាធរក្រុង ស្រុក ឃុំ សង្កាត់ រួតរះធ្វើការទូទាត់សងរតនាគារឱ្យបានទាន់ពេលវេលា |
| 3 | ការបញ្ជូនអាណត្តិបើកប្រាក់បៀវត្សរបស់ ឃុំ សង្កាត់ មួយចំនួនមករតនាគារមានការយឺតយ៉ាវមិនអនុវត្តតាមសារាចរណែនាំ | ស្នើសុំឃុំ សង្កាត់ ក៏ដូចជាអង្គភាពដែលពាក់ព័ន្ធជួយជំរុញឱ្យអនុវត្តតាមសារាចរណែនាំលេខ.07សរ ចុះថ្ងៃទី12 ខែធ្នូ ឆ្នាំ2018 ស្តីពីការកំណត់នីតិវិធីសម្រាប់បើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ |
| **13. មន្ទីរទេសចរណ៍** | | |
| 1 | អាជីវករមួយចំនួនតូចនៅមានការដំឡើងថ្លៃសេវាកម្មក្នុងពេលមានពិធីបុណ្យម្តងៗ | ធ្វើសេចក្តីជូនដំណឹងជាបន្តបន្ទាប់ដល់អាជីវកម្មទេសចណ៍ទាំងអស់ក្នុងខេត្តអំពីបញ្ហាដំឡើងថ្លៃ និងពង្រឹងលក្ខណៈសម្បត្តិក្នុងការបម្រើសេវារបស់ខ្លួនឱ្យមានលក្ខណៈសមរម្យ |
| 2 | ខ្វះមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា | បានស្នើសុំទៅក្រសួង និងកំពុងរង់ចាំការឆ្លើយតប |
| **14. មន្ទីរផែនការ** | | |
| 1 | សមត្ថភាពមន្ត្រីជំនាញ នៅមានកម្រិត ក្នុងការវិភាគទិន្នន័យចងក្រង និងការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ពិសេសការិយាល័យប្រជាជន និងការអភិវឌ្ឍ ដែលទើបបង្កើតថ្មី ស្របពេលដែលបច្ចេកវិទ្យាកាន់តែទំនើប | ស្នើសុំក្រសួងបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមតាមជំនាញ ផែនការ ស្ថិតិ និងវិធីសាស្ត្រវិភាគការបម្រែបម្រួលប្រជាជន និងការអភិវឌ្ឍ ការរៀបចំចងក្រងទិន្នន័យ |

| | | |
|---|---|---|
| 2 | កង្វះខាតថវិកាសម្រាប់ថែទាំឧបករណ៍ប្រើប្រាស់ក្នុងការិយាល័យ (កុំព្យូទ័រ, ព្រីនធ័រ, ហ្វូតូកូពី...) | បន្តស្នើសុំក្រសួងផ្តល់ថវិកាបន្ថែមសម្រាប់ថែទាំឧបករណ៍ និងសម្រាប់ប្រើប្រាស់ |
| **15. មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍** | | |
| 1 | ជំនាញបច្ចេកទេសរបស់មន្ត្រីក្នុងអង្គភាពនៅមានកម្រិត | បញ្ជូនចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវគ្គបំប៉ននានារយៈពេលវែង ខ្លីដែលមាន |
| 2 | ខ្វះមន្ត្រីបម្រើការងារនៅក្នុងមន្ទីរ | ធ្វើសំណើសុំក្របខ័ណ្ឌបន្ថែមទៅក្រសួង |
| **16. មន្ទីរមុខងារសាធារណៈ** | | |
| 1 | មន្ត្រីទទួលបន្ទុកការងារបៀវត្ស មន្ទីរ អង្គភាពមួយចំនួនរៀបចំឯកសារបៀវត្ស និងឯកសារពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលប្រចាំខែ ជូនមន្ត្រីរាជការរបស់មន្ទីរសាមី នៅមានការខ្វះខាតឯកសារ និងយឺតយ៉ាវ មិនបានតាមការកំណត់នៅឡើយ | បន្តពង្រឹងការរៀបចំឯកសារឱ្យបានទាន់ពេលវេលា និងមានលក្ខណៈគ្រប់គ្រាន់ |
| 2 | ខ្វះមធ្យោបាយធ្វើដំណើរសម្រាប់ចុះធ្វើការតាមបណ្តាស្រុក និងឡើងទៅប្រជុំនៅរាជធានីភ្នំពេញ | បន្តខិតខំស្វែងរក ដោះស្រាយ និងស្នើសុំពីក្រសួង |
| 3 | មានមន្ទីរ/អង្គភាពមួយចំនួនតូច មិនបានបង្វែរប្រាក់ឱ្យទាន់ពេលវេលាក្នុងការបើកប្រាក់លើស និងបើកប្រាក់មិនប្រក្រតី ។ល។ | បន្តជំរុញដល់មន្ទីរ អង្គភាព បង្វែរប្រាក់សងវិញឱ្យទាន់ពេលវេលា |
| **17. មន្ទីរអប់រំ យុវជន និងកីឡា** | | |
| 1 | សមត្ថភាពប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យារបស់បុគ្គលិកអប់រំមួយចំនួននៅមានកម្រិត | បំប៉នបន្ថែមដោយប្រើប្រាស់យន្តការអ្នកចេះច្រើនបង្រៀនអ្នកចេះតិច |
| 2 | ខ្វះក្របខ័ណ្ឌគ្រូនៅតាមតំបន់ដាច់ស្រយាល និងសាលានៅទីប្រជុំជនខ្វះគ្រូតាមឯកទេស | -ប្រើប្រាស់ពីរពេលគួប ម៉ោងលើស និងគ្រូជាប់កិច្ចសន្យា<br>-ស្នើតម្រូវការទៅក្រសួង តាមឯកទេសដែលខ្វះ |
| 3 | ការអនុវត្តសកម្មភាពក្នុងផែនការប្រចាំឆ្នាំ មិនទាន់ឆ្លើយតបគ្រប់ចំណុចដៅ ដែលបានគ្រោងទុក | ប្រជុំពិភាក្សាឡើងវិញ ដើម្បីឆ្លុះបញ្ចាំងសកម្មភាពដែលមិនបានអនុវត្ត |
| 4 | ដោយជំងឺកូវីដ-19 មានការរីករាលដាលខ្លាំងក្នុងសហគមន៍ រាល់ការបំពេញភារកិច្ចផ្សេងៗ និងការសិក្សារបស់សិស្សានុសិស្សមានការពិបាក ជាពិសេសនៅតាមតំបន់ដាច់ស្រយាល | បំពេញការងារដោយដាក់វេនប្រចាំការ និងតាមប្រព័ន្ធអនឡាញ<br>-ឱ្យសិស្សសិក្សាពីចម្ងាយ ចែកសន្លឹកកិច្ចការ និងរៀនតាមបណ្តុំតូចៗ |
| 5 | ការបញ្ជូនសំណុំឯកសារ ឬរបាយការណ៍ផ្សេងៗ នៅតែមានការយឺតយ៉ាវមិនទាន់តាមកាលបរិច្ឆេទ | បានរៀបចំលិខិតស្នើទៅរដ្ឋបាលក្រុង/ស្រុក ដើម្បីជួយជំរុញបន្ថែម |
| **18. មន្ទីរសុខាភិបាល** | | |
| 1 | ការប្រើប្រាស់សេវាសុខភាពសាធារណៈនៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាពនៅមានកម្រិតទាប | ពង្រឹងការផ្សព្វផ្សាយតាមរយៈការចុះផ្តល់សេវាដល់មូលដ្ឋានស្តីពីចំនួនសេវារបស់មន្ទីរពេទ្យ និងមណ្ឌលសុខភាព |
| 2 | ការយល់ដឹងពីការផ្តល់ថ្នាំបង្ការ របស់ប្រជាជនមួយចំនួននៅមានកម្រិត | ពង្រឹងការផ្សព្វផ្សាយតាមរយៈការចុះផ្តល់សេវាដល់មូលដ្ឋានស្តីពីអត្ថប្រយោជន៍ការផ្តល់ថ្នាំបង្ការ និងសុខភាពកុមារ |
| 3 | ការយល់ដឹង និងការចូលរួមពីសហគមន៍ អំពីការអនាម័យ ការពាក់ម៉ាស់ គម្លាតសុវត្ថិភាពសង្គមលើការបង្ការការចម្លងមេរោគកូវីដ-19 នៅមានកម្រិត | ពង្រឹងការផ្សព្វផ្សាយ អំពីវិធានការ ការពារជំងឺកូវីដ-19 និងចុះណែនាំ |
| 4 | ជំងឺកូវីដ-19 នៅតែបន្តការឆ្លងរាតត្បាតចូលក្នុងសហគមន៍ | ជំរុញការផ្សព្វផ្សាយអំពីវិធានការសុខាភិបាល 3ការពារ 3កុំ |

| | | |
|---|---|---|
| **19.** | **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | |
| 1 | ប័ណ្ណសមធម៌របស់គ្រួសារក្រីក្រត្រូវបានប្លុក ភ្លេចលេខកូដ និងគ្មានលុយក្នុងគណនី | ស្នើទៅថ្នាក់ជាតិដើម្បីដោះស្រាយជូនប្រជាពលរដ្ឋ |
| 2 | ឈ្មោះមេគ្រួសារក្នុងប័ណ្ណជុំទី11 ខុសពីឈ្មោះមេគ្រួសារក្នុងប័ណ្ណជុំទី14 | សហការជាមួយមន្ទីរផែនការខេត្ត និងឃុំ/សង្កាត់ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋ |
| 3 | មិនបានទទួលព័ត៌មានអំពីការប្រព្រឹត្តបទល្មើសអនីតិជនទំនាស់នឹងច្បាប់ឱ្យបានទាន់ពេលវេលា | ស្នើសុំកិច្ចសហការជាមួយព្រះរាជអាជ្ញា និងនគរបាលយុត្តិធម៌ ដើម្បីទទួលបានព័ត៌មានដែលទាក់ទងជាមួយអនីតិជនទំនាស់នឹងច្បាប់ |
| 4 | កិច្ចសហការរវាងអនុគណៈកម្មាធិការដោះស្រាយបញ្ហាជនអនាថាមិនទាន់រលូន | ស្នើឱ្យមានកិច្ចប្រជុំប្រចាំខែ |
| **20.** | **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | |
| 1 | សហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ហត្ថពលកម្មបរទេសមានការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសប្រចាំឆ្នាំ2021 | ជំរុញដល់ម្ចាស់ សហគ្រាស គ្រឹះស្ថានឱ្យប្រញាប់ដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសតាមរយៈប្រព័ន្ធអនឡាញ |
| 2 | កម្មករនិយោជិត និងនិយោជក នៃសហគ្រាស គ្រឹះស្ថានមួយចំនួនយល់ដឹងនៅមានកម្រិតអំពីច្បាប់ស្តីពីការងារ និងលក្ខខណ្ឌការងារ | បន្តផ្សព្វផ្សាយច្បាប់ ស្តីពីការងារ និងលក្ខខណ្ឌការងារតាមរយៈក្រុមអធិការកិច្ចការងារ ឬ បើកវគ្គសិក្ខាសាលាផ្សព្វផ្សាយ |
| 3 | ការចុះធ្វើអធិការកិច្ចការងារតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន ត្រូវបានផ្អាកដោយសារការរាតត្បាតនៃជំងឺកូវីដ-19 | បន្តពង្រឹងការចុះអធិការកិច្ចការងារនៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាន បន្ទាប់ពីស្ថានភាពជំងឺកូវីដ-19 ធូរស្បើយ |
| 4 | សហគ្រាស គ្រឹះស្ថានមួយចំនួនមិនរាយការណ៍ឱ្យបានច្បាស់អំពីតួលេខជនបរទេសដែលកំពុងធ្វើការក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួន | ពង្រឹងការចុះអធិការកិច្ចការងារជនបរទេស ដោយសហការជាមួយនគរបាលអន្តោប្រវេសន៍ |
| 5 | សហគ្រាស គ្រឹះស្ថាន បើកថ្មីមួយចំនួនមានភាពយឺតយ៉ាវក្នុងការមកបំពេញបែបបទស្តីពីសហគ្រាស | ជំរុញដល់ម្ចាស់សហគ្រាស គ្រឹះស្ថានឱ្យមកបំពេញបែបបទស្តីពីសហគ្រាស តាមរយៈក្រុមអធិការកិច្ចការងាររបស់មន្ទីរ |
| **21.** | **មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ** | |
| 1 | ខ្វះសារមន្ទីរតាំងពិព័រណ៍វត្ថុបុរាណ | បានស្នើសុំក្រសួងរួចរាល់ហើយ កំពុងរង់ចាំការសម្រេចពីក្រសួង |
| 2 | រូបចម្លាក់ និងវត្ថុមួយចំនួនធំ ជាងចម្លាក់ធ្វើតាមតម្រូវការអតិថិជន តាមបែបវប្បធម៌បរទេស | ណែនាំដល់ជាងចម្លាក់ឱ្យជួយផ្សព្វផ្សាយអំពីចម្លាក់វប្បធម៌ជាតិខ្មែរ |
| 3 | ការផ្តល់សេវាវិស័យវប្បធម៌លើកស្លាក/ប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្ម ចាប់ពី04ម$^2$ ឡើងទៅ ត្រូវបានផ្អាកការយកតម្លៃសេវាជាបណ្តោះអាសន្ន នាំឱ្យបាត់ចំណូលក្នុងអង្គភាពរដ្ឋ | រង់ចាំការសម្រេចអន្តរក្រសួងកំណត់តម្លៃសេវាឡើងវិញ |
| 4 | ផ្លូវចូលស្ថានីយអ្នករកី ក្នុងស្រុកថ្មបាំង ត្រូវឆ្លងកាត់លើដីប្រជាជន ម្ចាស់ដីបានឈូសឆាយ និងព័ទ្ធរបង | សុំកិច្ចសហការអន្តរគមន៍ជាមួយអាជ្ញាធរពាក់ព័ន្ធចុះសម្របសម្រួលដោះស្រាយជាមួយម្ចាស់ដី |

| | | |
|---|---|---|
| 22. | **មន្ទីរកិច្ចការនារី** | |
| 1 | អំពើហិង្សាក្នុងគ្រួសារ នៅតែកើតមានចំពោះគ្រួសារក្រីក្រ | ចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមភូមិគោលដៅ ពីផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ |
| 2 | ករណីរំលោភសេពសន្ថវៈលើស្ត្រី និងក្មេងស្រី នៅតែមានតាមបណ្តាស្រុកមួយចំនួន (ឆ្នាំ2021 ចំនួន 05ករណី) | -ចុះផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហិង្សា និងការរំលោភសេពសន្ថវៈ ដល់ប្រជាពលរដ្ឋ<br>-សហការជាអាជ្ញាធរជួយអន្តរាគមន៍ និងស្នើសុំមេធាវីជួយការពារក្តីជូនដល់ជនរងគ្រោះ |
| 3 | ពុំសូវមានសិស្សចាប់អារម្មណ៍នឹងការចូលរៀនជំនាញកាត់ដេរ និងសម្អាងកាយ | ព្យាយាមផ្សព្វផ្សាយបន្ថែមពីអត្ថប្រយោជន៍ នៃការចូលរៀនជំនាញកាត់ដេរ និងសម្អាងកាយ ដល់ស្ត្រី និងក្មេងស្រីក្រីក្រ |
| 4 | ដោយសារបញ្ហាកូវីដ-19 មិនអាចជួបជុំគ្នាច្រើនបានដូចនេះការផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលផ្សេងៗជាមួយប្រជាពលរដ្ឋ ត្រូវរៀបចំច្រើនលើក | បន្ថយចំនួនអ្នកចូលរួម តែបង្កើនវគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាលផ្សេងៗ |
| 5 | ប្រជាពលរដ្ឋមួយចំនួន ពេលជួបបញ្ហាអំពើហិង្សាផ្សេងៗ នៅតែមិនមានភាពក្លាហានក្នុងការផ្តល់ព័ត៌មានដល់អាជ្ញាធរ និងមន្ទីរពាក់ព័ន្ធ ដើម្បីជួយរកដំណោះស្រាយ | ចុះផ្សព្វផ្សាយ និងជំរុញដល់ប្រជាពលរដ្ឋឱ្យផ្តល់ព័ត៌មានបានទាន់ពេលវេលា ដើម្បីឱ្យអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធជួយរកដំណោះស្រាយជូនគាត់ |
| 23. | **មន្ទីរព័ត៌មាន** | |
| 1 | ខ្វះមន្ត្រីបម្រើការងារ | ស្នើសុំក្រសួងជ្រើសរើសមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាបន្ថែម |
| 2 | មន្ត្រីជំនាញបច្ចេកទេសវិទ្យុ ទូរទស្សន៍នៅមានកម្រិត | ស្នើសុំក្រសួងផ្តល់វគ្គបណ្តុះបណ្តាល |
| 3 | ខ្វះខាតសម្ភារបច្ចេកទេសបម្រើការងារព័ត៌មាន | ជួសជុលសម្ភារចាស់ៗ ប្រើប្រាស់បណ្តោះអាសន្ន និងស្នើសុំថ្មីទៅក្រសួង |
| 4 | ខ្វះរថយន្តសម្រាប់ក្រុមការងារព័ត៌មាន | ស្នើសុំក្រសួងផ្តល់រថយន្ត 01គ្រឿង |
| 5 | វិសាលភាពផ្សព្វផ្សាយវិទ្យុពុំទាន់បានគ្របដណ្តប់ទូទាំងខេត្ត | ស្នើសុំក្រសួងដំឡើងកម្លាំងផ្សាយរបស់វិទ្យុ |
| 24. | **មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** | |
| 1 | ខ្វះមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីកិច្ចសន្យា ដើម្បីបំពេញការងារនៅមន្ទីរ | ស្នើសុំក្រសួងជ្រើសរើសមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាបន្ថែម |
| 2 | មិនទាន់មានច្បាប់អធិការកិច្ច ដែលជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តភារកិច្ចរបស់មន្ទីរ | -ស្នើសុំក្រសួងជួយបង្កលក្ខណៈឱ្យមន្ទីរបានចូលរួមជាមួយប្រតិភូក្រសួងករណីពាក់ព័ន្ធនឹងការងារតាមដានការអនុវត្តច្បាប់<br>-ស្នើសុំក្រសួងជួយជំរុញការរៀបចំច្បាប់អធិការកិច្ច |
| 25. | **មន្ទីរធម្មការ និងសាសនា** | |
| 1 | ខ្វះមន្ត្រីជាច្រើននាក់ ដើម្បីបម្រើការងារតាមការិយាល័យ | ស្នើសុំក្រសួងបន្តប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការបន្ថែមទៀត |
| 2 | គណៈសង្ឃខេត្ត ក្រុង ស្រុក នៅខ្វះសមាសភាពមន្ត្រីសង្ឃជាច្រើនអង្គ ដើម្បីគ្រប់គ្រង អនុវត្តការងារក្នុងវិស័យព្រះពុទ្ធសាសនា | ស្នើសុំគណៈសង្ឃនាយកព្រះមេត្តាជួយជំរុញព្រះមេគណខេត្ត ឱ្យស្នើសុំតែងតាំងព្រះមន្ត្រីសង្ឃខេត្តក្រុង ស្រុក បន្ថែមទៀត |

| | | |
|---|---|---|
| 3 | អគារមន្ទីរ ដែលកំពុងបម្រើការងារសព្វថ្ងៃ មានសភាពចាស់ អាយុកាលតាំងពីសម័យទសវត្សរ៍ទី60 | ស្នើសុំក្រសួងជួយសាងសង់អគារមន្ទីរធម្មការ និងសាសនា ខេត្តថ្មី |
| **26. ការងារសាលាដំបូង** | | |
| 1 | ខ្វះកុំព្យូទ័រចំនួន 10គ្រឿង | ស្នើសុំ ឯកឧត្តមរដ្ឋមន្ត្រី ជួយដោះស្រាយ |
| 2 | ខ្វះអាផ្ទាសាលាចំនួន 02 រូប | |
| **27. មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | | |
| 1 | សំណង់ផ្សេងៗ ត្រូវបានសាងសង់មុនមានលិខិតអនុញ្ញាត | ពង្រឹងកិច្ចសហការជាមួយអាជ្ញាធរដែនដី ដើម្បីចុះតាមដានត្រួតពិនិត្យជាប្រចាំ |
| 2 | ការសាងសង់សំណង់រំលោភដីអូរ ប្រឡាយ ព្រែក និងដីសាធារណៈ | ចុះទប់ស្កាត់ ផ្អាក និងអនុវត្តតាមនីតិវិធី |
| **30. មន្ទីរបរិស្ថាន** | | |
| 1 | ខ្វះឧបករណ៍ត្រួតពិនិត្យការបំពុលខ្យល់ ទឹក ជាបឋម | ស្នើសុំក្រសួង ជួយដោះស្រាយ |
| 2 | ខ្វះសម្ភារត្រួតពិនិត្យទីតាំងស្នើសុំរបស់អាជីវករ សិប្បកម្ម ក្នុងការត្រួតពិនិត្យខ្យល់ សំឡេង និងសំណល់រាវ | ស្នើសុំក្រសួង ជួយដោះស្រាយ |
| 3 | បទល្មើសកាប់ទន្រ្ទានដីព្រៃ ការបោះបង្គោលហ៊ុមព័ទ្ធ និងលាបថ្នាំពណ៌ ដើម្បីយកដីព្រៃធ្វើជាកម្មសិទ្ធិខុសច្បាប់ កំពុងកើតមានគ្រប់តំបន់ការពារធម្មជាតិ | ចុះអប់រំ ផ្សព្វផ្សាយ និងល្បាតតាមដាន បង្ក្រាបជាប្រចាំ |
| 4 | ប្រជាពលរដ្ឋមួយចំនួននៅតែកាប់គាស់ រុករាន កាប់ឆ្ការដុតព្រៃ យកដីធ្វើជាកម្មសិទ្ធិ និងការបរបាញ់ ការចាប់សត្វព្រៃក្នុងតំបន់ការពារធម្មជាតិ | -បន្តអប់រំផ្សព្វផ្សាយ និងចុះការពារទប់ស្កាត់<br>-អនុវត្តនីតិវិធីច្បាប់ និងការផាកពិន័យ |
| **31.មន្ទីរសាធារណការ និងដឹកជញ្ជូន** | | |
| 1 | ខ្វះធនធានមនុស្សសម្រាប់បម្រើការងារ ព្រោះមន្ត្រីមួយចំនួនដល់អាយុចូលនិវត្តន៍ | បានធ្វើសំណើទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីបំពេញមន្ត្រីបន្ថែម |
| 2 | ប្រជាពលរដ្ឋមួយចំនួនរំលោភយកដីចំណីផ្លូវសាធារណៈរបស់រដ្ឋមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន | ស្នើដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ធ្វើការណែនាំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ |
| **32. ការងារអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព** | | |
| 1 | អាជ្ញាធរមួយចំនួនជាប់រវល់ការងាររបស់គាត់មិនសូវបានចូលរួមជាមួយកងកម្លាំងនគរបាល ក្នុងការផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងធ្វើវេទិកាសាធារណៈអំពីសន្តិសុខក្នុងសហគមន៍ | ពង្រឹងកិច្ចសហការជាមួយអាជ្ញាធរ ដើម្បីបន្តចុះធ្វើការផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងបញ្ជ្រាបផ្សព្វផ្សាយខ្លឹមសារណែនាំរបស់ក្រសួងសុខាភិបាល និងប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល 3ការពារ 3កុំ ដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ឱ្យចេះទប់ស្កាត់ និងការពារការរីករាលដាលជំងឺកូវីដ-19 |
| 2 | ខ្វះកម្លាំងមន្ត្រីប៉ុស្តិ៍ និងថវិកាជួយឧបត្ថម្ភជូនប្រជាការពារក្នុងការបំពេញការងារ | ស្នើសុំបន្ថែមកម្លាំង និងកៀរគរថវិកាពីសប្បុរសជន |
| **33. ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** | | |
| 1 | ការគ្រប់គ្រងស្ថិតិយានយន្តគ្រប់ប្រភេទមិនមានទិន្នន័យ | សហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត និង |

| | | |
|---|---|---|
| | ជាក់លាក់ ដោយសារយានជំនិះមួយចំនួនគ្មានពន្ធនាំចូល មិនបានចុះបញ្ជីយានយន្តត្រឹមត្រូវ ។ល។ | មន្ទីរ អង្គភាពពាក់ព័ន្ធ ដើម្បីស្រង់ស្ថិតិយានយន្ត និងពន្លឿនឱ្យមានការចុះបញ្ជីយានយន្តឱ្យបានត្រឹមត្រូវ |
| 2 | ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត អំពីការប្រើប្រាស់ចិញ្ចើមផ្លូវ ការចត ឈប់ ការចោលសំរាម ។ល។ | ផ្សព្វផ្សាយ ណែនាំដល់ប្រជាពលរដ្ឋ និងចុះធ្វើសណ្តាប់ធ្នាប់ក្នុងទីប្រជុំជនឱ្យមានរបៀបរៀបរយ |
| **34. ការងារគ្រប់គ្រងពន្ធនាគារ** | | |
| 1 | ខ្វះប្រាក់បេសកកម្មសម្រាប់មន្ត្រី ខ្វះប្រេងសម្រាប់ដឹកជញ្ជូន ខ្វះថវិកាសម្រាប់ទូទាត់សម្ភារប្រើប្រាស់ក្នុងការិយាល័យ និងថវិកាទូទាត់អគ្គិសនី ទឹកស្អាត និងខ្វះថវិកាសម្រាប់ជួសជុលថែទាំអគារ និងមធ្យោបាយ ដឹកជញ្ជូន | ស្នើសុំអគ្គនាយកដ្ឋានពន្ធនាគារ ជួយគាំទ្រដោះស្រាយ |
| 2 | បន្ទប់ឃុំឃាំងមានភាពចង្អៀតណែន | ស្នើសុំអគ្គនាយកដ្ឋានពន្ធនាគារ សាងសង់បន្ទប់ឃុំឃាំងបន្ថែមទៀត |
| **35. ការងារគ្រប់គ្រងជនអន្តោប្រវេសន៍** | | |
| 1 | ជនបរទេសអន្តោប្រវេសន្ត ដែលបានទទួលប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដំបូងផុតកំណត់ មិនព្រមចូលខ្លួនមកបង់អាករ និងដាក់ពាក្យសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី1 | ណែនាំ និងអប់រំផ្សព្វផ្សាយជូនពួកគាត់តាមជំហានៗ មុននឹងឈានដល់ការអនុវត្តនីតិវិធីច្បាប់ |
| 2 | ជនបរទេសអន្តោប្រវេសន្ត ដែលបានទទួលប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដំបូងផុតកំណត់ សាមីខ្លួន ផ្លាស់ប្តូរទីលំនៅចេញពីខេត្តដោយមិនបានជូនដំណឹងដល់អាជ្ញាធរដែនដី | ផ្សព្វផ្សាយដល់ជនបរទេសអន្តោប្រវេសន្ត និងញាតិសន្តានឱ្យជូនដំណឹងដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ នៅពេលផ្លាស់ប្តូរទីលំនៅទៅខេត្តផ្សេង |
| 3 | ម្ចាស់ផ្ទះសំណាក់ និងផ្ទះជួលមួយចំនួនផ្តល់ទិន្នន័យវត្តមានជនបរទេស មិនច្បាស់លាស់ | បន្តជំរុញអប់រំ ណែនាំ ឱ្យម្ចាស់ផ្ទះសំណាក់ និងផ្ទះជួលអនុវត្តតាមមាត្រា18 នៃច្បាប់អន្តោប្រវេសន៍ និងសេចក្តីជូនដំណឹងលេខ2028 របស់ក្រសួងមហាផ្ទៃឱ្យកាន់តែល្អប្រសើរ |
| 4 | ម្ចាស់ផ្ទះសំណាក់ និងផ្ទះជួលមួយចំនួនមិនសហការផ្តល់ទិន្នន័យវត្តមានជនបរទេស | ណែនាំ និងអប់រំផ្សព្វផ្សាយ មុនឈានដល់ការផាកពិន័យអន្តរការណ៍តាមនីតិវិធីច្បាប់ស្តីពីអន្តោប្រវេសន៍ |

# ផ្នែកទី៥

# ទិសដៅការងារឆ្នាំបន្ទាប់

## ៥.១. រដ្ឋបាលខេត្ត

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| **1. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការ** | | | | | |
| 1 | រៀបចំកិច្ចប្រជុំសាមញ្ញ របស់ក្រុមប្រឹក្សាខេត្ត | ✓ | ✓ | ✓ | ✓ |
| 2 | រៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត | ✓ | ✓ | ✓ | ✓ |
| 3 | រៀបចំកិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សាខេត្ត | ✓ | ✓ | ✓ | ✓ |
| 4 | រៀបចំកិច្ចប្រជុំគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត | ✓ | ✓ | ✓ | ✓ |
| 5 | រៀបចំវេទិការបស់ក្រុមប្រឹក្សាខេត្តតាមបណ្តា ក្រុង ស្រុក | | | | ✓ |

| | | | | | |
|---|---|---|---|---|---|
| 2. ការងារគណៈអភិបាល | | | | | |
| 1 | ប្រជុំការងារគណៈអភិបាលប្រចាំខែ | ✓ | ✓ | ✓ | ✓ |
| 2 | ចូលរួមប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត | ✓ | ✓ | ✓ | ✓ |
| 3 | សម្របសម្រួល ដោះស្រាយវិវាទផ្សេងៗក្នុងដែនសមត្ថកិច្ច | ✓ | ✓ | ✓ | ✓ |
| 4 | ចូលរួមប្រជុំ សិក្ខាសាលាផ្សេងៗតាមការអញ្ជើញរបស់ថ្នាក់ជាតិ | ✓ | ✓ | ✓ | ✓ |
| 5 | ចូលរួមជាអធិបតីក្នុងកម្មវិធីផ្សេងៗក្នុងខេត្ត | ✓ | ✓ | ✓ | ✓ |
| 6 | បន្តប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-19 | ✓ | ✓ | ✓ | ✓ |
| 3. ទីចាត់ការរដ្ឋបាល | | | | | |
| 1 | ចងក្រងឯកសារសម្រាប់តម្កល់ទុកប្រចាំខែ | ✓ | ✓ | ✓ | ✓ |
| 2 | ទទួល និងបែងចែកលិខិតចេញ ចូល ទូរស័ព្ទ | ✓ | ✓ | ✓ | ✓ |
| 3 | ទទួលពិនិត្យឯកសារផ្សេងៗ | ✓ | ✓ | ✓ | ✓ |
| 4 | រៀបចំកម្មវិធីការងារប្រចាំសប្តាហ៍ជូនគណៈអភិបាល | ✓ | ✓ | ✓ | ✓ |
| 5 | ប្រមូលចងក្រងរបាយការណ៍អនុវត្តការងាររបស់គណៈអភិបាលខេត្តប្រចាំខែ | ✓ | ✓ | ✓ | ✓ |
| 6 | ទទួល និងប្រគល់ឯកសារចេញ និងចូលរបស់រដ្ឋបាលខេត្ត តាមមន្ទីរ អង្គភាពនានា | ✓ | ✓ | ✓ | ✓ |
| 7 | រៀបចំរបាយការណ៍របស់រដ្ឋបាលខេត្ត | ✓ | ✓ | ✓ | ✓ |
| 8 | ចុះយកព័ត៌មានក្នុងកម្មវិធីផ្សេងៗរបស់ខេត្ត | ✓ | ✓ | ✓ | ✓ |
| 9 | ទទួល និងផ្តល់ព័ត៌មានជូនសាធារណជននានាដែលមកទាក់ទងការងារនៅសាលាខេត្ត | ✓ | ✓ | ✓ | ✓ |
| 10 | រៀបចំពិធីបដិសណ្ឋារកិច្ចចំពោះគណៈប្រតិភូ ភ្ញៀវជាតិ អន្តរជាតិ | ✓ | ✓ | ✓ | ✓ |
| 11 | ការចងសម្ព័ន្ធមេត្រីភាពជាមួយទីក្រុង និងខេត្តជាដៃគូ | ✓ | ✓ | ✓ | ✓ |
| 12 | រៀបចំឯកសារសេចក្តីព្រាងអនុស្សរណៈ ឬ កិច្ចព្រមព្រៀងនានារវាងខេត្ត និងខេត្ត ក្រុងជាដៃគូ និងអង្គការអន្តរជាតិនានា | ✓ | ✓ | ✓ | ✓ |
| 13 | កិច្ចសហការ និងការគាំទ្រពីខេត្ត ក្រុងសម្ព័ន្ធមេត្រីភាព និងពីអង្គការជាតិ អន្តរជាតិ | ✓ | ✓ | ✓ | ✓ |
| 14 | តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីកិច្ចសហប្រតិបត្តិការរវាងខេត្តជាមួយខេត្ត ក្រុងជាដៃគូ និងអង្គការអន្តរជាតិនានា | ✓ | ✓ | ✓ | ✓ |
| 15 | រៀបចំសន្និបាតប្រចាំឆ្នាំ | ✓ | | | |
| 4. ទីចាត់ការហិរញ្ញវត្ថុ | | | | | |
| 1 | រៀបចំកម្មវិធីចំណូល ចំណាយប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ |
| 2 | រៀបចំគម្រោងចំណូល ចំណាយប្រចាំត្រីមាស | ✓ | ✓ | ✓ | ✓ |
| 3 | រៀបចំគម្រោងអនុវត្តថវិកាប្រចាំខែ ត្រីមាស ឆ្នាំ | ✓ | ✓ | ✓ | ✓ |
| 4 | រៀបចំអាណត្តិទូទាត់បើកប្រាក់បៀវត្ស ទូទាត់បុរេប្រទាន ទូទាត់ត្រង់ ទូទាត់បេសកកម្ម និងលទ្ធកម្ម | ✓ | ✓ | ✓ | ✓ |
| 5. ទីចាត់ការផែនការ និងវិនិយោគ | | | | | |
| 1 | គាំទ្រដល់ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (2023-2025) របស់រដ្ឋបាលខេត្ត | ✓ | ✓ | ✓ | |
| 2 | គាំទ្រដល់ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (2022-2024) របស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ | ✓ | | | |

| | | | | | |
|---|---|---|---|---|---|
| 3 | គាំទ្រ និងសម្របសម្រួលដល់ការអនុវត្តគម្រោងអាហារូបត្ថម្ភនៅកម្ពុជា ខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 4 | គាំទ្រ និងសហការសិក្សា រៀបចំប្លង់បច្ចេកទេស ប៉ាន់ស្មានតម្លៃគម្រោង និងរៀបចំសំណើគម្រោងខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ឆ្នាំ2022 | ✓ | ✓ | ✓ | ✓ |
| 5 | គាំទ្រដំណើរប្រជុំដេញថ្លៃ និងរៀបចំកិច្ចសន្យាគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ2022 | ✓ | ✓ | ✓ | ✓ |
| 6 | ចុះត្រួតពិនិត្យ និងវាយតម្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ2021 និងឆ្នាំ2022 | ✓ | ✓ | ✓ | ✓ |
| 7 | គាំទ្រដំណើរការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងផ្នែកបច្ចេកទេសដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ | ✓ | ✓ | ✓ | ✓ |
| 8 | ចងក្រងទិន្នន័យ និងរបាយការណ៍ស្តីពីការវិនិយោគនានាក្នុងខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 9 | គាំទ្រដំណើរការពិនិត្យលើសំណើសុំ និងការចុះពិនិត្យគម្រោងវិនិយោគនានានៅក្នុងខេត្ត | ✓ | ✓ | ✓ | ✓ |
| 10 | រៀបចំបញ្ជីឈ្មោះអ្នកទទួលការសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ឆ្នាំ2023 | | | | ✓ |
| 11 | រៀបចំបញ្ជីតម្លៃសម្ភារស្តង់ដារសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ឆ្នាំ2023 | | | | ✓ |
| **6. ទីចាត់ការអន្តរវិស័យ** | | | | | |
| 1 | បន្តសហការជាមួយ ក្រសួង មន្ទីរ អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីនៅសេសសល់ជូនប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ |
| 2 | បន្តសហការជាមួយ ក្រសួង មន្ទីរ អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ធ្វើការបោះបង្គោលព្រំដីរដ្ឋដែលបានកាត់ឆ្វៀលដីចេញពីតំបន់ការពារធម្មជាតិ តំបន់ជីវៈចម្រុះ និងគម្របព្រៃឈើឆ្នាំ2002 | ✓ | ✓ | ✓ | ✓ |
| 3 | បន្តសហការជាមួយ ក្រសួង មន្ទីរ អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ចុះធ្វើបច្ចុប្បន្នភាពស្លាកសញ្ញា ប៉ាណូផ្សាយពាណិជ្ជកម្ម | ✓ | ✓ | ✓ | ✓ |
| **7. ទីចាត់ការគ្រប់គ្រងធនធានមនុស្ស** | | | | | |
| 1 | រៀបចំសំណើសុំទៅក្រសួងមហាផ្ទៃ តែងតាំង លោក សុប ប៉ាស្សារី បច្ចុប្បន្នជានាយករងរដ្ឋបាលទៅជានាយករដ្ឋបាលសាលាក្រុងខេមរភូមិន្ទ | ✓ | | | |
| 2 | ជូនដំណឹងដល់មន្ត្រីកិច្ចសន្យា មកបំពេញសំណុំបែបបទសម្រាប់បន្តកិច្ចសន្យា សម្រាប់ឆ្នាំ 2022 ដើម្បីស្នើ លោកជំទាវអភិបាលខេត្ត ពិនិត្យ និងសម្រេច និងរៀបចំបែបបទតាមនីតិវិធីទៅមន្ទីរមុខងារសាធារណៈ និងក្រសួងមុខងារជោរណៈ | ✓ | ✓ | | |
| 3 | រៀបចំបញ្ជីបច្ចុប្បន្នភាពមន្ត្រីរាជការនៃរដ្ឋបាលខេត្តក្នុងឆ្នាំ2021 ដើម្បីទុកជាទិន្នន័យដើមគ្រាក្នុងឆ្នាំ2022 និងបន្តធ្វើបច្ចុប្បន្នភាពជាប្រចាំត្រីមាស | ✓ | ✓ | ✓ | ✓ |
| 4 | រៀបចំតាក់តែងដីកាស្តីពីការដំឡើងថ្នាក់ ឋានន្តរស័ក្តិ តាមវេនអតីតភាព ជូនមន្ត្រីរាជការ នៃរដ្ឋបាលខេត្ត សម្រាប់ឆ្នាំ2022 | ✓ | ✓ | ✓ | ✓ |
| 5 | ត្រៀមរៀបចំស្នើដាក់របៀបវារៈការតែងតាំងមន្ត្រីរាជការ ក្នុងកិច្ចប្រជុំគណៈអភិបាល | ✓ | ✓ | ✓ | ✓ |
| 6 | សម្របសម្រួល និងជួយដល់រដ្ឋបាលក្រុង ស្រុក ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពក្រុមប្រឹក្សា និងមន្ត្រី បុគ្គលិកកិច្ចសន្យា ក្នុងឆ្នាំ2022 | ✓ | | | |
| 7 | គាំទ្រដល់ដំណើរការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន សម្រាប់រដ្ឋបាលខេត្ត ក្រុង ស្រុក ឆ្នាំ2022 | ✓ | ✓ | ✓ | ✓ |
| 8 | សម្របសម្រួលដល់ការចុះសិក្សាស្រាវជ្រាវរបស់និស្សិតនៃសាកលវិទ្យាល័យនានា ដែលមានគោលបំណងក្នុងការសិក្សាស្រាវជ្រាវនៅខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 9 | ពង្រឹងការអនុវត្តការងារគណនេយ្យសង្គម ក្នុងឆ្នាំ2022 | ✓ | ✓ | ✓ | ✓ |

| | | | | | |
|---|---|---|---|---|---|
| **8. អង្គភាពលទ្ធកម្ម** | | | | | |
| 1 | បន្តរៀបចំឯកសារលទ្ធកម្មទំនិញ | ✓ | ✓ | ✓ | ✓ |
| 2 | បន្តរៀបចំឯកសារលទ្ធកម្មសំណង់ | ✓ | ✓ | ✓ | ✓ |
| **9. អង្គភាពច្រកចេញ ចូលតែមួយ** | | | | | |
| 1 | បន្តការផ្តល់សេវាជូនប្រជាពលរដ្ឋ ឱ្យកាន់តែល្អប្រសើរជាមុន | ✓ | ✓ | ✓ | ✓ |
| 2 | បន្តបណ្តុះបណ្តាលនូវលិខិតបទដ្ឋានគតិយុត្តថ្មីៗ ដល់មន្ត្រីក្នុងអង្គភាព | ✓ | ✓ | ✓ | ✓ |
| 3 | ពង្រឹងកិច្ចការប្រចាំថ្ងៃក្នុងអង្គភាព និងធ្វើរបាយការណ៍ប្រចាំខែជូនថ្នាក់ដឹកនាំខេត្ត និងក្រសួងពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ |
| 4 | រៀបចំកិច្ចប្រជុំជាមួយមន្ទីរពាក់ព័ន្ធដើម្បីបន្សីគ្នាលើរបាយការណ៍ប្រចាំខែនីមួយៗ | ✓ | ✓ | ✓ | ✓ |
| 5 | អនុវត្តការងារក្នុងអង្គភាពតាមភាពជាក់ស្តែង គោលដៅដើម្បីឱ្យដំណើរការបានរលូន | ✓ | ✓ | ✓ | ✓ |

**៥.២. មន្ទីរ អង្គភាពជំនាញ**

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| **1. មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | | |
| 1 | បន្តចុះតាមដាន និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មតាមបណ្តាក្រុង/ស្រុកទូទាំងខេត្ត | ✓ | ✓ | ✓ | ✓ |
| 2 | ត្រៀមអន្តរាគមន៍ពីការបំផ្លាញរបស់សត្វល្អិតចង្រៃលើដំណាំតាមបណ្តាក្រុង/ស្រុក | ✓ | ✓ | ✓ | ✓ |
| 3 | តាមដាន ត្រួតពិនិត្យ និងទប់ស្កាត់ការរីករាលដំងឺឆ្លងសត្វ | ✓ | ✓ | ✓ | ✓ |
| 4 | ពង្រឹងការត្រួតពិនិត្យអនាម័យចលនាដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វ | ✓ | ✓ | ✓ | ✓ |
| 5 | ចុះពង្រឹង និងធ្វើបច្ចុប្បន្នភាពភ្នាក់ងារសុខភាពសត្វភូមិតាមបណ្តាក្រុង/ស្រុក | | ✓ | | ✓ |
| 6 | ចុះបណ្តុះបណ្តាលការជួសជុល និងការថែទាំគ្រឿងយន្តកសិកម្ម ដល់ប្រជាកសិករ | | ✓ | | ✓ |
| 7 | ចុះបណ្តុះបណ្តាលនីតិវិធីស្រង់ស្ថិតិគ្រឿងយន្តកសិកម្ម ដល់អាជ្ញាធរតាមបណ្តាមូលដ្ឋាន | | | ✓ | |
| 8 | បើកវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសការប្រមូលផល និងការកែច្នៃផលិតផលកសិកម្ម | | ✓ | | ✓ |
| 9 | ចុះពិនិត្យ និងវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្ត | | ✓ | ✓ | |
| 10 | ចុះបណ្តុះបណ្តាលបច្ចេកទេសបើកមុខចៀរជ័រកៅស៊ូដំបូងដល់កសិករនៅស្រុកបូទុមសាគរ និងស្រុកស្រែអំបិល | | ✓ | ✓ | |
| 11 | ចុះផ្ទៀងផ្ទាត់ទិន្នន័យកៅស៊ូនៅតាមបណ្តាមូលដ្ឋានទូទាំងខេត្ត | ✓ | ✓ | | |
| 12 | បន្តគាំទ្រ អង្កេតតាមដាន និងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដែលកំពុងដំណើរការ | ✓ | ✓ | ✓ | ✓ |
| 13 | ចុះត្រួតពិនិត្យ តាមដានទីតាំងអាជីវកម្ម និងការចរាចរណ៍ជី-ថ្នាំកសិកម្មក្នុងខេត្ត | ✓ | ✓ | ✓ | ✓ |
| 14 | ចុះផ្សព្វផ្សាយពីវិធានបច្ចេកទេសនៃការប្រើប្រាស់ថ្នាំកសិកម្ម និងជីកសិកម្ម ព្រមទាំងវិធានសុវត្ថិភាពដល់អាជីវករ និងកសិករ | ✓ | ✓ | ✓ | ✓ |
| 15 | ចុះធ្វើបច្ចុប្បន្នភាព និងស្រង់តម្លៃថ្នាំកសិកម្ម និងជីកសិកម្ម តាមដេប៉ូលក់ដុំ លក់រាយក្នុងខេត្ត | ✓ | | ✓ | |
| 16 | បន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន កម្លាំងល្បាតរបស់សហគមន៍នេសាទក្នុងការបង្ក្រាបបទល្មើសនេសាទ | ✓ | ✓ | ✓ | ✓ |
| 17 | ចុះបណ្តុះបណ្តាលបច្ចេកទេសកែច្នៃផលិតផលជលផល | | ✓ | | ✓ |
| 18 | ចុះបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ | ✓ | | ✓ | |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| 19 | បន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន កម្លាំងល្បាតរបស់សហគមន៍ព្រៃឈើ ក្នុងការបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ ឱ្យបានទាន់ពេលវេលា | ✓ | ✓ | ✓ | ✓ |
| 20 | បន្តចុះតាមដាន និងត្រួតពិនិត្យករណីរំលោភទន្ទ្រានកាន់កាប់ សាងសង់ផ្ទះ ពីសំណាក់ប្រជាពលរដ្ឋ នៅលើដីចម្ការឈើអាកាស្យា ស្ថិតនៅភូមិ1 សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ | ✓ | ✓ | ✓ | ✓ |
| 21 | អនុវត្តកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) តាមផែនការ សកម្មភាពប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ |
| 22 | សហការជាមួយអង្គការ Save The Children និងគម្រោងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋតាមរយៈការពង្រឹងផលិតកម្មកសិកម្ម និងទីផ្សារ (STEER) ដើម្បីចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដល់កសិករតាម មូលដ្ឋាននានាក្នុងស្រុកគោលដៅ | ✓ | ✓ | ✓ | ✓ |
| **2. មន្ទីរធនធានទឹក និងឧតុនិយម** | | | | | |
| 1 | ជំរុញការងារពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកខ្ពង់ ស្ថិតនៅភូមិខ្ពង់ ឃុំស្រែអំបិល និងសហគមន៍កសិករប្រើប្រាស់ទឹកកណ្តោលជាបន្ត ដែលស្ថិតនៅភូមិផ្ទង់ និងភូមិកណ្តោល ឃុំកណ្តោល | ✓ | ✓ | ✓ | ✓ |
| 2 | ពង្រឹងការងារប្រមូលទិន្នន័យឧតុនិយមនៅតាមបណ្តាស្រុកដែលមានស្ថានីយឧតុនិយមក្នុងខេត្តឱ្យកាន់តែឆាប់រហ័ស និងសុក្រឹតដើម្បីចងក្រងបញ្ជូនទៅក្រសួងធនធានទឹក និងឧតុនិយម | ✓ | ✓ | ✓ | ✓ |
| 3 | ចុះសិក្សាគម្រោងស្តារប្រឡាយដោះទឹកជំនន់តាមបណ្តោយទំនប់ការពារទឹកប្រៃបឹងព្រាវ ក្នុងឃុំបឹងព្រាវ ស្រុកស្រែអំបិល នាពេលខាងមុខ | ✓ | ✓ | ✓ | ✓ |
| 4 | ចុះសិក្សាគម្រោងជួសជុលទ្វារអាងទឹកជីត្រេះ ក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ | ✓ | ✓ | ✓ | ✓ |
| 5 | ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃកណ្តោល ក្នុងឃុំកណ្តោល ស្រុកបូទុមសាគរ | ✓ | ✓ | ✓ | ✓ |
| 6 | ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃតាំកន់ ក្នុងឃុំកណ្តោល ស្រុកបូទុមសាគរ | ✓ | ✓ | ✓ | ✓ |
| 7 | ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃជីមាល ឃុំអណ្តូលទឹក ស្រុកបូទុមសាគរ | ✓ | ✓ | ✓ | ✓ |
| 8 | ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃជីត្រេះ ក្នុងឃុំអណ្តូលទឹក ស្រុកបូទុមសាគរ | ✓ | ✓ | ✓ | ✓ |
| 9 | ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃបឹងព្រាវ ក្នុងឃុំបឹងព្រាវ ស្រុកស្រែអំបិល | ✓ | ✓ | ✓ | ✓ |
| 10 | ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃតានី ក្នុងឃុំជីខលើ ស្រុកស្រែអំបិល | ✓ | ✓ | ✓ | ✓ |
| **3. មន្ទីរអភិវឌ្ឍន៍ជនបទ** | | | | | |
| 1 | បន្តសកម្មភាពចុះធ្វើបច្ចុប្បន្នភាព ខ្សែផ្លូវជនបទនៅទូទាំងស្រុកក្នុងខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 2 | បន្តចុះស្រង់ទិន្នន័យផ្លូវជនបទថ្មី នៅទូទាំងស្រុកក្នុងខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 3 | បន្តចុះរាប់ចំនួនចរាចរណ៍លើខ្សែផ្លូវជនបទថ្មី នៅទូទាំងស្រុកក្នុងខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 4 | បន្តការងារសាងសង់ ថែទាំ ជួសជុល លក្ខណៈខួប ប្រចាំ និង បន្ទាន់ នៅតាមតំបនជនបទ | ✓ | ✓ | ✓ | ✓ |
| 5 | បន្តសាងសង់ស្រះសហគមន៍នៅទូទាំងស្រុកក្នុងខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 6 | បន្តការងារជួសជុលអណ្តូងស្នប់នៅទូទាំងស្រុកក្នុងខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 7 | ចុះជំរុញផ្សព្វផ្សាយពីអត្ថប្រយោជន៍ក្នុងការសន្សំប្រាក់របស់ប្រជាពលរដ្ឋនៅតាមសហគមន៍ | ✓ | ✓ | ✓ | ✓ |
| 8 | បន្តចុះធ្វើបច្ចុប្បន្នភាពក្រុមសន្សំប្រាក់នៅតាមសហគមន៍មូលដ្ឋាន | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| 9 | បន្តចុះណែនាំស្តីពីការគ្រប់គ្រងក្នុងការចុះកិច្ចបញ្ជីការទៅដល់ប្រធានក្រុមសន្សំប្រាក់ នៅតាមសហគមន៍នីមួយៗ | ✓ | ✓ | ✓ | ✓ |
| **4.** | **មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** | | | | |
| 1 | ចុះត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ដែបាញ់ប្រេង ទំនិញផលិតទំនិញវេចខ្ចប់ និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅតាមបណ្តាក្រុង ស្រុក | ✓ | ✓ | ✓ | ✓ |
| 2 | បន្តអនុវត្តការងារយន្តការច្រកចេញចូលតែមួយរបស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ខេត្ត លើការផ្តល់សេវាសាធារណៈជូនម្ចាស់សហគ្រាស/សិប្បកម្ម | ✓ | ✓ | ✓ | ✓ |
| 3 | បន្តសហការជាមួយមន្ត្រីទទួលបន្ទុកវិស័យឧស្សាហកម្ម និងសិប្បកម្ម តាម ក្រុង ស្រុក ដើម្បីអនុវត្ត សេចក្តីណែនាំអន្តរក្រសួង លេខ 002/MISTI2020 ចុះថ្ងៃទី06 ខែកក្កដា ឆ្នាំ2020 ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | ✓ | ✓ | ✓ | ✓ |
| 4 | រៀបចំរបាយការណ៍លទ្ធផលនៃការអនុវត្តការងារប្រតិភូកម្មរបស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តកោះកុង<br>- សេចក្តីសម្រេចបង្កើតសហគ្រាស/សិប្បកម្ម<br>- វិញ្ញាបនបត្រថ្មី និងបន្ត<br>- សហគ្រាស/សិប្បកម្ម បិទទ្វារ និងព្យួរ<br>- សហគ្រាស/សិប្បកម្មពង្រីកមុខផលិតផលថ្មី ឬពង្រីកដើមទុន ឬប្តូរទីតាំង ឬ ប្តូរម្ចាស់ | ✓ | ✓ | ✓ | ✓ |
| 5 | ចុះត្រួតពិនិត្យតាមបណ្តាសហគ្រាស សិប្បកម្ម ដើម្បីយកសំណាកផលិតផលទៅវិភាគគុណភាពនៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (រាជធានីភ្នំពេញ) | ✓ | ✓ | ✓ | ✓ |
| 6 | ចុះស្រង់ស្ថិតិរោងចក្រ សហគ្រាស សិប្បកម្ម ដែលបានបិតទ្វារឈប់ដំណើរការ និងផ្អាកដំណើរការបណ្តោះអាសន្ន និងធ្វើរបាយការណ៍ជូនរដ្ឋបាលខេត្ត និងក្រសួង | ✓ | ✓ | ✓ | ✓ |
| 7 | បន្តជំរុញដល់ម្ចាស់សហគ្រាស/សិប្បកម្មឱ្យយកចិត្តទុកដាក់អនុវត្តគោលការណ៍ អនាម័យល្អ ផលិតកម្មល្អ និងគោលការណ៍ ស5 (សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដារ ស្ថិតស្ថេរ) | ✓ | ✓ | ✓ | ✓ |
| 8 | បន្តជំរុញដល់ក្រុមហ៊ុន និងសិប្បកម្មផលិតទឹកស្អាត យកទឹកទៅវិភាគ នៅមន្ទីរពិសោធន៍ រៀងរាល់ 6ខែម្តង ដើម្បីធានាពីគុណភាពទឹកឱ្យមានអនាម័យល្អ | ✓ | ✓ | ✓ | ✓ |
| **5.** | **មន្ទីររ៉ែ និងថាមពល** | | | | |
| 1 | បន្តផ្សព្វផ្សាយដល់អាជីវករឱ្យយល់ពីច្បាប់ ស្តីពីការគ្រប់គ្រងធនធានរ៉ែ | ✓ | ✓ | ✓ | ✓ |
| 2 | បន្តផ្សព្វផ្សាយសារាចរ សេចក្តីណែនាំ ស្តីពីការគ្រប់គ្រងស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ ជូនដល់អាជីវករក្នុងខេត្ត | ✓ | ✓ | ✓ | ✓ |
| 3 | ជំរុញ និងគាំទ្រដល់ក្រុមហ៊ុនផលិត ផ្គត់ផ្គង់ និងចែកចាយថាមពលអគ្គិសនី ទាំងអស់ឱ្យពង្រីកបណ្តាញបន្តទៀត | ✓ | ✓ | ✓ | ✓ |
| 4 | តាមដាន និងត្រួតពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធបណ្តាញអគ្គិសនីឱ្យមានលក្ខណៈបច្ចេកទេស | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| | និងមានគុណភាព ប្រសិទ្ធភាព ចីរភាព សោភណ្ឌភាពក្នុងទីក្រុង ទីប្រជុំជន ដើម្បីចៀសវាងឧបទ្ទវហេតុផ្សេងៗ កើតមានឡើង | | | | |
| 5 | បន្តខិតខំកៀរគរចំណូលសួយសារធនធានរ៉ែ ដើម្បីបង់ចូលថវិការដ្ឋ | ✓ | ✓ | ✓ | ✓ |
| **6. មន្ទីរពាណិជ្ជកម្ម** | | | | | |
| 1 | ផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួលការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក និងបំពេញប្រតិវេទន៍ប្រចាំឆ្នាំ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម | ✓ | ✓ | ✓ | ✓ |
| 2 | បន្តសហការជាមួយមន្ត្រីការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញ ចូលតែមួយនៅតាមបណ្តាក្រុង ស្រុក ដើម្បីផ្សព្វផ្សាយស្តីពីការងារបំពេញបែបបទការស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម និងអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ ដល់អាជីវករ | ✓ | ✓ | ✓ | ✓ |
| 3 | ចុះសិក្សាទំនិញសក្តានុពលនៅតាមបណ្តាស្រុក | ✓ | ✓ | ✓ | ✓ |
| 4 | រៀបចំ ផ្សារផលិតផលចុងសប្តាហ៍ខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 5 | ចូលរួមការតាំងពិព័រណ៍ពាណិជ្ជកម្មថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ខេត្ត | ✓ | ✓ | ✓ | ✓ |
| 6 | តាមដានស្តីពីសន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារ ចំនួន 119មុខ ប្រចាំថ្ងៃ | ✓ | ✓ | ✓ | ✓ |
| 7 | តាមដានការផ្គត់ផ្គង់ តម្រូវការ និងតម្លៃទំនិញប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ រៀងរាល់ 2ដងក្នុងមួយសប្តាហ៍ និងស្ថានភាពដួញដូរតាមព្រំដែន | ✓ | ✓ | ✓ | ✓ |
| 8 | ចុះពិនិត្យថ្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ និងដេប៉ូ ក្នុងក្រុង ស្រុក ទូទាំងខេត្ត | ✓ | ✓ | ✓ | ✓ |
| 9 | បន្តចូលរួមសហការចុះត្រួតពិនិត្យគុណភាពទំនិញ និងសុវត្ថិភាពចំណីអាហារ ជាមួយសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត | ✓ | ✓ | ✓ | ✓ |
| 10 | សហការជាមួយសភាពាណិជ្ជកម្មខេត្តក្នុងការអភិវឌ្ឍន៍ពាណិជ្ជកម្ម។ | ✓ | ✓ | ✓ | ✓ |
| **7. សាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត** | | | | | |
| 1 | រៀបចំផែនការសកម្មភាព និងពង្រឹងស្មារតីទទួលខុសត្រូវសម្រាប់ការអនុវត្តការងារក្នុងឆ្នាំ2022 | ✓ | ✓ | ✓ | ✓ |
| 2 | បន្តអង្កេតស្រាវជ្រាវ និងកំណត់បទល្មើស ដើម្បីអនុវត្តតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធ ជាធរមាន | ✓ | ✓ | ✓ | ✓ |
| 3 | ពង្រឹងការទប់ស្កាត់ទំនិញក្លែងបន្លំ និងខូចគុណភាព នៅតាមទីផ្សារឱ្យមានប្រសិទ្ធភាពខ្ពស់ | ✓ | ✓ | ✓ | ✓ |
| 4 | បន្តអប់រំ ផ្សព្វផ្សាយស្តីពី សុវត្ថិភាពម្ហូបចំណី និងការយល់ដឹងអំពីការពុលស្រាស ស្រាថ្នាំ និងផលប៉ះពាល់សុខភាព | ✓ | ✓ | ✓ | ✓ |
| 5 | បន្តចុះផ្សព្វផ្សាយខិតប័ណ្ណអប់រំពីផលប៉ះពាល់សុខភាពនៃសារធាតុ អាបេស្តុស ដល់អ្នកលក់គ្រឿងសំណង់ក្នុងខេត្ត | ✓ | ✓ | ✓ | ✓ |
| 6 | ត្រៀមសហការរៀបចំបើកវគ្គផ្សព្វផ្សាយច្បាប់ស្តីពី ការប្រកួតប្រជែង ដែលទើបប្រកាសឱ្យប្រើប្រាស់នាពេលថ្មីៗនេះ ដល់មន្ត្រីរាជការ អាជីវករ និងប្រជាពលរដ្ឋក្នុងខេត្តកោះកុងបានយល់អំពីច្បាប់នេះ | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| **8. មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | | | | |
| 1 | ពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | ✓ | ✓ | ✓ | ✓ |
| 2 | ពង្រឹងការត្រួតពិនិត្យចំណូល ចំណាយតាមបណ្ដាអង្គភាពក្រុង ស្រុក ឱ្យបានត្រឹមត្រូវ | ✓ | ✓ | ✓ | ✓ |
| 3 | ត្រៀមបណ្ដុះបណ្ដាលមន្ត្រីហិរញ្ញវត្ថុតាមបណ្ដាអង្គភាពអនុវត្តថវិកានូវនីតិវិធីអនុវត្តថវិកា និងកិច្ចលទ្ធកម្មសាធារណៈ | ✓ | ✓ | ✓ | ✓ |
| 4 | ពង្រឹងការត្រួតពិនិត្យប្រគល់ ទទួល ចំពោះកិច្ចលទ្ធកម្មសាធារណៈ | ✓ | ✓ | ✓ | ✓ |
| 5 | រៀបចំប្រព័ន្ធការគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុសាធារណៈ (FMIS) ជាបន្តបន្ទាប់ | ✓ | ✓ | ✓ | ✓ |
| 6 | ជំរុញរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ធ្វើសារពើភណ្ឌ (ទាំងដីមានកម្មសិទ្ធិ និងដីបម្រុង) | ✓ | ✓ | ✓ | ✓ |
| **9. សាខាគយ និងរដ្ឋាករ** | | | | | |
| 1 | បន្តពង្រឹងការងារគ្រប់គ្រងការប្រមូលពន្ធឱ្យបានតាមផែនការកំណត់ ពង្រឹងការអនុវត្តវិមជ្ឈការតម្លៃឱ្យបានល្អ | ✓ | ✓ | ✓ | ✓ |
| 2 | ជំរុញសកម្មភាពចល័តស្រាវជ្រាវ និងបង្ក្រាបអំពើរត់គេចពន្ធក្នុងភូមិសាស្ត្រទទួលបន្ទុក | ✓ | ✓ | ✓ | ✓ |
| 3 | ចាត់វិធានការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូន ចេញ និងចូល ឱ្យកាន់តែសុក្រឹត | ✓ | ✓ | ✓ | ✓ |
| 4 | បន្តទប់ស្កាត់ និងបង្ក្រាបនូវរាល់សកម្មភាពរត់គេចពន្ធខុសច្បាប់ | ✓ | ✓ | ✓ | ✓ |
| 5 | ជំរុញសកម្មភាពគ្រប់គ្រងផលនេសាទនាំចេញ នាំចូលឱ្យមកបង់ពន្ធតាមនីតិវិធីគយ | ✓ | ✓ | ✓ | ✓ |
| 6 | ពង្រឹងអភិបាលកិច្ចរបស់អង្គភាពគយ ពិសេសកែសម្រួលកម្លាំង ដើម្បីបំពេញភារកិច្ច មានការទទួលខុសត្រូវច្បាស់លាស់តាមបទដ្ឋានគយ និងរដ្ឋាករ | ✓ | ✓ | ✓ | ✓ |
| **10. សាខាពន្ធដារ** | | | | | |
| 1 | រៀបចំក្រុមការងារចម្រុះដើម្បីចុះត្រួតពិនិត្យលើការប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះ គ្រប់ប្រភេទសម្រាប់ឆ្នាំ2021 ចាប់ពីថ្ងៃទី01 ខែមករា ឆ្នាំ2022 ដល់ ថ្ងៃទី31 ខែមីនា ឆ្នាំ2022 | ✓ | | | |
| 2 | ផ្សព្វផ្សាយស្ដីពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ2021 ការបង់ពន្ធប៉ាតង់ឆ្នាំ 2022 និងពន្ធលើស្លាកយីហោផ្ទាំងផ្សាយពាណិជ្ជកម្មប្រចាំឆ្នាំ2022 ជូនដល់សហគ្រាសអ្នកជាប់ពន្ធតូច និងមធ្យម | ✓ | ✓ | ✓ | ✓ |
| 3 | បន្តផ្សព្វផ្សាយ និងណែនាំជូនអ្នកជាប់ពន្ធស្ដីពីការផ្ដល់ជូនសេវាកម្មអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលក្នុងនោះមាន៖ ប្រព័ន្ធបង់ប្រាក់ពន្ធ (E-payment) ប្រព័ន្ធបញ្ជូនឯកសារអេឡិចត្រូនិក (E-Document Submission System) កម្មវិធីបង់ប្រាក់ពន្ធអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទលើទូរស័ព្ទដៃ និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ |
| 4 | បន្តការចុះអង្កេតតាមដងផ្លូវ ដើម្បីជំរុញការចុះបញ្ជីពន្ធដាររបស់អាជីវកម្មដែលទើបនឹងបង្កើតថ្មី | ✓ | ✓ | ✓ | ✓ |
| 5 | បន្តចុះផ្សព្វផ្សាយ និងជំរុញម្ចាស់អចលនទ្រព្យដែលបានដាក់ជួលឱ្យចុះបញ្ជីនិងបង់ពន្ធលើឈ្នួលដី និងផ្ទះ | ✓ | ✓ | ✓ | ✓ |
| 6 | សិក្សាផលប៉ះពាល់មួយចំនួនទៅលើប្រភេទពន្ធដែលប៉ះពាល់ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ2022 | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| **11. សាខាធនាគារខេត្ត** | | | | | |
| 1 | ប្តូរប្រាក់ចាស់ ទក់រហែក ជូនអតិថិជន | ✓ | ✓ | ✓ | ✓ |
| 2 | ពង្រឹងគុណភាពសេវាបើក-បង់ជូនអតិថិជន | ✓ | ✓ | ✓ | ✓ |
| 3 | តាមដានចរាចរប្រាក់ក្លែងក្លាយ | ✓ | ✓ | ✓ | ✓ |
| 4 | ធ្វើបច្ចុប្បន្នភាពសៀវភៅក្នុងបណ្ណាល័យរបស់សាខា | ✓ | | | |
| 5 | ធ្វើបច្ចុប្បន្នភាពប្រវត្តិរូបរបស់មន្ត្រីបុគ្គលិកនៅក្នុងសាខា | ✓ | | | |
| 6 | រៀបចំប្រជុំគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិសារពើភ័ណ្ឌប្រចាំសាខា | ✓ | | | |
| 7 | ត្រួតពិនិត្យ ទ្រព្យសម្បត្តិទៅក្នុងបញ្ជីសារពើភណ្ឌរបស់សាខា | ✓ | | | |
| **12. រតនាគារ** | | | | | |
| 1 | បន្តការអនុវត្តតាមគោលការណ៍កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមដំណាក់កាលបន្តបន្ទាប់ | ✓ | ✓ | ✓ | ✓ |
| 2 | ពង្រឹងការកត់ត្រាចំណូល ចំណាយ តាមប្រព័ន្ធFMIS ឱ្យកាន់តែប្រសើរ | ✓ | ✓ | ✓ | ✓ |
| 3 | អនុវត្តតាមសារាចរណែនាំ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ 02 សប្តាហ៍ម្តងក្នុងខែនីមួយៗ | ✓ | ✓ | ✓ | ✓ |
| 4 | ពិនិត្យផ្ទៀងផ្ទាត់ និងធ្វើរបាយការណ៍ចំណូលចំណាយ និងតារាងតុល្យភាព ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា | ✓ | ✓ | ✓ | ✓ |
| 5 | បន្តការណែនាំដល់មន្ទីរ អង្គភាព ស្ថាប័នថវិកាកម្មវិធី ជាពិសេសអង្គភាពថវិកាលើការងារពាក់ព័ន្ធ និងការអនុវត្តចំណាយរដ្ឋទេយ្យបុរេប្រទាន និងចំណាត់ថ្នាក់ទាំង 7នៃមាតិកាថវិកា | ✓ | ✓ | ✓ | ✓ |
| 6 | ពង្រឹងសមត្ថភាពការងារមន្ត្រីជំនាញ លើការត្រួតពិនិត្យការអនុវត្តចំណាយថវិកាឱ្យបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ និងស្របតាមលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងពង្រឹងការតាមដានវឌ្ឍនភាពការងារជាប្រចាំ | ✓ | ✓ | ✓ | ✓ |
| 7 | បន្តដំណើរការអនុវត្តប្រព័ន្ធទូទាត់អេឡិចត្រូនិក (E-Fund Transfer) | ✓ | ✓ | ✓ | ✓ |
| 8 | រៀបចំធ្វើការអនុវត្តនូវសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីអំពីការបិទបញ្ជីចំណូលចំណាយថវិកាគណនេយ្យថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ឆ្នាំ2021 និងទិសដៅអនុវត្តនៅឆ្នាំ2022 | ✓ | ✓ | ✓ | ✓ |
| **13. មន្ទីរទេសចរណ៍** | | | | | |
| 1 | ផ្សព្វផ្សាយអំពីសក្តានុពល និងគោលដៅទេសចរណ៍ទាក់ទាញ សំខាន់ៗក្នុងខេត្តតាមរយៈសៀវភៅផ្នត់ ហ្វេសប៊ុករបស់មន្ទីរផ្ទាល់ (មន្ទីរទេសចរណ៍ខេត្តកោះកុង និងមន្ទីរទេសចរណ៍ខេត្តកោះកុង DoT KK និងគេហទំព័រ (www.kohkongtourism.gov.kh (www.visitcambodia.travel) និង (kohkong.gov.kh) | ✓ | ✓ | ✓ | ✓ |
| 2 | ផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណ៍ សារាចរ គោលការណ៍ សេចក្តីជូនដំណឹង សេចក្តីណែនាំរបស់ក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្តដល់ភ្ញៀវទេសចរ និងអាជីវករក្នុងវិស័យទេសចរណ៍ | ✓ | ✓ | ✓ | ✓ |
| 3 | ជំរុញឱ្យអាជីវករ មកធ្វើ និងបន្តអាជ្ញាប័ណ្ណទេសចរណ៍ ឱ្យបានទាន់ពេលវេលា នៅអង្គភាព | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| | ច្រកចេញចូលតែមួយរដ្ឋបាលខេត្ត ការិយាល័យ និងយន្តការច្រកចេញចូលតែមួយតាមបណ្តាស្រុក | | | | |
| 4 | បន្តផ្សព្វផ្សាយ និងចុះត្រួតពិនិត្យការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍របស់អាជីវកម្ម សេវាកម្មទេសចរណ៍ក្នុងខេត្ត ដើម្បីធានាឱ្យបាននូវសុវត្ថិភាព និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-19 សម្រាប់ភ្ញៀវទេសចរជាតិ អន្តរជាតិ | ✓ | ✓ | ✓ | ✓ |
| 5 | ផលិតសៀវភៅផ្នត់ សៀវភៅមគ្គុទ្ទេសក៏ និងផ្ទាំងប៉ាណូសំរាប់ផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ក្នុងខេត្ត | ✓ | ✓ | ✓ | ✓ |
| 6 | បន្តកិច្ចសហការជាមួយមន្ទីរអង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ | ✓ | ✓ | ✓ | ✓ |
| 7 | ចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធក្នុងការពង្រឹងសន្តិសុខ សុវត្ថិភាពជូនភ្ញៀវទេសចរ | ✓ | ✓ | ✓ | ✓ |
| 8 | បន្តចុះពង្រឹងសេវាកម្មទេសចរណ៍តាមក្រុង ស្រុក ទូទាំងខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 9 | ចូលរួមផ្សព្វផ្សាយប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមមូលដ្ឋានអាជីវកម្មទេសចរណ៍ទូទាំងខេត្ត | ✓ | ✓ | ✓ | ✓ |
| 10 | ចុះធ្វើបច្ចុប្បន្នភាពអាជីវកម្ម សេវាកម្មទេសចរណ៍ទូទាំងខេត្ត | ✓ | ✓ | ✓ | ✓ |
| 11 | បន្តចុះស្រាវជ្រាវនូវប្រវត្តិរមណីយដ្ឋាននានានៅក្នុងភូមិសាស្ត្រខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| **14. មន្ទីរផែនការ** | | | | | |
| 1 | បញ្ចូលគម្រោងកិច្ចសន្យាបណ្តោះអាសន្ន ឆ្នាំ2021 ទៅក្នុងកម្មវិធី SPD Program (ប្រព័ន្ធទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ) | ✓ | | | |
| 2 | បន្តប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ឆ្នាំ2021 | ✓ | | | |
| 3 | បញ្ចូលទិន្នន័យមូលដ្ឋានទៅក្នុងកម្មវិធីប្រព័ន្ធគ្រប់គ្រងទិន្នន័យឃុំ-សង្កាត់ CDB8 (Commune Database8) 2021 | | ✓ | ✓ | |
| 4 | ផលិតឯកសាព័ត៌មានស្ថានភាព និងឯកសារពិន្ទុវិស័យឃុំ-សង្កាត់ ក្រុង-ស្រុក ខេត្ត ឆ្នាំ2021 | | | ✓ | ✓ |
| 5 | បញ្ចូលគម្រោងអាទិភាពតាមបណ្តាឃុំសង្កាត់ និងរបាយការណ៍លទ្ធផល ទៅក្នុងកម្មវិធី SPD Program (ប្រព័ន្ធទិន្នន័យគម្រោង ថ្នាក់ក្រោមជាតិ) | | | ✓ | ✓ |
| 6 | រៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់ ថ្នាក់ក្រុង ស្រុក | | | | ✓ |
| 7 | ប្រមូលទិន្នន័យពីបណ្តាមន្ទីរ អង្គភាពជុំវិញខេត្ត សម្រាប់ចងក្រងផលិតផលសរុបក្នុងស្រុកខេត្តកោះកុង (GDP) | | | | ✓ |
| 8 | ប្រមូលទិន្នន័យតាមផ្សារ ដើម្បីចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ប្រចាំខែ (CPI) | ✓ | ✓ | ✓ | ✓ |
| 9 | រៀបចំ និងផលិតទិន្នន័យគម្រោងអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិសម្រាប់កសាងផែនការថ្នាក់ក្រោមជាតិ | | | | ✓ |
| 10 | បន្តធ្វើបច្ចុប្បន្នភាពគ្រួសារក្រីក្រ ដើម្បីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមការស្នើសុំ និងជនងាយរងគ្រោះ ដោយប្រើប្រាស់ឧបករណ៍តាប្លេត (Tablet) App OD ID-Poor | ✓ | ✓ | ✓ | ✓ |
| 11 | ចូលរួមសហការក្នុងការធ្វើជំរឿន និងអង្កេតផ្សេងៗ របស់វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| **15. មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍** | | | | | |
| 1 | បន្តសហការជាមួយ អាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ មន្ទីរអង្គភាពនានាជុំវិញខេត្ត និងបណ្តាក្រុមហ៊ុនបម្រើសេវាទូរគមនាគមន៍ ប្រតិបត្តិករប្រៃសណីយ៍កម្ពុជា និងទូរគមនាគមន៍កម្ពុជា ដើម្បីអនុវត្តការងារឱ្យបានល្អ | ✓ | ✓ | ✓ | ✓ |
| 2 | ចុះពិនិត្យ ពង្រឹងការគ្រប់គ្រងគោលនយោបាយលើការប្រើប្រាស់ និងការធ្វើសេវាលើវិស័យប្រៃសណីយ៍ វិស័យទូរគមនាគមន៍ វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានគ្រប់ប្រភេទក្នុងខេត្ត | ✓ | ✓ | ✓ | ✓ |
| 3 | ចុះត្រួតពិនិត្យលើការប្រើប្រាស់ និងការធ្វើសេវាលើវិស័យប្រៃសណីយ៍ វិស័យទូរគមនាគមន៍ វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានគ្រប់ប្រភេទនៅតាមបណ្តាស្រុកក្នុងខេត្ត | ✓ | ✓ | ✓ | ✓ |
| 4 | បន្តផ្សព្វផ្សាយគោលនយោបាយច្បាប់ ប្រកាសរួមរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវលិខិតលេខ 498 សហវ.ប្រក ចុះថ្ងៃទី08 ខែឧសភា ឆ្នាំ2018 ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដល់អាជីវករពាក់ព័ន្ធការបើកធ្វើសេវាអាជីវកម្មលើវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគម - នាគមន៍ និងព័ត៌មាននៅក្នុងខេត្ត | ✓ | ✓ | ✓ | ✓ |
| 5 | ចុះផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ 291 បទ.ខកក ដល់ប្រតិបត្តិករក្រុមហ៊ុនទូរស័ព្ទចល័តសាខាលក់ និងអ្នកចែកចាយបន្តនូវស៊ីមកាតគ្រប់ប្រព័ន្ធជូនអតិថិជនក្នុងខេត្តកោះកុង ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ ខ្ជាប់ខ្ជួន ក្នុងនោះត្រូវបំពេញបែបបទ និងមានឯកសារភ្ជាប់ជាមួយឱ្យបានត្រឹមត្រូវ | ✓ | ✓ | ✓ | ✓ |
| **16. មន្ទីរមុខងារសាធារណៈ** | | | | | |
| 1 | ត្រួតពិនិត្យសំណុំឯកសារបៀវត្សរបស់មន្ទីរ និងអង្គភាពជុំវិញខេត្ត | ✓ | ✓ | ✓ | ✓ |
| 2 | ត្រួតពិនិត្យលើឯកសារប្រែប្រួលស្ថានភាពមន្ត្រីរាជការរបស់មន្ទីរ និងអង្គភាពនានាជុំវិញខេត្ត និងយករបាយការណ៍ប្រែប្រួលឡើងទៅក្រសួងមុខងារសាធារណៈ | ✓ | ✓ | ✓ | ✓ |
| 3 | បន្តផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជូនដល់មន្ទីរ អង្គភាពនានា | ✓ | ✓ | ✓ | ✓ |
| 4 | រៀបចំតារាងតាមដានឥណទានបៀវត្សប្រចាំខែរបស់មន្ទីរ អង្គភាពទាំង25 និងក្រុង ស្រុកទាំង 7 ជូនរតនាគារខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 5 | រៀបចំរបាយការណ៍វឌ្ឍនភាពក្របខ័ណ្ឌ និងឥណទានបៀវត្សជូនក្រសួងមុខងារសាធារណៈ និងរដ្ឋបាលខេត្ត | ✓ | ✓ | ✓ | ✓ |
| 6 | បន្តតាមដានត្រួតពិនិត្យការបំពេញការងាររបស់មន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់ពីរវេន និងគួប នៅតាមបណ្តាមន្ទីរ អង្គភាព និងក្រុង ស្រុក | ✓ | ✓ | ✓ | ✓ |
| **17. មន្ទីរអប់រំ យុវជន និងកីឡា** | | | | | |
| 1 | រៀបចំបើកបវេសនកាលសម្រាប់ឆ្នាំសិក្សា2021-2022 | ✓ | | | |
| 2 | រៀបចំយុទ្ធនាការប្រមូលសិស្សចូលរៀន នៅទូទាំងខេត្ត | ✓ | | | |
| 3 | ចុះពិនិត្យតាមដានគ្រូចេញថ្មី ការងារគ្រប់គ្រងបុគ្គលិក ការប្រើប្រាស់គ្រូជាប់កិច្ចសន្យា ការបង្រៀនពីរពេល ថ្នាក់គួប និងបើកវគ្គបំប៉ន | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| 4 | ចុះពិនិត្យតាមដាន វាយតម្លៃ និងគាំទ្រលើការងារបច្ចេកទេសរៀន និងបង្រៀនដើម្បីជួយនាយក និងគ្រូនៅតាមគ្រឹះស្ថានសិក្សា និងការងារអប់រំក្រៅប្រព័ន្ធ | ✓ | ✓ | ✓ | ✓ |
| 5 | ចុះអធិការកិច្ចតាមកាលកំណត់នៅតាមគ្រឹះស្ថានសិក្សា | | ✓ | ✓ | |
| 6 | ចុះពិនិត្យ និងរៀបចំការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ទុតិយភូមិ និងការប្រឡងផ្សេងៗ | | ✓ | ✓ | ✓ |
| 7 | បើកវគ្គសិក្ខាសាលាបំប៉ន និងវគ្គបណ្តុះបណ្តាល ជូនមន្ត្រីគ្រប់គ្រង មន្ត្រីជំនាញ នាយក និងលោកគ្រូ អ្នកគ្រូ នៅតាមគ្រឹះស្ថានសិក្សា និងតាមប្រព័ន្ធអនឡាញ | | ✓ | ✓ | ✓ |
| 8 | រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ (AOP) របាយការណ៍សមិទ្ធកម្ម និងរបាយការណ៍ពិសេស | ✓ | | | ✓ |
| 9 | ហ្វឹកហាត់ក្រុមកីឡាករ និងចូលរួមការប្រកួតកីឡាផ្សេងនៅក្នុងខេត្ត និងតាមបណ្តារាជធានី ខេត្ត | ✓ | ✓ | ✓ | ✓ |
| 10 | ប្រជុំផ្លាស់ប្តូរទីកន្លែងបម្រើការងារបុគ្គលិក និងពង្រាយបុគ្គលិកតាមការស្ម័គ្រចិត្តពីកន្លែងលើសទៅកន្លែងខ្វះ ក្នុង និងក្រៅខេត្ត | | | ✓ | ✓ |
| 11 | រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ បញ្ជីជាតិដីធ្លី និងធ្វើតារាងប្រៀបធៀបបញ្ជីសម្ភារកើនឡើង ថយចុះប្រចាំឆ្នាំ និងធ្វើការជម្រះបញ្ជីសារពើភណ្ឌ | ✓ | ✓ | ✓ | ✓ |
| **18. មន្ទីរសុខាភិបាល** | | | | | |
| 1 | បន្តផ្សព្វផ្សាយអប់រំ ស្រាវជ្រាវ និងព្យាបាល ដើម្បីបង្ការ ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-19 | ✓ | ✓ | ✓ | ✓ |
| 2 | បន្តការចាក់វ៉ាក់សាំងកូវីដ-19 ជូនប្រជាជន | ✓ | ✓ | ✓ | ✓ |
| 3 | ចាត់ក្រុមការងារចត្តាឡីស័កប្រចាំការច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម ដើម្បីពិនិត្យកម្តៅ ធ្វើតេស្តរហ័ស លើគ្រប់អ្នកដំណើរ និងអ្នកបើកបររថយន្តចេញ-ចូលច្រកព្រំដែន ជារៀងរាល់ថ្ងៃ ព្រមទាំងបាញ់ថ្នាំសម្លាប់មេរោគទៅលើរថយន្តដឹកទំនិញចេញ-ចូលគ្រប់ប្រភេទ | ✓ | ✓ | ✓ | ✓ |
| 4 | បន្តអនុវត្តវិធានការចត្តាឡីស័កចំពោះពលករ និងអ្នកធ្វើដំណើរមកពីបរទេស នៅមណ្ឌលចត្តាឡីស័កកម្រិត2 ដោយមានការសហការជាមួយអាជ្ញាធរក្រុង ស្រុក ខេត្ត កម្លាំងសមត្ថកិច្ច និងមន្ត្រីមណ្ឌលចត្តាឡីស័កខេត្ត | ✓ | ✓ | ✓ | ✓ |
| 5 | ផ្សព្វផ្សាយដល់ស្ត្រីដែលមានផ្ទៃពោះឱ្យមកពិនិត្យផ្ទៃពោះ និងសម្រាលកូនជាមួយឆ្មបជំនាញ | ✓ | ✓ | ✓ | ✓ |
| 6 | បន្តផ្សព្វផ្សាយអំពីវិធីបង្ការជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម | ✓ | ✓ | ✓ | ✓ |
| 7 | ចុះអង្កេតត្រួតពិនិត្យជំងឺឆ្លង និងជំងឺគ្រុនឈាមនៅពេលមានករណីកើតឡើង | ✓ | ✓ | ✓ | ✓ |
| 8 | បន្តការផ្តល់សេវាព្យាបាល និងបង្ការតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាពជូនប្រជាជន | ✓ | ✓ | ✓ | ✓ |
| 9 | បន្ត និងពង្រឹងការគ្រប់គ្រងសេវាសុខាភិបាលឯកជន និងឱសថស្ថានឱ្យបានល្អស្របតាមនីតិវិធី | ✓ | ✓ | ✓ | ✓ |
| **19. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | | | | | |
| 1 | បន្តកិច្ចសហការជាមួយឃុំ-សង្កាត់ ក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-19 | ✓ | ✓ | ✓ | ✓ |
| 2 | បន្តពង្រឹងកិច្ចសហការជាមួយឃុំ-សង្កាត់ និងមូលដ្ឋានសុខាភិបាលក្នុងខេត្តកោះកុងដើម្បីដោះស្រាយបញ្ហា និងការប្រឈមនានាលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម 2ឆ្នាំ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-19 | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| 3 | បន្តពង្រឹងសមត្ថភាព និងគាំទ្រដល់មន្ត្រីទទួលបន្ទុកតាមឃុំ-សង្កាត់លើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម 2ឆ្នាំ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-19 | ✓ | ✓ | ✓ | ✓ |
| 4 | បន្តពង្រឹងកិច្ចសហការជាមួយអភិបាលក្រុង ស្រុក ពីបញ្ហាជនអនាថា និងបញ្ជ្រាបអំពីតួនាទីភារកិច្ចដល់អនុគណៈកម្មការជនអនាថា | ✓ | ✓ | ✓ | ✓ |
| 5 | បន្តចុះតាមដាន និងកែសម្រួលនូវរចនាសម្ព័ន្ធសមាគមមនុស្សចាស់តាមភូមិ ឃុំ | ✓ | ✓ | ✓ | ✓ |
| 6 | បន្តចុះសួរសុខទុក្ខចាស់ជរាគ្មានទីពឹង និងចាស់ជរារស់នៅក្នុងគ្រួសារក្រីក្រ | ✓ | ✓ | ✓ | ✓ |
| 7 | បន្តចុះសហការ និងផ្តល់បច្ចេកទេសជូនប្រធានសមាគមមនុស្សចាស់តាមភូមិ ឃុំ | ✓ | ✓ | ✓ | ✓ |
| 8 | បន្តជំរុញដល់សមាគមមនុស្សចាស់ដែលបានបង្កើតរួច ដើម្បីឱ្យដំណើរការជាផ្លូវការ | ✓ | ✓ | ✓ | ✓ |
| 9 | បន្តជំរុញអាជ្ញាធរស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល ក្នុងការចុះសម្ភាសជនមានពិការភាពតាមគំរូសង្គមតាមរយៈប្រព័ន្ធអែប (App) ដើម្បីកំណត់អត្តសញ្ញាណកម្មជនមានពិការភាព | ✓ | ✓ | ✓ | ✓ |
| 10 | បន្តចុះបើកហិបមូលនិធិជនពិការនៅតាមវត្តអារាម ភោជនីយដ្ឋាន ផ្ទះសំណាក់ រមណីយដ្ឋាននានាទូទាំងខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 11 | ពង្រឹង និងបង្កើនប្រសិទ្ធភាពផ្នែកសោធន តាមរយៈការបើកផ្តល់របបសន្តិសុខសង្គមជូននិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងអ្នកនៅក្នុងបន្ទុក និងបង្កើតយន្តការសិក្សាស្រាវជ្រាវបន្ថែមដើម្បីកាត់បន្ថយគម្លាតនៃរបបសោធនរបស់មន្ត្រីសាធារណៈ | ✓ | ✓ | ✓ | ✓ |
| 12 | បង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារឱ្យបានទាន់ពេលវេលា | ✓ | ✓ | ✓ | ✓ |
| 13 | បន្តនិរន្តភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនមានពិការភាព | ✓ | ✓ | ✓ | ✓ |
| 14 | បន្តសហការជាមួយសមាគមអតីតយុទ្ធជន ដើម្បីបើកផ្តល់ប្រាក់បេឡាមរណៈសង្គ្រោះជូនដល់គ្រួសារសពអតីតយុទ្ធជនដែលទទួលមរណភាព ឱ្យបានទាន់ពេលវេលា | ✓ | ✓ | ✓ | ✓ |
| **20. មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | | | |
| 1 | បន្តជំរុញនាយក សហគ្រាស គ្រឹះស្ថាន ដែលប្រើកម្មករ និយោជិតខ្មែរ និងបរទេសមុនចូលបម្រើការងារ និងកំពុងបម្រើការងារឱ្យមកធ្វើសៀវភៅ និងប័ណ្ណការងារដើម្បីប្រមូលអាករបង់ចូលថវិការដ្ឋ | ✓ | ✓ | ✓ | ✓ |
| 2 | បន្តពង្រឹងការអនុវត្តលក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង | ✓ | ✓ | ✓ | ✓ |
| 3 | បន្តពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករ និយោជិត និងនិយោជក | ✓ | ✓ | ✓ | ✓ |
| 4 | បន្តពង្រឹងយន្តការដោះស្រាយវិវាទការងាររួម និងវិវាទបុគ្គល | ✓ | ✓ | ✓ | ✓ |
| 5 | បន្តពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារតាមបណ្តាសហគ្រាស គ្រឹះស្ថានក្នុងខេត្ត | ✓ | ✓ | ✓ | ✓ |
| 6 | បន្តការបង្កើនប្រសិទ្ធភាព និងគុណភាពសេវារដ្ឋបាលសាធារណៈ | ✓ | ✓ | ✓ | ✓ |
| 7 | បន្តពង្រឹង និងជំរុញសហគ្រាស គ្រឹះស្ថាន ឱ្យមានការធ្វើតេស្តរហ័សរកមេរោគកូវីដ-19 ដល់កម្មករនិយោជិតដែលមានអាការៈសង្ស័យ | ✓ | ✓ | ✓ | ✓ |
| **21. មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ** | | | | | |
| 1 | បន្តតាំងពិព័រណ៍បង្ហាញវត្ថុសិល្បៈដែលស្រង់ពីសំពៅលិច និងវត្ថុដែលមាននៅតាមជ្ជួរភ្នំក្រវាញ ក្នុងសារមន្ទីរ | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| 2 | បន្តផ្សព្វផ្សាយពីជំនាញ តម្បាញ និងទម្រង់ក្បាច់ចម្លាក់បុរាណខ្មែរ ដល់ជាងចម្លាក់ និងមហាជន | ✓ | | ✓ | |
| 3 | ជំរុញការគ្រប់គ្រង ថែរក្សា និងការពាររមណីយដ្ឋានប្រវត្តិសាស្ត្រវត្ថុបុរាណឱ្យបានល្អ | ✓ | ✓ | ✓ | ✓ |
| 4 | បន្តចុះពិនិត្យមឈូសបុរាណ ពាង និងវត្ថុសិល្បៈដែលនៅតាមជួរភ្នំក្រវាញ | ✓ | ✓ | ✓ | ✓ |
| 5 | បន្តចុះស្រង់ទិន្នន័យបឋមនៃមរតកវប្បធម៌អរូបីនៅក្នុងក្រុងខេមរភូមិន្ទ | | | | ✓ |
| 6 | បន្តចុះរុករកស្រាវជ្រាវស្ថានីយថ្មីៗបន្ថែមទៀត នៅស្រុកថ្មបាំង ខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 7 | ផ្សព្វផ្សាយច្បាប់ស្តីពីបេតិកភណ្ឌវប្បធម៌ នៅស្រុកថ្មបាំង ស្រុកស្រែអំបិល និងស្រុកកោះកុង | | ✓ | | ✓ |
| 8 | បន្តចុះតាមដានត្រួតពិនិត្យរាល់ផ្ទាំងសន្សនីយភាពផ្សេងៗដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ជាតិ និងសង្គមជាតិ | ✓ | ✓ | ✓ | ✓ |
| 9 | ពង្រឹងការសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យ សកម្មភាពការធ្វើអាជីវកម្មជួល លក់ CD និង VCD ដែលគ្មានច្បាប់អនុញ្ញាត | | ✓ | | ✓ |
| 10 | បន្តសិក្សាស្រាវជ្រាវ អ្នកមានចំណេះជំនាញទាក់ទងនឹងវិស័យវប្បធម៌ | ✓ | ✓ | ✓ | ✓ |
| 11 | បន្តចុះត្រួតពិនិត្យរាល់ការលើកស្លាកសញ្ញា និងផ្ទាំងផ្សាយពាណិជ្ជកម្មឱ្យបានល្អជាងមុន | ✓ | ✓ | ✓ | ✓ |
| 12 | បន្តចុះត្រួតពិនិត្យ និងណែនាំដល់អាជីវករ សេវាកម្មវិស័យវប្បធម៌ ក្នុងខេត្តកោះកុងឱ្យមកធ្វើច្បាប់ ឬបន្តសុពលភាពច្បាប់អនុញ្ញាតនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត និងការិយាល័យ-យន្តការច្រកចេញចូលតែមួយក្រុង ស្រុក | ✓ | ✓ | ✓ | ✓ |
| 13 | សហការជាមួយរដ្ឋបាលខេត្តកោះកុងរៀបចំពិធីបុណ្យជាតិផ្សេងៗ | ✓ | ✓ | ✓ | ✓ |
| 14 | ត្រៀមរៀបចំ និងប្រារព្ធទិវាវប្បធម៌ជាតិ 3មីនា ថ្នាក់ខេត្ត | ✓ | | | |
| 15 | ចូលរួមមហោស្រពបង្ហើរខ្លែងខ្មែរ | | | | ✓ |
| 16 | បន្តបណ្តុះបណ្តាលរបាំចាស់ៗ ភ្លេងប្រពៃណី និងភ្លេងពិណពាទ្យ ឆៃយ៉ាំ ដល់ក្រុមយុវជន និងតាមវត្ត | | | ✓ | ✓ |
| 17 | ពង្រឹងសមត្ថភាពជំនាញ និងជំរុញស្នាដៃសិល្បៈមហាជន និងសិល្បៈអាជីព ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជនក្នុងខេត្ត | | | ✓ | ✓ |
| 18 | បន្តចេញប័ណ្ណ និងលិខិតអនុញ្ញាតជូនអាជីវករក្នុងវិស័យវប្បធម៌ | ✓ | ✓ | ✓ | ✓ |
| **22. មន្ទីរកិច្ចការនារី** | | | | | |
| 1 | រៀបចំមីទិញអបអរសាទរខួបលើកទី111 ទិវាអន្តរជាតិនារី 8 មីនា ឆ្នាំ2022 | ✓ | | | |
| 2 | រៀបចំកិច្ចប្រជុំជាមួយបណ្តាញយេនឌ័រ តាមមន្ទីរវិស័យ | ✓ | | ✓ | |
| 3 | រៀបចំបច្ចុប្បន្នភាពមន្ត្រីរាជការជានារី ថ្នាក់ខេត្ត ក្រុង ស្រុក | ✓ | | | |
| 4 | ចុះផ្សព្វផ្សាយពីការបង្ការទប់ស្កាត់ ការរីករាលដាលនៃជំងឺកូវីដ-19 និងមេរោគបំប្លែងថ្មីផ្សេងៗ ដល់ប្រជាពលរដ្ឋ | ✓ | | | |
| 5 | រៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពដល់ គ.ក.ន.ក ឃុំ សង្កាត់ | | | ✓ | |
| 6 | ចុះផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋតាមភូមិ នៅក្នុងស្រុក/ក្រុង ទាំង7 | ✓ | ✓ | ✓ | |
| 7 | ចុះផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដល់សិស្សានុសិស្ស | | ✓ | | |
| 8 | បើកវគ្គបណ្តុះបណ្តាលជំនាញកាត់ដេរ និងសម្អាងកាយ ដល់ស្ត្រី និងក្មេងស្រីក្រីក្រ | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| **23. មន្ទីរព័ត៌មាន** | | | | | |
| 1 | ជំរុញការផ្សព្វផ្សាយផ្នែកឯកជននានាឱ្យគោរពច្បាប់ និងបទដ្ឋានបច្ចេកទេស | ✓ | ✓ | ✓ | ✓ |
| 2 | បន្តចុះផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការស្នើសុំបើក និងបន្តសុពលភាពការធ្វើអាជីវកម្មសោតទស្សន៍ ការផ្សព្វផ្សាយប៉ាណូ អាហ្វីស ។ល។ ជូនសាធារណជនឱ្យបានជ្រាប និងអនុវត្តទៅតាមច្បាប់នៅក្នុងក្រុងខេមរភូមិន្ទ | ✓ | ✓ | ✓ | ✓ |
| 3 | ផ្សព្វផ្សាយសេចក្តីជូនដំណឹងដល់ម្ចាស់អាជីវកម្មលើសេវាសោតទស្សន៍បន្តទៀត ដើម្បីជាការជំរុញបន្ថែមលើការមកដាក់ពាក្យស្នើសុំបើក និងបន្តសុពលភាពអាជីវកម្ម និងបង់សេវាប្រចាំឆ្នាំ ឱ្យបានទាន់ពេលវេលា នៅអង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត | ✓ | ✓ | ✓ | ✓ |
| 4 | បន្តទទួលការទំនាក់ទំនងតាមទូរស័ព្ទ ដើម្បីជំរុញអតិថិជនឱ្យមកទទួលសេវានៅអង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត | ✓ | ✓ | ✓ | ✓ |
| 5 | ជំរុញចុះយកព័ត៌មានឱ្យដល់មូលដ្ឋាន | ✓ | ✓ | ✓ | ✓ |
| 6 | បង្កើនការទំនាក់ទំនងតាមបណ្តាក្រុង ស្រុក ដើម្បីទទួលបានព័ត៌មាន | ✓ | ✓ | ✓ | ✓ |
| 7 | បង្កើនការទំនាក់ទំនងជាមួយភ្នាក់ងារទូរទស្សន៍ឯកជននានាឱ្យបានល្អ | ✓ | ✓ | ✓ | ✓ |
| 8 | ស្រាវជ្រាវលើបច្ចេកវិទ្យា និងកម្មវិធីថ្មីៗស្របតាមកាលៈទេសៈសង្គម | ✓ | ✓ | ✓ | ✓ |
| 9 | បង្កើនការផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ ទូរទស្សន៍បាយ័ន និងទូរទស្សន៍ផ្សេងៗទៀត | ✓ | ✓ | ✓ | ✓ |
| 10 | បង្កើនការផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម ឱ្យកាន់តែទូលំទូលាយជាងមុន | ✓ | ✓ | ✓ | ✓ |
| 11 | បង្កើនការយកចិត្តទុកដាក់កែលម្អកម្មវិធីផ្សាយរបស់វិទ្យុផ្សាយសំឡេង | ✓ | ✓ | ✓ | ✓ |
| 12 | បន្តផ្សព្វផ្សាយព័ត៌មាន ស្ប៉តអប់រំផ្សេងៗ ពិសេសស្ប៉តស្តីពីជំងឺកូវីដ-19 | ✓ | ✓ | ✓ | ✓ |
| 13 | បន្តផ្សព្វផ្សាយរាល់សកម្មភាពរបស់ថ្នាក់ដឹកនាំជាតិ និងខេត្តឱ្យកាន់តែទូលំទូលាយ | ✓ | ✓ | ✓ | ✓ |
| **24. មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** | | | | | |
| 1 | បន្តសហការជាមួយមន្ទីរជំនាញចុះតាមដានការអនុវត្តច្បាប់ របស់រាជរដ្ឋាភិបាលនៅតាមក្រុង ស្រុក ទូទាំងខេត្តកោះកុង | ✓ | ✓ | ✓ | ✓ |
| 2 | បន្តសម្របសម្រួល ទំនាក់ទំនងរាល់ការងាររវាងអាជ្ញាធរខេត្ត និងសមាជិករដ្ឋសភា-ព្រឹទ្ធសភាក្នុងមណ្ឌលខេត្តរបស់ខ្លួន | ✓ | ✓ | ✓ | ✓ |
| 3 | សិក្សាស្រាវជ្រាវ និងស្វែងយល់នូវអនុក្រឹត្យ ព្រះរាជក្រឹត្យ ព្រមទាំងច្បាប់នានាដើម្បីត្រៀមលក្ខណៈសហការជាមួយប្រតិភូក្រសួងចុះផ្សព្វផ្សាយជូនសាធារណជនក្នុងខេត្តឱ្យបានយល់ដឹង | ✓ | ✓ | ✓ | ✓ |
| 4 | បន្តតាមដានការអនុវត្តច្បាប់ កម្មវិធីនយោបាយ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ អនុសាសន៍ សេចក្តីជូនដំណឹង និងបទប្បញ្ញត្តិផ្សេងៗរបស់រាជរដ្ឋាភិបាល | ✓ | ✓ | ✓ | ✓ |
| 5 | ចុះក្តាប់សភាពការណ៍លើគ្រប់វិស័យក្នុងការអនុវត្តច្បាប់ កម្មវិធីនយោបាយ និងសារព័ត៌មានដែលបានផ្សព្វផ្សាយពាក់ព័ន្ធទៅនឹងសកម្មភាព ធ្វើអធិការកិច្ច ដើម្បីសុំគោលការណ៍ថ្នាក់លើមានវិធានការ | ✓ | ✓ | ✓ | ✓ |
| 6 | ទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងមជ្ឈដ្ឋាននានាដើម្បីចាត់បញ្ជូនទៅសមត្ថកិច្ចដោះស្រាយ និងចុះសង្កេតស្រាវជ្រាវបណ្តឹង ឬ បាតុភាពផ្សេងៗ និងលទ្ធផលរបស់អធិការកិច្ចនានាដែលពុំទាន់ត្រឹមត្រូវតាមការយល់ព្រមពីក្រសួង | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| 7 | ចុះធ្វើអធិការកិច្ចលើគ្រប់វិស័យតាមការណែនាំរបស់ក្រសួង សំដៅប្រឆាំងនឹងការរំលោភដោយអំណាច បាតុភាពអសកម្មនានា ការក្លែងបន្លំកិបកេងទ្រព្យសម្បត្តិរដ្ឋ និងការងារដឹកនាំគ្រប់គ្រងចំណូល ចំណាយថវិកាជាតិ និងការប្រើប្រាស់ជំនួយជាតិ ត្រួតពិនិត្យបញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិរដ្ឋ ជាប្រចាំទូទាំងខេត្ត | ✓ | ✓ | ✓ | ✓ |
| 8 | លើកសំណើសុំឱ្យក្រសួង ខេត្ត ចេញសេចក្តីសម្រេចផ្អាកជាបណ្តោះអាសន្នចំពោះមន្ត្រីរាជការណាមិនព្រមសហការ ឬ ការអនុវត្តទាំងឡាយណាដែលបានពិនិត្យឃើញថាបង្កនូវមហន្តរាយប៉ះពាល់ធ្ងន់ធ្ងរដល់សាធារណជន និងទ្រព្យសម្បត្តិស្របច្បាប់របស់ប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ |
| **25. មន្ទីរធម្មការ និងសាសនា** | | | | | |
| 1 | ត្រៀមចូលរួមសហការរៀបចំពិធីបុណ្យចូលព្រះវស្សា | | | ✓ | |
| 2 | ត្រៀមចូលរួមសហការរៀបចំពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ | | | ✓ | |
| 3 | ត្រៀមចូលរួមសហការរៀបចំប្រារព្ធពិធីបុណ្យគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ" | | | | ✓ |
| 4 | ត្រៀមសហការរៀបចំពិធីបុណ្យចេញព្រះវស្សា | | | | ✓ |
| 5 | ត្រៀមសហការរៀបចំពិធីបុណ្យកឋិនទាន | | | | ✓ |
| 6 | ត្រៀមសហការជាមួយសាលាគណទាំងពីរគណៈ ដើម្បីរៀបចំអបអរសាទរពិធីគ្រងរាជព្រះបរមរាជសម្បត្តិ ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា | | | | ✓ |
| 7 | ត្រៀមសហការដើម្បីអបអរសាទរពិធីបុណ្យឯករាជ្យជាតិ | | | | ✓ |
| 8 | ត្រៀមកិច្ចសហការ ដើម្បីរៀបចំអបអរសាទរពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ | | | | ✓ |
| 9 | ត្រៀមកិច្ចសហការក្នុងការរៀបចំពិធីបុណ្យព្រះពុទ្ធសាសនា បុណ្យជាតិ និងបុណ្យអន្តរជាតិចាំបាច់មួយចំនួនទៀត | ✓ | ✓ | ✓ | ✓ |
| 10 | ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ អង្គការ សមាគមដែលពាក់ព័ន្ធជាមួយ (ពាហិរសាសនា) វិស័យធម្មការ និងសាសនាខេត្តឱ្យមានភាពរឹងមាំដើម្បីសុខដុមនីយកម្មសាសនា | ✓ | ✓ | ✓ | ✓ |
| 11 | បញ្ជ្រាបបញ្ហាគ្រឿងញៀនតាមរយៈការទេសនារបស់ព្រះសង្ឃតាមកម្មវិធីបុណ្យ និងកម្មវិធីចាំបាច់ចំនួនទៀតដល់ប្រជាពលរដ្ឋខ្មែរ | ✓ | ✓ | ✓ | ✓ |
| 12 | ទំនាក់ទំនងជាមួយគណៈសង្ឃគ្រប់ឋានានុក្រម អាចារ្យ គណៈកម្មការគ្រប់វត្តអារាមទូទាំងខេត្ត | ✓ | ✓ | ✓ | ✓ |
| **26. សាលាដំបូង** | | | | | |
| 1 | ខិតខំយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរ ដែលនៅសល់ឱ្យបានសម្រេចពី 70% ទៅ 100% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច | ✓ | ✓ | ✓ | ✓ |
| 2 | ខិតខំយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះដែលនៅសល់ ឱ្យបានសម្រេចពី 70% ទៅ 100% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច | ✓ | ✓ | ✓ | ✓ |
| 3 | ខិតខំយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងរដ្ឋប្បវេណីជំនុំជម្រះដែលនៅសល់ឱ្យបានសម្រេចពី 70% ទៅ 100% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| **27. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី** | | | | | |
| 1 | បន្តអនុវត្តការងារចុះបញ្ជីដីជាប្រព័ន្ធ និងដាច់ដោយដុំ | ✓ | ✓ | ✓ | ✓ |
| 2 | ពង្រឹង និងយកចិត្តទុកដាក់ការងារគ្រប់គ្រងសំណង់ | ✓ | ✓ | ✓ | ✓ |
| 3 | ពង្រឹងការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ | ✓ | ✓ | ✓ | ✓ |
| 4 | បន្តអនុវត្តការងារកាត់ឆ្វៀលដីតាមអនុក្រឹត្យលេខ 30អនក្រ.បក ចុះថ្ងៃទី02 ខែមីនា ឆ្នាំ2021 និងអនុក្រឹត្យលេខ 46អនក្រ.បក ចុះថ្ងៃទី24 ខែមីនា ឆ្នាំ2021 | ✓ | ✓ | ✓ | ✓ |
| 5 | បន្តចែកវិញ្ញាបនបត្រសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋ | ✓ | ✓ | ✓ | ✓ |
| **28. មន្ទីរបរិស្ថាន** | | | | | |
| 1 | ចុះត្រួតពិនិត្យការបំពុលបរិស្ថានលើទីតាំងអាជីវកម្ម សិប្បកម្ម សណ្ឋាគារ ផ្ទះសំណាក់ក្នុងក្រុង ស្រុក | ✓ | ✓ | ✓ | ✓ |
| 2 | សម្របសម្រួលប្រជុំផ្សព្វផ្សាយ និងការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍អាណត្តិថ្មីចំនួន 04លើក | ✓ | ✓ | | |
| 3 | តាមដានវឌ្ឍនភាពការចិញ្ចឹមសត្វ និងគ្រំចំពុះទាចំនួន 03លើក | ✓ | ✓ | ✓ | ✓ |
| 4 | សម្របសម្រួលការចុះកិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិកោះកាពិ និងកោះស្រឡៅចំនួន 02លើក | ✓ | ✓ | | |
| 5 | សម្របសម្រួលកិច្ចប្រជុំ និងរៀបចំសហគមន៍តំបន់ការពារធម្មជាតិថ្មីតាតៃក្រោម និងពាធិ៍បឹងចំនួន 04លើក | ✓ | ✓ | ✓ | ✓ |
| 6 | ជំរុញដល់គម្រោង សិប្បកម្ម អាជីវកម្មផ្សេងៗ ធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន | ✓ | ✓ | ✓ | ✓ |
| 7 | ចុះផ្សព្វផ្សាយ និងអប់រំដល់ប្រជាពលរដ្ឋកុំឱ្យទន្ទ្រានដីព្រៃ និងការពារភ្លើងឆេះព្រៃ | ✓ | ✓ | ✓ | ✓ |
| 8 | ចុះបើកវគ្គផ្សព្វផ្សាយអនុក្រឹត្យលេខ 113 អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងអនុក្រឹត្យលេខ 168អនក្រ.បក ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិកនៅក្រុងខេមរភូមិន្ទ និងស្រុកទាំង6 | ✓ | ✓ | ✓ | ✓ |
| 9 | រៀបចំប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក 5 មិថុនា និងទិវាអនាម័យបរិស្ថានជាតិ 23វិច្ឆិកា | | ✓ | | ✓ |
| **29. ការងារសាធារណការ និងកែលម្អសោភ័ណភាព** | | | | | |
| 1 | បន្តការងារថែទាំផ្លូវថ្នល់ជាប្រចាំ កំណាត់ផ្លូវជាតិ និងផ្លូវខេត្ត (ផ្លូវក្រាលកៅស៊ូ) ដែលមានប្រវែងសរុប 76.87គ.ម | ✓ | ✓ | ✓ | ✓ |
| 2 | បន្តការងារថែទាំផ្លូវថ្នល់ជាប្រចាំ លើកំណាត់ផ្លូវខេត្ត (ផ្លូវក្រាលដីល្បាយថ្ម) ដែលមានប្រវែងសរុប 78.60គ.ម | ✓ | ✓ | ✓ | ✓ |
| 3 | បន្តជួសជុលកំណាត់ផ្លូវខេត្តលេខ1485អា (61) ត្រង់គ.ម 28+600 ដល់ គ.ម 49+030 ដោយក្រាលកៅស៊ូបាចថ្មពីរជាន់ DBST ប្រវែង 2000ម ទទឹង 8ម | ✓ | ✓ | ✓ | ✓ |
| 4 | បន្តជួសជុលផ្លូវជាតិលេខ 48-5 (វិថីសាយភូថង) (61) ចន្លោះ គ.ម 01+780 ដល់ គ.ម 49+030 កាត់ជួសជុលក្រាលកៅស៊ូបាចថ្មពីរជាន់ DBST ប្រវែង 4110ម ស្មើនឹង 54.510ម | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| 5 | បន្តសហការជាមួយកងកម្លាំងសមត្ថកិច្ចនគរបាលចរាចរណ៍ផ្លូវគោកខេត្ត ស្រុក ចុះត្រួតពិនិត្យតាមយានដ្ឋាននានា និងចុះអនុវត្តតាមដងផ្លូវ ដើម្បីទប់ស្កាត់ការកែច្នៃយានយន្តខុសលក្ខណៈបច្ចេកទេស ការដឹកលើសទម្ងន់កម្រិតច្បាប់កំណត់ | ✓ | ✓ | ✓ | ✓ |
| 6 | បន្តផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកដល់ប្រជាពលរដ្ឋជាពិសេសនៅតាមតំបន់ដែលងាយរងគ្រោះថ្នាក់ចរាចរណ៍ និងចែកខិតប័ណ្ណអប់រំ សៀវភៅច្បាប់ចរាចរណ៍ និងរូបភាពពាក់ព័ន្ធនឹងសុវត្ថិភាពចរាចរណ៍ផ្លូវគោក | ✓ | ✓ | ✓ | ✓ |
| **30. គោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព** | | | | | |
| 1 | បន្តការផ្សព្វផ្សាយគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព លេខ 01 គ.ន.ប ចុះថ្ងៃទី26 ខែមករា ឆ្នាំ2021 របស់រាជរដ្ឋាភិបាលឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ គ្រប់ភូមិ ឃុំ សង្កាត់ និងបណ្ដាអង្គការសង្គមស៊ីវិលទូទាំងខេត្ត | ✓ | ✓ | ✓ | ✓ |
| 2 | ខិតខំកសាងផែនការ និងកម្មវិធីការងារប្រចាំខែសម្រាប់ចុះអនុវត្តគោលនយោបាយនៅតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ ដែលក្រុមនីមួយៗទទួលខុសត្រូវ | ✓ | ✓ | ✓ | ✓ |
| 3 | បន្តដឹកនាំអនុវត្តឱ្យបានទៀងទាត់នូវរបបប្រជុំប្រចាំខែ ដើម្បីត្រួតពិនិត្យលទ្ធផលកិច្ចប្រតិបត្តិការ និងដាក់ចេញផែនការ វិធានការអនុវត្តជាក់ស្ដែង ក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន | ✓ | ✓ | ✓ | ✓ |
| 4 | ជំរុញចលនាប្រឡងប្រណាំងបង្កើតស្នាដៃនៅតាមភូមិ ឃុំ សង្កាត់ ឱ្យបានផុលផុសក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព សម្រាប់ទទួលការសរសើរ និងជូនរង្វាន់ប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ |
| 5 | យកចិត្តទុកដាក់ចាត់តាំងអនុវត្តនូវបណ្ដាវិធានការស្ដីពីការលុបបំបាត់បទល្មើស និងគ្រោះថ្នាក់សង្គម ពាក់ព័ន្ធនឹងលក្ខណៈសម្បត្តិទាំង 07យ៉ាង នៃគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពឱ្យមានប្រសិទ្ធភាពខ្ពស់ | ✓ | ✓ | ✓ | ✓ |
| 6 | បង្កើនកម្មវិធីធ្វើវេទិកាសាធារណៈឱ្យបានគ្រប់ភូមិ ឃុំ សង្កាត់ទូទាំងខេត្ត ដើម្បីបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមយោបល់ដោះស្រាយបញ្ហាផ្សេងៗ ដែលបានកើតឡើងក្នុងមូលដ្ឋានរបស់ខ្លួន និងទិតៀនកែលម្អរាល់សកម្មភាពអសកម្មរបស់សមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានដែលមានកន្លងមក សំដៅបង្កើនសកម្មភាពអនុវត្តគោលនយោបាយ(ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព)ឱ្យកាន់តែមានប្រសិទ្ធភាព | ✓ | ✓ | ✓ | ✓ |
| **31. ការងារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងចរាចរណ៍** | | | | | |
| 1 | ជំរុញការអនុវត្តផែនការ 016 ផ.ក របស់អគ្គស្នងការដ្ឋាននគរបាលជាតិ | ✓ | ✓ | ✓ | ✓ |
| 2 | ស្រាវជ្រាវក្ដាប់សភាពការណ៍ឧបាយកលរបស់បណ្ដាភាគីអមិត្ត និងចលនាប្រឆាំងផ្សេងៗចំពោះរាជរដ្ឋាភិបាល ដើម្បីមានវិធានការទប់ស្កាត់បង្ក្រាបទាន់ពេលវេលា | ✓ | ✓ | ✓ | ✓ |
| 3 | ពង្រឹងការងារត្រួតពិនិត្យវត្តមានជនបរទេសឆ្លងកាត់ និងស្នាក់នៅក្នុងខេត្តដើម្បីទប់ស្កាត់ការលួចជ្រៀតចូលរបស់ក្រុមភេរវជន | ✓ | ✓ | ✓ | ✓ |
| 4 | ក្ដាប់សភាពការណ៍បាតុកម្ម កូដកម្ម និងអំពើភេរវកម្មផ្សេងៗ ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា | ✓ | ✓ | ✓ | ✓ |
| 5 | ប្រមូលផ្ដុំក្ដាប់រាល់សភាពការណ៍ បទល្មើសព្រហ្មទណ្ឌទូទាំងខេត្ត និងធ្វើការវិភាគវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីដាក់ចេញនូវវិធានការបង្ការ និងបង្ក្រាបឱ្យមានប្រសិទ្ធភាព | ✓ | ✓ | ✓ | ✓ |
| 6 | បន្តជំរុញវិធានការ និងបង្ក្រាបក្រុមក្មេងទំនើងនៅទូទាំងខេត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរក្សាសណ្ដាប់ធ្នាប់របៀបរៀបរយ និងកាត់បន្ថយបទល្មើសក្នុងសង្គម | ✓ | ✓ | ✓ | ✓ |

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 |
| 7 | ខិតខំពង្រឹងបំប៉នជំនាញឱ្យដល់មន្រ្តីនគរបាលយុត្តិធម៌គ្រប់លំដាប់ថ្នាក់ ដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព | ✓ | ✓ | ✓ | ✓ |
| 8 | បន្តសហការជាមួយអាជ្ញាធរដែនដី ដើម្បីបំផុសចលនាប្រជាពលរដ្ឋចូលរួមប្រឆាំងទប់ស្កាត់បទល្មើសគ្រឿងញៀន | ✓ | ✓ | ✓ | ✓ |
| 9 | បន្តកិច្ចសហប្រតិបត្តិការល្អជាមួយភ្នាក់ងារប្រឆាំងគ្រឿងញៀនភាគីថៃ ដើម្បីដកបទពិសោធន៍ និងផ្តល់ព័ត៌មានជូនគ្នាទៅវិញទៅមក សំដៅធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀនឆ្លងដែនឱ្យមានប្រសិទ្ធភាព | ✓ | ✓ | ✓ | ✓ |
| 10 | បន្តការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មី ដើម្បីអប់រំឱ្យស៊ីជម្រៅ ដល់ប្រជាពលរដ្ឋសំដៅកាត់បន្ថយនូវអត្រាគ្រោះថ្នាក់ចរាចរណ៍ និងមានវិធានការផាកពិន័យតាមច្បាប់កំណត់ | ✓ | ✓ | ✓ | ✓ |
| 11 | បង្កើនការគ្រប់គ្រងបណ្តាគោលដៅដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ច ដូចជាសណ្ឋាគារ ផ្ទះសំណាក់។ល។ ដោយធ្វើកិច្ចសន្យា តាមដានកុំឱ្យគោលដៅទាំងនោះ ក្លាយជាកន្លែងប្រព្រឹត្តបទល្មើស | ✓ | ✓ | ✓ | ✓ |
| 12 | បន្តចុះស្រង់ទិន្នន័យ និងស្រាវជ្រាវប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ | ✓ | ✓ | ✓ | ✓ |
| 13 | ជំរុញការអនុវត្តតួនាទីភារកិច្ចឱ្យបានល្អប្រសើរ | ✓ | ✓ | ✓ | ✓ |
| **32. ការងារពន្ធនាគារ** | | | | | |
| 1 | អប់រំមន្ត្រីឱ្យយល់ដឹងពីច្បាប់ ក្រមសីលធម៌ បទវិន័យរបស់មន្ត្រីអនុរក្សពន្ធនាគារ | ✓ | ✓ | ✓ | ✓ |
| 2 | សហការជាមួយអង្គការដៃគូ សប្បុរសជន អាជ្ញាធរ និងប្រជាជនតាមមូលដ្ឋានឱ្យកាន់តែមានទំនាក់ទំនងល្អ | ✓ | ✓ | ✓ | ✓ |
| 3 | ពិនិត្យរៀបចំកម្មវិធី ផែនការកសិកម្ម ឧស្សាហកម្មក្នុងពន្ធនាគារ | ✓ | ✓ | ✓ | ✓ |
| 4 | ពង្រឹងការគ្រប់គ្រងពន្ធនាគារ ការផ្គត់ផ្គង់ជីវភាព សេវាថែទាំសុខភាពរបស់ ជនជាប់ឃុំ អនាម័យក្នុងពន្ធនាគារឱ្យស្របតាមនីតិវិធី | ✓ | ✓ | ✓ | ✓ |
| 5 | ពិនិត្យ ឆែកឆេរយ៉ាងហ្មត់ចត់ក្នុងតំបន់ឃុំ | ✓ | ✓ | ✓ | ✓ |
| 6 | ពិនិត្យ និងថែទាំគ្រប់សំណង់អគារ ក្នុងពន្ធនាគារ តាមដានគ្រប់ប្រព័ន្ធអគ្គិសនីតាមអគារឃុំ | ✓ | ✓ | ✓ | ✓ |
| 33. **ការងារគ្រប់គ្រងជនអន្តោប្រវេសន៍** | | | | | |
| 1 | ពង្រឹងការអនុវត្តច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីសញ្ជាតិ ជាពិសេសគឺជំរុញសកម្មភាពត្រួតពិនិត្យ បង្ក្រាបនូវករណីល្មើសច្បាប់អន្តោប្រវេសន៍ និងទប់ស្កាត់ការលួចជ្រៀតចូលដោយខុសច្បាប់ តាមគ្រប់រូបភាពក្នុងដែនសមត្ថកិច្ចទូទាំងខេត្ត | ✓ | ✓ | ✓ | ✓ |
| 2 | យកចិត្តទុកដាក់គ្រប់គ្រងវត្តមានជនបរទេស ដែលចូលមកស្នាក់នៅក្នុងខេត្តឱ្យបានហ្មត់ចត់តាមរយៈប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេស ក្នុងព្រះរាជាណាចក្រកម្ពុជា Foreigner Present in Cambodia System (FPCS) | ✓ | ✓ | ✓ | ✓ |
| 3 | ពង្រឹងការសហការជាមួយអង្គភាពពន្ធនាគារ ដើម្បីប្រមូលទិន្នន័យជនបរទេសជាប់ពន្ធនាគារ និងយកចិត្តទុកដាក់ក្តាប់នូវសកម្មភាពជនល្មើសដែលជាជនបរទេស មានបំណងបង្កគ្រោះមហន្តរាយ ឬ ធ្វើឱ្យមានការគំរាមកំហែងដល់សន្តិសុខជាតិ | ✓ | ✓ | ✓ | ✓ |

## ផ្នែកទី៦

## សេចក្ដីសន្និដ្ឋាន

ក្នុងឆ្នាំ២០២១ នេះ ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត បានរៀបចំរចនាសម្ព័ន្ធ ដឹកនាំ គ្រប់គ្រង ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន ព្រមទាំងបានអនុវត្តការងារ ស្របតាមការបែងចែក តួនាទីភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត។ ជាមួយគ្នានេះ អង្គភាពច្រកចេញចូលតែមួយ ការិយាល័យប្រជាពលរដ្ឋ បានបន្តផ្តល់សេវាជូនប្រជាពលរដ្ឋ និងដំណោះស្រាយរាល់ពាក្យបណ្តឹងនានា កាន់តែឆាប់រហ័សប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងទំនួលខុសត្រូវ ដើម្បីជានានិរន្តរភាពនៃថ្នាក់រដ្ឋបាលមួយនេះ។

ក្នុងការអនុវត្តតួនាទីភារកិច្ច ក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា គណៈអភិបាល បានយកចិត្តទុកដាក់លើការប្រជុំស្របតាមគោលការណ៍ច្បាប់ដែលបានកំណត់ ដើម្បីដោះស្រាយបញ្ហានានារបស់ខ្លួនតាមប្រតិទិនដែលបានគ្រោងទុក និងតាមការចាំបាច់។

ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ធ្វើឱ្យការអភិវឌ្ឍក្នុងមូលដ្ឋានមានការកើនឡើងយឺត ទន្ទឹមនឹងតម្រូវការនៅមូលដ្ឋានមានកាន់តែច្រើន ដូចនេះរដ្ឋបាលខេត្តចាំបាច់នឹងកៀរគរប្រភពធនធានបន្ថែមទៀត ទាំងការស្នើសុំអន្តរាគមន៍ថវិកាពីថ្នាក់ជាតិ ស្ថាប័ននៅថ្នាក់ក្រោមជាតិ និងសប្បុរសជនដើម្បីបង្កើនមូលនិធិអភិវឌ្ឍ សម្រាប់ជាប្រយោជន៍ឆ្លើយតបនឹងសេចក្តីត្រូវការចាំបាច់នានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋានបានកាន់តែប្រសើរឡើង និងដើម្បីបន្តជំរុញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងគោលនយោបាយកំណែទម្រង់ដ៏ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលសម្រាប់ នីតិកាលទី៦ នៃរដ្ឋសភា កាន់តែទទួលបានផ្លែផ្កាថែមទៀត។

ដោយឡែក តាមរយៈសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងដោយមានកិច្ចសហការជាមួយរដ្ឋបាលមូលដ្ឋានគ្រប់លំដាប់ថ្នាក់ បានធ្វើឱ្យការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ការងារសេដ្ឋកិច្ច សង្គម និងការដោះស្រាយបញ្ហា មានភាពល្អប្រសើរ។ សមិទ្ធផលដែលសម្រេចបាន អាស្រ័យដោយក្រុមការងារគ្រប់ថ្នាក់ បានយកចិត្តទុកដាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានឆន្ទៈមុតមាំក្នុងការអនុវត្តបទបញ្ជា សេចក្តីណែនាំ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ជាមួយកិច្ចសហការគាំទ្រទៅវិញទៅមក ក្នុងគោលដៅច្បាស់លាស់ ធ្វើឱ្យការដោះស្រាយបញ្ហាផ្សេងៗជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានទទួលបានលទ្ធផលល្អប្រសើរ។

របាយការណ៍ប្រចាំឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២នេះ ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី៣៥ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង នាថ្ងៃអង្គារ ៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២។

ថ្ងៃ.................ខែ..........ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

កោះកុង ថ្ងៃទី.........ខែ..........ឆ្នាំ២០២២

**អភិបាល**

**មិថុនា ភូថង**